ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ កម្ពុជា ក្នុងនាមជាប្រធានអាស៊ានឆ្នាំ២០១២

◆ ស៊ីវ ធួន ៖ ដំណើរឆ្លងកាត់របបខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៥១ ខែកក្កដា ឆ្នាំ២០១២

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត

លេខ១៥១ ខែកក្កដា ឆ្នាំ២០១២

## មាតិកា

◆កម្ពុជា ក្នុងនាមជាប្រធានអាស៊ានឆ្នាំ២០១២ .................................... ១

**ផ្នែកឯកសារ**

◆អ៊ឹ ឈឿន ហៅ ម៉ៃ អតីតសមាជិកតំបន់៦ ភូមិភាគ ........................... ៣

◆សីលធម៌១២ប្រការរបស់ជនបដិវត្តន៍ ............................................. ១៥

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ប្ដីស្លាប់តែខំរស់ដើម្បីកូន .......................................................... ២០

◆ការងារនៅរោងពុម្ពមន្ទីរក-២៨ ................................................... ២៤

**ផ្នែកច្បាប់**

◆ការការពារការសម្ងាត់របស់ដំណើរការស៊ើបអង្កេត ....................... ២៨

**វេទិកាពិភាក្សាសាធារណៈ**

◆វិសាលភាពនៃកាតព្វកិច្ចស៊ើបអង្កេតរបស់សហចៅក្រម ................. ៤២

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ស៊ីវ ធួន ៈ ដំណើរឆ្លងកាត់របបខ្មែរក្រហម ................................ ៥១



**អ៊ឹម ចែម កំពុងអានទស្សនាវដ្ដីស្វែងរកការពិតនៅអន្លង់វែង**

***ក្របមុខ*** ៈ *លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា កំពុងរៀបរាប់អំពីរឿងរ៉ាវនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ដល់លោកស្រី ហ៊ីលឡារី គ្លីនតុន (រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក) និង លោកស្រី ខារ៉ូល រ៉ដលី (ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា) កាលពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១០ ។ លោកស្រី ហ៊ីលឡារី គ្លីនតុន បានធ្វើទស្សនកិច្ចជាផ្លូវការលើកដំបូងនៅប្រទេសកម្ពុជាកាលពីចុងឆ្នាំ ២០១០ ។ (រូបថត ៈ វីល បេក្សទើភ្នំពេញប៉ុស្តិ៍)*

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ** ៈ ម៉ម សុវណ្ណ, គ្រីស្ដា ណេលសាន់, ថាឆាណា សៃណាទី, ស៊ីវ ធួន **អ្នកនិពន្ធនិងស្រាវជ្រាវ** ៈ ទាវ សារៈមុនិន្ទ, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែ** ៈ ទែន សុខស្រីនិត **និពន្ធនាយកទូទៅ** ៈ ឆាំង យុ **ជំនួយការនិពន្ធនាយក** ៈ ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រ** ៈ ស៊ឹម សុភ័ក្រ **គ្រប់គ្រងការចែកផ្សាយ** ៈ ឆេង វើង Email: dccam@online.com.kh, Homepage: www.dccam.org

# កម្ពុជា ក្នុងនាមជាប្រធានអាស៊ានឆ្នាំ២០១២

ខ្ញុំសូមសម្តែងនូវការស្វាគមន៍ដល់ភ្ញៀវជាតិ និងអន្តរជាតិទាំងឡាយដែលបានធ្វើដំណើរមកកាន់ប្រទេសកម្ពុជាពីប្រទេសនានាក្នុងតំបន់ដើម្បីមកចូលរួមកិច្ចប្រជុំរបស់សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ជាផ្លូវការនិងដើម្បីពិភាក្សាពីកិច្ចការមួយចំនួនទៀតរវាងសមាគមអាស៊ាននិងសង្គមស៊ីវិល ។

ប្រជាជនកម្ពុជាមានក្តីមោទកភាពក្រៃលែងដែលបានធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំអាស៊ានឆ្នាំ២០១២នេះ ។ ប្រទេសកម្ពុជាមានទំព័រប្រវត្តិសាស្ត្រដ៏អាប់អួរដែលកាលនោះកម្ពុជាត្រូវបានកាត់ផ្តាច់ចេញពីប្រទេសជាច្រើននៅលើសាកលលោកនិងប្រទេសនៅក្នុងតំបន់ ។ វាជារឿងដែលមិនគួរជឿទាល់តែសោះដែលថាប្រទេសជាម្ចាស់នៃប្រាសាទអង្គរវត្តដ៏ធំស្កឹមស្កៃមួយនៅតំបន់អាស៊ីអាគ្នេយ៍ បែរជាប្រទេសចុងក្រោយបង្អស់ដែលបានចូលរួមក្នុងសមាគមអាស៊ានទៅវិញ កាលពី១៣ឆ្នាំមុន ។

នៅពេលយើងដែលជាប្រជាជនកម្ពុជាសម្លឹងមើលទៅអតីតកាលពីជាងសាមសិបឆ្នាំមុន យើងនឹងឃើញប្រវត្តិសាស្ត្រដ៏គួរឲ្យរន្ធត់ ប៉ុន្តែប្រសិនបើយើងសម្លឹងមើលទៅមុខយើងនឹងឃើញឱកាសដ៏ធំធេងមួយដើម្បីលូតលាស់ និងស្តាបនាស្ពានជាមួយដៃគូរអាស៊ានរបស់យើង ។ យើងមើលឃើញនូវកាតព្វកិច្ចមួយដើម្បីជួយឲ្យប្រជាជនកម្ពុជាចងចាំព្យាបាលមុខរបួសឈឺចាប់និងកសាងអនាគតឲ្យភ្លឺស្វាងក្រោយពេលដែលរបបខ្មែរក្រហមបានដួលរំលំទៅ ។ យើងក៏មើលឃើញនូវកាតព្វកិច្ចមួយដើម្បីប្តូរបទពិសោធន៍គ្នាទៅវិញទៅមកជាមួយមិត្តដែលជាសមាជិកនៃប្រទេសអាស៊ានដើម្បីកសាងអនាគតរួមគ្នានៅក្នុងតំបន់ទាំងមូល ។

ការពុះពារដោះស្រាយកេរដំណែលនៃរបបខ្មែរក្រហម



កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាននៅប្រទេសកម្ពុជាកាលពីខែកក្កដា ឆ្នាំ២០១២ ។ រូបថតៈ រស្មីកម្ពុជា

គឺធ្វើយ៉ាងណាដើម្បីធានាឲ្យយើងមានសិទ្ធិក្នុងការរស់រានមានជីវិត ។ ខ្មែរក្រហមបានដកហូតពីប្រជាជនកម្ពុជាយើងនូវជីវិតប្រចាំថ្ងៃដែលមិនអាចខ្វះបានរបស់មនុស្សគឺសេចក្តីស្រឡាញ់ ការរាប់អានគ្នាក្នុងនាមអ្នកជិតខាង សេចក្តីស្រឡាញ់ចំពោះគ្រួសារ និងជោគវាសនារបស់មនុស្សម្នាក់ៗ ។ យើងទាំងអស់គ្នាត្រូវតែខិតខំធ្វើយ៉ាងណាស្តារ និងការពារសិទ្ធិជាមូលដ្ឋាននិងសេរីភាពទូទាំងតំបន់អាស៊ានឡើងវិញ ។ នៅក្នុងប្រទេសកម្ពុជា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមកំពុងតែជួយតម្រង់ទិសប្រទេសជាតិទៅរកផ្លូវវិជ្ជមានមួយ ។ តុលាការនេះបានជំរុញឲ្យមានការពិភាក្សាគ្នាជាច្រើនក្នុងស្រទាប់ប្រជាជនកម្ពុជាដែលនេះគឺជាព្រឹត្តិការណ៍ដ៏កម្រមួយនៅក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជា ។ ប្រជាជនកម្ពុជាស្ទើរគ្រប់ស្រទាប់វណ្ណៈទាំងអស់សុទ្ធតែបានរងគ្រោះដោយសាររបបខ្មែរក្រហម ទោះតិចឬច្រើន ។

ការពិភាក្សាទាក់ទងទៅនឹងតុលាការកាត់ទោសមេដឹកខ្មែរក្រហមបានជួបប្រទះនូវភាពតានតឹងជាច្រើនដោយសារតែប្រជាជនកម្ពុជាមួយចំនួនមិនយល់ស្របទៅនឹងសេចក្តីតម្រូវការសំខាន់ៗមួយចំនួនដូចជា ទស្សនៈយុត្តិធម៌ និងការបង្រួមបង្រួមជាតិ ។ ប៉ុន្តែការពិភាក្សានោះក៏បានជួយលើកកម្ពស់ឲ្យមានភាពស្មើសិទ្ធិគ្នាក្នុងចំណោមប្រជាជនកម្ពុជា ។ សេរីភាពជាមូលដ្ឋានទាំងនេះបង្កើតនូវវប្បធម៌ពិភាក្សាគ្នានិងជំរុញឲ្យមានការត្រៀមខ្លួនទុកជាមុន ។ វប្បធម៌ពិភាក្សាគ្នានេះគឺជាមូលដ្ឋានគ្រឹះដើម្បីលទ្ធិប្រជាធិបតេយ្យដ៏រឹងមាំមួយ ។

វប្បធម៌នៃការពិភាក្សាគ្នានេះ ជួយឲ្យប្រជាជនកម្ពុជាបានដឹងពីគំនិតផ្សេងៗគ្នារបស់បុគ្គលម្នាក់ៗ ដោយការគោរពគ្នាទៅវិញទៅមក ។ ការមិនយល់ស្របគ្នាតាមបែបសន្តិវិធីជួយកាត់បន្ថយអំពើហិង្សា និងជំរុញឲ្យមានការព្យាបាលរបួសក្នុងកម្រិតបុគ្គលនិងក្នុងសហគមន៍ទាំងមូល ។ ការសន្ទនា និងការពិភាក្សាគ្នាក៏ជួយបង្កើននូវកម្លាំងកាយ ចិត្ត និងគំនិតច្នៃប្រឌិតទៅក្នុងប្រព័ន្ធអប់រំរបស់យើងតាមសាលារៀន និងជួយជំរុញឲ្យមានការរៀនសូត្រពីប្រវត្តិសាស្ត្រឲ្យបានប្រសើរជាងមុននិងអំពីជំនាញចាំបាច់ណាមួយសម្រាប់កសាងសង្គមដ៏រឹងមាំទៅថ្ងៃអនាគត ។

អ្វីដែលជាកិច្ចការសំខាន់ទៀតនោះ គឺការជំរុញឲ្យស្ត្រីនិងជនជាតិភាគតិចបញ្ចេញមតិរបស់ខ្លួន ។ នៅក្នុងប្រទេសកម្ពុជាអ្នកដែលរួចរស់ជីវិតពីរបបខ្មែរក្រហមភាគច្រើនគឺជាស្ត្រី ។ ស្ត្រីមួយចំនួនបានខិតខំពុះពារចិញ្ចឹមកូនតែម្នាក់ឯងក្រោយរបបខ្មែរក្រហម ហើយស្ត្រីទាំងនោះបានដើរតួនាទីយ៉ាងសំខាន់ដើម្បីស្តារនិងកសាងប្រទេសជាតិឡើងវិញ ប៉ុន្តែស្ត្រីទាំងនោះមិនសូវមានឱកាសបញ្ចេញមតិ និងយោបល់របស់ខ្លួនទេ ។ ជនជាតិភាគតិចក៏ត្រូវមានតួនាទីបញ្ចេញមតិយោបល់ដែរ ។ ប្រសិនបើអំពើប្រល័យពូជសាសន៍ខ្មែរក្រហមអាចរំពុកយើងគ្រប់រឿងរ៉ាវទាំងអស់នោះ ក៏ត្រូវតែមានតម្រូវការការពារក្រុមដែលងាយទទួល រងគ្រោះនៅក្នុងសង្គមកម្ពុជាយើងដែរ ។

ការសន្ទនានិងកិច្ចការពិភាក្សាគ្នាគឺជាកិច្ចការដ៏មានសារៈសំខាន់មួយដើម្បីធានាបាននូវការគោរពសិទ្ធិជាមូលដ្ឋាននៅក្នុងតំបន់អាស៊ាន ។ យើងដែលជាប្រជាជនកម្ពុជាស្វាគមន៍នូវការបង្កើតគណៈកម្មាធិការអន្តររដ្ឋាភិបាលទទួលបន្ទុកសិទ្ធិមនុស្សរបស់សមាគមន៍អាស៊ាន និងការរីកចម្រើនទៅមុខឆ្ពោះទៅរកសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន ។ យើងដែលជាប្រជាជនកម្ពុជាសូមជំរុញលើកទឹកចិត្តមន្ត្រីរដ្ឋាភិបាលនៃបណ្តាប្រទេសអាស៊ានទាំងអស់ឲ្យយកគណៈកម្មាធិការអន្តររដ្ឋាភិបាលនេះដើម្បីឲ្យប្រជាជនអាស៊ានទាំងអស់យល់ដឹងពីបញ្ហាសិទ្ធិមនុស្ស ។ គណៈកម្មាធិការអន្តររដ្ឋាភិបាលនេះបានផ្តល់នូវសំឡេងដ៏ខ្លាំងមួយសម្រាប់សង្គមស៊ីវិល និងសម្រាប់ប្រជាជនសាមញ្ញ ។ ប្រជាពលរដ្ឋគឺជាអ្នកដែលទទួលរងគ្រោះខ្លាំងបំផុតប្រសិនបើសិទ្ធិមិនត្រូវបានគោរព ។ ប្រជាពលរដ្ឋគឺជាអ្នកដែលបានផ្តល់ក្តីសង្ឃឹមដ៏ធំធេងដើម្បីធានាថាសិទ្ធិមនុស្សត្រូវបានលើកកំពស់ និងការពារនៅក្នុងថ្ងៃអនាគត ។

យើងដែលជាប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជាមានក្តីមោទកភាពត្រង់ថា យើងកំពុងតែបោះជំហ៊ានទៅមុខដើម្បីដោះស្រាយផលលំបាកមួយចំនួនដែលបានកើតមានឡើងកាលពីអតីតកាល ។ យើងមានចិត្តរីករាយក្នុងការចូលរួមចំណែកចែកបទពិសោធន៍របស់យើងជាមួយដៃគូដែលជាសមាជិកអាស៊ាន ហើយយើងមានក្តីសោមនស្សរីករាយក្នុងការដើរតួជាយន្តការមួយដើម្បីលើកកម្ពស់សិទ្ធិមនុស្សនៅក្នុងតំបន់អាស៊ានទាំងមូល ។

**ឆាំង យុ**

# អ៊ឹំ ឈឿន ហៅ ម៉ែ អតីតសមាជិកតំបន់៦ ភូមិភាគពាយ័ព្យ និងជាពិធីការក្រសួងការបរទេស

## ដកស្រង់ចេញពីចម្លើយសារភាព ឯកសារ J00៦៣២

អ៊ឹំ ឈឿន អតីតសមាជិកតំបន់៦ ភូមិភាគពាយ័ព្យ ក្រោយមកជាពិធីការនៅក្រសួងការបរទេស ត្រូវបានចាប់ខ្លួនមកដាក់នៅក្រសួងសន្តិសុខ(មន្ទីរស-២១) នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៧៧ ។ ឈឿន ត្រូវបានសួរចម្លើយដោយមនុស្សពីរនាក់ គឺ ឈិន និង វុន រយៈពេលប្រាំខែ គឺរហូតមកដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៧ ទើបគាត់បានចុះហត្ថលេខាលើឯកសារចម្លើយសារភាពកម្រាស់៤៥ទំព័រ ដែលគាត់បានឆ្លើយ ។

ឯកសារចម្លើយសារភាពរបស់ ឈឿន នេះត្រូវបានបញ្ជូនបន្តទៅថ្នាក់លើ និងមានចំណារថា "សម្ងាត់" និង "សំខាន់ដែរ" ។ នៅលើគម្របមុខរបស់សៀវភៅចម្លើយសារភាពនោះ មានសរសេរថា ៖ ១) ជូនពាយ័ព្យមួយច្បាប់ ២) ចម្លើយអាម៉ែ នេះទាក់ទិននឹងសមមិត្ត គ្រិន ។ ចំណារនេះសរសេរនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ។

យោងតាម កាំង ហ្គេចអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរស-២១ បានរៀបរាប់ថា ឈ្មោះ អ៊ឹំ ឈឿន ហៅ ម៉ែ បានចេញទៅធ្វើបដិវត្តន៍ជាមួយ តាម៉ុក នៅភូមិភាគនិរតី ។ ដោយសារ តាម៉ុក មិនពេញចិត្តនឹងគាត់ដែលមានប្រវត្តិរូបជាអតីតគ្រូបង្រៀន ទើប តាម៉ុក បណ្តេញគាត់ចេញពីការងារ ។ ឃើញដូច្នេះ ប៉ុល ពត បានមកសម្រុះសម្រួល រួចហើយក៏បញ្ជូនគាត់ឲ្យទៅធ្វើការនៅភូមិភាគពាយ័ព្យវិញ ។

ក្រោយមក អង្គការបានដកគាត់ឲ្យមកធ្វើការនៅក្រសួងការបរទេស ហើយត្រូវបានចាប់ខ្លួនតែម្តង ។ ឌុច ក៏បានបញ្ជាក់បន្ថែមថា ក្នុងចំណោមអ្នកទោសដែលចាប់ខ្លួនបញ្ជូនមកឃុំឃាំងនៅមន្ទីរស-២១ទាំងអស់សុទ្ធតែត្រូវទទួលរងទារុណកម្ម លើកលែងតែ កុយ ធួន លេខាភូមិភាគឧត្តរមួយប៉ុណ្ណោះ ។ ចំណែកចម្លើយដែលបានមកពីការសួរចម្លើយទាំងនោះ ក៏មិនមែនពិតទាំងអស់នោះដែរ ។

ខាងក្រោមនោះ គឺជាអត្ថបទដកស្រង់ចេញពីឯកសារចម្លើយសារភាពរបស់ អ៊ឹំ ឈឿន ហៅ ម៉ែ ៖

ខ្ញុំឈ្មោះ អ៊ឹំ ឈឿន អាយុ៤២ឆ្នាំ ជាពិធីការក្រសួងការបរទេស កើតនៅភូមិចង្រុះ ឃុំរំចេក ស្រុកបាភ្នំ ខេត្តព្រៃវែង ។ ឪពុកឈ្មោះ អ៊ឹំ ប៉ែក ធ្វើស្មៀនមេឃុំចាស់ ក្រោយមក រកស៊ីធ្វើស្រែ ។ ម្តាយឈ្មោះ អ៊ិនដ្ឋិង ធ្វើស្រែ ។

ពីឆ្នាំ១៩៤២-៤៣ ខ្ញុំបានចូលរៀននៅសាលាវត្តសទ្ធាក្នុងឃុំរំចេក និងពីឆ្នាំ១៩៤៣-៥៣ ខ្ញុំបានរៀននៅសាលាបឋមសិក្សាឈើកាច់ ។ ដល់ចុងឆ្នាំ១៩៥៣ ខ្ញុំរៀនចប់ រួចទៅប្រលងនៅខេត្តស្វាយរៀង ដើម្បីបន្តការរៀនសូត្រទៀត តែប្រលងធ្លាក់ ។ លុះសាលាជ្រើសរើសយកបេក្ខជនជាប់នាក់ឲ្យទៅរៀននៅសាលាគរុវិជ្ជាភ្នំពេញ រូបខ្ញុំជាប់ឈ្មោះក្នុងនោះដែរ ។ ដូច្នេះចាប់ពីឆ្នាំ១៩៥៣មក ខ្ញុំទៅរៀននៅភ្នំពេញ ហើយនៅឆ្នាំ១៩៦១ ខ្ញុំបានចេញទៅធ្វើសាស្ត្រាចារ្យនៅវិទ្យាល័យកំពង់ធំ ។

ក្រោយមក នៅឆ្នាំ១៩៦៥ ខ្ញុំបានផ្លាស់មកធ្វើសាស្ត្រាចារ្យនៅវិទ្យាល័យតាខ្មៅវិញ ដោយមានការទទួលរាក់ទាក់ពី កែ គឹមហួត ហៅ សុត អតីតសាស្ត្រាចារ្យនៅតាខ្មៅ បច្ចុប្បន្នជាលេខាតំបន់៧ ភូមិភាគពាយ័ព្យ ។ សាំង រិន ហៅ អុន អតីតសាស្ត្រាចារ្យ និងនៅឆ្នាំ១៩៧៤ ជាលេខាតំបន់ នៅភូមិភាគនិរតី ។ ធុច រិន ហៅ គ្រិន អតីតសាស្ត្រាចារ្យ ក្រោយមកជាប្រធានដែកំពង់សោម ។ លុះបានស្គាល់គ្នាមួយរយៈ កែ គឹមហួត តែងតែមកនិយាយអួតសរសើរពីរបបលោកសេរី និងសរសើរពីរបបមូលធននិយមដឹកនាំដោយអង្គការ សេ.អ៊ី.អា ប្រឆាំងនឹងរបបកុម្មុយនីស្តឲ្យខ្ញុំស្តាប់ ។

ថ្ងៃមួយក្នុងខែឧសភា ឆ្នាំ១៩៦៦ សាំង រិន បានមកសួរយោបល់ខ្ញុំថា "តើ ឈឿន ឯងយល់យ៉ាងណាពីអង្គការ

សេ.អ៊ី.អា ហើយតើអាចចូលជាសមាជិកបានឬទេ?” ខ្ញុំបានប្រាប់ទៅ សាំង រិន វិញថា ខ្ញុំអាចចូលជាសមាជិក សេ.អ៊ី.អា បាន ។ លុះព្រឹកឡើង ជាថ្ងៃអាទិត្យ ខែមិថុនា ឆ្នាំ១៩៦៦ ស្រាប់តែឃើញ សាំង រិន មកដល់ផ្ទះខ្ញុំ ។ អង្គុយស្រួលបួលហើយ សាំង រិន ក៏ប្រាប់ខ្ញុំថា “ថ្ងៃនេះ ឈឿន ឯងត្រូវរៀបចំបញ្ចូលជាសមាជិក សេ.អ៊ី.អា រួចហើយគាត់ក៏បបួលខ្ញុំមកសាលាគាខ្មៅ” ។ ពេលដើរចូលដល់កន្លែងធ្វើការរបស់ កែ គីមហួត ភ្លាម ស្រាប់តែឃើញ ធុច រិន អង្គុយចាំស្រេចជាមួយ កែ គីមហួត ។ អង្គុយនិយាយគ្នាលេងបន្តិច កែ គីមហួត ក៏បបួលទាំងអស់គ្នាទៅកន្លែងរៀបចំបញ្ចូល ដែលមានរៀបចំតុ កៅអី និងទង់ សេ.អ៊ី.អា នៅក្នុងបន្ទប់មួយនៅផ្ទាល់ដី ។ កែគីមហួត បានប្រាប់ខ្ញុំ, សាំងរិននិង ធុច រិន ឲ្យអង្គុយជុំវិញតុបួនជ្រុង ។ បន្ទាប់មក គាត់ឡើងប្រកាសកម្មវិធីបញ្ចូលខ្ញុំនៅចំពោះមុខអង្គប្រជុំ ។ ទី១) គឺគោរពទង់ សេ.អ៊ី.អា ។ ទី២) ឲ្យ សាំងរិនពិនិត្យមើលប្រវត្តិរូបរបស់ខ្ញុំដោយមានការយល់ព្រមពីគាត់ (កែ គីមហួត) និង ធុច រិន ។ ទី៣) ផ្ដែផ្ដាំរំឭកពីភារកិច្ច សេ.អ៊ី.អា ។ ទី៤) ពិធីបញ្ចូល ។ ទី៥) រៀបចំជប់លៀង ហូបនំនែកជាការបញ្ចប់កម្មវិធី រួចហើយបំបែកគ្នាត្រឡប់ទៅផ្ទះរៀងៗខ្លួន ។

ក្នុងរយៈប្រហែលមួយខែក្រោយពីចូលជាសមាជិក សេ.អ៊ី.អា មក កែ គីមហួត ក៏បានហៅខ្ញុំ និង សាំង រិន ទៅប្រជុំ (នៅផ្ទះ សាំង រិន) ដោយលើកឡើងដូចតទៅៈ

១) បញ្ជាក់ពីភារកិច្ចថ្មីរបស់ខ្ញុំ គឺកសាងកម្លាំង សេ.អ៊ី.អា ឲ្យបាន រួមជុំនឹងកម្លាំងចាស់ ដែលកសាងបាននៅក្នុងសាលាគាខ្មៅ ។

២) បញ្ជាក់ពីខ្សែទាក់ទង ដោយរូបខ្ញុំត្រូវទាក់ទងផ្ទាល់ជាមួយ សាំង រិន លើគ្រប់កិច្ចការ ឯ សាំង រិន វិញ ត្រូវទាក់ទងផ្ទាល់មកគាត់ (កែគីមហួត) ។

៣) គាត់បានខទ្មេសនាមពីកម្លាំង សេ.អ៊ី.អា ចាស់នៅក្នុងសាលាគាខ្មៅ មានឈ្មោះ សាន ប៊ុនហ៊ី ហៅ គួន, ស្រេង, លី ស្រាយ, ហ៊ិត, ឈុន, នារី គោ សារិន, នារី គោ សុគន្ធារី ជាសិស្សវិទ្យាល័យនេះដែលមាន សាន ប៊ុនហ៊ី ជាអ្នកទទួលខុសត្រូវរួម ។

ក្រោយពីប្រជុំរួចខ្ញុំបានសាកសួរយោបល់ពី សាំងរិន ធ្វើយ៉ាងណាដើម្បីកសាងកម្លាំងនៅក្នុងសាលា? សាំង រិន ប្រាប់ថា ដើម្បីកសាងកម្លាំងបានលុះត្រាតែយើងចុះផ្ទាល់ដល់សហករណ៍លក់ដូររបស់សិស្សនៅក្នុងសាលា ។ ដូច្នេះរាល់ពេលមកបង្រៀន ខ្ញុំបានឆ្លៀតពេលចុះផ្ទាល់ដល់សហករណ៍លក់ដូរ ខ្ញុំជួយមើលជួយ









ឧបត្ថម្ភដល់សហករណ៍ ទើបបានស្គាល់សិស្សខ្លះដូចជា កែ មុនី, នារី លី ស្រួយ និង ហ៊្កិច ជាដើម ហើយខ្ញុំតែងតែទាក់ទង និងបបួលសិស្សទាំងនោះមកលេងផ្ទះខ្ញុំ ។

ពេលជួប កែ មុនី កូនអ្នកក្រម្តង១ ខ្ញុំប្រាប់គេថា អ្នកក្រទាល់តែចូលខាងអ្នកមាន ដូចជា ប្រទេសលោកសេរី ប្រទេសអាមេរិកជាដើម ទើបស្គាល់មាន ស្គាល់បាននឹងគេ បើចូលខាងប្រទេសកុម្មុយនីស្តរឹតតែក្រទៀត ។ ចំពោះសិស្សនារីដែលជាកូនអ្នកធូធារហើយ ខ្ញុំប្រាប់គេថា អ្នកធូរធាហើយ បើធ្វើកុម្មុយនីស្តរឹតតែបាត់បង់ភាពធូធារទៀត ព្រោះកុម្មុយនីស្តគ្មានកម្មសិទ្ធិ ឬទ្រព្យសម្បត្តិផ្ទាល់ខ្លួនទេ ។

រាល់ពេលជួបសិស្សទាំងបីនាក់ ទាំងនៅផ្ទះខ្ញុំ ឬនៅក្នុងសាលា ខ្ញុំឃោសនាអប់រំដដែល១ ។ លុះមានជំនឿស៊ប់មកខ្ញុំ ហើយក្នុងរវាងពាក់កណ្តាលឆ្នាំ១៩៦៧ ខ្ញុំបានហៅ កែ មុនី, លី ស្រួយ និង ហ៊្កិច មកជួបជុំសម្ងាត់ក្នុងផ្ទះខ្ញុំ និងបានចាត់តាំងអ្នកទាំងនោះទៅជាសមាជិក សេ.អ៊ី.អា ។ ក្រោយពីចាត់តាំងសិស្សទាំងបីនាក់រួចហើយ ខ្ញុំបានទៅជួបផ្ទាល់នឹង សាំង រិន ដើម្បីរាយការណ៍ឲ្យគាត់ពីសកម្មភាពដែលខ្ញុំបានបំពេញនៅក្នុងសាលា ។ សាំង រិន បានណែនាំថា កម្លាំងថ្មីនេះ យើងអាចបញ្ចូលក្នុងកម្លាំងចាស់ពីមុនដែលមាន សាន ប៊ុនហ៊ី ទទួលខុសត្រូវ ។

ថ្ងៃមួយខ្ញុំ បានហៅ កែ មុនី, លី ស្រួយ និង ហ៊្កិច មកឧទ្ទេសនាមឲ្យ សាន ប៊ុនហ៊ី ក្នុងបន្ទប់មួយនៅសាលា ដើម្បីឲ្យ ប៊ុនហ៊ី ដឹកនាំធ្វើសកម្មភាពជាមួយកម្លាំងចាស់ពីមុន ដែលមាន ស្រេង, លី ស្រាយ, ហ៊ាត, ឈុន, នារី គោ សុន្ទារី, នារី គោ សារ៉ែន ។

រហូតពេលរំាកងធំ ខ្ញុំបានចុះដាប់សហករណ៍លក់ដូររបស់សិស្ស ដើម្បីទាក់ទងសិស្សថ្មីបន្ថែមទៀត និងឃោសនាបន្ទាប់ពីប្រទេសកុម្មុយនីស្ត ។ លុះដល់ចូលរៀនវិញ ថ្ងៃមួយ សាំង រិន មកផ្ទះខ្ញុំ និងបានប្រាប់ខ្ញុំថា «ឈឿន ឯងត្រូវទៅបង្កប់ក្នុងជួរបដិវត្តន៍ នៅជនបទតទៅទៀត ដើម្បីងាយស្រួលធ្វើការងារ និងពិភាក្សាគ្នា ។ ឈឿនឯងត្រូវទៅជាមួយ កែ គឹមហួត នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៦៧ វេលាម៉ោង៧យប់ ហើយកន្លែងណាត់ជួបគ្នា គឺជ្រុងខាងត្បូងឈៀងខាងកើតសាលាសន្ធរម៉ុក ។ អ្នកចាំទទួល គឺស្មៀនរបស់សមាគមសាស្ត្រាចារ្យ ឈ្មោះបដិវត្តន៍គិន ឬ គុន ។

លុះថ្ងៃកំណត់មកដល់ ខ្ញុំ និង កែ គឹមហួត ទៅដល់កន្លែងណាត់ជួប ភ្លាមនោះ គុន បាននាំយើងទាំងពីរនាក់ទៅជិះឡានហ្ស៊ីប ដោយមាននីរសារឈ្មោះ សេង និងគ្រូបង្រៀននៅសាលាគុរុវិជ្ជា ឈ្មោះ ថៃ ជូនដំណើរ ។









យប់នោះ យើងទាំងពីរនាក់ទៅដល់ភូមិមួយឈ្មោះភូមិគោល ឃុំវាលពន់ ភូមិភាគនិរតី ដោយមាន តាប៉ាល់ ទទួលខុសត្រូវ ។ ពេលនោះ ខ្ញុំមានភារកិច្ចចេញចូលធ្វើការក្នុងភូមិមួយឈ្មោះ ភូមិត្រពាំងស្រង៉ែ ក្នុងឃុំពាម ។ ខ្ញុំ និង កែ គឹមហួត អប់រំបានមិត្តម្នាក់ឈ្មោះ ព្រេះ ។ ពេលជួបនឹងមិត្ត ព្រេះ ម្តងៗ ខ្ញុំនិយាយតែចំណុចខ្សោយរបស់បដិវត្តន៍ថា មិនដឹងទៅឈ្នះសម្តេចសីហនុ និងចក្រពត្តិម៉េចនឹងកើត បើស្អីក៏គ្មាន ប្រជាជនក៏គ្មាន សេដ្ឋកិច្ចក៏គ្មាន កងទ័ពក៏គ្មានផងនោះ ។

ខ្ញុំអប់រំរយៈពេលជាងពីរខែ មិត្ត ព្រេះ ក៏មានជំនឿមកខាងខ្ញុំ ។ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៨៦ ខ្ញុំ និង កែ គឹមហួត ហៅមិត្ត ព្រេះ មកជួប រួចហើយចាត់តាំងគាត់ទៅជាសមាជិក សេ.អ៊ី.អា ដោយយើងបានបញ្ជាក់ពីភារកិច្ចគាត់ឲ្យកសាងកម្លាំងប្រឆាំងបដិវត្តន៍ ។

លុះដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៦៨ ជាថ្ងៃរឹបអូសអាវុធពីខ្មាំងនៅនិរតី តាប៉ាល់ ដឹកនាំកម្លាំងជប់នាក់ឡើងទៅនៅលើភ្នំឱរ៉ាល់ ដោយមាន ខ្ញុំ និង កែ គឹមហួត ទៅជាមួយដែរ ។ ពេលផ្ទុតទឹកថ្ងៃៗ នៅលើភ្នំ កែ គឹមហួត តែងតែពិភាក្សាជាមួយខ្ញុំពីផែនការដែលត្រូវធ្វើ ហើយនៅក្នុងខែមេសា និងឧសភា ឆ្នាំ១៩៦៨ ជាដើមពេលលំបាក ខ្ញុំ និង កែ គឹមហួត បានបំផុសឲ្យយុវជនអស់សង្ឃឹមពីបដិវត្តន៍ ។

យុវជនឈ្មោះ អ៊ាន បានរត់ចេញពីជួរត្រឡប់ទៅផ្ទះវិញ ចំណែកយុវជនឈ្មោះ ហួន និង ឈ្មោះ យ៉េង ក៏ខ្ញុំ និង កែ គឹមហួត ទាក់ទាញទឹកចិត្តបាន ដោយយើងជួយឧបត្ថម្ភ និងជួយព្យាបាលគាត់នៅពេលឈឺថ្កាត់ ។ នៅខែកក្កដា ឆ្នាំ១៩៦៨ យើងទាំងពីរនាក់បញ្ចូល ហួន និង យ៉េង មកជាសមាជិក សេ.អ៊ី.អា ។

ក្នុងរវាងចុងឆ្នាំ១៩៦៩ កែ គឹមហួត និងខ្ញុំត្រូវអង្គការផ្លាស់មកឲ្យនៅខាងភូមិឱរ៉ាល់វិញ ។ ខ្ញុំដែលត្រូវកាន់ក្រុម បានធ្វើឲ្យក្រុមរអាក់រអួលជាប់ សមាជិកក្រុមត្រូវឈឺថ្កាត់ ខ្វះស្បៀង ដោយខ្ញុំរវល់តែកសាងកម្លាំង ចំណែកក្រុមដទៃអាចទៅរកក្តួចមកទប់ទល់ការខ្វះខាតបាន ។ ពេលនោះ ខ្ញុំកសាងបានយុវជនពីភ្នំពេញឈ្មោះ បូ បានម្នាក់ ។

លុះដល់ខែមិថុនា ឆ្នាំ១៩៧០ កែគឹមហួត ត្រូវអង្គការផ្លាស់ឲ្យទៅធ្វើការនៅសន្ទៃ ភូមិភាគពាយ័ព្យវិញ ហើយរវាងខែសីហា ឬខែកញ្ញា ឆ្នាំ១៩៧០ ខ្ញុំត្រូវបានផ្លាស់ទៅនៅមន្ទីរភាគនិរតីដែរ ។ ខ្ញុំត្រូវដាច់ការទាក់ទងពី កែ គឹមហួត ចាប់តាំងពីពេលនោះមក ។

ពេលមួយ សាំង រិន និង ធុច រិន មានរវល់ជាមួយ







អង្គការភូមិភាគនិរតី ខ្ញុំក៏បានជួបគាត់ទាំងពីរនាក់នៅទីងកន្លែងខ្ញុំ ។ ជាឱកាសល្អ ខ្ញុំក៏បានរាយការណ៍ឲ្យ សាំង រិន, ធុច រិន ពីសកម្មភាពដែលខ្ញុំ និង កែ គឹមហួត កសាងបាន ច្រេះ, ហួន, យ៉េង, បូ និងសកម្មភាពញុះញង់បំបែកកម្លាំងបដិវត្តន៍ ។ ខ្ញុំក៏បានប្រាប់គាត់ទាំងពីរនាក់ថា កែ គឹមហួត ផ្លាស់ទៅធ្វើការនៅឯសន្ទៃហើយ ។

លុះដល់ចុងខែវិច្ឆិកា ឆ្នាំ១៩៧០ អង្គការភូមិភាគនិរតី បានផ្លាស់ខ្ញុំឲ្យទៅធ្វើការនៅភូមិភាគពាយ័ព្យវិញ ។ រហូតដល់ដើមខែមករា ឆ្នាំ១៩៧១ ទើបអង្គការភូមិភាគពាយ័ព្យចាត់តាំងខ្ញុំឲ្យធ្វើប្រធានមន្ទីរភូមិភាគ ។ នៅខែមេសា ឆ្នាំ១៩៧១ ភូមិភាគពាយ័ព្យបានបើកសាលារៀនសូត្រនៅជិតមន្ទីរភូមិភាគ ដោយគ្រប់តំបន់ក្នុងភូមិភាគ ត្រូវមករៀនសូត្រ ។ កែ គឹមហួត, ខែក ប៉ែន ហៅ ស៊ូ អតីតសាស្ត្រាចារ្យនៅកំពង់ស្ពឺ បច្ចុប្បន្នប្រធានគណៈទាក់ទងកម្ពុជាថៃ ក៏មករៀនសូត្រដែរ ។ ឆ្លៀតឱកាសពេលសម្រាកថ្ងៃ កែ គឹមហួត បានហៅខ្ញុំ និង ខែក ប៉ែន ទៅជួបជុំគ្នានៅក្រោមម្លប់ឈើមួយដាច់ឆ្ងាយពីគេ ។ យើងខ្ញុំទាំងបីនាក់ក៏ស្គាល់កន្លែងគ្នាដោយ កែ គឹមហួត ប្រាប់ថាគាត់ធ្វើការនៅសន្ទៃ ស្រុកក្រគរ តំបន់២ ។ ខែក ប៉ែន និយាយថា គាត់នៅតំបន់៤ ។ ឯខ្ញុំប្រាប់ថា សព្វថ្ងៃនៅមន្ទីរភូមិភាគ ។

ឆ្លៀតពេលនោះ កែ គឹមហួត បានបញ្ជាក់ទៀតថា ទៅថ្ងៃមុខទៀត យើងត្រូវដាក់ខ្សែទាក់ទងគ្នាឲ្យជាប់ ។ បន្ទាប់មក ខែក ប៉ែន ក៏បាននិយាយប្រាប់ខ្ញុំដែរថា នៅភាគពាយ័ព្យនេះមានខ្សែក្បត់មួយដែលមិត្តអាចទាក់ទងបាន គឺបង សាយ បច្ចុប្បន្នគណៈភូមិភាគជាអ្នកទទួលខុសត្រូវ ។ ខែក ប៉ែន បានបញ្ជាក់ទៀតថា ចាំគាត់ប្រាប់បង សាយ ឲ្យស្គាល់មិត្ត ។

ក្រោយពេលបញ្ចប់វគ្គ ខ្ញុំបានបំផុសឲ្យយុវជនខ្លះរត់ត្រឡប់ទៅផ្ទះវិញ ដែលមានឈ្មោះ ហ៊ុត, យុត ជាដើម ។ ខ្ញុំឧស្សាហ៍ឃោសនាថា គ្រប់ការងារបដិវត្តន៍ ដូចជា ឃ្វាលគោ, រត់នីរសារ បង្កបង្កើនផល សុទ្ធតែដូចគ្នានឹងការងារនៅផ្ទះទាំងអស់ គ្មានមុខមាត់បុណ្យសក្តិអីទេ ។ នៅពេលនោះ មានយុវជនមួយចំនួនទៀតអស់សង្ឃឹមលើបដិវត្តន៍ លែងជឿលើបដិវត្តន៍ ខ្ញុំក៏ចាត់តាំងអ្នកទាំងនោះ ជា សេ.អ៊ី.អា ទៀត ដែលរួមមានឈ្មោះ កើត យោធាតំបន់៦, ឈ្មោះ កើន គណៈស្រុកពាមព្រួស, ឈ្មោះ ពេន អតីតកងការពារ និងឈ្មោះយុយ គណៈស្រុកមោង ។

នៅឆ្នាំ១៩៧២ តាមការណែនាំរបស់បង សាយ ខ្ញុំបានចាត់តាំងភ្នាក់ងារសម្ងាត់ម្នាក់ឈ្មោះ ពេន ឲ្យស៊ើបរកកន្លែងសម្ងាត់របស់បដិវត្តន៍ ។ ស៊ើបអស់រយៈពេលបួនទៅប្រាំខែ ពេន រកឃើញ








ឃ្លាំងស្រូវ ឃ្លាំងអាវុធ និងគ្រាប់ លាក់នៅជើងភ្នំពាក់ទ្រយោង ព្រមទាំងមន្ទីរពេទ្យសម្ងាត់សម្រាប់យោធារបួសនៅក្នុងព្រៃជិតភូមិបូសដូងទៀត ។ ខ្ញុំក៏យកដំណឹងនេះទៅរាយការណ៍ផ្ទាល់ឲ្យបង សាយ ហើយតាមផែនការរបស់គណៈកម្មាធិការ សេ.អ៊ី.អា ដែលមានគាត់ជាអ្នកទទួលខុសត្រូវគឺត្រូវបំផ្លិចបំផ្លាញឃ្លាំងទាំងនោះចោលតាមគ្រប់វិធី និងតាមលទ្ធភាព ។ ប៉ុន្តែការប៉ុនប៉ងជាបន្តបន្ទាប់ចេះតែមិនបានសម្រេច ព្រោះវិធានការការពារកន្លែងសំខាន់ៗរបស់បដិវត្តន៍ ម៉ឺងម៉ាត់ ហ្មត់ចត់ និងយាមល្បាតទាំងយប់ទាំងថ្ងៃ ។

បន្ទាប់មកខ្ញុំក៏បន្តសកម្មភាពនៅក្នុងមន្ទីរទូរលេខភូមិភាគ ដោយខ្ញុំបំផុសឲ្យយុវជន យុវនារី ស្រើបស្រាលតែពីរឿងគ្រួសារ និងរឿងស្នេហា ។ មិនយូរប៉ុន្មាន យុវជនឈ្មោះ រួម និង ឈុន បានទៅប្រព្រឹត្តរំលោភខុសសីលធម៌ ដោយយុវជន ឈុន ជាមួយយុវនារី រិន បានរំលោភគ្នាធ្លាក់ទៅបែបពុករលួយ ។ សភាពនេះធ្វើឲ្យផ្ទៃក្នុងទូរលេខ រង្គោះរង្គើយ៉ាងខ្លាំង ទំនាស់ប្របូកប្របល់ ដោះមិនរួច ។ យុវជនរួម, ឈុន, យុវនារីរិនភ័យខ្លួនខ្លាចបដិវត្តន៍ យកទោសពីរឿងប្រព្រឹត្តខុសសីលធម៌នេះក៏បានអែបជាប់មកខាងខ្ញុំ ។ ខ្ញុំស្គាល់ចំណុចខ្សោយរបស់អ្នកទាំងបី ហើយបំភ្លៃថែមតិចតួចទៀត ធ្វើឲ្យគេស្តាប់តាមខ្ញុំទាំងអស់ ។ ខ្ញុំបានចាត់តាំងអ្នកទាំងបីឲ្យទៅជាសមាជិក សេ.អ៊ី.អា ថ្មី ថែមទៀត ។

ឆ្នាំ១៩៧៣ ដោយសារកន្លែងធ្វើការរបស់បង សាយ និងខ្ញុំនៅជិតគ្នា ខ្ញុំចាប់ធ្វើសកម្មភាពនៅមន្ទីររោងពុម្ពរបស់គាត់ទៀត ព្រោះខ្ញុំមានមនុស្សជិតស្និទ្ធ ឈ្មោះ គិម យ៉ាន ជួយធ្វើការនៅរោងពុម្ពនោះ ។ ខ្ញុំតែងណែនាំបំផុស គិម យាន ឲ្យធ្វើខូចនេះខូចនោះ ជួនកាលគាត់ទៅឆ្កឹះម៉ាស៊ីនទាញពុម្ពអក្សរនាំឲ្យម៉ាស៊ីនខូចម៉ោះខានបោះពុម្ព ខាតពេលមួយរយៈ កាសែតត្រូវគាំងដំណើរខានចេញផ្សាយ ។ ជួនកាល ខ្ញុំអត់ទៅដោះស្រាយទិញក្រដាសហើយម្យ៉ាងទៀត ដោយនៅរោងពុម្ពមាន អ្នកកម្លាំងខ្សោយគឺ គិម យ៉ាន និង គុយ អាន ហើយមិត្តម្នាក់ជាអ្នកពលកម្មខ្លាំងដូច្នេះខ្ញុំតែងបំផុសដល់អ្នកកម្លាំងខ្សោយថា ត្រូវធ្វើតាមកម្លាំង តាមសមត្ថភាព ចុះ ព្រោះអ្នកខ្សោយទៅប្រៀបអ្នកពលកម្មខ្លាំងម្តេចកើត អ្នកខ្លាំងទៅកាប់រំលំដើមឈើតែមួយភ្លែត អ្នកខ្សោយត្រូវកាប់មួយព្រឹក ។ ចាប់តាំងពីពេលនោះមក ផ្ទៃក្នុងរោងពុម្ពចេះតែបែកបាក់ប្រេះឆាជាប់តាំងពីស៊ីចុករស់នៅរហូតដល់ការងារ ។

ដោយខ្ញុំស្គាល់ចំណុចខ្សោយ គិម យ៉ាន, គុយ អាន ទាំងកម្លាំងកាយ ទាំងសតិអារម្មណ៍ ។ ដូច្នេះពេលជួបគ្នាម្តងៗ ខ្ញុំតែងបំផុសអប់រំអ្នកទាំងពីរមិនឲ្យមានជំនឿលើបដិវត្តន៍ ដោយបន្ទាប់បដិវត្តន៍ថា គ្មានអីសប្បាយរីករាយ គ្មានអនាគត សុភមង្គលសម្រាប់ខ្លួន គឺអ្វីៗទាំងអស់សម្រាប់តែរួម សម្រាប់តែសមូហភាព ចាប់ពីរបស់របរ ធនធាន ទ្រព្យសម្បត្តិ ផ្ទះសម្បែង កន្លែងលក់ដូរ រោងចក្រ រោងឧស្សាហកម្មសព្វបែបយ៉ាង ។ ខ្ញុំឧស្សាហ៍អប់រំ គិម យ៉ាន, គុយ អាន យូរខែទៅ អ្នកទាំងពីរមកខាងខ្ញុំទាំងស្រុង ។ ទីបំផុត ខ្ញុំកសាងឈ្មោះ គិម យ៉ាន និង គុយ អាន មកជាសមាជិក សេ.អ៊ី.អា ថែមទៀត ។

ដល់ដើមខែមករា ឆ្នាំ១៩៧៤ អង្គការភូមិភាគផ្លាស់ខ្ញុំឲ្យមកធ្វើការនៅតំបន់៦វិញ ។ មុននឹងចេញមកតំបន់៦ បង សាយ បានណែនាំខ្ញុំជាប់ពីផែនការកសាងកម្លាំង ។ ដូច្នេះ មកដល់តំបន់៦ភ្លាម ខ្ញុំក៏ចាប់ផ្តើមធ្វើសកម្មភាពក្នុងតំបន់ខ្ញុំគ្រប់គ្រង គឺក្នុងស្រុកលាច ដោយដំបូង ខ្ញុំបំផ្លើសមាគ៌ាអង្គការដែលចែងថា របស់ប្រើប្រាស់ផ្ទាល់ខ្លួនដូចជា មាស ប្រាក់ ខ្សែដៃ ខ្សែក កែវកង មិនបាច់ចូលក្នុងសហករណ៍ទេ ។ តែខ្ញុំទៅពន្យល់ណែនាំគណៈឃុំក្នុងស្រុកថា សហករណ៍គឺចូលគ្នាទាំងអស់ រួមគ្នាទាំងអស់ ចូលតាំងពីកម្លាំងមនុស្ស កម្លាំងសត្វ មធ្យោបាយបង្កបង្កើនផល ដីធ្លី រហូតដល់របស់របរប្រើប្រាស់ ។ ពន្យល់ណែនាំគណៈឃុំហើយ ខ្ញុំក៏យកទៅបំផ្លើសប្រជាជន ហើយបង្ខំឲ្យប្រជាជនអនុវត្តតាម បណ្តាលឲ្យប៉ះពាល់ផលប្រយោជន៍ប្រជាជន ការបង្កបង្កើនផល និងបង្កឲ្យមានទំនាស់ក្នុងសហករណ៍ ។ ប្រជាជនអស់ជំនឿលើសហករណ៍ និងចលនាបដិវត្តន៍ទៀត ។

បន្ទាប់មក ខ្ញុំបានបំផុសយុវជន យុវនារី នៅភូមិសាលាក្នុងឃុំរវៀង មិនឲ្យទៅសមរភូមិមុខ ដោយបំភ្លៃថា បើទៅមុខគឺស្លាប់ ដូច្នេះយុវជន យុវនារីសម្ងំនៅខាងក្រោយ ដើម្បីរៀបចំយកគ្រួសារ ។ ខ្ញុំបានបំផុសទៀតថា កម្លាំងយុវជន នារី សម្ភារ ស្បៀង ស្រូវ អង្ករ បន្លែ បង្ការគ្គី មិនបាច់ឧបត្ថម្ភដល់សមរភូមិមុខទេ ព្រោះខាងក្រោយមិនមានកម្លាំង និងគ្មានស្បៀងសម្រាប់ចិញ្ចឹម

ក្រពះទេ ។

ក្នុងរយៈបីបួនខែប៉ុណ្ណោះ ខ្ញុំទាក់ទាញបានកម្លាំងមួយចំនួននៅខាងពាណិជ្ជកម្មមានឈ្មោះ ផាស់, ម៉ាច, ពន ឯខាងពេទ្យមានឈ្មោះ លឿន ។ គណៈឃុំទាំងអស់ក្នុងស្រុកលាចក៏ខ្ញុំទាក់ទាញទឹកចិត្តបានដូចជា នៅឃុំលាចមានឈ្មោះ ខាត់, នៅឃុំបឹងអង់មានឈ្មោះ វ៉េត និង អ៊ឹ, នៅឃុំរវៀង មានឈ្មោះ ចិត្រ, ថោង និង ឆេង ។ បន្ទាប់មក ខ្ញុំបញ្ចូលឈ្មោះទាំងនេះចូលជាសមាជិក សេ.អ៊ី.អា ថែមទៀត ។

ដោយតំបន់៦ដែលខ្ញុំគ្រប់គ្រង និងស្រុកក្រគរនៅជាប់គ្នា នៅដើមខែឧសភា ឆ្នាំ១៩៧៤ ខ្ញុំទៅរាយការណ៍ផ្ទាល់ឲ្យ កែ គឹមហួត ពីសកម្មភាពដែលធ្វើឲ្យប្រជាជនរំដើបរំដួល បំផ្លើសមាគ៌ាអង្គការ បំផុសសមរភូមិក្រោយ មិនឲ្យជួយខាងមុខ និងកម្លាំង សេ.អ៊ី.អា ដែលទើបកសាង ។

ដល់ចុងខែមិថុនា ឆ្នាំ១៩៧៤ ភូមិភាគពាយ័ព្យបានបើកសាលារៀនសូត្រលើកទី១ ដោយគ្រប់តំបន់ត្រូវមកចូលរួម ។ មុនពេលចូលរៀនខ្ញុំឆ្លៀតពេលទៅជួបនឹងបង សាយ នៅនឹងកន្លែងរបស់គាត់ផ្ទាល់ដើម្បីរាយការណ៍ពីសកម្មភាពដែលខ្ញុំបានធ្វើនៅតំបន់៦ ។ ពេលជួបគ្នាលើកនេះ បង សាយ បានខទ្មេសនាមខ្ញុំពីកម្លាំងនៅភាគពាយ័ព្យ មានឈ្មោះ ជា ហួន ហៅ វ៉ាញ អតីតសាស្ត្រាចារ្យឆ្នាំ១៩៧៤ គណៈតំបន់២, ជុន ហៅ ហ៊ឹង្ស អតីតសិស្សឆ្នាំ១៩៧៤ គណៈតំបន់៥, នង សារឹម ហៅ សាន អតីតសាស្ត្រាចារ្យឆ្នាំ១៩៧៤ គណៈតំបន់៣ ។ បង សាយ តែងឆ្លៀតពេលជួបគ្នាផ្ទាល់តាមបុគ្គល ឬតាមក្រុម ហើយឆ្លៀតពេលសម្រាកថ្ងៃ គាត់បានហៅ ខ្ញុំ, ខែក ប៉ែន, កែ គឹមហួត ទៅជួបជុំគ្នានៅកន្លែងផ្ទួតទឹកតាមមាត់ស្ទឹង ដើម្បីរំពុកពីផែនការ និងសកម្មភាព សេ.អ៊ី.អា ដែលត្រូវបង្កើនឲ្យខ្លាំងក្លាថែមទៀត ។ សមាជិកទាំងអស់គ្នាយល់ស្របតាមយោបល់បង សាយ ហើយការជួបជុំបានបញ្ចប់ ។

វគ្គរៀនសូត្រឆ្នាំ១៩៧៤ ត្រូវបន្តអស់រយៈជាងម្ភៃថ្ងៃទើបចប់ ហើយគ្រប់តំបន់ត្រូវត្រឡប់ទៅកន្លែងរៀងៗខ្លួនវិញ ។ មកដល់កន្លែងខ្ញុំបានហៅមិត្ត ផាស់ និង ម៉ាច មកប្រជុំធ្វើសកម្មភាពនៅពាណិជ្ជកម្ម ។ ខ្ញុំបានលើកយោបល់ធ្វើយ៉ាងណាឲ្យផ្នែកពាណិជ្ជកម្មប្រឆាំងនឹងចលនាបដិវត្តន៍ ។ មិត្ត ផាស់ ក៏ដូចមិត្ត ម៉ាច យល់ស្របគ្នាថា ឲ្យតែយើងលក់ចេញ ហើយកុំទិញចូលមកវិញ នោះពាណិជ្ជកម្មនឹងត្រូវគាំងដំណើរ ។ ខ្ញុំនិងកម្លាំងនៅពាណិជ្ជកម្មចាប់ទិញផលិតផលទាំងអស់ ដែលប្រជាជនរកបាន ដូចជា ជ័រ វល្លិ៍ ខ្លឹមឈើ និងផលផ្សេងៗទៀត ដើម្បីលក់យកចំណេញ តែមិនបានទិញក្រណាត់ សម្លៀកបំពាក់ អំបោះត្បាញ សំពត់ភ្លៀង អំបិល ប្រហុក និងរបស់របរប្រើប្រាស់ចាំបាច់ចូលមកវិញទេ ។ ប្រជាជនត្រូវខ្វះសព្វខ្វះគ្រប់ ខ្វះរបស់របរប្រើប្រាស់ ខ្វះអំបិល ប្រហុក ស្លៀកពាក់រយេរយៃ លេចមុខលេចក្រោយ ស្ទើរមិនហ៊ានចេញពីផ្ទះ ។ កង្វះខាតខ្វះទាំងសព្វ ខ្វះទាំងគ្រប់ ធ្វើឲ្យប៉ះពាល់ដល់ចលនារួមរបស់បដិវត្តន៍ ទាំងការបង្កបង្កើនផលខាងក្រោយ ទាំងសមរភូមិក្តៅខាងមុខ ។

ឯនៅពេទ្យតំបន់ ខ្ញុំចាត់តាំងឈ្មោះ លឿន ឲ្យធ្វើសកម្មភាពអុកឡុក បំផ្លិចបំផ្លាញនៅពេទ្យ ដោយបង្អត់ថ្នាំសង្កូវ មិនដោះស្រាយថ្នាំសម័យ ខ្វះអ្នកមើលជំងឺ ខ្វះអ្នកព្យាបាល អ្នកវះកាត់ក៏មិនដោះស្រាយ ។ ចំណែកប្រដាប់ប្រដារប្រើប្រាស់ត្រូវបានធ្វើឲ្យខូចខាត អន្តរាយជាបន្តបន្ទាប់ បណ្តាលឲ្យប្រជាជនឈឺថ្កាត់គ្មានឈប់ឈរ ។

សកម្មភាពបំផ្លាញផ្នែកពាណិជ្ជកម្ម និងពេទ្យបន្តអនុវត្តរាប់ខែ រហូតដល់ក្រោយរំដោះឆ្នាំ១៩៧៥ទៀត ។ ប្រជាជនក្នុងតំបន់ទាំងមូលជួបការលំបាកខ្លាំងឡើងៗ ជំងឺឈឺថ្កាត់កាន់តែរីករាលដាល ម្យ៉ោះហើយការលើកទំនប់ ភ្លឺប្រឡាយ អាង ស្រះ ត្រពាំង ភ្លឺស្រែថ្មី ត្រូវគាំងដំណើរមួយរយៈ ។

មកដល់ថ្ងៃ៣០ ខែមេសា ឆ្នាំ១៩៧៥ គណៈកម្មាធិការ សេ.អ៊ី.អា នៅពាយ័ព្យដែលមានបង សាយ ទទួលខុសត្រូវបានបើកប្រជុំនៅសាកលវិទ្យាល័យបាត់ដំបង រួមមាន ១) បង សាយ គណៈភូមិភាគ និងជាលេខាតំបន់១, ២) មិត្ត វ៉ាញ ពាណិជ្ជកម្មភូមិភាគ ៣) មិត្ត សាន គណៈកម្មាធិការយោធាភូមិភាគ ៤) មិត្ត ហ៊ឹង្ស លេខាតំបន់៥, ៥) មិត្ត ស៊ូ គណៈតំបន់៤, ៦) មិត្ត ស៊ុយ លេខាតំបន់៤ និង ៧) ខ្ញុំ គណៈតំបន់៦ ហើយខ្លឹមសារដែលបានលើកក្នុងអង្គប្រជុំនោះមានដូចតទៅ ៖

១) ត្រៀមរៀបចំកម្លាំង សេ.អ៊ី.អា ដែលមានក្នុងភូមិភាគពាយ័ព្យ ។

២) ស្រាវជ្រាវកម្លាំងដែលមានស្រាប់ មុននិងក្រោយរំដោះ ។

៣) រៀបចំអប់រំ កសាងកម្លាំង សេ.អ៊ី.អា ក្នុងមូលដ្ឋានតំបន់ អង្គភាព និងក្រសួងនីមួយៗ ។

៤) រៀបចំតាំងតែងកម្លាំងតាមភារកិច្ចនីមួយៗ ។

បន្ទាប់ពីបានជជែកវែកញែក និងលើកយោបល់រួច ខ្ញុំបានបន្តស្រាវជ្រាវរកកម្លាំងដែលខ្ញុំបានកសាងរួចហើយ នៅពាយ័ព្យ មានឈ្មោះ ពេន, មេន, កើត, កើន,យុយ, រួម, ឈុន, រិន, គិម យ៉ាន, គុយ, អាន, ថាស់, ម៉ាច, ពន, លឿន, ខាត់, វ៉េត, អ៊ុំ, ចិត្រ, ថោង, ឆេង សរុបទាំងអស់ម្ភៃនាក់ ។

នៅដើមខែឧសភា ឆ្នាំ១៩៧៥ ខ្ញុំក៏បានទៅរកទាក់ទងជាមួយមិត្ត វ៉ាញ នៅបាត់ដំបង ដែលពេល នោះ បង សាយ ក៏នៅនឹងខេត្តនោះដែរ ។ ដោយឃើញថា ស្រូវជ័យភណ្ឌនៅគ្រប់រោងចក្រកិនស្រូវធំៗក្នុងក្រុង បង សាយ បានហៅខ្ញុំ និងមិត្ត វ៉ាញ ទៅជួបជុំនៅសាកលវិទ្យាល័យបាត់ដំបង (ជាកន្លែងស្នាក់នៅរបស់មិត្ត វ៉ាញ) ។ បង សាយ មានយោបល់ថា យើងត្រូវលៃទុកដាក់ស្រូវខ្លះ ដើម្បីបម្រើការងារ និងផែនការយើង ។ គាត់បន្តថា ស្រូវយើងមានច្រើនណាស់ ដូច្នេះយើងត្រូវលៃលកទុកជាបីផ្នែក គឺទុកខាងមិត្ត វ៉ាញ ព្រោះមានឃ្លាំងធំៗ និងមានមនុស្សសម្រាប់ទុកដាក់ ។ មួយផ្នែកទៀត ខាងគាត់ (សាយ) ទុកនៅបាណន់ ឬនៅស្ពោ ព្រោះមានឃ្លាំង និងកន្លែងសម្ងាត់ ។ ឯតំបន់៦ ទុកខាងមិត្ត ម៉ៃ (ខ្ញុំ) ចំនួន១៥,០០០ថាំង ។ ខ្ញុំបន្ថែមថា អាចធានាទុកដាក់បាន ព្រោះខ្ញុំមានកម្លាំងនៅពាណិជ្ជកម្ម និងមានជង្រុកធំៗ នៅលាចស្រាប់ ។




លុះដល់ថ្ងៃ២៦ ខែមិថុនា ឆ្នាំ១៩៧៥ បង កន គណៈអចិន្ត្រៃយ៍ភាគបានផ្ទាស់ខ្ញុំឲ្យមកខាងពាណិជ្ជកម្មភូមិភាគ ដោយមានមិត្ត វ៉ាញ ជាលេខា និង ខ្ញុំជាសមាជិក ។ ពេលខ្ញុំទៅដល់ វ៉ាញ់បានប្រមូលសម្ភារជ័យភណ្ឌ គ្រប់បែបយ៉ាងពីក្រុងបាត់ដំបងដាក់នៅផ្ទះ និងឃ្លាំងស្រេចទៅហើយ ដែលមានដូចជា ៖ ប្រដាប់ប្រដារគ្រឿងបន្លាស់ គ្រប់បែបយ៉ាងសម្រាប់ជួសជុលឡាន និងត្រាក់ទ័រ ។ ចំណែករោងឧស្សាហកម្មធ្វើនំចំណី ធ្វើទឹកក្រូច ក៏បានដំឡើងស្រេចដែរ ។

រហូតដល់ដើមខែកក្កដា ឆ្នាំ១៩៧៥ មិត្ត វ៉ាញ បានហៅខ្ញុំទៅជួបសម្ងាត់នៅផ្ទះគាត់ ។ គាត់បាន និយាយថា ការប្រមូលទុកដាក់សម្ភារ គ្រឿងឡាន ការដំឡើងរោងជាង រោងឧស្សាហកម្មទាំងនោះគឺដើម្បីបម្រើផែនការរដ្ឋប្រហារ ។ ខណៈនោះ ខ្ញុំយល់ស្រប ទាំងស្រុងពីការលើកឡើងនេះ ។

នៅខែសីហា ឆ្នាំ១៩៧៥ គណៈកម្មាធិការនៅភូមិភាគពាយ័ព្យបានបើកប្រជុំលើកទី២ នៅសាកលវិទ្យាល័យបាត់ដំបង ដើម្បីលើកពីផែនការរដ្ឋប្រហារមាន បងសាយ, មិត្ត វ៉ាញ, មិត្ត សាន, មិត្ត ហ៊ីង្ស, មិត្ត ស៊ូ, មិត្ត ស៊ុយ និងខ្ញុំ ។ ដំបូងបង្អស់ បង សាយ ឲ្យអង្គប្រជុំពិនិត្យមើលកម្លាំង សេ.អ៊ី.អា ចាស់ដែលកសាងបាន ហើយ និងកម្លាំងកសាងថ្មី ។ បន្ទាប់មកគាត់លើកផែនការដូចជា ៖

១) កសាងកម្លាំង សេ.អ៊ី.អា តាមមូលដ្ឋាននីមួយៗ ។

២) ការឃោសនាអប់រំ បំពាក់បំប៉នដល់កម្លាំង សេ.អ៊ី.អា ថ្មី ។

៣) ត្រូវមានមូលដ្ឋានបង្អែកក្បត់មួយ នៅក្នុងព្រៃ តាមព្រំដែនប្រទេសថៃ ។

៤) ការត្រៀមស្បៀង ដើម្បីធ្វើរដ្ឋប្រហារ ។

៥) ការរៀបចំកម្លាំងដែលរត់ទៅជ្រកនៅប្រទេសថៃ ។

៦) ត្រូវធ្វើសកម្មភាពបំផុសប្រជាជនឲ្យរត់ចេញទៅប្រទេសថៃ។ បន្ទាប់មកបង សាយ ក៏អំពាវនាវដល់អង្គប្រជុំឲ្យមានយោបល់ ។ មិត្ត ស៊ូ លើកឡើងថា ចំពោះស្រូវអង្ករ និង សម្ភារផ្សេងៗទៀត សម្រាប់មូលដ្ឋានបង្អែកយើងអាចទិញដូរតាមច្រកប្រទេសថៃ។ ខ្ញុំក៏មានយោបល់ថា ក្រៅពីទិញដូរតាមច្រកថៃនេះ ស្បៀងយើងក៏បានត្រៀមលាក់ទុកដាក់នៅតំបន់៦ តំបន់២ តំបន់១ និងនៅក្នុងក្រុងបាត់ដំបងដែរ ។ ឯមិត្ត ហ៊ីង្ស ក៏មានយោបល់ថា តាំងពីក្រោយរំដោះមក គាត់បំផុសប្រជាជនឲ្យរត់ទៅថៃជាច្រើនរយគ្រួសារ ដោយមានទាំងគណៈឃុំក្នុងស្រុកថ្មពួកដងដែរ ។

ក្រោយពីប្រជុំលើកទី២មក មិត្តវ៉ាញ, ខ្ញុំ និងមិត្តគិម យ៉ាន បានជួបជុំគ្នាម្តងទៀត ។ ខ្ញុំមានយោបល់ថា ចំពោះអង្ករ និងអំបិល ដែលមិត្ត គិម យ៉ាន បានទិញពីច្រកថៃនោះ យើងបានទុកដាក់ខ្លះហើយ ។ មិត្ត វ៉ាញ និងខ្ញុំ យល់ស្របគ្នាថា អង្ករ និងអំបិល យើងលាក់ទុកក្នុងស្រុកអូរជ្រៅ ព្រោះមិត្ត នៅ គ្រប់គ្រងកងពលប្រចាំព្រំដែននេះស្រាប់ ។ មិត្ត នៅ មានឃ្លាំងធំៗ នៅនិមិត្ត នៅកូប និងមានភ្នាក់ងារមើលការខុសត្រូវទៀត ។

នៅខែកញ្ញា ឆ្នាំ១៩៧៥ ខ្ញុំ និងមិត្ត ស៊ុយ ព្រមទាំងមិត្ត កើន គណៈស្រុកពាមព្រួស បានជួប ជុំគ្នានៅលាចរកវិធីបញ្ចេញមនុស្សឲ្យរត់ទៅថៃ។ មិត្ត កើន មានយោបល់ថា នៅភូមិអូរសោម ឃុំវាលវែង មានអ្នកធ្លាប់រកស៊ីចេញចូលទៅខាងថៃ ដូច្នេះការបំផុសឲ្យរត់ទៅថៃនោះជាការងារស្រួលណាស់ ដោយយើងគ្រាន់តែបំផុសថា បដិវត្តន៍គ្មានរកស៊ីលក់ដូរ គ្មានចាយលុយ គ្មានផ្សារ គ្មានសាសនា គ្មានជំនឿ ដូចនៅថៃទេ ។ ពិភាក្សាគ្នារួចហើយ ខ្ញុំក៏បានចាត់តាំងមិត្ត កើន ឲ្យទៅបំផុសនៅ អូរសោម ។ តាមមិត្ត កើន មករាយការណ៍ឲ្យខ្ញុំនៅបាត់ដំបងថា មានប្រជាជនសរុបទាំងអស់ជាង ១០០គ្រួសាររត់ទៅថៃ ។

ខ្ញុំក៏បានសួរបញ្ជាក់ថា តើយើងអាចបោះទីតាំងបង្អែកនៅស្រុកពាមព្រួស តំបន់៦ ពេលផ្ទុះរដ្ឋប្រហារក្បត់បានទេ? មិត្ត កើន បានឆ្លើយតបថា បើមូលដ្ឋានបង្អែកគឺល្អណាស់ ព្រោះនៅតាមព្រំដែនតំបន់៦ មានច្រកចេញចូលតាមភូមិថៃឈ្មោះ ម៉ៃរោត និង ស្ពានហ៊ីន ។ ចំណែកប្រជាជនខ្លះដែលរត់ទៅថៃ ក៏មានរស់នៅក្នុងភូមិនេះ ហើយយើងអាចទាក់ទងថ្ងៃក្រោយបានដែរ ។

ស្រាប់តែដើមខែវិច្ឆិកា ឆ្នាំ១៩៧៥ ក្រសួងការបរទេស បានផ្លាស់ប្តូរខ្ញុំ និងមិត្ត ស៊ូ ឲ្យមកនៅខាងគណៈទាក់ទងកម្ពុជាថៃ ប្រចាំនៅប៉ោយប៉ែតវិញ ។ ពេលមកដល់ប៉ោយប៉ែតដំបូង ខ្ញុំ មិត្ត ស៊ូ និងមិត្ត នៅ ប្រធានកងពលទី១ ក៏បានបើកដៃឲ្យមនុស្សប្អូននាក់ក្លែងខ្លួនជាអ្នកថតកុនរត់ចេញទៅថៃ ហើយនៅដើមឆ្នាំ១៩៧៦ យើងបើកឲ្យយោធាបួននាក់ឈ្មោះ កង, កយ ជាយុទ្ធជនខាងកងពលទី១, ឈ្មោះ ធី ជាមេពួកក្នុងកងពលទី១ និងអ្នកបើកឡានម្នាក់ទៀត នៅថ្មគោល រត់ចេញទៅថៃតាមច្រកដដែល ។

រហូតមកដល់ដើមឆ្នាំ១៩៧៦ ពាណិជ្ជកម្មភូមិភាគត្រូវអង្គការប្រគល់ឲ្យមកខាងគណៈទាក់ទងកម្ពុជាថៃ ដែលមានមិត្ត ស៊ូ ជាប្រធានទៀត ។ ពេលនោះ ខ្ញុំ, មិត្ត ស៊ូ, មិត្ត សាន និង មិត្ត នៅ គិតតែពីបញ្ចេញត្រី សាច់គ្រប់មុខ ទាំងត្រីឆ្អៀត ត្រីឆ្អើ ឬត្រីស្រស់ ទៅឲ្យឈ្មួញថៃក្នុងមួយថ្ងៃៗ រាប់តោន និងដឹកទាំងឡានៗ ។ មិត្ត ហ៊ីង្ស តំបន់៥ ក៏បានទាក់ទងផ្ទាល់មកខ្ញុំ និងមិត្ត ស៊ូ ឲ្យជួយ បញ្ចេញមាស និងត្បូងតាមច្រកប៉ោយប៉ែតនេះដែរ ។ ក្រៅពីមុខទំនិញទាំងនេះ យើងបានបញ្ចេញគ្រាប់ឈូក និងកាហ្វេរាប់រយតោនថែមទៀត ។ ចំណែកប្រជាជន ក៏យើងបើកឲ្យរត់ទៅថៃ តាមច្រកខាងជើង និងខាងត្បូងប៉ោយប៉ែតអស់ច្រើនរយនាក់ ។

នៅដើមឆ្នាំ១៩៧៦ដដែល អង្គការបញ្ជាឲ្យទិញអំបិលពីថៃឲ្យបានចំនួនពីរម៉ឺនតោន តែខាងថៃមិនទាន់ប្រគល់មកឲ្យទេ ។ ថ្ងៃមួយ ពេលល្ងាចណាស់ទៅហើយ ប្រធានគណៈទាក់ទងថៃឈ្មោះ ស្នង បានទូរស័ព្ទមកប្រធានគណៈទាក់ទងកម្ពុជាច្រើនសាថា លោកអនុរដ្ឋមន្ត្រីឈ្មោះ ជែន មកសុំជួបនឹងប្រធានទាក់ទងកម្ពុជា ។ ដោយពេលខ្ជីពេក យើងសម្រេចថា ឲ្យមកចុះ ។ ពេលអនុរដ្ឋមន្ត្រីឈ្មោះ ជែន និងគណៈទាក់ទងថៃមក ខ្ញុំក៏ឃើញអ្នកថតរូប និងផ្នែកឃ្លាំងថៃមកជាមួយដែរ ។ ជែន ប្រាប់ថា គាត់មកនេះគឺដើម្បីប្រគល់អំបិល ដោយពេលនោះមានថង់ប្លាស្ទិចដាក់អំបិលមកផង ហើយសុំឲ្យថតរូបជាមួយគ្នា (ទាំងមិត្ត ស៊ូ និងខ្ញុំ) ។ យើងថា មិនបាច់ថតទេ តែខាងថៃចេះតែចាប់បង្ខំឲ្យថត ដោយឲ្យមិត្ត ស៊ូ កាន់ថង់អំបិល តំណាងពិធីប្រគល់អំបិល រួចអ្នកថតរូបថតភ្លាមៗ

តែម្តង ។ ថតរួចហើយ ខាងថៃសុំទៅមើលចំណតរថភ្លើងក្នុងផ្សារ ប៉ោយប៉ែតទៀត មិត្ត ស៊ូ និងខ្ញុំ ក៏នាំទៅមើល ។ ដើរមើលសព្វគ្រប់ហើយ ដែន និយាយថា "ចំពោះផ្លូវរថភ្លើង ប៉ោយប៉ែតនេះ ខាងថៃយើងខ្ញុំអាចធានាជួយធ្វើឲ្យទាំងអស់" ។ មិត្ត ស៊ូ និងខ្ញុំ ក៏ឆ្លើយតបទីងថៃថា យើងត្រេកអរណាស់ដែលលោកបម្រុងជួយជួសជុលយ៉ាងនេះ ចាំថ្ងៃណាដល់ពេលត្រូវការជួសជុល យើងខ្ញុំនឹងជម្រាបទៅលោកភ្លាម ។ បន្ទាប់មក យើងនាំគណៈប្រតិភូថៃទៅសម្រាកនៅមុខកន្លែងធ្វើការមួយភ្លែត ដោយទទួលស្រាមួយកែវៗម្នាក់ ។ យើងជជែកលេងពីនេះពីនោះ រួចហើយខាងថៃក៏សុំលាត្រឡប់ទៅវិញ ។

ក្រោយមក មិត្ត សាន, មិត្ត នៅ, មិត្ត ស៊ូ និងខ្ញុំ បានចាត់តាំងមិត្ត ធី (មេពួកក្នុងកងពលទី១ដែលរត់ទៅថៃ) ឲ្យទៅប្រមូលកម្លាំង និងទៅរក អ៊ិន តាំ ដោយបញ្ជាក់ទៀតថា រក អ៊ិន តាំ ឃើញលុះត្រាតែមិត្តខស្សាហ៍ទៅឯជុំវិញជនភៀសខ្លួនខ្មែរនៅក្នុងស្រុកអារញ្ញ ។ ចំណែក យាយ ផុន ជាឈ្មួញថៃដែលមករកស៊ីរាល់ថ្ងៃនៅប៉ោយប៉ែតនេះក៏ស្គាល់កន្លែងនោះច្បាស់ដែរ ។ ដូច្នេះ ពេលណាមានផ្ទុះរដ្ឋប្រហារ នោះមិត្តនាំកម្លាំងដែលកសាងបាននៅថៃមកជួយវាយបដិវត្តន៍ ។

នៅពាក់កណ្តាលខែកុម្ភៈ ឆ្នាំ១៩៧៦ បង សាយ បានហៅកម្លាំងទាំងអស់នៅពាយ័ព្យ មករួមប្រជុំនៅសកលវិទ្យាល័យបាត់ដំបង ក្នុងគោលបំណងធ្វើរដ្ឋប្រហារ ដោយមានៈ

១) បង សាយ គណៈភូមិភាគ
២) មិត្ត វ៉ាញ ពាណិជ្ជភូមិភាគ
៣) មិត្ត សាន គណៈកម្មាធិការយោធាភូមិភាគ
៤) មិត្ត ស៊ូ គណៈទាក់ទងកម្ពុជាថៃ
៥) មិត្ត ស៊ុយ គណៈតំបន់៤
៦) មិត្ត ហ៊ីង្ស លេខាតំបន់៥
៧) សុត លេខាតំបន់៧
៨) ខ្ញុំ គណៈទាក់ទងកម្ពុជាថៃ
៩) ហ៊ាង លេខាតំបន់៤
១០) ខ្វៃង គណៈយោធភូមិភាគ
១១) ខូយ កងពលទី២
១២) នៅ កងពលទី១
១៣) គួ គណៈតំបន់៣
១៤) ខាន គណៈតំបន់២

បង សាយ លើកផែនការវាយបដិវត្តន៍នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៦ បន្ទាប់មក គាត់លើកផែនការមួយចំនួនទៀត ជូនដល់អង្គប្រជុំជួយពិនិត្យ រួមមានផែនការវាយ និងរៀបចំកងទ័ពដែលមានកងពលទី១ ដឹកនាំដោយមិត្ត នៅ ប្រចាំការនៅព្រំដែនខាងលិច និងកងពលទី២ ដឹកនាំមិត្ត ខូយ ប្រចាំនៅពាយ័ព្យ ប៉ែកខាងត្បូងបោះទីតាំងនៅក្រកោះ ជិតទីរួមស្រុកមោង ។

ប្រធានអង្គប្រជុំក៏បន្តថា ខាងភូមិភាគឧត្តរមាន ស្រេង ជាសមាជិកគណៈភូមិភាគ និងភូមិភាគបូព៌ាមាន ឈូក ជាសមាជិកអចិន្ត្រៃយ៍ភូមិភាគ និង ខឿន ប្រធានមន្ទីរ៨៧០ ជាអ្នកដឹកនាំកម្លាំងវាយក្រុងភ្នំពេញ ។ ប៉ុន្តែ ផែនការវាយក្រុងភ្នំពេញត្រូវខកខានមកពីអ្នកដឹកនាំរួម ធុច ត្រូវអង្គការដកការកិច្ច និងចាប់ឃុំឃាំងហើយ ខឿន ក៏ត្រូវផ្លាស់ឲ្យមកនៅជិតអង្គការទៀត ។ ចំណែកផែនការវាយនៅពាយ័ព្យលើកនេះ ក៏មិនបានសម្រេចទៀតព្រោះខាងភូមិភាគមានវិធានការទប់ទល់មុនរួចហើយបានផ្លាស់ វ៉ាញ ទៅនៅតំបន់១ រីឯ បង សាយ ក៏ត្រូវអង្គការ ផ្លាស់មកមន្ទីរភូមិភាគដែរ ។ ឃើញដូច្នេះ កម្លាំងដឹកនាំបានរកផ្លូវចេញទៅប្រទេសថៃ រួមមានទាំងខ្ញុំដែរ ប៉ុន្តែចេញមិនរួចដោយអង្គការមានវិធានការហ្មត់ចត់ ។

មកដល់ខែកក្កដា-សីហា ឆ្នាំ១៩៧៦ ការទិញដូរជាមួយថៃដែលគ្រប់គ្រងដោយគណៈទាក់ទងកម្ពុជា-ថៃ ត្រូវពាណិជ្ជកម្មរដ្ឋដែលមានមិត្ត ឈឿន មកកាន់កាប់វិញ ។ ដំបូងមិត្ត ឈឿន បានទៅដល់ប៉ោយប៉ែត ហើយគាត់បានពឹងខ្ញុំឲ្យទៅជួបនឹងឈ្មួញថៃ ។ មិត្ត ឈឿន ផ្តាំខ្ញុំថា ពេលជួបនឹងឈ្មួញ សូមប្រាប់ថា ខាងកម្ពុជាមានក្រុមហ៊ុនរកស៊ីត្រឹមត្រូវ រដ្ឋទទួលស្គាល់ និងធានាអះអាង ដូច្នេះខាងថៃ ត្រូវមានក្រុមហ៊ុនមករកស៊ីជាមួយខាងកម្ពុជាវិញដែរ មិនមែនមករកស៊ីរាត់រាយ ជាឯកជន ជារត់គយទេ ។ ខ្ញុំបន្ថែមថា តែការបង់លុយកាក់មិនធ្វើតាមធនាគារទេ ព្រោះកម្ពុជាគ្មានធនាគារ ។ ការបង់លុយកាក់ត្រូវទូទាត់គ្នាទៅតាមចំនួនរបស់របរទាំងសងខាង និងតាមតម្លៃទំនិញនីមួយៗ ។

ដល់ខែកញ្ញា ឆ្នាំ១៩៧៦ មិត្ត ឈឿន បានទៅដល់

ប៉ោយប៉ែតម្តងទៀត ហើយគាត់បានទៅជួបខ្ញុំ និង ស៊ូ (នៅនឹងផ្ទះស៊ូ) ។ មិត្ត ឈឿន បន្តថា ខាងពាណិជ្ជកម្ម មានផែនការបញ្ចេញទៅថៃ នូវមុខទំនិញដូចជា កៅស៊ូ និងធនធានធម្មជាតិផ្សេងៗទៀត ដែលជាផែនការបំផ្លិចបំផ្លាញសេដ្ឋកិច្ចកម្ពុជា ។ ខ្ញុំបានប្រាប់វិញថា កន្លងមក ខ្ញុំ, មិត្ត ស៊ូ ព្រមទាំងមិត្ត នៅ បានបញ្ចេញត្បូង ពេជ្រ និងត្រីសាច់ក្នុងមួយខែៗរាប់រយតោន ។ មិនត្រឹមតែប៉ុណ្ណោះ យើងបញ្ចេញមនុស្សច្រើនរយគ្រួសារថែមទៀតផង ។

រហូតដល់ខែមករា ឆ្នាំ១៩៧៧ ខ្ញុំ និងមិត្ត ស៊ូ បានអញ្ជើញគណៈទាក់ទងថៃថ្មីឈ្មោះ ស៊ឹម ប៊ុន ប្រធាន, អំ នួយ អនុប្រធាន និង ខុត្តម ជាសមាជិក មកជួបគ្នានៅប៉ោយប៉ែត ។ ពេលជួបនឹងគណៈទាក់ទងថៃ មិត្ត ស៊ូ និងខ្ញុំ បានអញ្ជើញខាងថៃឲ្យចូលមកលេងក្នុងកន្លែងទទួលភ្ញៀវរបស់យើង ។ យើងបានឲ្យគណៈប្រតិភូថៃ ហូបផ្លែឈើ ហូបស្រា និងទទួលបារីចុងក្រោយ ។ បន្ទាប់មកទៀត មិត្ត ស៊ូ និងខ្ញុំក៏រំឭកគណៈទាក់ទងថៃថ្មីថា កាលពីដើមឆ្នាំ១៩៧៦ លោកអនុរដ្ឋមន្ត្រី ដែន ធានាជួយជួសជុលផ្លូវរទេះភ្លើងយើងខ្ញុំនៅម្តុំប៉ោយប៉ែត ។ ឥឡូវនេះជាពេលវេលាដែលខាងថៃ ត្រូវមកជួយជួសជុលឲ្យ និងជួយកសាងហើយ ព្រោះខាងយើងត្រូវការជាចាំបាច់ ហើយឆាប់ៗផង បន្ទាប់មកយើងក៏បំបែកគ្នា ។

នៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៧ គណៈកម្មាធិការនៅពាយ័ព្យមានបង សាយ ជាប្រធាន បានបើកប្រជុំមួយនៅមន្ទីរភាគពាយ័ព្យមាន ៖ ១) បង សាយ គណៈភូមិភាគ, ២) មិត្ត វ៉ាញ លេខាតំបន់១, ៣) មិត្ត សាន គណៈកម្មាធិការយោធា, ៤) មិត្ត ស៊ុយ គណៈតំបន់៦, ៥) មិត្ត ហ៊ាង លេខាតំបន់៤, ៦) មិត្ត គូ គណៈតំបន់៣, ៧) មិត្ត ខាន គណៈតំបន់២, ៨) មិត្ត សុត លេខាតំបន់៧, ៩) មិត្ត ស៊ូ ប្រធានគណៈទាក់ទងកម្ពុជាថៃ, ១០) មិត្ត ម៉ៃ (ខ្ញុំ) គណៈទាក់ទង កម្ពុជាថៃ, ១១) នៅ គណៈកងពល, ១២) ខួយ គណៈកងពលដើម្បីលើកផែនការវាយថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៧ ម្តងទៀត ។

ក្រោយពីប្រជុំមក កម្លាំងទាំងអស់នៅពាយ័ព្យ ក៏ចាប់រៀបចំបំពេញភារកិច្ចរៀងៗខ្លួនតាមការណែនាំរបស់អង្គប្រជុំ ។ ពេលនោះ ខ្ញុំប្រាប់មិត្ត ធី ថា ពីរថ្ងៃមុនផ្ទុះ គាត់ត្រូវនាំកម្លាំងនោះមកជួបនឹងខ្ញុំនៅម្តុំភូមិខែដន ជិតនិមិត្ត ។

លុះដល់ថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៧ ជាថ្ងៃកំណត់ផែនការធ្វើរដ្ឋប្រហារ បែរជាអាក់ខានទៅវិញ ដោយសារដំណឹងត្រូវបែកសុះសាយ ហើយអង្គការមានវិធានការដើម្បីទប់ទល់វិញ ។ អង្គការបានដក មិត្ត សាន និងមិត្ត សុត លេខាតំបន់៧ ឲ្យមកមន្ទីរភូមិភាគ ចំណែក មិត្ត ស៊ូ ក៏ត្រូវផ្លាស់ទៅក្រសួងការបរទេសនៅភ្នំពេញដែរ ។

លុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧ ក្រសួងការបរទេស ក៏បានទូរលេខប្រាប់ខ្ញុំឲ្យត្រឡប់មកក្រសួងនៅភ្នំពេញ ព្រោះអង្គការផ្អាកការទាក់ទងជាមួយថៃហើយ ។ ខ្ញុំមកនៅក្នុងក្រសួងការបរទេសបានរយៈពេលជាងម្ភៃថ្ងៃ គឺរហូតមកដល់ថ្ងៃ២១ ខែមិថុនា ឆ្នាំ១៩៧៧ ខ្ញុំ និងមិត្ត ស៊ូ ត្រូវអង្គការចាប់ខ្លួនមកដាក់ក្នុងក្រសួងសន្តិសុខតែម្តង ។ **សោម ប៊ុនថន**

# ដំណឹងសួររកបងប្អូន

នាងខ្ញុំឈ្មោះ តាំង សុគន្ធា អាយុ៤៦ឆ្នាំ សព្វថ្ងៃរស់នៅភូមិថ្មល់បត់ ឃុំឫស្សីក្រាំង ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។ នាងខ្ញុំសូមសួររកប្អូនៗ ខាងម្តាយរបស់ខ្ញុំចំនួនបីនាក់ដែលមានស្រុកកំណើតនៅស្រុកអូររាំងឪ ខេត្តកំពង់ចាម ដែលបាត់ខ្លួនក្នុងរបបខ្មែរក្រហមមានដូចជា ៖

១) ទូច កាន ភេទស្រី ត្រូវជាម្តាយមីង មកដល់សព្វថ្ងៃអាយុជាង៥០ឆ្នាំ ។

២) ទូច ហេង ភេទប្រុស ត្រូវជាពូ ។

៣) ទូច ហ៊ាង ភេទប្រុស ត្រូវជាពូ ។

ប្រសិនជាបងប្អូនណាបានស្គាល់ឈ្មោះដូចខាងលើ សូមមេត្តាទាក់ទងមកនាងខ្ញុំតាមរយៈអាសយដ្ឋានដូចខាងលើ ឬតាមរយៈទូរស័ព្ទលេខ ៖ ០៩៧ ៥១៤ ៦៩ ៣៧ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា អាសយដ្ឋានផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ!

# ព័ត៌មានទាក់ទិន ឃួន ដារិត បុគ្គលិកបេសកម្មរដ្ឋាភិបាលរួបរួមជាតិកម្ពុជានៅទីក្រុងប៉ារីស

ក្នុងនាមជាសាក្សីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅខែមេសា ឆ្នាំ២០១២ សាឡុត បាន អតីតអគ្គលេខាធិការក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥-៧៩ និងជាក្មួយប្រុសបង្កើតរបស់ ប៉ុល ពត បាន ឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះទាក់ទងនឹងការចាប់ខ្លួនបុគ្គលិកការទូត និស្សិត បញ្ញាជនខ្មែរមកពីក្រៅប្រទេសថា នៅក្នុងតួនាទីរបស់ខ្លួន គាត់មិនបានដឹងឮពីការបាត់ខ្លួន និងការចាប់ខ្លួនអ្នកទាំងអស់នោះទេគឺគាត់មានតួនាទីត្រឹមតែថែរក្សារបស់របរ និងវ៉ាលីសរបស់អ្នកទាំងនោះប៉ុណ្ណោះ ។

បាន បានបញ្ជាក់ថា មានតែប៉ង់ (ឈឹម សំអ៊ក) ដែលជាអ្នកទទួលខុសត្រូវខាងផ្នែកសន្តិសុខរបស់មន្ទីរ៨៧០ (មន្ទីរមជ្ឈិម) ប៉ុណ្ណោះ ដែលទទួលខុសត្រូវលើការចាប់ខ្លួន និងនាំយកបុគ្គលិកទាំងអស់នោះចេញពីក្រសួងទៅដាក់នៅមន្ទីរអប់រំកែប្រែបឹងត្របែក ។ បាន បន្តថា នៅក្នុងអំឡុងពេលធ្វើការនៅក្រសួងការបរទេសគាត់បានឮឈ្មោះ ឃួន ដារិត តាមរយៈអ្នកដែលមកពីបរទេសនិងតាមរយៈអ្នកធ្លាប់ស្គាល់ថា ឃួន ដារិត ជាអ្នកដែលចេះដឹងនិងរៀនពូកែក្នុងអំឡុងពេលសិក្សានៅបរទេស ។


I08501

ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង

ឈ្មោះដើម ឃួន ដារិត

ដូច្នេះក្នុងឱកាសដែលឪពុកមា (ប៉ុល ពត) របស់គាត់ប្រាប់គាត់ឲ្យជ្រើសរើសមនុស្សពូកែក្នុងចំណោមអ្នកដែលមកពីបរទេសដើម្បីយកមកធ្វើការ គាត់ក៏បានលើកឡើងអំពីឈ្មោះ ឃួនដារិត ។ បន្ទាប់មក ប៉ុល ពត ក៏បានប្រាប់គាត់ឲ្យទៅតាមរកឈ្មោះ ឃួន ដារិត នេះ ហើយគាត់ក៏បានទៅប្រាប់ ប៉ង់ បន្តដើម្បីឲ្យជួយតាមរកឈ្មោះនេះ ។ ប៉ុន្តែក្រោយមក គាត់មិនដែលបានទទួលដំណឹងពីឈ្មោះ ដារិត ទេ ។

បាន បន្ថែមទៀតថា គាត់មិនបានដឹងថាមានរឿងរ៉ាវអ្វីកើតឡើងចំពោះ ឃួន ដារិត ទេ ។ ប៉ុន្តែនៅក្នុងប្រវត្តិរូបអ្នកទោសដែលជាប់ឃុំឃាំងបានបញ្ជាក់យ៉ាងច្បាស់ថា ឃួនដារិត មានអាយុ៣០ឆ្នាំ កើតនៅភូមិវត្តពោធិ៍វាល ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង មានតួនាទីជាបុគ្គលិកបេសកម្មរដ្ឋាភិបាលរួបរួមជាតិកម្ពុជានៅប៉ារីស ប្រទេសបារាំង ត្រូវបានឃាត់ខ្លួននៅបឹងត្របែកខាងត្បូង នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៦ ។

**សោម ប៊ុនថន**

# សីលធម៌ ១២ប្រការរបស់ជនបដិវត្តន៍

**ចម្លងចេញពីឯកសារដើមផាំងស្រុង D២១៤០៨**

សីលធម៌១២ ប្រការរបស់ជនបដិវត្តន៍ជាក្រិត្យវិន័យរបស់បក្សដែលជនគ្រប់រូបត្រូវតែគោរព អនុវត្តន៍តាមគ្រប់ខដោយជ្រួតជ្រាប និងភ្ជាក់រឭក ដើម្បីកសាងខ្លួន ឲ្យទៅជាជនបដិវត្តន៍ល្អ បរិសុទ្ធ ដូរផង់ អាចវាយសម្រុកសម្រេចភារកិច្ចបដិវត្តន៍តូចធំជាផលប្រយោជន៍ដល់ប្រទេសជាតិ ប្រជាជន បក្ស និងវណ្ណៈក្រីក្រយើង ។ សីលធម៌១២ប្រការរបស់ជនបដិវត្តន៍នេះ បានកកើតឡើងនៅក្នុងឆ្នាំ១៩៦៨ ។

ឆ្នាំ១៩៦៨ ជាដូវបត់ធំមួយក្នុងបដិវត្តន៍កម្ពុជាយើង ។ គឺជាឆ្នាំដែលប្រជាជន កម្មករ កសិករក្រីក្រ ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជាចាប់ផ្តើមផ្ទុះអាវុធវាយកម្ទេចខ្មាំងសត្រូវជាខ្មាំងប្រជាជាតិ និងខ្មាំងវណ្ណៈដោយរួមផ្សំនឹងការតស៊ូនយោបាយផង ។

ឆ្នាំ១៩៦៨ ក៏ជាឆ្នាំលំបាកស្មុគស្មាញបំផុត តែក៏ជាឆ្នាំដែលបើកទំព័រប្រវត្តិសាស្ត្រថ្មីនៃចលនាតស៊ូបដិវត្តន៍របស់ប្រជាជនកម្ពុជាក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជាយើង ។ ជាឆ្នាំភ្លឺស្វាង ដែលប្រជាជននិងកងទ័ពបដិវត្តន៍កម្ពុជាយើងផ្អែកលើហឹង្សាអាវុធ វាយកម្ទេចរដ្ឋអំណាច ជិះជាន់យោរយៅហ្វាស៊ីសរបស់ពួកក្បត់ជាតិនិងវណ្ណៈសក្តិភូមិ នាយទុនឲ្យរង្គោះរង្គើរលំរលាយជាបន្តបន្ទាប់ រហូតដល់រលំរលាយទាំងស្រុងអស់ពីលើទឹកដីកម្ពុជាយើងនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ។

ក្នុងឆ្នាំ១៩៧៨នេះ ខ្មាំងក៏បានបង្កើនការបង្ក្រាបរាតត្បាត ចាប់ចង កាប់សម្លាប់ជនបដិវត្តន៍ ជនស្នេហាជាតិ និងចម្រើន ហើយជាពិសេស គឺប្រជាជនក្រីក្រយើងនៅតាមជនបទចុងកាត់មាត់ញក យ៉ាងព្រៃផ្សៃហ្វាស៊ីសបំផុត ។ ខ្មាំងអនុវត្តយ៉ាងពេញទំហឹង និងដោយឥតញញើតដៃឡើយ នូវនយោបាយទុរគតភាវូបនីយកម្ម នយោបាយពលាភាវូបនីយកម្ម និងនយោបាយហ្វាស៊ីសភាវូបនីយកម្មនៅគ្រប់ទិសទីតាំងពីទីក្រុងរហូតដល់ជនបទចុងកាត់មាត់ញក ហើយពិសេសគឺនៅតាមជនបទមាត់ញក ។

ដើម្បីទប់ទល់នឹងវាយកម្ទាត់នូវនយោបាយហ្វាស៊ីសទាំងបីខាងលើនេះរបស់ខ្មាំង ការពារ និងកសាងពង្រឹងពង្រីកកម្លាំងបដិវត្តន៍ឲ្យរីកចម្រើនខ្លាំងក្លា យ៉ាងឆាប់រហ័សនិងដើម្បីសម្រេចភារកិច្ចបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យ ឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត បក្សកុម្មុយនីស្តកម្ពុជាយើង ដោយឈរលើមាគ៌ាជាយុទ្ធសាស្ត្រ និងមាគ៌ាជាយុទ្ធវិធីរបស់បក្ស និងដោយឈរលើសភាពការណ៍ជាក់ស្តែងនៃចលនាបដិវត្តន៍របស់យើងក្នុងរយៈកាលនោះ បានរៀបចំចងក្រងឡើងនូវឯកសារសីលធម៌១២ប្រការរបស់ជនបដិវត្តន៍នេះ ។

ដូច្នេះ ឯកសារ១២ប្រការរបស់ជនបដិវត្តន៍នេះ មិនមែនជាគម្ពីរ ឬជាទ្រឹស្តី ដែលគាត់តែងឡើងដោយបុគ្គលណាម្នាក់ ឬក្រុមជនណាមួយក្រុមឡើយ ។ តែគឺចេញមកពីសាច់ស្រស់ ឈាមស្រស់របស់បុព្វបុរសបដិវត្តន៍យើង និងប្រជាជនយើងក្នុងគ្រប់កាលសម័យតស៊ូបដិវត្តន៍ ។ គឺពិតជាចេញមកពីចលនាបដវត្តន៍ជាក់ស្តែងរបស់ប្រជាជនកម្មករ កសិករយើងក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជាជាបន្តបន្ទាប់មក ។ ដូច្នេះ ឯកសារសីលធម៌១២ប្រការនេះ គឺពិតជាក្រិត្យវិន័យជាទស្សនៈ គោលជំហរ និងជាសីលធម៌របស់បក្សកុម្មុយនីស្តកម្ពុជាយើង របស់ជនកុម្មុយនីស្ត និងរបស់ប្រជាជនបដិវត្តន៍កម្ពុជាយើង ។

ដូច្នេះហើយ បានជាឯកសារនេះ ត្រូវបានផ្សព្វផ្សាយនៅក្នុងចំណោមយុទ្ធជន យុទ្ធនារី និងកម្មាភិបាលបដិវត្តន៍យើងនៅទូទាំងប្រទេស និងនៅក្នុងចំណោមប្រជាជន មហាជនបដិវត្តន៍នៅគ្រប់ទិសទីតាំងពីឆ្នាំ១៩៦៨មកម្ល៉េះ ។ ប្រជាជន មហាជនបដិវត្តន៍នៅទូទាំងប្រទេស អបអរសាទរ រីករាយ ពេញចិត្តពេញថ្លើមទទួលយកសីលធម៌បដិវត្តន៍១២ប្រការនេះ ទៅរៀនសូត្របំពាក់

បំប៉នឲ្យខ្លួនជាប់ជានិច្ចប្រែក្លាយទៅជាទស្សនៈគោលជំហរ និងសីលធម៌បដិវត្តន៍ប្រចាំជីវិតរបស់ខ្លួន ក្នុងការអនុវត្តភារកិច្ចប្រចាំថ្ងៃជាបន្តបន្ទាប់មក ។ ដោយយុទ្ធជន យុទ្ធនារី និងកម្មាភិបាលបដិវត្តន៍គ្រប់ជាន់ថ្នាក់ជ្រួតជ្រាប និងអនុវត្តន៍នូវសីលធម៌១២ប្រការនេះរបស់បក្សបានល្អត្រឹមត្រូវជានិច្ច បានជាប្រជាជនស្រឡាញ់ ពេញចិត្តពេញថ្លើម យុទ្ធជន យុទ្ធនារី និងកម្មាភិបាលបដិវត្តន៍ ហើយចាត់ទុកជនបដិវត្តន៍ជាសាច់ជាឈាមរបស់គេផ្ទាល់ ។ ដូច្នេះហើយបានជាបដិវត្តន៍យើងអាចចលនាប្រមូលកៀងគរកម្លាំងប្រជាជនគ្រប់ស្រទាប់វណ្ណៈបានច្រើនកុះករ ហើយប្រយុទ្ធវាយកម្ទេចខ្មាំងសត្រូវគ្រប់ប្រភេទក៏បានខ្លាំងក្លាជាប់ជានិច្ច ទោះបីពេលនោះ យើងឋិតក្នុងសភាពក្រខ្សត់ អត់ឃ្លានខ្វះសព្វខ្វះគ្រប់យ៉ាងណាក្តី ហើយទោះបីខ្មាំងសត្រូវ វាឃោរឃៅកាចសាហាវ និងហ្វាស៊ីសកម្រិតខ្ពស់យ៉ាងណាក្តី ។

ក្នុងរយៈកាលថ្មីនៃបដិវត្តន៍កម្ពុជាយើងបច្ចុប្បន្ននេះ សីលធម៌១២ប្រការរបស់ជនបដិវត្តន៍នៅតែមានសារៈសំខាន់ និងមានអត្ថន័យជ្រាលជ្រៅចំពោះយើងជាជនបដិវត្តន៍ដដែល ។ បើយើងដណ្តើមបានជ័យជម្នះហើយ យើងត្រឡប់ទៅជាបោះបង់ ឬបំភ្លេចចោលនូវគោលជំហរសីលធម៌១២ប្រការនេះ នោះចលនាបដិវត្តន៍សង្គមនិយមរបស់យើងនិងជួបប្រទះនូវការលំបាករហូតដល់អាចទទួលបរាជ័យវិញក៏មានដែរ ។

◆ ព្រោះយើងប្រើប្រាស់ចាកសីលធម៌បដិវត្តន៍១២ប្រការ យុទ្ធជន យុទ្ធនារី និងកម្មាភិបាល យើងគ្រប់ជាន់ថ្នាក់អាចប្រែធាតុបដិវត្តន៍បន្តិចម្តងៗ ឬក៏ប្រែប្រួលលឿនឆាប់រហ័សជាងនេះទៀតទៅជាសេរីនិយម នាម៉ឺននិយម អាជ្ញានិយម ។ ហើយទោះចង់ឬមិនចង់ វានឹងប្រែធាតុពីបដិវត្តន៍ វណ្ណៈអធនទៅជាអនុធនភាវូបនីយកម្ម នាយទុនភាវូបនីយកម្មពុំខានឡើយ ។

◆ បើយុទ្ធជន យុទ្ធនារី និងកម្មាភិបាលបដិវត្តន៍គ្រប់ថ្នាក់ប្រែធាតុបដិវត្តន៍ទៅជាយ៉ាងនេះហើយ នោះបដិវត្តន៍សង្គមនិយមរបស់យើងពុំមែនឋិតនៅជាបដិវត្តន៍សង្គមនិយមរបស់វណ្ណៈអធន ដែលបម្រើផលប្រយោជន៍ប្រទេសជាតិ និងប្រជាជនកម្ពុជាជាទូទៅឡើយ ។ តែវាជាបដិវត្តន៍សង្គមនិយមតែសម្បកតែផ្ទាក ឯខ្លឹមសារគឺបដិវត្តន៍នាយទុន ជាបដិវត្តន៍សេរី ដែលបម្រើតែផលប្រយោជន៍របស់វណ្ណៈកាន់អំណាចមួយក្តាប់តូចប៉ុណ្ណោះ ដូច្នេះពលីកម្មច្រើនឥតគណនារបស់បុព្វបុរសបដិវត្តន៍យើង របស់យុទ្ធមិត្តយើង និងប្រជាជនកម្មករ កសិករក្រីក្រយើងរាប់ជំនាន់មកហើយ នោះនឹងទៅជាអាសាឥតការ ។

◆ បើបដិវត្តន៍សង្គមនិយមយើង ប្រែធាតុពិតយ៉ាងនេះទៅជាខ្ញុំកញ្ជះគេវិញ អាប់ឱនទាបថោករកទីបំផុតគ្មាន ។ ប្រជាជនយើងពិតជានឹងធ្លាក់ខ្លួនទៅជាខ្ញុំគេហើយ រងទុក្ខវេទនា ឈឺចាប់ខ្លោចផ្សាពុំដឹងពេលណារើខ្លួនរួចវិញឡើយ ។ ហើយខ្ញុំគេលើកនេះគឺខ្ញុំយួនឈ្លានពាន វាតទីលេបទឹកដី បំបាត់ពូជសាសន៍នេះឯង ។ ដូច្នេះ មហារថោកទាប មហាហោមរហាមយ៉ាងពិតប្រាកដ ។ នេះជាគ្រោះថ្នាក់ធំណាស់ចំពោះរូបយើងម្នាក់ៗដែលជាជនបដិវត្តន៍ ក៏ដូចជាចំពោះប្រទេសជាតិ ប្រជាជន និងចលនាបដិវត្តន៍យើងដែរ ។

ឃើញយ៉ាងនេះ យើងជាយុវជន យុវនារីបដិវត្តន៍គ្រប់រូប ក៏ដូចជាប្រជាជនកម្ពុជាទូទៅដែរ ចាំបាច់យកចិត្តទុកដាក់ បំពាក់បំប៉នបន្ថែម បន្ថែមហើយបន្ថែមទៀតជាប់ជានិច្ច អំពីសីលធម៌១២ប្រការរបស់ជនបដិវត្តន៍នេះជារៀងរហូតទៅ ។ យកសីលធម៌១២ប្រការរបស់ជនបដិវត្តន៍នេះមកជាក្រិត្យវិន័យសម្រាប់អនុវត្តន៍ជាប់ជាប្រចាំក្នុងជីវិតរបស់ខ្លួន មកជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងមើលនូវការខុស និងការត្រូវរបស់ខ្លួនក្នុងការប្រព្រឹត្តដាក់ស្តែងប្រចាំថ្ងៃ ដើម្បីកែលម្អ និងកសាងខ្លួនយើងម្នាក់ៗក៏ដូចក្នុងការជួយកសាងសមមិត្តដទៃឲ្យបានរីកចម្រើនទៅជាជនបដិវត្តន៍ល្អបរិសុទ្ធរឹងប៉ឹងខ្លាំងក្លាជាបន្តបន្ទាប់ និងជារៀងរហូត ។

តទៅនេះ ជាសីលធម៌១២ប្រការរបស់ជនបដិវត្តន៍ៈ

### ១) ស្រឡាញ់ គោរព ហើយបម្រើប្រជាជន កម្មករ កសិករជាប់ជានិច្ច

បើស្រឡាញ់ គោរពប្រជាជនហើយ យុវជន យុវនារីបដិវត្តន៍យើងគ្មានហេតុផលអ្វីទៅធ្វើឲ្យប៉ះពាល់ប្រជាជនទេ ទោះបីជាពាក្យសម្តីក្តី ប៉ះពាល់ជាផលប្រយោជន៍របស់ប្រជាជនក្តី ។ ហើយបើស្រឡាញ់ គោរព ប្រជាជនហើយ មុខជានឹងបម្រើប្រជាជនដោយការប្រព្រឹត្តដាក់ស្តែងឲ្យចេញទៅជាសាច់ការជាបន្តបន្ទាប់ ។ បម្រើប្រជាជននេះគឺបំពេញភារកិច្ចបដិវត្តន៍របស់ខ្លួនឲ្យបានល្អ ដោយខ្នះខ្នែង ដោះស្រាយគ្រប់បញ្ហាជួយប្រជាជន

ឲ្យបានល្អ ហើយយកចិត្តទុកដាក់អប់រំ កសាងប្រជាជន ក៏ឲ្យបានល្អ ធ្វើយ៉ាងណាឲ្យកម្លាំងប្រជាជនទាំងអស់ទៅជាកម្លាំងបដិវត្តន៍រឹងប៉ឹង ។ បើស្រឡាញ់ គោរព ហើយមប្រើប្រជាជនយ៉ាងនេះហើយ ឃើញប្រជាជន មហាជនខុសឆ្គងអ្វីខ្លះៗ យើងមិនរឹងសម្បារ មិនប្រើអាជ្ញា ឬមិនប្រើវិធានការចាត់តាំងទៅលើប្រជាជនមហាជនទេ តែផ្ទុយទៅវិញ យើងឈឺឆ្អាលខិតខំអប់រំ ណែនាំ និងពន្យល់ប្រជាជន មហាជន ឲ្យគេកាន់តែភ្ញាក់រឭក ហើយបន្ថយការខុសឆ្គងរបស់គេជាអតិបរមា រហូតដល់ប្រជាជនភ្ញាក់រឭកបដិវត្តន៍ខ្ពស់ លែងធ្វើអ្វីខុសឆ្គងទៀត ។

នៅតាមមន្ទីរក្រសួង យុវជន យុវនារី និងកម្មាភិបាលបដិវត្តន៍យើងមិនបាននៅជាប់និងប្រជាជនក៏ពិតមែន តែក៏ត្រូវមានទស្សនៈគោលជំហរគោរពស្រឡាញ់ប្រជាជនដោយអស់ពីចិត្តពីថ្លើមដែរ ហើយខិតខំបម្រើប្រជាជនតាមរយៈនៃការបំពេញភារកិច្ចស្នូលរបស់ខ្លួនឲ្យបានល្អ ដោយឈ្មុសឈ្មុល ច្នៃប្រឌិត គំនិតផ្តើមរស់រវើក និងសន្សំសំចៃខ្ពស់ជាប់ជានិច្ច ។

**២) នៅកន្លែងណា បម្រើប្រជាជននៅកន្លែងនោះឲ្យអស់ពីចិត្តពីថ្លើម**

យើងជាជនបដិវត្តន៍ ដូច្នេះ ជាអ្នកបម្រើប្រជាជនក្នុងគ្រប់កាលៈទេសៈ ។ នៅកន្លែងណា ក៏ត្រូវបម្រើប្រជាជននៅកន្លែងនោះឲ្យបានល្អ ដោយខិតខំបំពេញភារកិច្ចបដិវត្តន៍របស់ខ្លួនឲ្យបានល្អឲ្យអស់ពីចិត្តពីថ្លើម ។ ព្រោះនៅកន្លែងណាក៏ដោយ ការងារអ្វីក៏ដោយ សុទ្ធតែបម្រើប្រជាជនទាំងអស់ ។ គ្មានការងារណាថោកទាប គ្មានភារកិច្ចកន្លែងណាវាកិត្តិយសជាងកន្លែងណាទេ ។ ចំពោះយើង ជាជនបដិវត្តន៍ បញ្ហាចោទតែត្រង់ថា បំពេញភារកិច្ចបម្រើប្រជាជនបានល្អឬមិនល្អតែប៉ុណ្ណោះ ។ ដូច្នេះ សូម្បីតែយើងទៅកន្លែងណាមួយម្តងៗ ទោះជារយៈពេលខ្លីក៏ដោយ ក៏ត្រូវតែឆ្លៀតឱកាសរួមធ្វើការងារជាមួយប្រជាជនកន្លែងនោះ ដើម្បីជាផលប្រយោជន៍ដល់ប្រជាជនគ្រប់ពេលវេលា រួមជំរុញការងារនៅកន្លែងនោះឲ្យបានខ្លាំងក្លា ។

**៣) មិនធ្វើអ្វីដែលប៉ះពាល់ដល់ប្រជាជនឲ្យសោះទោះជាម្ទេសមួយផ្លែ ឬសម្តីមួយម៉ាត់ក្តី**

នៅក្នុងប្រជាជនយើង ច្រើនចាត់ទុកម្ទេសមួយផ្លែ ពីរផ្លែ ជារបស់តូចតាចបំផុត ។ ប្រជាជនយើងនិយមដាំតាមភូមិ តាមចម្ការ តាមក្បែររបង ក្បែរផ្លូវសម្រាប់ចែកញាតិសន្តានក្នុងភូមិហូប ។ ដូច្នេះ អ្នកណាក៏អាចមកបេះហូបបានដែរ ។ ប៉ុន្តែ ចំពោះយើងជាជនបដិវត្តន៍ សូម្បីតែម្ទេសមួយផ្លែ ដែលប្រជាជនយើងមិនចាប់អារម្មណ៍ផងក៏ដោយ ក៏យើងមិនត្រូវប៉ះពាល់ បេះបោចរបស់ប្រជាជន ជាដាច់ខាត ដោយគ្មានសុំអនុញ្ញាតអំពីម្ចាស់អ្នកដាំជាមុនឡើយ ។ ដូច្នេះ ជាន័យអនុវត្តជាក់ស្តែង បើម្ទេសមួយផ្លែនេះទៅទៀត គឺតាំងពីពាក្យសម្តី មនោសញ្ចេតនា រហូតដល់ផលប្រយោជន៍ធំៗរបស់ប្រជាជនទៀត នោះយើងជាជនបដិវត្តន៍ រឹតតែមិនត្រូវធ្វើ និងមិនប្រព្រឹត្តធ្វើឲ្យប៉ះពាល់ទៅលើប្រជាជនណាស់ទៅទៀត ។ ជាន័យអនុវត្តជាក់ស្តែង ម្យ៉ាងទៀតគឺថា យុវជន យុវនារីបដិវត្តន៍យើងត្រូវប្រុងប្រយ័ត្ន តាំងពីពាក្យសម្តី អាកប្បកិរិយា របៀបរបបធ្វើការងាររហូតដល់ទស្សនៈ គោលជំហរ ធ្វើយ៉ាងណាកុំឲ្យទើសភ្នែក ទើសចិត្តប្រជាជន រហូតកុំឲ្យមានអីប៉ះដល់មនោសញ្ចេតនារបស់ប្រជាជន ។

**៤) បើមានការខុសឆ្គងអីពីប្រជាជន ត្រូវសុំទោសប្រជាជន បើមានធ្វើអ្វីឲ្យខូចខាតដល់ប្រជាជនត្រូវសងប្រជាជនវិញ**

ឥឡូវនេះ មិនមែនចោទបញ្ហាសងទេ ។ សំណូមពរសំខាន់របស់បក្សគឺកុំឲ្យធ្វើអីខុសទៅលើប្រជាជន ។ ហើយបើឃើញថាមានខុសអី ទោះតិចតួចក្តី ជាសរសៃញាក់គឺត្រូវកែប្រែភ្លាម ។ បើនៅជាមួយប្រជាជនត្រូវធ្វើទិតៀនចំពោះប្រជាជន ។ បើមិននៅជាមួយទេ ក៏ត្រូវរកវិធីទាក់ទងជាមួយប្រជាជនដើម្បីរកវិធីដោះស្រាយ ធ្វើយ៉ាងណាឲ្យប្រជាជនជ្រះស្រឡះខាងសតិអារម្មណ៍ ។ ជារួម ប្រជាជនយើងអត់ទាមទារអ្វីពីយើងទេ ទាមទារតែកាយវិការ និងសីលធម៌បដិវត្តន៍ត្រឹមត្រូវរបស់យើងប៉ុណ្ណោះ ។ ទោះបីមានការលើសលោះ ធំក្តី តូចក្តី ឲ្យតែយើងបង្ហាញនូវសីលធម៌បដិវត្តន៍ត្រឹមត្រូវ ប្រជាជនអត់មានអីប្រកែប្រកាន់នឹងយើងទៀតទេ ។

**៥) និយាយស្តី ដេកដើរ ឈរអង្គុយ ស៊ីចុក ស្លៀកពាក់ លេងសើច តាមសភាពប្រជាជន**

កាលពីឆ្នាំ១៩៦៨ ដែលបក្សធ្វើឯកសារនេះគឺយើងត្រូវការប្រជាជនណាស់ ព្រោះប្រជាជនទូទៅឋិតក្នុងកណ្តាប់ដៃ

ខ្លាំងនៅឡើយ ។ ឯយើងពេលនោះ អត់ទាន់មានប្រជាជនទេ ។ យើងត្រូវការប្រាស្រ័យទាក់ទងជាមួយប្រជាជនណាស់ ។ ដូច្នេះ ក្នុងការរស់នៅប្រចាំថ្ងៃក៏ដូចជាក្នុងការធ្វើការងារ យុទ្ធជន យុទ្ធនារី និងកម្មាភិបាលបដិវត្តន៍យើងគ្រប់ថ្នាក់ តែងសម្របខ្លួនតាមសភាពប្រជាជន ។ ទាំងក្នុងការនិយាយស្តី ទាំងក្នុងការឈរអង្គុយ ស៊ីចុកស្លៀកពាក់ រហូតដល់លេងសើចទៀត យើងប្រយ័ត្នប្រយែងណាស់ មិនធ្វើអ្វីឲ្យខុសពីសភាពប្រជាជន ពោលគឺមិនធ្វើអ្វីឲ្យទាស់ភ្នែក ឬប៉ះអារម្មណ៍ប្រជាជនឡើយ ។ ម្យ៉ាងដើម្បីបង្កប់ខ្លួននៅក្នុងប្រជាជន លាក់បំពួនខ្លួនពីភ្នែកខ្មាំងសត្រូវ ។ តែម្យ៉ាងទៀត ក៏ដើម្បីឲ្យប្រជាជនស្រឡាញ់ពេញចិត្ត ពេញថ្លើម ជឿទុកចិត្តលើបុគ្គលយើង ។ ហើយតាមរយៈនេះ ក៏ប្រជាជនស្រឡាញ់ ជឿជាក់ ហើយខបត្ថម្ភគាំទ្រចលនាបដិវត្តន៍ និងចូលរួមប្រាស្រ័យ ធ្វើបដិវត្តន៍ដោយមោះមុតដាច់ខាត ។

ចុះឥឡូវ យើងកាន់កាប់រដ្ឋអំណាចទូទាំងប្រទេសហើយ ប្រជាជននៅជាមួយយើងទាំងអស់ ហើយតើយើងត្រូវកែប្រែទស្សនៈ គោលជំហរ អាកប្បកិរិយារបស់យើងខាងលើនេះទេ?

◆ ប្រជាជននៅជាមួយបដិវត្តន៍ក៏ព្រោះតែស្រឡាញ់ ហើយជឿទុកចិត្ត និងកក់ក្តៅលើបដិវត្តន៍ យល់ឃើញថា បដិវត្តន៍ត្រឹមត្រូវ បដិវត្តន៍បម្រើ និងការពារផលប្រយោជន៍គេ ។ តែបើពេលណាយុទ្ធជន យុទ្ធនារី និងកម្មាភិបាលបដិវត្តន៍យើងគ្រប់ថ្នាក់ កែប្រែនូវអាកប្បកិរិយា ឬទស្សនៈគោលជំហរ ដែលជាសីលធម៌បដិវត្តន៍របស់យើងខាងលើនេះ ហើយនោះប្រជាជនមុខជាមិនពេញចិត្តនឹងយើងទេ ហើយរហូតដល់ខឹងសម្បារ ហើយស្អប់យើង មិនចង់ឲ្យចូលភូមិទៀតផង ។ ដូច្នេះ យើងដាច់ពីប្រជាជនតាមរយៈបដិវត្តន៍នេះ និងដាច់ពីប្រជាជនគ្មានកម្លាំងប្រជាជនខបត្ថម្ភគាំទ្រ ។ ដូច្នេះ ធ្វើអ្វីក៏មិនខ្លាំងដែរ ការពារប្រទេសក៏មិនខ្លាំង កសាងប្រទេសក៏មិនលឿន ។ ការនេះបញ្ជាក់ឲ្យយើងឃើញច្បាស់ថា នៅក្នុងរយៈកាលថ្មីនៃបដិវត្តន៍កម្ពុជាបច្ចុប្បន្ននេះ យើងរឹតតែត្រូវការកម្លាំង ប្រជាជនណាស់ទៅទៀត ដើម្បីការពារប្រទេសឲ្យបានខ្លាំងក្លា និងកសាងប្រទេសឲ្យបានខ្លាំងក្លា និងលោតផ្លោះ ។

### ៦) កុំប្រព្រឹត្តអ្វីដែលល្មើសនឹងស្ត្រីភេទឲ្យសោះ

និយាយរួម គឺកុំប៉ះពាល់សីលធម៌នារី បុរសឲ្យសោះ ។ ព្រោះបញ្ហានេះវានាំឲ្យប៉ះពាល់កិត្តិយសយើង ឥទ្ធិពលយើងជាជនបដិវត្តន៍ នាំឲ្យប៉ះពាល់ដល់ប្រពៃណីស្អាតស្អំ ថ្លៃថ្នូររបស់ប្រជាជនយើង ។ ដូច្នេះ ប៉ះពាល់ដល់ប្រជាជនយើង ។ នេះម្យ៉ាង ។ តែសំខាន់ម្យ៉ាងទៀត គឺបើយើងប៉ះពាល់សីលធម៌ នារីបុរស ដែលជាធាតុពិតពុករលួយស្អុយគគ្រុករបស់ខ្មាំងសត្រូវគ្រប់ប្រភេទនោះ និងនាំឲ្យខ្មាំងអូសទាញយើងបាន ។ ដូច្នេះ គ្រោះថ្នាក់ដល់ខ្លួន គ្រោះថ្នាក់ដល់ចលនាបដិវត្តន៍ ។

ចំពោះបញ្ហារៀបចំគ្រួសារបច្ចុប្បន្ននេះ គ្មានអ្វីជាឧបសគ្គទេ ឲ្យតែឈរលើគោលការណ៍របស់បក្សទាំងពីរយ៉ាងគឺៈ

ទី១) សាម៉ីខ្លួនទាំងសងខាងយល់ព្រម

ទី២) សមូហភាពយល់ព្រម ក៏ជាការស្រេចទៅហើយ ។ តើមានហេតុផលអី នាំឲ្យយើងប៉ះពាល់សីលធម៌នារីបុរស ។

### ៧) កុំផឹកស៊ីអ្វីដែលមានលក្ខណៈមិនបដិវត្តន៍ឲ្យសោះ

កាលពីសម័យមុនរំដោះ បញ្ហានេះវាមានពាសពេញសង្គមជាតិយើង ។ ដូច្នេះ ជនបដិវត្តន៍គ្រប់រូបត្រូវបង្ការលើបញ្ហានេះ ។ តែឥឡូវនេះអត់មានបញ្ហានេះទេ តែក៏ត្រូវអប់រំ កុំឲ្យផឹកស៊ីអ្វីដែលខុសពីជីវភាពរស់នៅរបស់ប្រជាជន ។ ពោលគឺយើងត្រូវរស់នៅឲ្យសមរម្យតាមមាគ៌ា តាមលក្ខណៈ និងតាមរបបបក្សកំណត់ ។ ហើយបើឃើញជនណា ទោះជាកម្មាភិបាលថ្នាក់ណាក្តី ឬយុទ្ធជន យុទ្ធនារីក្តី ឬក្នុងប្រជាជនក្តី មានសភាពស៊ីផឹកនេះ យើងត្រូវចាប់អារម្មណ៍ អប់រំកសាង ឬពិនិត្យតាមដានក្រែងលោមានសភាពខ្លាំងបង្កប់ វាបំផុសបញ្ហានេះឡើង ។

### ៨) កុំលេងល្បែងស៊ីសងឲ្យសោះ

ឥឡូវនេះគ្មានល្បែងស៊ីសងអីទៀតទេ ។ តែទោះជាយ៉ាងនេះក៏ដោយ ក៏ត្រូវអប់រំជាប់ ដើម្បីផ្តាច់ឫសគល់វាឲ្យអស់ពីសង្គមជាតិយើង ។

### ៩) កុំប៉ះពាល់លុយកាក់រួម ទ្រព្យសម្បត្តិរួម ទោះជាប្រាក់១រៀលក្តី អង្ករ១កំប៉ុង ឬថ្នាំមួយគ្រាប់ក្តី

ឥឡូវ យើងកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ជាសមូហភាពហើយ ។ តែក៏ត្រូវអប់រំ បំពាក់បំប៉ន សីលធម៌បដិវត្តន៍ទី៩ នេះឲ្យបានជាប់ជាប្រចាំដែរ ។ កុំប៉ះពាល់ក្នុងនេះ គឺកុំយកប្រើប្រាស់ខ្ជះខ្ជាយ រាយមាយ ។ គឺត្រូវថែទាំទុកដាក់ហ្មត់ចត់ សម្រាប់ប្រើ

ប្រាស់ កសាងប្រទេស ការពារប្រទេសឲ្យបានយូរអង្វែង ។ គឺសន្សំសំចៃ នូវរបស់របរសព្វសារពើឲ្យបានជាអតិបរមា កុំឲ្យខូចខាតចោល អាសារឥតការ ។ ជាន័យអនុវត្តមួយទៀត កុំប៉ះពាល់ទ្រព្យសម្បត្តិរួម គឺបើទុកដាក់សម្ភាររួម ត្រូវថែទាំឲ្យគត់មត់ កុំឲ្យខូចខាត ទោះបីបន្តិចបន្តួចក្តី ។ ហើយបើធ្វើការងារ ត្រូវបន្ថយការខូចខាត ការបាក់បែក ការបាត់បង់ ឲ្យបានជាអតិបរមា ។ ដូច្នេះក្នុងការប្រជុំជីវភាពត្រូវកសាងអំពីបញ្ហានេះឲ្យជាប់ ។

**១០) សុភាពរាបសារជាច់ខាតចំពោះប្រជាជន តែមានកំហឹង ឆាបឆេះជានិច្ចចំពោះខ្មាំង**

សីលធម៌របស់យើងគឺសុភាពរាបសារ ចំពោះប្រជាជន តែឆាបឆេះចំពោះខ្មាំង ។ បើឆាបឆេះ ចំពោះខ្មាំងហើយ យើងសកម្មប្រយុទ្ធហើយ ។ សកម្មប្រយុទ្ធទាំងនៅសមរភូមិមុខ សកម្មប្រយុទ្ធទាំងនៅសមរភូមិក្រោយ ។ ដូច្នេះ ត្រូវអប់រំរៀនសូត្រជាប់ ។ អប់រំហើយត្រូវចាត់តាំងព្រោះបើធ្វើតែការងារនយោបាយ សតិអារម្មណ៍មិនចាត់តាំងនោះ មិនអាចសកម្មប្រយុទ្ធទៅបានទេ ។

**១១) ស្រឡាញ់ ហើយធ្វើពលកម្មជានិច្ច**

ន័យពលកម្មនេះគឺការងារគ្រប់ផ្នែកដែលទទួលបន្ទុកចំពោះបក្ស ។ ត្រូវខិតខំបំពេញភារកិច្ច ដែលជាការងារស្នូលរបស់ខ្លួន ដោយពេញចិត្ត ពេញថ្លើម និងហ្មត់ចត់ ។ ត្រូវចៀសវាងយ៉ាងណាកុំឲ្យខុស គឺឲ្យចេះចម្រើនទៅមុខជានិច្ច ។

ស្រឡាញ់ពលកម្ម ក្នុងន័យទីពីរ គឺពលកម្មបង្កបង្កើនផល ។ ក្រៅពីការងារស្នូល ត្រូវស្រឡាញ់ ពេញចិត្ត ពេញថ្លើម រួមកម្លាំងក្នុងកិច្ចការពលកម្មបង្កបង្កើនផលឲ្យចេញជាបន្លែបង្ការ ជាឈើហូបផ្លែ និងជាដំណាំដាំដុះសព្វមុខ ។ មួយថ្ងៃកើនបន្តិច មួយថ្ងៃកើនបន្តិច មន្ទីរក្រសួងមួយ ភូមិដ្ឋានមួយៗ ក្លាយទៅជាសួនដំណាំ ។ ម្យ៉ាងយើងចាត់ចែងធ្វើ ម្យ៉ាងទៀតត្រូវឆ្លៀតពេលរួមធ្វើជាមួយមហាជន ដោយស្រឡាញ់ពេញចិត្ត ពេញថ្លើម ។

**១២) ប្រយុទ្ធនឹងខ្មាំង ប្រយុទ្ធនឹងឧបសគ្គដោយអង់អាច ហើយហ៊ានធ្វើពលីកម្មគ្រប់បែបយ៉ាងជូនប្រជាជនកម្មករ កសិករ ជូនបក្ស ជូនបដិវត្តន៍ ដោយឥតលក្ខខណ្ឌក្នុងគ្រប់កាលៈទេសៈ**

នេះជាសីលធម៌របស់ជនកុម្មុយនីស្តរបស់ជនបដិវត្តន៍ដែលចេញមកពីធាតុពិតរបស់វណ្ណៈអធន ដែលឈានមុខលះបង់អ្វីៗទាំងអស់ ។ ក្នុងការប្រយុទ្ធនឹងខ្មាំង ក៏ដូចប្រយុទ្ធនឹងឧបសគ្គនានាបច្ចុប្បន្ននេះ យើងមានលក្ខណៈងាយស្រួលច្រើនជាងមុនឆ្ងាយណាស់ ។ មិនដូចពីជំនាន់មុនទេ ដែលស្អីក៏ខ្វះ ស្អីក៏ខ្វះ ខ្វះសព្វខ្វះគ្រប់ ។ បញ្ហាវាចោទតែលើសីលធម៌ប្រយុទ្ធធ្វើ ។ បើយើងមានសីលធម៌ប្រយុទ្ធស្រួចស្រាវ ពុះពារគ្រប់ឧបសគ្គបានហើយ ហើយមានការចាត់តាំងធ្វើឬប្រយុទ្ធជាសមូហភាពទៀត នោះគ្មានខ្មាំងសត្រូវណាមកធ្វើអីយើងបានទេ គ្មានឧបសគ្គណាមករាំងស្ទះដំណើរលោតផ្លោះរបស់យើងបានទេ ។ ប៉ុន្តែផ្ទុយទៅវិញ ទោះបីមានលក្ខណៈសម្បត្តិល្អយ៉ាងណា មានមធ្យោបាយច្រើនយ៉ាងណា តែបើគ្មានសីលធម៌ប្រយុទ្ធស្រួចស្រាវ មោះមុតពុះពារឧបសគ្គនិងជម្នះការលំបាកសព្វបែបយ៉ាងទេ ក៏ពុំអាចធ្វើអ្វីកើតដែរ ឬបើទោះជាធ្វើបាន ក៏យឺតយ៉ាវ មិនខ្លាំងក្លា មិនលោតផ្លោះ តាមសំណូមពររបស់ចលនាបដិវត្តន៍ឡើយ ។

## ដំណឹងស្វែងរកពូ

នាងខ្ញុំឈ្មោះ លឹម ភានុវណ្ណរង្សីសីហៈ រស់នៅសង្កាត់សន្សំកុសល ខណ្ឌមានជ័យ ក្រុងភ្នំពេញ សូមប្រកាសរកពូឈ្មោះ ហាក់ អុល មកដល់បច្ចុប្បន្នមានអាយុ៧២ឆ្នាំ ។ កាលពីសម័យ លន់ នល់ ពូរបស់នាងខ្ញុំមានផ្ទះនៅទួលគោក ហើយគាត់ធ្វើជាប៉េអឹម ។ គាត់បានបែកពីគ្រួសារនៅម្តុំវត្តលង្កា ពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីក្រុងឆ្នាំ១៩៧៥ ។ ចាប់តាំងពីពេលនោះមក គ្រួសារនាងខ្ញុំបាត់ដំណឹងគាត់រហូត ។

ប្រសិនបើ បងប្អូនណាបានដឹង ឬស្គាល់ឈ្មោះពូរបស់នាងខ្ញុំ សូមមេត្តាទាក់ទងមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ : ០១៥ ៥៥៥ ០០៧ ឬ ០១២ ៩៩៦ ៧៥០ ឬ មជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈអាសយដ្ឋាន ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ខណ្ឌចំការមន ក្រុងភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១៦ ៨៧៦ ៦៩២ ។

សូមអរគុណ!

# ប្តីស្លាប់តែប្រឹងរស់ដើម្បីកូន

របបខ្មែរក្រហមបានធ្វើឲ្យបាត់បង់កម្លាំងពលកម្ម និង ធនធានមនុស្សយ៉ាងច្រើន ហើយក្រោយរបបនេះដួលរលំនៅ ឆ្នាំ១៩៧៩ ស្ត្រីដើរតួនាទីជាកម្លាំងសំខាន់ក្នុងការជួយទំនុកបម្រុង ជីវភាពគ្រួសារ និងស្តារសង្គមជាតិឡើងវិញដូចជា យ៉េប សារ៉ែស ។ សារ៉ែស ជាស្ត្រីមេម៉ាយបានបាត់បង់កូន និងប្តីក្នុងរបបខ្មែរក្រហម ប៉ុន្តែគាត់បានខិតប្រឹងប្រែងរកស៊ីចិញ្ចឹមកូនដែលនៅរស់និងបាន បញ្ជូនឲ្យទៅរៀនសូត្រគ្រប់គ្នា ។

យ៉េប សារ៉ែស មានស្រុកកំណើតនៅឃុំអរិយក្សត្រ ស្រុក ខ្សាច់កណ្តាល ខេត្តកណ្តាល ។ សារ៉ែស មានបងប្អូនប្រាំមួយ នាក់ និងមានឪពុកឈ្មោះ យ៉េប និងម្តាយឈ្មោះ សាតះ ប្រកប មុខរបរនេសាទត្រីកាលពី សម័យសង្គមរាស្ត្រនិយម ។


យ៉េប សារ៉ែស

កាលពីកុមារ សារ៉ែស បានចូលរៀនភាសាចាមរយៈ ពេលប្រាំឆ្នាំ ។ ក្រោយមក សារ៉ែស បានឈប់រៀន ហើយនៅឆ្នាំ ១៩៦៩ គាត់បានរៀបការជាមួយប្តីឈ្មោះ តូប ឡោះ ។ សារ៉ែស និងប្តីបន្តរស់នៅក្នុងភូមិ និងប្រកបមុខរបរនេសាទត្រីរហូតដល់ សម័យ លន់ នល់ ។ នៅយប់ថ្ងៃមួយនាដើមឆ្នាំ១៩៧៥ កងទ័ព ខ្មែរក្រហមបានចូលទៅដុតកំពង់ជ និងផ្ទះសម្បែងប្រជាជននៅ ក្នុងភូមិ ទើបក្រុមគ្រួសារ សារ៉ែស ភៀសខ្លួនទៅរស់នៅលើទូក ស្ថិតនៅតាមបណ្តោយមាត់ទន្លេ នៅម្តុំស្ពានជ្រោយចង្វារ ។ ប៉ុន្តែ ក្រោយមក ដោយសារខ្មែរក្រហមផ្លោងគ្រាប់ចូលក្រុងភ្នំពេញ កាន់តែខ្លាំង ក្រុមគ្រួសារ សារ៉ែស ឡើងពីទូកទៅរស់នៅក្នុងលេណ ដ្ឋានដើម្បីការពារខ្លួន ។

សារ៉ែស រស់នៅជ្រោយចង្វារបានរយៈពេលពីរខែ យោធា ខ្មែរក្រហមក៏វាយរំដោះបានទីក្រុងភ្នំពេញ ។ ខ្មែរក្រហមបាន បញ្ជាឲ្យក្រុមគ្រួសាររបស់គាត់ប្រមូលរបស់របរទុកមួយកន្លែង និង ប្រាប់ឲ្យចាកចេញពីផ្ទះរយៈពេលបីថ្ងៃ ។ សារ៉ែស បានជិះទូកទៅ រស់នៅឫស្សីជ្រោយក្នុងស្រុករការកោង ខេត្តកណ្តាលបានមួយ រយៈ ទើបខ្មែរក្រហមបើកកាណូតទៅដឹកក្រុមគ្រួសារគាត់ដែល រួមមាន ប្តីនិងកូនបីនាក់ទៀតមកព្រែកក្តាម បន្ទាប់មកទើបយក ឡានមកដឹកបន្តទៅនៅខេត្តពោធិ៍សាត់ ។

ខ្មែរក្រហមបានយកគ្រួសារគាត់ទៅដាក់នៅសហករណ៍ ព្រៃផ្តៅ ដោយនៅទីនោះ ប្រធានសហករណ៍បានចាត់តាំងប្តី សារ៉ែស ឲ្យទៅរកត្រីមកផ្គត់ផ្គង់រោងបាយរួម ចំណែក សារ៉ែស ធ្វើ ការងារ ដកស្ទូង និងប្រមូលជីដាក់ស្រែ ។ ដំបូង សារ៉ែស មានអាហារ ហូបគ្រប់គ្រាន់ ព្រោះក្រៅពីបើករបបរួម ប្តីរបស់គាត់តែងតែលួច យកត្រីដែលរកបានមកឲ្យគាត់ហូបរាល់ថ្ងៃ ។ ប៉ុន្តែក្រោយពេល ប្រធានសហករណ៍ដកប្តីគាត់ឲ្យមកនៅកងភ្ជួររវិញ ទើបក្រុមគ្រួសារ សារ៉ែស ខ្វះខាតអាហារបរិភោគ ។

ថ្ងៃមួយ ក្រោយពេលប្តី សារ៉ែស ត្រឡប់ពីភ្ជួរស្រែវិញ ឈ្លបខ្មែរក្រហមបានមកប្រាប់ប្តីគាត់ថា អង្គការឲ្យគាត់ទៅធ្វើការ នៅកន្លែងផ្សេង ព្រោះនៅទីនោះមានអាហារហូបច្រើន ។ ព្រដូច្នេះ ប្តីរបស់គាត់បានផ្តាំផ្ញើគាត់ថា "ម៉ាក់វានៅធ្វើការ និងមើលថែទាំ កូនៗនៅទីនេះហើយ បើខ្ញុំទៅធ្វើការនៅទីនោះ និងរកអាហារបាន ខ្ញុំនឹងផ្ញើមកឲ្យម៉ាក់វាឯង និងកូនហូប" ។

បន្ទាប់ពីប្តីរបស់ សារ៉ែស ចាកចេញពីផ្ទះបានរយៈពេល មួយថ្ងៃ មានឈ្លបខ្មែរក្រហមម្នាក់បាន មកសុំយកអង្រឹងពីគាត់ ដោយប្រាប់ថាយកទៅឲ្យប្តីរបស់គាត់ចងដេក ព្រោះនៅទីនោះ មានសត្វសង្កើចច្រើនណាស់ ។ ប៉ុន្តែ សារ៉ែស បានឆ្លើយតបទៅវិញ ថាគាត់គ្មានអង្រឹងទេ ស្រាប់តែឈ្លបនោះចាកចេញទៅបាត់ ។ ក្រោយមក មានអ្នកភូមិម្នាក់ (ដែលឈ្លបមកហៅទៅជាមួយប្តី សារ៉ែស ហើយបានរត់គេចខ្លួនរួច) មកប្រាប់ សារ៉ែស ថា ឈ្លបយក ប្តីគាត់ទៅវាយចោលនៅខាងចុងភូមិហើយ ។

ពេលនោះ សារ៉ីស រន្ធត់យ៉ាងខ្លាំងពេលទទួលបានដំណឹងនោះ ប៉ុន្តែគាត់នៅតែទន្ទឹងរង់ចាំប្តីរបស់គាត់ត្រឡប់មកផ្ទះវិញ ។ ក្រោយមកទើប សារ៉ីស ជឿជាក់ថា ប្តីរបស់គាត់ពិតជាស្លាប់ហើយ ព្រោះឈ្លបបានចោទប្តីគាត់ថា ជាទាហាន លន់ នល់ ពាក់ស័ក្តិពីរ ដោយសារតែប្តីគាត់មានមាឌធំ និងមានសម្បុរស ។

រយៈពេលដប់ថ្ងៃក្រោយពីប្តីស្លាប់ កូនស្រីរបស់ សារ៉ីស ដែលទើបមានអាយុបីឆ្នាំ កើតជំងឺពិស រហូតដើរលែងរួច ។ សារ៉ីស បានដើររកថ្នាំខ្មែរមកបិតលើដំបៅឲ្យកូន ប៉ុន្តែដោយសារជំងឺកាន់តែធ្ងន់ធ្ងរ កូនរបស់គាត់ក៏ស្លាប់ទៅ ។ នៅពេលនោះ ដោយសារគ្មានបងប្អូនអាចពឹងពាក់បានទើប សារ៉ីស ទៅរកអ្នកភូមិម្នាក់ដែលជាជនជាតិចាមដូចគ្នាឲ្យជួយជីករណ្តៅកប់កូនរបស់គាត់ ដែលដំបូងអ្នកភូមិនោះបានបដិសេធ ។ ប៉ុន្តែដោយសារ សារ៉ីស អង្វរករ និងសន្យាប្រគល់ខោអាវប្តីរបស់គាត់ដែលនៅសេសសល់ឲ្យ ទើបអ្នកភូមិនោះយល់ព្រម ។

ក្រោយមក នៅក្នុងភូមិមានការខ្វះខាតអាហារយ៉ាងខ្លាំង សារ៉ីស ទទួលបានរបបបបរពីរវែកក្នុងមួយពេល ហើយពេលខ្លះគាត់ទទួលបានតែដំឡូងបីដុំប៉ុណ្ណោះ ។ ការខ្វះខាតបែបនេះ ធ្វើឲ្យ សារ៉ីស ធ្លាក់ខ្លួនឈឺស្គមស្គាំង ហើយដោយមិនសង្ឃឹមថានៅរស់ជីវិតទៀត ទើបគាត់ទៅអង្វរគ្រួសារជនជាតិចាមដែលរស់នៅក្នុងភូមិជាមួយឲ្យមកយកកូនគាត់ទាំងពីរនាក់ (ប្រុសម្នាក់ និងស្រីម្នាក់) ទៅចិញ្ចឹម ។ ប៉ុន្តែកូនរបស់គាត់ទាំងពីរនាក់បានបដិសេធមិនព្រមចាកចេញទៅជាមួយគ្រួសារនោះទេ ហើយបានរត់មកនៅជាមួយគាត់វិញ ។

នៅពេលនោះ ដោយសារអាណិតកូនខ្លាំងពេក ឆ្លៀតពេលសម្រាកពីការងារដកស្ទូង សារ៉ីស បានដើរទៅក្រោយភូមិដើម្បីបេះស្លឹកប្រក្រុងមកប្របាច់លាយជាមួយស្លឹកឬស្សីយកមកឲ្យកូនហូប ។ ប៉ុន្តែ សារ៉ីស ភ័យខ្លាចយ៉ាងខ្លាំង ព្រោះគាត់ឃើញរណ្តៅសាកសពយ៉ាងច្រើនផុសឡើង បន្ទាប់ពីភ្លៀងធ្លាក់ និងឃើញសំណល់ខោអាវនៅខាងក្រោយភូមិនោះ ។

ថ្ងៃមួយនៅពេលបើកអាហារ ដោយសារតែស្រេកឃ្លានខ្លាំងពេក កូនរបស់ សារ៉ីស បានដេរចុងកៅ ព្រោះតែចុងកៅនោះយឺតយូរក្នុងការបើករបបអាហារឲ្យ ។ ឃើញដូច្នេះ សារ៉ីស បានយកស្លាបព្រាទៅវាយលើក្បាលកូនបណ្តាលឲ្យបែកចេញឈាម ដោយសារតែគាត់ខ្លាចឈ្លបចាប់យកទៅវាយធ្វើបាប និងសម្លាប់ចោល ។ ក្រោយពីវាយរួច សារ៉ីស បានដើររកថ្នាំមករុំព្យាបាលកូនរហូតបានជាសះស្បើយ ។

នៅសហករណ៍ព្រៃផ្តៅ សារ៉ីស ឃើញឈ្លបខ្មែរក្រហមយកប្រជាជនដែលជម្លៀសមកថ្មីៗពីខេត្តស្វាយរៀងទៅសម្លាប់យ៉ាងច្រើន ដោយចោទថាខ្មាំងជាប់ខ្សែយួន ។ ថ្ងៃមួយ យាយ ហុង ដែលជាប្រជាជនថ្មីបានដេរអ្នកនៅរោងបាយដែលបានឡើងទៅរើយកចានសម្រាប់ដាក់របបអាហាររបស់គាត់ ប៉ុន្តែឈ្លបបានស្តាប់ឮរួចហើយទៅរាយការណ៍ឲ្យប្រធានកង ។

រយៈពេលមួយថ្ងៃក្រោយមក ប្រធានកងមកប្រាប់ យាយ ហុង ថា អង្គការឲ្យគាត់ទៅយាមស្រូវ ។ ប៉ុន្តែនៅពេល យាយ ហុង ដើរចេញពីភូមិបានប្រហែល៥០០ម៉ែត្រ ស្រាប់តែ សារ៉ីស ឮស្នូរកាំភ្លើងបាញ់ជាច្រើនគ្រាប់ ។ នៅខណៈនោះ កូនស្រីរបស់យាយ ហុង ពីរនាក់ដែលនៅជាមួយ សារ៉ីស ដែរបានយំសោកយ៉ាងខ្លាំង ឃើញដូច្នេះ សារ៉ីស លួងលោម និងណែនាំដើម្បីក្មេងស្រីទាំងពីរនោះកុំនិយាយប៉ះពាល់ទៅដល់អង្គការទៀត ព្រោះខ្លាចយកទោសពៃរ៍ទៀត ។

រហូតដល់ពេលកងទ័ពវៀតណាមចូលមកប្រទេសកម្ពុជាឆ្នាំ១៩៧៩ ខ្មែរក្រហមបានបញ្ជាឲ្យ សារ៉ីស រែកស្រូវពីសហករណ៍ទៅលាក់ទុកនៅក្នុងព្រៃឆ្ងាយៗ ។ នៅតាមផ្លូវ សារ៉ីស ឃើញឈ្លបខ្មែរក្រហមចងស្លាបសេកនារីម្នាក់ និងវាយធ្វើទារុណកម្មរហូតធ្វើឲ្យខ្លាចលែងហ៊ានក្រឡេកមើល ។ ក្រោយមកទើប សារ៉ីស នាំកូនពីរនាក់គេចខ្លួនដើរទៅខេត្តបាត់ដំបង ដើម្បីស្វែងរកបងប្អូន និងឪពុកម្តាយ ។ សារ៉ីស រស់នៅទីនោះបានមួយឆ្នាំ ទើបក្រុមគ្រួសារ និងឪពុកម្តាយគាត់ត្រឡប់មករស់នៅគីឡូម៉ែត្រលេខ៧វិញ ។ សារ៉ីស បានប្រកបរបរលក់ចាប់ហួយ និងបានបញ្ជូនកូនរបស់គាត់ទាំងពីរនាក់ឲ្យទៅរៀនសូត្ររហូតមានការងារធ្វើ និងមានគ្រួសារគ្រប់ៗគ្នា ។

សព្វថ្ងៃ សារ៉ីស អាយុ៦០ឆ្នាំហើយ ប៉ុន្តែគាត់នៅតែនឹកឃើញពីរឿងរ៉ាវអត់ឃ្លាន ការឈឺចាប់ និង ការបាត់បង់កូន និងប្តី ។ ចុងក្រោយ សារ៉ីស និយាយថា “ខ្ញុំខំប្រឹងរស់ដើម្បីកូនប៉ុណ្ណោះ” ។

**សោម ប៊ុនថន**

# ទស្សនាខ្សែភាពយន្តអំពីរបបខ្មែរក្រហមនៅ មជ្ឈមណ្ឌលឯកសារកម្ពុជា

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ផ្ទុកទៅដោយខ្សែភាពយន្តអំពីរបបខ្មែរក្រហមជាង២០០ នៅក្នុងបណ្ណសារ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានអាសយដ្ឋានដូចរៀបរាប់ខាងលើ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រមែប្រមូលឯកសារនានាទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យដែលបានបង្កវិនាសកម្មដ៏ធំធេងទាំងផ្លូវកាយនិងផ្លូវចិត្តដល់ពលរដ្ឋកម្ពុជាទូទៅ ។ ដើម្បីផ្តល់ឱកាសដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម អ្នកស្រាវជ្រាវ សិស្ស និស្សិត មន្ត្រីរដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាលនានារៀនសូត្រ និងយល់ដឹងពីរបបខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជាបើកទទួលអ្នកដែលមានចំណាប់អារម្មណ៍ទាំងអស់ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពីម៉ោង ៨ៈ០០ ដល់ម៉ោង ៥ៈ០០ ល្ងាច ដើម្បីមើលខ្សែភាពយន្តទាក់ទងទៅនឹងរបបខ្មែរក្រហម ។ បើសាធារណជនចង់ជ្រាបព័ត៌មានបន្ថែមទាក់ទងទៅនឹងខ្សែភាពយន្តសូមទាក់ទង ឡេង រតនៈ ឬ សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។

មកដល់ពេលនេះមជ្ឈមណ្ឌលបានផលិតខ្សែភាពយន្តបានចំនួនបួនហើយ




**១) វាលស្រែខ្មែរក្រហមៈ រឿងរ៉ាវរបស់ស្ត្រីម្នាក់ឈ្មោះ តាំង គីម ដែលត្រូវបានរំលោភដោយយោធាខ្មែរក្រហមៈ** យប់មួយក្នុងឆ្នាំ១៩៧៥ នារីវ័យក្មេងម្នាក់ឈ្មោះ តាំង គីម ដែលទើបតែរៀបការរួចថ្មីៗ ត្រូវបានយោធាខ្មែរក្រហមមកហៅឲ្យទៅជួបប្តីរបស់ខ្លួនដែលជាទាហាន លន់ នល់ ។ តែតាមពិត តាំង គីម គឺជាស្ត្រីម្នាក់ក្នុងចំណោមស្ត្រីប្រាំបីនាក់ដែលត្រូវបានបញ្ជូនទៅកាន់វាលស្រែមួយក្បែរភូមិដើម្បីសម្លាប់ចោល ។ ពេលដែលកំពុងយាមដោយយោធាខ្មែរក្រហមម្នាក់ តាំង គីម បានឮសំឡេងស្ត្រីដទៃទៀតស្រែកយំដោយក្តីឈឺចាប់ ពេលស្ត្រីទាំងនោះត្រូវយោធាខ្មែរក្រហមមួយក្រុមរំលោភ ។ ក្រោយមកយោធាខ្មែរក្រហមឯទៀតបានចូលមករំលោភគាត់ដែរ ។ ខ្សែភាពយន្តនេះរៀបរាប់អំពីរឿងរ៉ាវរបស់ស្ត្រី តាំង គីម ដែលក្រោយមកបានបួសជាដូនជីដែលបានតស៊ូជាមួយនិងបច្ចុប្បន្នកាលនិងអតីតកាល ។




**២) នៅគៀនជញ្ជាំងនៃមន្ទីរស-២១ៈ** ខ្សែភាពយន្តនេះបង្ហាញពីការរៀបរាប់ខ្សែជីវិតរបស់មនុស្សបីនាក់ ក្នុងនោះពីរនាក់គឺជាជនរងគ្រោះនិងម្នាក់ទៀតជាកម្មាភិបាលខ្មែរក្រហមនៅមន្ទីរស-២១ ដែលជាកន្លែងឃុំឃាំងអ្នកទោសដ៏ធំបំផុតក្នុងសម័យកាលរបបកម្ពុជាប្រជាធិបតេយ្យ១៩៧៥-១៩៧៩ ។ ខ្សែភាពយន្តនេះរៀបរាប់ពីដំណើរជីវិតមនុស្សទាំងបីនាក់ដែលចាប់កំណើតក្នុងទីកន្លែងផ្សេងគ្នា តែទីបញ្ចប់ទទួលនូវជោគវាសនាដូចគ្នានៅទីកន្លែងតែមួយគឺមន្ទីរស-២១ ។ ជាងបីទសវត្សរ៍ក្រោយពីរបបខ្មែរក្រហមដួលរលំ អ្នកទាំងបីបានរៀបរាប់ពីដំណើរជីវិតមុននិងក្លាយជាអ្នកទោស និងក្លាយជាកងការពារអ្នកទោសនៅមន្ទីរស-២១នេះ ។

**៣) គ្រៀមខ្លួនស្វែងរកយុត្តិធម៌ៈ** ទូទាំងឆ្នាំ២០០៦ មជ្ឈមណ្ឌលឯកសារកម្ពុជាបាន




អញ្ជើញអ្នកភូមិដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ហើយកំពុងរស់នៅតំបន់នានាទូទាំងប្រទេស ដើម្បីមកទស្សនាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីអប់រំប្រជាជនកម្ពុជាអំពីដំណើរកិច្ចការងារនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងដើម្បីផ្តល់ឱកាសដល់អ្នករស់រានជីវិតពីរបបខ្មែរក្រហមចូលរួមចំណែកក្នុងដំណើរការយុត្តិធម៌ ។ ក្នុងដំណើរទស្សនកិច្ចនេះ អ្នកភូមិក៏បានទៅដល់ទីតាំងវាលពិឃាតនានា ដើម្បីឲ្យគាត់អាចវិនិច្ឆ័យដោយខ្លួនឯងចំពោះទង្វើបទឧក្រិដ្ឋដែលខ្មែរក្រហមបានប្រព្រឹត្ត ។ ដំណើរទស្សនកិច្ចនេះបានបញ្ចូលមនុស្សគ្រប់ស្រទាប់វណ្ណៈក្នុងសង្គមដូចជាដូនជី ជនជាតិខ្មែរឥស្លាម សិស្សនិស្សិត និងអ្នកភូមិដែលរស់នៅក្នុងតំបន់ក្រីក្រនានាទូទាំងប្រទេសដែលមិនមានលទ្ធភាពទទួលបានព័ត៌មានផ្សេងៗ ។ ដំណើរទស្សនៈកិច្ចនេះដើម្បីបង្ហាញថា តុលាការនិងមានប្រសិទ្ធភាពបើសិនជាមានការចូលរួមពីជនរងគ្រោះ ។ ខ្សែភាពយន្តនេះបង្ហាញពីដំណើរទស្សនកិច្ចនេះ និងអំពីទស្សនៈយល់ឃើញរបស់អ្នកភូមិជុំវិញរបបខ្មែរក្រហមនិងដំណើរការសាលាក្តីខ្មែរក្រហម ។




**៤) រណ្តៅសាកសពក្បែរវត្ត ៖** ខ្សែភាពយន្តឯកសារនេះរៀបរាប់អំពីដំណើរជីវិតរបស់ស្ត្រីពីររូបគឺ លៀប និង វ៉ាំង ដែលប្រឈមមុខរាល់ថ្ងៃទៅនឹងហេតុការណ៍ពិតដែលថា ឪពុកនិងពូជាទីស្រឡាញ់របស់ខ្លួនត្រូវបានសម្លាប់ដោយស្នាដៃរបស់បុរសម្នាក់ឈ្មោះ គិន ដែលជាអតីតឈ្លបឃុំមួយរូបកាលពីជំនាន់ខ្មែរក្រហម ។

រណ្តៅសាកសពរបស់ឪពុក លៀប ដែលមានទីតាំងនៅក្បែរវត្តដែល គិន ធ្វើជាអាចារ្យនាពេលបច្ចុប្បន្ននេះគឺជារណ្តៅមួយក្នុងចំណោមរណ្តៅចំនួនជាងពីរម៉ឺនកន្លែងដែលបន្សល់ពីជំនាន់ខ្មែរក្រហម ។ អ្វីដែលគួរឲ្យភ្ញាក់ផ្អើលនោះគឺថា ទោះបីជា គិន ទទួលខុសត្រូវចំពោះមរណភាពឪពុករបស់ លៀប និងពូរបស់ វ៉ាំង ក៏ដោយ ក៏ គិន នៅតែទទួលបាននូវការគោរពពីសំណាក់អ្នកភូមិរួមទាំង លៀប និង វ៉ាំង ផង ដោយសារតែគាត់ជាអាចារ្យវត្ត ។

ដូចអ្នករស់រានពីរបបខ្មែរក្រហមផ្សេងទៀតដែរ លៀប និង វ៉ាំង មិនបានសងសឹកជាមួយជនដៃដល់ទេ ។ ប៉ុន្តែនេះមិនប្រាកដថាអ្នកទាំងពីរអាចអត់ឱនទោសឲ្យ គិន បានទេ ។ លៀប និង វ៉ាំង នៅតែត្រងត្រាប់តាមឱវាទរបស់ព្រះពុទ្ធដោយ «ពៀររំងាប់ដោយការមិនចងពៀរ» ។

នៅក្នុងខ្សែភាពយន្តឯកសារនេះ លៀប បាននិយាយថា «ប្រហែលជាឪពុកខ្ញុំជំពាក់ តាគិន បានជា តាគិន មកសម្លាប់ឪពុកខ្ញុំ ។ ខ្ញុំមិនឲ្យប្អូនទៅសងសឹក (គិន) ទេ ព្រោះខ្លាចជំពាក់ឈាមគត្នា» ។

ព្រះពុទ្ធបានថែងថា អ្នកធ្វើអំពើអាក្រក់និងទទួលបានផលអាក្រក់ ទោះជាតិនេះក្តីឬជាតិក្រោយក្តី ។

ខុសពី គិន អតីតកម្មាភិបាលខ្មែរក្រហមផ្សេងទៀត មិនដែលសារភាពពីអ្វីដែលខ្លួនបានធ្វើកាលពីជំនាន់ខ្មែរក្រហមទេ ។ ប៉ុន្តែការអត់ឱនពិតជាអាចកើតឡើងបាន ហើយជនដៃដល់មួយចំនួនក៏ទទួលស្គាល់ពីកំហុសរបស់ខ្លួនដែរ ។ រឿងរ៉ាវរបស់ គិន, លៀប និង វ៉ាំង គឺជាករណីមួយក្នុងចំណោមករណីជាច្រើនទៀតទូទាំងប្រទេស ដែលជនដៃដល់និងជនរងគ្រោះរស់នៅជាមួយគ្នាក្នុងភូមិ ឬសហគមន៍តែមួយ ។ «រណ្តៅសាកសពក្បែរវត្ត» អាចរកមើលបាននៅការិយាល័យមជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏តាមរយៈគេហទំព័រ *http://www.dccam.org/Archives/Films/Films.htm* ឬក៏តាមរយៈគេហទំព័រ *youtube* ។

# ការងារនៅរោងពុម្ពមន្ទីរក-២៨

ចក់ រួន ហៅ សា ភេទប្រុស រស់នៅខេត្តព្រៃវែង ត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅរោងពុម្ពក-២៨របស់របបកម្ពុជាប្រជាធិបតេយ្យ ។ សា បានរៀបរាប់ពីដំណើរជីវិតមុនចូលមកធ្វើការនៅរោងពុម្ពក-២៨នេះ ។ សា ឈប់រៀនត្រឹមថ្នាក់ទី៩ ដោយសារតែឪពុកម្ដាយជាកសិករ ហើយគ្រួសារមានការលំបាកខ្វះខាតក្នុងការផ្គត់ផ្គង់ដល់ជីវភាពដែលមានកូនក្នុងបន្ទុកចំនួនប្រាំពីរនាក់ ។ បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្ដេច សីហនុ ដែលដឹកនាំដោយសេនាប្រមុខ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ភ្លើងកំហឹងបានផ្ទុះឡើងដោយបង្កើតជាចលនាបះបោរនៅតាមភូមិឃុំនានា ។ សា បានឃើញព្រឹត្តិការណ៍នោះដោយផ្ទាល់ភ្នែក ។

សា និយាយថា កាលនោះមានជនកុម្មុយនីស្តពីរនាក់បងប្អូនគឺឈ្មោះអ៊ំ ឌិត និងអ៊ំ ដុស ដែលអ្នកទាំងពីរជាអ្នកភូមិរបសគាត់ដែរ ។ ឌិត និង ដុស បានមកបំផុសបំផុលអ្នកភូមិឲ្យបះបោរប្រឆាំងនឹងរបប លន់ នល់ ហើយឲ្យអ្នកភូមិរត់ចូលព្រៃម៉ាគីដើម្បីធ្វើការតស៊ូ ។ ឌិត និង ដុស បានដិះកង់កាត់ពីភូមិមួយទៅភូមិមួយ ដោយស្រែកថា «ស្អែកយើងទៅបាតុកម្មប្រឆាំងនឹង លន់ នល់ ដើម្បីយកសម្ដេចឪមកវិញ!» ។ ក្នុងពេលធ្វើការបះបោរនោះដែរ សា បាននិយាយថា មានក្បួនដង្ហែរបស់អ្នកភូមិផ្សេងទៀតបានស្រែក



ការងារបោះពុម្ពឯកសារ និងទស្សនាវដ្ដីនៅក្នុងរបបកម្ពុជា ប្រជាធិបតេយ្យ

ថា "ជយោ! សម្តេចឪ! នរណាមិនទៅសម្លាប់ចោល" ។ ដោយសារខ្លាចផង និងដោយសារស្មារតីចង់បានសម្តេចឪមកវិញផង យុវជន យុវនារី និងអ្នកភូមិជាច្រើន បានចូលរួមក្នុងចលនាបះបោរ ដោយអ្នកខ្លះកាន់ពូថៅ អ្នកខ្លះកាន់ដំបង ។

ភ្លើងកំហឹងរបស់ប្រជាជនខ្មែរនៅតែឆេះជាបន្តបន្ទាប់ ។ ស្របពេលជាមួយគ្នានោះដែរ អ្នកភូមិក៏ទទួលការគាបសង្កត់ពីរបប លន់ នល់ ដែរ ព្រមជាមួយនិងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកផង ។ សា បាននិយាយទៀតថា "នៅចន្លោះខែឧសភា និងខែមិថុនាក្នុងឆ្នាំ១៩៧០ មានការប្រយុទ្ធគ្នាខ្លាំងរវាងយោធាខ្មែរក្រហម និងទាហាន លន់ នល់ នៅក្នុងស្រុកស្វាយអន្ទរជាពិសេសនៅមុខវត្តស្វាយអន្ទរតែម្តង" ។ ជារៀងរាល់ថ្ងៃ សា ឮតែស្នូរគ្រាប់ផ្លោង និងគ្រាប់កាំភ្លើងឥតដាច់ក្នុងអំឡុងពេលប្រយុទ្ធគ្នា ។ នៅតាមដងផ្លូវមានសភាពស្ងាត់ជ្រងំ គ្មាននរណាម្នាក់ហ៊ានចេញពីផ្ទះឡើយ ។ តំបន់ភាគច្រើនក្នុងខេត្តព្រៃវែងត្រូវបានគ្រប់គ្រងដោយខ្មែរក្រហមតាំងពីឆ្នាំ១៩៧១ ។ បន្ទាប់ពីខ្មែរក្រហមគ្រប់គ្រងបានហើយ ក៏មានការរៀបចំចាត់ចែងភូមិឃុំដូចជាការបង្កើតមេក្រុម មេភូមិ កងតូច កងនារីឃុំ និងកងឈ្លប ដោយមានការសហការជួយជ្រោមជ្រែងពីកងទ័ពវៀតណាម ។

សា ស្ថិតនៅក្នុងវ័យ១៩ឆ្នាំ ត្រូវបានជ្រើសរើសឲ្យធ្វើជាឈ្លបឃុំក្នុងឆ្នាំ១៩៧២ ក្រោមការគ្រប់គ្រងរបស់ ប៊ុន លន់ ជាមេឃុំ ។ សា បាននិយាយថា គាត់មិនចង់ចូលរួម ធ្វើកងឈ្លបឃុំទេ ប៉ុន្តែមិនអាចគេចផុតពីការជ្រើសរើសរបស់មេឃុំបានទេ ព្រោះឃុំត្រូវការកម្លាំងយុវជន និងយុវនារី ដែលជាកម្លាំងស្នូលក្នុងការបម្រើបដិវត្តន៍ ដើម្បីរំដោះប្រទេសជាតិពីការគ្រប់គ្រងរបស់ លន់ នល់ ។

សា បានរៀបរាប់ពីការងារថា "ខ្ញុំឃ្លាតឆ្ងាយពីឪពុកម្តាយ ។ សមាជិកកងឈ្លបចំនួនប្រាំទៅប្រាំមួយនាក់ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រធានឈ្លបឈ្មោះ សុត ។ ការងារសំខាន់ជាប្រចាំក្នុងភូមិគឺត្រូវដើរតាមផ្ទះអ្នកភូមិដើម្បីលបស្តាប់ក្រែងមាននរណាមិនពេញចិត្តនឹងបដិវត្តន៍ ហើយមានគំនិតជំទាស់នឹងភារកិច្ចផែនការរបស់បក្ស" ។ សា បានបន្តទៀតថា "ក្រោយមកខ្ញុំត្រូវជ្រើសរើសឲ្យធ្វើជាទ័ព" ។

ក្រោយពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះលើរបប លន់ នល់ ក្នុងឆ្នាំ១៩៧៥ សា និងយោធាចំនួន៥០០នាក់ផ្សេងទៀតត្រូវបានបញ្ជូនទៅបណ្តុះបណ្តាលពីគោលនយោបាយបដិវត្តន៍ និងមនោគមវិជ្ជារបស់ខ្មែរក្រហម និងហ្វឹកហ្វឺនពីវិធីសាស្ត្រធ្វើសឹកសង្គ្រាមនៅមន្ទីរស-២០០ ស្ថិតនៅក្នុងភូមិពាមនា ឃុំក្តៀងរាយ ។ មន្ទីរស-២០០ ជាមន្ទីរមជ្ឈិមដែលស្ថិតក្នុងភូមិភាគបូព៌ា និងនៅក្រោមការត្រួតត្រារបស់លេខាភូមិភាគបូព៌ា សោ ភឹម ។ សា និយាយថា មន្ទីរស-២០០គ្មានអគារឬបន្ទប់សម្រាប់ធ្វើការបណ្តុះបណ្តាល ឬកន្លែងសម្រាប់ហ្វឹកហាត់ទេ គឺម្នាក់ៗត្រូវហាត់រៀននៅកណ្តាលវាល និងនៅក្រោមដើមឈើជាដើម ។

ក្រោយមក ដោយមើលឃើញថា គាត់ជាមនុស្សធ្លាប់តស៊ូជាមួយនឹងបដិវត្តន៍អស់ជាច្រើនឆ្នាំកន្លងមក សា ត្រូវបានចាត់តាំងឲ្យទៅធ្វើការផ្នែកបច្ចេកទេសខាងបោះពុម្ពនៅរោងពុម្ពមន្ទីរក-២៨ ក្នុងទីក្រុងភ្នំពេញ ។ សា បាននិយាយថា រោងពុម្ពមន្ទីរក-២៨ មានទីតាំងនៅទល់មុខសណ្ឋាគារកាំបូឌីយ៉ាណា ហើយរោងពុម្ពនេះមានមនុស្សធ្វើការពី៤០ទៅ៥០នាក់មកពីគ្រប់ភូមិភាគទាំងអស់ ។ អ្នកគ្រប់គ្រងរោងពុម្ពមន្ទីរក-២៨ ឈ្មោះ យ៉េ តែដែលជាអ្នកបង្ហាត់បង្រៀនដល់ សា ផ្ទាល់ខាងបច្ចេកទេសប្រើប្រាស់ម៉ាស៊ីនបោះពុម្ព ហើយគាត់ក៏ទទួលការបង្រៀនពីជនជាតិចិនម្នាក់ទៀត ។

សា និយាយថា ក្នុងឆ្នាំ១៩៧៨ គាត់បានក្លាយជាប្រធានផ្នែកបច្ចេកទេសខាងបោះពុម្ព ហើយវិស្វករជនជាតិចិនដែលបានបង្ហាត់បង្រៀនក៏បាត់ឈឹងមិនដឹងទៅណាទេ ។ សា បានបញ្ជាក់ទៀតថា នៅក្នុងទីក្រុងភ្នំពេញមានរោងពុម្ពចំនួនបីគឺរោងពុម្ពមន្ទីរក-២៦, រោងពុម្ពមន្ទីរក-២៧ និងរោងពុម្ពមន្ទីរក-២៨ ដែលរោងពុម្ពទាំងបីនេះដឹកនាំដោយ យ៉ុន យ៉ាត ជារដ្ឋមន្ត្រីក្រសួងសិក្សាធិការ ។ រោងពុម្ពមន្ទីរក-២៨ ភាគច្រើនបោះពុម្ពលិខិតឆ្លងដែន និងដែនទីរបស់របបកម្ពុជាប្រជាធិបតេយ្យ ។

សា និយាយរៀបរាប់ទៀតថា "ផែនទីកម្ពុជាប្រជាធិបតេយ្យមានបីប្រភេទដូចជា ផែនទីនយោបាយ ផែនទីសេដ្ឋកិច្ច និងផែនទីភូមិសាស្ត្ររដ្ឋបាល ។ ទាក់ទងកិច្ចការបោះពុម្ពលិខិតឆ្លងដែន សា ធ្លាប់ដឹងថា អៀង សារី បានចេញបញ្ជាឲ្យបោះពុម្ពលិខិត



យ៉ុន យ៉ាត ពេលទទួលព្រះអង្គម្ចាស់ សុផានវង្ស របស់ប្រទេសឡាវ ក្នុងអំឡុងដំណើរទស្សនកិច្ចរបស់ព្រះអង្គមកកាន់ប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ (ពីឆ្វេងទៅស្តាំ ៖ ដួន ប្រាសិទ្ធិ, យ៉ុន យ៉ាត, អៀង ធីរិទ្ធ និង ខៀវ សំផន)

ឆ្លងដែនជាច្រើន “ខ្ញុំនៅចាំបានថា អៀង សារី បានបញ្ជាតាមរយៈក្រសួងសិក្សាធិការឲ្យរោងពុម្ពមន្ទីរក-២៨ បោះសៀវភៅជាលិខិតឆ្លងដែនចំនួនបីពាន់ក្បាលសម្រាប់កម្មាភិបាលខ្មែរក្រហមធ្វើដំណើរទៅក្រៅប្រទេសដើម្បីធ្វើទំនាក់ទំនងជាមួយបរទេស ។ លិខិតឆ្លងដែនរបបខ្មែរក្រហមនៅផ្នែកក្បាលខាងលើមានសរសេរជាភាសាអង់គ្លេសជាមួយនឹងការប្រើប្រាស់និមិត្តសញ្ញារបស់របបកម្ពុជាប្រជាធិបតេយ្យ” ។ រីឯការបោះពុម្ពផែនទីវិញ សា បាននិយាយថា ផែនទីរបបខ្មែរក្រហមយកគំរូតាមផែនទីពីសង្គមចាស់ដោយកែបន្តិចបន្តួចដាក់ជាលេខសម្គាល់ភូមិភាគ និងតំបន់ លើខេត្តដែលត្រូវរួមបញ្ចូលតែមួយ ហើយផែនទីខ្នាតធំមានប្រវែងបណ្តោយមួយម៉ែត្រ ទទឹងប្រាំតឹក ។ម្យ៉ាងទៀត រោងពុម្ពមន្ទីរក-២៧ជារោងពុម្ពមួយធំជាងគេនៅក្នុងទីក្រុងភ្នំពេញ ដែលស្ថិតនៅខាងត្បូងផ្សារធំថ្មីសម្រាប់ការបោះពុម្ពជាទស្សនាវដ្តីរូបភាព បង្ហាញពីកសិកម្មរបស់កសិករ ដូចជា ការដកស្ទូង ភ្ជួររាស់ លើកទំនប់ ជីកប្រឡាយ ស្ថិតក្រោមរបបខ្មែរក្រហម ។ រោងពុម្ពនេះប្រើប្រាស់ម៉ាស៊ីនស្វ័យប្រវត្តិមកពីអាល្លឺម៉ង់ ។ ចំណែករោងពុម្ពមន្ទីរក-២៦មានទីតាំងនៅខាងកើតពហុកីឡដ្ឋានជាតិអូឡាំពិកសម្រាប់បោះពុម្ពកាសែតសារព័ត៌មានផ្សាយដំណឹងសំខាន់ៗ ដោយប្រើប្រាស់ម៉ាស៊ីនស្វ័យប្រវត្តិមកពីប្រទេសស៊ីស ។

សា បន្តថា “ខ្ញុំឃើញមានសៀវភៅទង់បដិវត្តន៍ និងសៀវភៅសិក្សា តែរោងពុម្ពមន្ទីរក-២៨ មិនបានបោះពុម្ពសៀវភៅទាំងនោះទេ ។ ចំពោះក្រដាសនិងសម្ភារសម្រាប់បោះពុម្ពគឺយករបស់ដែលសេសសល់ពីសង្គមចាស់ ហើយរោងពុម្ពរបស់គាត់មិនដែលទិញក្រដាសថែមទេ ។ សា បញ្ជាក់ទៀតថា គាត់ធ្លាប់ឃើញ ខៀវ សំផន មកត្រួតពិនិត្យការងាររោងពុម្ពម្តងក្នុងឆ្នាំ១៩៧៨ ។ ក្រៅពីកិច្ចការបោះពុម្ព សា ធ្លាប់បានទៅចូលរួមប្រជុំនៅពហុកីឡដ្ឋានជាតិអូឡាំពិក ដែលពេលនោះគាត់ឃើញមេដឹកនាំខ្មែរក្រហមជាច្រើន ។ ចំពោះរឿងម្ហូបអាហារប្រចាំថ្ងៃ សា ទទួលបានរបបហូបចុកពីរពេលក្នុងមួយថ្ងៃ ។ ចំណែកម៉ោងធ្វើការ គាត់ធ្វើការពីម៉ោង៧ដល់ម៉ោង១១ព្រឹក បន្ទាប់មកចាប់ពីម៉ោង១ដល់ម៉ោង៥ល្ងាច ដោយជួនកាលគាត់ត្រូវធ្វើការលើសនោះពេលណាមានការងារបោះពុម្ពចាំបាច់ ។

ទោះបីជាយ៉ាងណា សា និយាយថា ការងារនៅរោងពុម្ពមិនសូវជាមមាញឹកប៉ុន្មានទេ ។ គាត់ធ្លាប់ទៅចូលរួមការសំដែងសិល្បៈនៅរោងមហោស្រពខ្លះដែរទោះបីជាសិល្បៈទាំងនោះមិនមែនជាការកំសាន្តសប្បាយក៏ដោយ ។

ពេលមានគណៈប្រតិភូអន្តរជាតិមកពីបរទេស ដូចជាប្រទេសចិន កូរ៉េ និងប្រទេសភូមា គាត់និងអ្នកផ្សេងទៀតត្រូវបានអញ្ជើញឲ្យទៅទទួលគណៈប្រតិភូទាំងនោះដោយគាត់ត្រូវបានប្រាប់ឲ្យពាក់អាវពណ៌ស និងនៅអាកាសយានដ្ឋានអន្តរជាតិ ពោធិ៍ចិនតុង «ក្នុងពិធីនោះ ខ្ញុំពាក់អាវពណ៌ស ខោពណ៌គគីរ ជួនណាស្លៀកខោពណ៌ទឹកប៊ិច ។ នេះគ្រាន់តែជាការសម្តែងល្ខោនបិទបាំងនូវទង្វើអាក្រក់របស់ខ្មែរក្រហមតែប៉ុណ្ណោះ ។ បក្សកុម្មុយនីស្តកម្ពុជាបានក្លែងបន្លំបរទេសថា កម្ពុជាជារបបស្អាតស្អំ រុងរឿង មហាអស្ចារ្យ មហាលោតផ្លោះ ។»

ពេលសួរថាគាត់មានបងប្អូនស្លាប់ក្នុងរបបខ្មែរក្រហមដែរឬទេ សា បាននិយាយថា បងស្រីរបស់គាត់ស្លាប់ដោយសារមិនមានអាហារហូបចុកគ្រប់គ្រាន់ ។ ចំណែកបងប្រុសម្នាក់ទៀត បានបាត់ខ្លួន បន្ទាប់ពីចូលធ្វើទ័ពខ្មែរក្រហម ។ រហូតដល់សព្វថ្ងៃនេះ សា មិនដឹងថាបងប្រុសរបស់គាត់ស្លាប់ឬរស់នៅទីណាទេ ។

ឆ្លងតាមបទពិសោធន៍ជីវិតផ្ទាល់ខ្លួនរស់នៅក្នុងរបបខ្មែរក្រហម សា បានរៀបរាប់ថា «របបខ្មែរក្រហមជារបបព្រៃផ្សៃ ដែលបានសម្លាប់មនុស្សគ្រាន់តែមានកំហុសបន្តិចបន្តួច និងជារបបមួយដែលប្រើមនុស្សឲ្យធ្វើការដូចសត្វធាតុ» ។ សា ចង់ឲ្យក្មេងជំនាន់ក្រោយបានរៀនសូត្រពីរបបខ្មែរក្រហម ហើយគាត់ក៏ខស្សវាហ៍និយាយប្រាប់កូនរបស់គាត់ពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដែរ ។

ថ្មីៗនេះ សា បានមកចូលរួមស្តាប់សវនាការនៅសាលាក្តីខ្មែរក្រហម ។ សា និយាយថា «មេដឹកខ្មែរក្រហមដែលជាអ្នកដឹកនាំប្រទេសត្រូវទទួលការកាត់ទោសដើម្បីកុំឲ្យមនុស្សជំនាន់ក្រោយយកតម្រាប់តាមរបបប្រល័យពូជសាសន៍នេះទៀត» ។

**ម៉ម សុវណ្ណ**




ប្រធានាធិបតីភូមាឈ្មោះ ណេ វិន មកធ្វើទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យនៅខែវិច្ឆិកា ឆ្នាំ១៩៧៧

# ការការពារការសម្ងាត់របស់ដំណើរការស៊ើបអង្កេត ឬមិនមាត់អ្នកសារព័ត៌មាន? សេរីភាពនៃការបញ្ចេញមតិ

**(តចប់)**

***ក) ខ្លឹមសារនៃព័ត៌មានដែលត្រូវបានការពារនៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី***

តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដំណើរការដោយអនុវត្តប្រព័ន្ធច្បាប់អេតវីសារៀល ដែលដំណើរការនីតិវិធីរបស់តុលាការត្រូវបើកចំហជាសាធារណៈ ។ នៅអំឡុងពេលជំនុំជម្រះក្ដី ដីកាការពារអាចនឹងត្រូវបានសម្រេចធ្វើឡើង បើមានការស្នើសុំពីភាគីពាក់ព័ន្ធណាមួយ បើយោងតាមវិធាននីតិវិធីទី៦៩របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលធានាពីការការពារជនរងគ្រោះនិងសាក្សី ។ លើសពីនេះ ចៅក្រម ឬអង្គជំនុំជម្រះសាលាដំបូង អាចចេញដីកាមិនឲ្យផ្សព្វផ្សាយឯកសារ ឬព័ត៌មាននៅក្នុងករណីណាៗទាំងអស់ដោយយោងទៅតាមវិធាន៥៣របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។



ចៅក្រម ម៉ាក់ សែលឡឺម៉ុង (រូបថត: អ.វ.ត.ក)



ចៅក្រម ហ្វ៊ីកប្រ៊ីក ប៊ុង (

ដើមឡើយ ជនដែលត្រូវបានអនុញ្ញាតទទួលបានព័ត៌មានសម្ងាត់ពីតុលាការត្រូវបាន ផ្សព្វផ្សាយនៅក្នុងសេចក្ដីប្រកាសយ៉ាងជាក់លាក់ ។ ជាឧទាហរណ៍ នៅក្នុងសេចក្ដីសម្រេចលើប្រធានបទសម្រាប់ការបិទបាំងព័ត៌មានកាលពីឆ្នាំ២០០៣ អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានអនុញ្ញាតឲ្យជនជាប់ចោទ វីជីស្លាវ សេសេលជ៍ ដឹងពីអត្តសញ្ញាណរបស់សាក្សីដែលត្រូវបានការពារដោយវិធាន៦៩ ។ ដីកានេះបានផ្ដល់នូវសេចក្ដីបង្គាប់យ៉ាងច្បាស់ ដែលរៀបរាប់ពីព័ត៌មានដែលត្រូវបានការពារ ។ ជាមួយគ្នានោះ អង្គជំនុំជម្រះសាលាដំបូងក៏បានគូសបញ្ជាក់យ៉ាងច្បាស់លាស់ថា ប្រសិនបើជនជាប់ចោទ វីជីស្លាវ សេសេលជ៍ យល់ឃើញថាវាមានសារសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មាននោះទៅកាន់អ្នកដទៃសម្រាប់សំណុំរឿង នោះជនជាប់ចោទរូបនេះ មានកាតព្វកិច្ចបង្គាប់ឲ្យអ្នកដែលទទួលព័ត៌មាននោះថាព័ត៌មានទាំងអស់នោះមិនអនុញ្ញាតឲ្យធ្វើការថតចម្លង រៀបចំឡើងវិញ ផ្សព្វផ្សាយជាសាធារណៈ ឬផ្សព្វផ្សាយតាមបែបផែនណាមួយឡើយ ។ ដីកាការពារនេះបានបញ្ចប់ដោយចេញជាសេចក្ដីបង្គាប់យ៉ាងច្បាស់មួយថា ការរំលោភបំពានណាមួយអាចនាំមកនូវអង្គនីតិវិធីស្ដីពីបទប្រមាថមើលងាយដល់តុលាការ ស្របតាមវិធាន៧៧របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ ដូច្នេះ អ្នកដែលទទួលព័ត៌មានសម្ងាត់ដូចជា វីជីស្លាវ សេសេលជ៍ នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់

អតីតប្រទេសយូហ្គោស្លាវី ត្រូវបានជម្រាបពីខ្លឹមសារនៃព័ត៌មាន ដែលត្រូវបានការពារ និងទទួលបានសេចក្ដីបង្គាប់ទាក់ទងនឹងកាតព្វកិច្ចរបស់ខ្លួនក្នុងការរក្សាឯកសារព័ត៌មានជាការសម្ងាត់ ហើយត្រូវបានព្រមានពីការដាក់ទណ្ឌកម្ម ប្រសិនបើព័ត៌មានដែលត្រូវបានការពារនោះត្រូវបានផ្សព្វផ្សាយ ។

**១) បទប្រមាថមើលងាយនៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី៖ ស្ថានភាពច្បាប់បច្ចុប្បន្ន**

វិធាននីតិវិធីទី៧៧របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី គ្រប់គ្រងលើអង្គជំនុំជម្រះពីបទប្រមាថមើលងាយ ។ ខ្លឹមសារនៃវិធានទី៧៧នេះគឺមានភាពប្រហាក់ប្រហែលគ្នានឹងវិធានផ្ទៃក្នុង៣៥របស់តុលាការខ្មែរក្រហម ហើយផ្នែកដែលជាប់ពាក់ព័ន្ធគ្នានោះចែងថា៖


(រូបថត៖ អ.វ.ត.ក)


ចៅក្រម ឡូរ៉ង់ ហ្គាស្ពឺ អាហ្សឺមេ (រូបថត៖ អ.វ.ត.ក)

(ក) ក្នុងការអនុវត្តអំណាចរបស់ខ្លួន តុលាការអាចកាត់ទោសពីបទប្រមាថមើលងាយលើជនណាដែលធ្វើការជ្រៀតជ្រែកដោយចេតនាលើការគ្រប់គ្រងលើវិស័យយុត្តិធម៌ដែលក្នុងនោះរួមទាំងជនដែលផ្សព្វផ្សាយព័ត៌មានដែលទាក់ទងនឹងអង្គនីតិវិធីរបស់តុលាការដោយបានដឹងពីការរំលោភបំពានលើដីការបស់ចៅក្រម ។

តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានផ្ដើមការកាត់ទោសអ្នករាយការណ៍សារព័ត៌មានជាច្រើននាក់ដោយផ្អែកតាមវិធាន៧៧(២) ហើយរហូតមកដល់រឿងក្ដីរបស់ជនជាប់ចោទ ហាម៉ាន់ ដែលបានបង្ហាញអត្តសញ្ញាណរបស់សាក្សី ដែលត្រូវបានការពារ ទើបមានការចោទប្រកាន់ពីបទជ្រៀតជ្រែកលើការគ្រប់គ្រងលើវិស័យយុត្តិធម៌ ។

ការរំលោភលើវិធាន៧៧របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីតម្រូវថាជនជាប់ចោទបានជ្រៀតជ្រែកដោយចេតនាលើការគ្រប់គ្រងលើវិស័យយុត្តិធម៌ ។ គោលការណ៍ចេតនាឧក្រិដ្ឋជាមុនសម្រាប់ការរំលោភបំពានលើវិធាន៧៧(២)គឺជាការទទួលស្គាល់ ដឹងឮថា ការផ្សព្វផ្សាយព័ត៌មាន នោះបានរំលោភលើដីការបស់តុលាការ ។ បើទោះបីជាកង្វះខាតនូវអង្គហេតុច្បាស់លាស់ និងភាពខុសគ្នានៃលទ្ធភាពនៃការបង្កគ្រោះថ្នាក់អាចចាត់ទុកបានជាចេតនាក៏ដោយ ក៏ការមិនអើពើតែម្យ៉ាងបែបនេះមិនមានលក្ខណៈគ្រប់គ្រាន់ទេ ។ ចេតនាជាក់លាក់ក្នុងការជ្រៀតជ្រែកលើការគ្រប់គ្រងលើវិស័យយុត្តិធម៌មិនត្រូវតម្រូវឲ្យមាននោះទេ ។

អំពើពិរុទ្ធទុកមុនដែលមានចែងនៅក្នុងវិធាន៧៧(ក)(២) «គឺសំដៅទៅលើការផ្សព្វផ្សាយព័ត៌មាន ដែលទាក់ទងនឹងអង្គនីតិវិធីនៅចំពោះមុខតុលាការដែលការផ្សព្វផ្សាយនេះបានរំលោភបំពាន» លើដីកាជាលាយល័ក្ខអក្សរ ឬដោយផ្ទាល់មាត់របស់ចៅក្រម ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តម្រូវមិនឲ្យមានការផ្សព្វផ្សាយព័ត៌មានដែលអាចបង្កនូវគ្រោះថ្នាក់ ហើយក៏មិនបង្កើតឲ្យមានព័ត៌មានស្ដីពីករណីលើកលែងដែលសាធារណជនបានដឹងឮនោះទេ ។ នៅពេលដែលមានការរំលោភបំពានដោយចេតនាលើដីការបស់ចៅក្រមកើតឡើង នោះភស្ដុតាងបន្ថែមស្ដីពីគ្រោះថ្នាក់ដែលមានចំពោះការគ្រប់គ្រងលើវិស័យ

យុត្តិធម៌របស់តុលាការមិនត្រូវបានតម្រូវឲ្យរកឃើញ ដើម្បីធានាឲ្យបាននូវការចោទប្រកាន់ពីបទប្រមាថមើលងាយនោះទេ ។ ដូច្នេះ ការរំលោភបំពានលើដីការបស់តុលាការក្នុងសណ្ឋាន "បែបនេះ" អាចចាត់ទុកជាការជ្រៀតជ្រែក និងការគ្រប់គ្រងលើវិស័យយុត្តិធម៌របស់តុលាការបាន ។

### ក) បទប្រមាថមើលងាយនៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ៈ រឿងក្តី របស់ ហ្វលរ៉ែន ហាម៉ាន់

រឿងក្តីរវាងព្រះរាជអាជ្ញា និង ហាម៉ាន់ មិនត្រឹមតែជារឿងក្តីថ្មីៗ ដែលស្តីពីបទប្រមាថមើលងាយ នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី នោះទេ វាថែមទាំងជារឿងក្តីដំបូងបង្អស់ដែលបានរកឃើញថាអ្នកសារព័ត៌មានម្នាក់មានទោសពីបទប្រមាថមើលងាយសម្រាប់ការពិភាក្សាពីការកកើតឡើងនៃការផ្សាយឯកសារបណ្តឹងឧទ្ធរណ៍សម្ងាត់ ដែលជាក់ស្តែងអ្នកសារព័ត៌មានរូបនេះមិនបានឃើញឯកសារនោះឡើយ ។ បទល្មើសរបស់ ហាម៉ាន់ គឺមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងការរំលោភបំពានលើគោលការណ៍សម្ងាត់របស់តុលាការខ្មែរក្រហម ។ ដូច្នេះ អ្នករាយការណ៍សារព័ត៌មានត្រូវបានព្រមានពីការដកស្រង់យកព័ត៌មានសម្ងាត់ដែលអ្នកទាំងអស់នេះមិនត្រូវបានអនុញ្ញាតឲ្យទទួលបាន ។ បើទោះបីជាមានភាពប្រហាក់ប្រហែលគ្នារវាងរឿងក្តីរបស់ ហាម៉ាន់ និងរឿងក្តីដែលនឹងអាចកើតមាននៅចំពោះមុខតុលាការខ្មែរក្រហមក៏ដោយ ក៏នៅមានភាពខុសគ្នាយ៉ាងសំខាន់លើអង្គនីតិវិធីដែលអនុវត្តនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងនៅតុលាការខ្មែរក្រហម ។ វាគឺជាភាពខុសគ្នាដែលអនុញ្ញាតឲ្យតុលាការខ្មែរក្រហមមិនយកគំរូតាមរឿងក្តីរបស់ ហាម៉ាន់ ។

### ក.១) ការការពារលើមូលហេតុតាមផ្លូវច្បាប់ និងព័ត៌មានផ្សេងៗ

ហាម៉ាន់ ត្រូវបានចោទប្រកាន់ពីបទផ្សព្វផ្សាយព័ត៌មានរសើបផ្នែកនយោបាយទាក់ទងនឹងតួនាទីរបស់ប្រទេសស៊ែប៊ី នៅក្នុងការសម្លាប់រង្គាលលើជនជាតិម៉ូស្លីម-បូស្នៀ ។ ព័ត៌មាននេះដែលតុលាការបានព្រួយបារម្ភអាចនឹងជះផលប៉ះពាល់ដល់សន្តិភាពនៅក្នុងតំបន់ និងបណ្តាលឲ្យមានភាពចលាចលក្នុងផ្នែកនយោបាយ ។ នៅឆ្នាំ២០០៧ ហាម៉ាន់ ដែលជាអតីតអ្នកនាំពាក្យរបស់ព្រះរាជអាជ្ញា ខាឡា ដឺ ប៉ុនតេ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានបោះពុម្ពសៀវភៅមួយក្បាលដែលមានចំណងជើងថា សន្តិភាព និង ទណ្ឌកម្មៈ សង្គ្រាមអាថ៌កំបាំងរវាងនយោបាយ និងយុត្តិធម៌អន្តរជាតិ និងអត្ថបទមួយចុះកាលពីឆ្នាំ២០០៨ដែលមានចំណងជើងថា ឯកសារស្តីពីអំពើប្រល័យពូជសាសន៍ដ៏សំខាន់ត្រូវបានលាក់ត្រដាង ។ នៅក្នុងសៀវភៅទាំងនោះ ហាម៉ាន់ បានសរសេរថា នៅក្នុងរឿងក្តីរបស់ ស្លូបូដាន មីឡូស៊ីវិក ចៅក្រមតុលាការឧទ្ធរណ៍មិនបានផ្សព្វផ្សាយប្រតិចារិកជាក់លាក់ណាមួយដែលបង្ហាញភស្តុតាងឲ្យឃើញពីការចូលរួមរបស់ប្រទេសស៊ែប៊ី នៅក្នុងការសម្លាប់រង្គាលលើជនជាតិម៉ូស្លីម-បូស្នៀ ឡើយ ។ ហាម៉ាន់ បាននិយាយថា "ចៅក្រមតុលាការឧក្រិដ្ឋកម្មអន្តរជាតិបានបិទបាំងព័ត៌មានសំខាន់ពីសាធារណជនក្នុងគោលបំណងតែមួយគត់គឺដើម្បីការពារប្រទេសស៊ែប៊ី ពីការចេញមុខមកទទួលខុសត្រូវចំពោះមុខតុលាការរបស់អង្គការសហប្រជាជាតិ" ។ នៅក្នុងដំណើរការពិភាក្សារបស់ខ្លួន ហាម៉ាន់ បានដកស្រង់សេចក្តីសម្រេចពីរចេញពីសេចក្តីសម្រេចរបស់តុលាការឧទ្ធរណ៍ ហើយបើយោងតាមចៅក្រមដែលត្រូវបានតែងតាំងឡើងជាពិសេសនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី នោះ ហាម៉ាន់ បានទទួលស្គាល់ពីខ្លឹមសារនៃសៀវភៅទាំងពីរនោះ ហើយមានបំណងបង្កឲ្យមានផលប៉ះពាល់ផ្សេងៗ ។

ចៅក្រមដែលត្រូវបានតែងតាំងជាពិសេសបានសម្រេចថា ហាម៉ាន់ បានជ្រៀតជ្រែកនឹងការ គ្រប់គ្រងលើវិស័យយុត្តិធម៌ដោយផ្សព្វផ្សាយព័ត៌មានដែលមានចែងនៅក្នុងសេចក្តីសម្រេចសម្ងាត់របស់រឿងក្តីរវាងព្រះរាជអាជ្ញា និង ស្លូបូដាន មីឡូស៊ីវិក ។ ហាម៉ាន់ បានផ្សព្វផ្សាយពីកាលបរិច្ឆេទនៃសេចក្តីសម្រេចទាំងនោះ ខ្លឹមសារនៃសេចក្តីសម្រេចនោះ និងអត្តសញ្ញាណរបស់ប្រទេសស៊ែប៊ី ដែលត្រូវបានចាត់ទុកជាប្រទេសទទួលបានវិធានការការពារ និងប្រភពកកើតឡើងនូវឯកសារសម្ងាត់ ប៉ុន្តែ ចៅក្រមពិសេសនេះក៏បានសម្រេចថា មូលហេតុតាមផ្លូវច្បាប់ដែលមានចែងនៅក្នុងសេចក្តីសម្រេចទាំងនោះត្រូវបានការពារដោយដីកា

របស់តុលាការៈ

មូលហេតុតាមផ្លូវច្បាប់តម្រូវឲ្យមានភាពជាប់ពាក់ព័ន្ធគ្នានៃច្បាប់ និងអង្គហេតុ ហើយតម្រូវថាមូលហេតុទាំងអស់ត្រូវបានការពារទាំងស្រុង ។ ច្បាប់គឺត្រូវបានដឹងឮជាសាធារណៈ ប៉ុន្តែអង្គហេតុ មិនតែងតែត្រូវបានដឹងឮជាសាធារណៈនោះទេ ។ ដូច្នេះភាពជាប់ពាក់ព័ន្ធគ្នានៃច្បាប់ និងអង្គហេតុ ត្រូវតែជាការសម្ងាត់ ។

តាមការប្រកាន់ខ្ជាប់នូវគោលការណ៍ដូច្នេះ ចៅក្រមដែលតែងតាំងជាពិសេសបានពង្រីកវិសាលភាពនៃវិធានការការពារនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។

**ក.២) គ្មានការទាមទារឲ្យមានចេតនាជាក់លាក់**

បើទោះបីជាមេធាវីការពារក្តីរបស់ ហាម៉ាន់ បានអះអាងថា ហាម៉ាន់ មិនមានចេតនារំលោភបំពានលើដីការបស់តុលាការក៏ដោយ ក៏ចៅក្រមដែលត្រូវបានតែងតាំងជាពិសេសបានសម្រេចថា ហាម៉ាន់ មានចេតនាទុកជាមុន ប៉ុន្តែ ចៅក្រមមិនបានទាមទារឲ្យមានចេតនាជាក់លាក់ក្នុងការរំលោភបំពានលើដីកាការពារដូចដែលមានចែងក្នុងមាត្រា៧៧ទេ ។ ខុសពីរឿងក្តីទាក់ទងពីបទប្រមាថមើលងាយមុនៗដែលកើតមាននៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដូចជារឿងក្តីរបស់ សេសេលជ័ជនជាប់ចោទ ហាម៉ាន់ មិនដែលបានចូលរួមស្តាប់សេចក្តីសម្រេចរបស់ចៅក្រមតុលាការខទ្ទរណ៍ដោយខ្លួនឯងឡើយ ហើយ ហាម៉ាន់ ក៏មិនដែលចុះហត្ថលេខាលើលិខិតទទួលយកដីកាការពារពីតុលាការដែរ ។ ជាងនេះ ហាម៉ាន់ បានពឹងផ្អែកលើព័ត៌មានចេញពីបទសម្ភាសរបស់អ្នកផ្សេងទៀតតែប៉ុណ្ណោះ ។ យ៉ាងណាមិញ ចៅក្រមបានបដិសេធមិនបានពិចារណាថា ចេតនារបស់ ហាម៉ាន់ គឺនៅមានលក្ខណៈខ្សោយ ។ ចៅក្រមបានលើកហេតុផលថា អ្វីដែលចោទជាបញ្ហានោះគឺថា ហាម៉ាន់ បានដឹងឮពីព័ត៌មានសម្ងាត់ និងអង្គហេតុសម្ងាត់របស់ព័ត៌មាននោះ ប៉ុន្តែ ហាម៉ាន់ នៅតែសម្រេចចិត្តផ្សព្វផ្សាយព័ត៌មាននោះ ។ ដូច្នេះ ចៅក្រមបានពិចារណាខ្លាំងលើហេតុផលដែលថា ហាម៉ាន់ បានដឹងឮពីព័ត៌មានសម្ងាត់ដែលលេចចេញពីប្រភពឯកសារយោងដែលមានលក្ខណៈជាឯកសារ "សម្ងាត់" ដែលមាននៅក្នុងអត្ថបទរបស់ ហាម៉ាន់ ។ ចៅក្រមក៏បានធ្វើការពិចារណាលើការព្រមានពីក្រឡាបញ្ជីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីដែលបានផ្ញើទៅឲ្យ ហាម៉ាន់ មុនពេលដែល ហាម៉ាន់ បោះពុម្ពផ្សាយសៀវភៅទាំងនោះ ។ បើទោះបីជា ហាម៉ាន់ មិនដែលបានអានសេចក្តីសម្រេចសម្ងាត់ទាំងនោះ ឬបានចុះហត្ថលេខាលើលិខិតទទួលយកដីកាការពារក៏ដោយ ក៏ ហាម៉ាន់ ត្រូវបានតុលាការសម្រេចថាមានចេតនាឧក្រិដ្ឋទុកជាមុនដោយយោងតាមវិធាន ៧៧ ។

**ក.៣) គ្មានកំហុសនៃអង្គហេតុដើម្បីការការពារក្តី**

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ចៅក្រមពិសេសបានបង្គាប់ថា ហាម៉ាន់ គួរតែពិគ្រោះជាមួយ នឹងតុលាការដើម្បីធានាថាសៀវភៅរបស់ខ្លួនដើរស្របទៅតាមច្បាប់ ដូច្នេះការដែល ហាម៉ាន់ មិនបានពិគ្រោះជាមួយនឹងតុលាការនេះហើយដែលមិនអនុញ្ញាតឲ្យ ហាម៉ាន់ ប្រើប្រាស់កំហុសក្នុងអង្គហេតុដើម្បីការពារក្តី ។ មុនពេលដែល ហាម៉ាន់ បោះពុម្ពសៀវភៅទាំងនោះ បើទោះបីជាព័ត៌មានដែល ហាម៉ាន់ បានផ្សព្វផ្សាយគឺជាព័ត៌មានដែលត្រូវបានដឹងឮជាសាធារណៈ ហើយជាប្រធានបទនៃការពិភាក្សារបស់ក្រុមអ្នកសារព័ត៌មានក៏ដោយ ក៏ចៅក្រមមិនបានពិចារណាថា ហាម៉ាន់ អាចនឹងយល់ឃើញថាព័ត៌មានទាំងនោះលែងជាព័ត៌មានសម្ងាត់តទៅទៀតហើយដែរ ។ ផ្ទុយទៅវិញ ចៅក្រមបែរជាលើកហេតុផលថា ហាម៉ាន់ គួរតែបានពិគ្រោះជាមួយនឹងអង្គការសហប្រជាជាតិ ឬ តុលាការមុនពេលបោះពុម្ពផ្សាយសៀវភៅទាំងនោះទៅវិញ ។

## ៤) សេរីភាពក្នុងការបញ្ចេញមតិ

រឿងក្តីរវាងព្រះរាជអាជ្ញា និង ហាម៉ាន់ គឺជារឿងក្តីទាក់ទងពីបទប្រមាថមើលងាយដំបូងគេនៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលឆ្លុះបញ្ចាំងឲ្យឃើញពីតុល្យភាពរវាងគោលការណ៍សម្ងាត់ និងការការពារលើសេរីភាពក្នុងការបញ្ចេញមតិ ។ នៅក្នុងអង្គពិភាក្សាខ្លី ចៅក្រមបានកត់សម្គាល់ពីយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សទ្វីបអឺរ៉ុបដែលតម្រូវថា ដើម្បីអនុញ្ញាតឲ្យមានរឿងក្តីស្តីពីការជ្រៀតជ្រែកនឹងសេរីភាពក្នុងការបញ្ចេញមតិបានលុះត្រាតែការជ្រៀតជ្រែកនោះមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ ។ ប៉ុន្តែ ចៅក្រមមិនបានធ្វើការពិនិត្យពិច័យឲ្យមានតុល្យភាពគ្រប់គ្រាន់តាមប្រព័ន្ធ

តុលាការសិទ្ធិមនុស្សរបស់ទ្វីបអឺរ៉ុបនោះទេ ហើយបានសម្រេចថា ការប្រើប្រាស់ការដាក់ទណ្ឌកម្មគឺមិនមែនជាការរំលោភលើសេរីភាពរបស់ ហាម៉ាន់ ក្នុងការបញ្ចេញមតិឡើយ ។

ដំបូង ចៅក្រមបានពិចារណាលើដីកាការពារដែលបានការពារមតិរបស់តុលាការឧទ្ធរណ៍ និងគោលដៅរបស់តុលាការនេះ ។ យោងតាមចៅក្រម គោលបំណងនៃបទបញ្ញត្តិគឺដើម្បីធានាឲ្យបាននូវការសហការរបស់ប្រទេសក្រៅគឺ ស៊េបឺ ជាមួយនឹងប្រយោជន៍របស់សាធារណជនក្នុងការទទួលបានព័ត៌មាន ។ ខ្លឹមសារនៃព័ត៌មានដែលត្រូវបានការពារនេះត្រូវបានគូសបញ្ជាក់យ៉ាងច្បាស់លាស់តាមរយៈដីកាផ្សព្វផ្សាយ ។ ដូច្នេះ បញ្ហាថាតើសាធារណជនមានសិទ្ធិក្នុងការទទួលបានព័ត៌មានដែរឬយ៉ាងណានោះគឺត្រូវតែសម្រេចដោយតុលាការ មិនមែនអ្នករាយការណ៍របស់សារព័ត៌មាននោះទេ ។ ផ្អែកលើហេតុផលនេះ តុលាការបានធ្វើការរិះគន់យ៉ាងខ្លាំងលើ ហាម៉ាន់ ហើយបានអះអាងថា “ជនណាដែលរួមទាំងអ្នកសារព័ត៌មានមិនអាចផ្សព្វផ្សាយព័ត៌មានដែលរំលោភបំពានលើដីការបស់តុលាការដោយឈរលើមូលដ្ឋានវាយតម្លៃពីប្រយោជន៍សាធារណៈដោយខ្លួនឯង នៅពេលដែលទទួលបានព័ត៌មានទេ” ។ ដោយសារតែ ហាម៉ាន់ បានបោះពុម្ពសៀវភៅដែលរំលោភលើដីកាផ្សព្វផ្សាតាមផ្លូវច្បាប់ នោះចៅក្រមបានសម្រេចថា ហាម៉ាន់ បានបង្កផលប៉ះពាល់ដល់ការជឿជាក់របស់តុលាការ ហើយបានធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងមកលើ “កម្រិតនៃការសហការដែលមានសារសំខាន់ដល់ការគ្រប់គ្រងលើវិស័យយុត្តិធម៌” ។

បើទោះបីជាចៅក្រមបានទទួលស្គាល់ការពិនិត្យពិច័យរបស់តុលាការសិទ្ធិមនុស្សទ្វីបអឺរ៉ុបក៏ដោយ ក៏ការពិនិត្យពិច័យនេះមិនមានជាប់ពាក់ព័ន្ធខ្លាំងណាស់ណាទេ នៅពេលដែលចៅក្រមបានកំណត់ថាសេចក្តីសម្រេចរបស់ខ្លួនមិនបានជ្រៀតជ្រែកនឹងសេរីភាពរបស់ ហាម៉ាន់ ក្នុងការបញ្ចេញមតិទេ ។ ចៅក្រមបានធ្វើការវិភាគមិនពេញលេញលើប្រយោជន៍របស់សាធារណជនក្នុងការទទួលបានព័ត៌មាន ហើយបែរជាសម្រេចថា អង្គនីតិវិធីស្តីពីបទប្រមាថមើលងាយមានលក្ខណៈខ្វះខាតនូវហេតុផលច្បាស់លាស់ ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនដែលថាគ្មានការជ្រៀតជ្រែកលើសេរីភាពរបស់ ហាម៉ាន់ ក្នុងការបញ្ចេញមតិនោះ ចៅក្រមបានផ្លាស់ប្តូរមិនដើរតាមគំរូដែលបានគ្រោងទុកជាស្រេចដែលជាភាពពាក់ព័ន្ធមួយដែលមិនងាយនឹងរកឃើញ ។ សេចក្តីសម្រេចរបស់ចៅក្រមបានបកស្រាយយ៉ាងសង្ខេបពីហេតុផលដែលជំរុញឲ្យមានយុត្តិសាស្ត្រសំខាន់នៅឯតុលាការសិទ្ធិមនុស្សទ្វីបអឺរ៉ុប ។ នេះគឺជាយុត្តិសាស្ត្រដែលបកស្រាយពីតួនាទីរបស់សារព័ត៌មានក្នុងដំណើរការស៊ើបអង្កេតសម្ងាត់របស់តុលាការក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូ ។ ដោយសារតែភាពជាប់ពាក់ព័ន្ធជាក់លាក់ រវាងប្រព័ន្ធច្បាប់ស៊ីវិលឡូ និងភាពសំបូរបែបនៃច្បាប់ករណីដែលមានយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សទ្វីបអឺរ៉ុប ដែលទាក់ទងនឹងការរំលោភលើសេរីភាពក្នុងការបញ្ចេញមតិបានដើរតួជាមូលដ្ឋានដ៏ប្រសើរមួយដែលតុលាការខ្មែរក្រហមគួរតែអនុវត្តតាម ។

**៤) ទណ្ឌកម្មនៅឯតុលាការសិទ្ធិមនុស្សទ្វីបអឺរ៉ុប ៖ ការរំលោភដ៏ត្រឹមត្រូវ និងដ៏សំខាន់ លើសេរីភាពក្នុងការបញ្ចេញមតិ**

វិធាន៧៧របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី គឺមានលក្ខណៈស្រដៀងគ្នានឹងវិធានផ្ទៃក្នុង៣៥របស់តុលាការខ្មែរក្រហម ។ យ៉ាងណាមិញ វិធាន៧៧ត្រូវបានអនុវត្តនៅក្នុងអង្គនីតិវិធីជំនុំជម្រះក្តីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីដែលត្រូវបានសន្មតថាដំណើរការជាសាធារណៈទាំងនៅតុលាការខ្មែរក្រហម និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ ហើយវិធាននេះក៏ទទួលបានដីកាការពារក្រោយពេលដែលចៅក្រមបានចេញដីកាការពារដាច់ខាតមួយ ។ ដោយឡែក តុលាការសិទ្ធិមនុស្សទ្វីបអឺរ៉ុបបានចេញសេចក្តីសម្រេចលើការទទួលបានព័ត៌មានរបស់អ្នកសារព័ត៌មាន និងការរំលោភបំពានលើគោលការណ៍សម្ងាត់របស់តុលាការនៅក្នុងអំឡុងដំណើរការស៊ើបអង្កេតដោយសម្ងាត់របស់តុលាការសម្រាប់ប្រទេសដែលអនុវត្តប្រព័ន្ធច្បាប់ស៊ីវិលឡូ ហើយក៏បានបង្កើតជាយុត្តិសាស្ត្រដ៏សមរម្យមួយសម្រាប់ឲ្យតុលាការខ្មែរក្រហមអនុវត្ត ។ ខុសពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ការរំលោភលើដីកាការពារ ឬការរំលោភបំពានលើការស៊ើបអង្កេតដោយសម្ងាត់របស់តុលាការមិនត្រូវបានចាត់ទុក “ថាជា” ការជ្រៀតជ្រែកនោះទេ ។ ជាក់ស្តែង

តុលាការសិទ្ធិមនុស្សទ្វីប អឺរ៉ុប បានពិនិត្យពិច័យដោយសមភាព តាមករណីនីមួយៗ ដើម្បីកំណត់ថាតើការរំលោភលើសេរីភាពក្នុង ការបញ្ចេញមតិពិតជាត្រូវបានប្រព្រឹត្តមែនឬយ៉ាងណា ។ ដំបូង ដើម្បីចេញដីកាសម្ងាត់ វាទាមទារឲ្យមានគោលដៅត្រឹមត្រូវតាម ផ្លូវច្បាប់ ។ ទីពីរ គោលដៅដែលត្រឹមត្រូវតាមផ្លូវច្បាប់នេះត្រូវតែ ជាការរំលោភបំពានដ៏ជាក់ស្តែងមួយដែលកើតឡើងក្នុងសង្គម ដែលដើរតាមលទ្ធិប្រជាធិបតេយ្យដែលអាចបង្ហាញឲ្យឃើញតាម រយៈភាពចាំបាច់សារព័ត៌មានរបស់សង្គម ។ ចុងក្រោយការជ្រៀត ជ្រែកត្រូវតែសមាមាត្រគ្នានឹងគោលដៅដែលត្រឹមត្រូវតាមផ្លូវ ច្បាប់ ហើយមូលហេតុដែលអះអាងពីការជ្រៀតជ្រែកនោះត្រូវ ជាប់ពាក់ព័ន្ធគ្នា ហើយមានខ្លឹមសារគ្រប់គ្រាន់ ។ ក្នុងការវាយតម្លៃ លើបទដ្ឋានអន្តរជាតិស្តីពីការដាក់ទណ្ឌកម្មដែលអនុលោមតាមវិធាន ផ្ទៃក្នុង៣៥ តុលាការខ្មែរក្រហមអាចនឹងទទួលយកសេចក្តីបង្គាប់ ទាក់ទងនឹងវិធាននីតិវិធីដែលត្រូវបានទទួលស្គាល់តាមបទដ្ឋានអន្តរ ជាតិ ហើយគ្មានការទាមទារថាប្រភពសារព័ត៌មានគួរតែផ្តល់សេចក្តី គោរពទៅលើលក្ខខណ្ឌទាំងអស់នោះទេ ។ ដូច្នេះ មិនមានហេតុផល ដែលគួសបញ្ជាក់ថា ហេតុអ្វីបានជាតុលាការខ្មែរក្រហមគួរតែគោរព តាមយុត្តិសាស្ត្រទាក់ទងនឹងអង្គជំនុំជម្រះក្តីទាក់ទងនឹងបទប្រមាថ មើលងាយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិជាងយុត្តិសាស្ត្រ របស់តុលាការសិទ្ធិមនុស្សទ្វីបអឺរ៉ុបនោះទេ ។ ជាក់ស្តែង ដោយសារ តែយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សទ្វីបអឺរ៉ុបត្រូវបានអនុវត្ត នៅក្នុងប្រទេសដែលដើរតាមប្រព័ន្ធច្បាប់ស៊ីវិលឡ នោះច្បាប់ករណី របស់តុលាការនេះត្រូវបានអនុម័តឡើងដែលមានលក្ខណៈស្រប តាមច្បាប់នីតិវិធីរបស់តុលាការខ្មែរក្រហមច្រើន ។

**ក) អ្នកឃ្លាំមើលដំណើរការលទ្ធិប្រជាធិបតេយ្យ និង ប្រយោជន៍ឯកជនរបស់មន្ត្រីរដ្ឋាភិបាល**

តុលាការសិទ្ធិមនុស្សទ្វីបអឺរ៉ុបមិនត្រឹមតែទទួលស្គាល់ពីការ ពិនិត្យពិច័យដោយសមភាពដ៏ត្រឹមត្រូវ និងដ៏សំខាន់នៅក្នុងដំណើរ ការស៊ើបអង្កេតដោយសម្ងាត់របស់តុលាការ ថែមទាំងទទួលស្គាល់ ពីសារសំខាន់នៃសេរីភាពក្នុងផ្នែកសារព័ត៌មានក្នុងការសម្រប សម្រួលដល់ការជជែកវែកញែកផ្នែកនយោបាយ ។ ឧទាហរណ៍ នៅក្នុងរឿងក្តីរវាង ឌុយប៉ុស និង ប្រទេសបារាំង អ្នកសារព័ត៌មាន ពីរនាក់ ត្រូវបានតុលាការសម្រេចថាមានទោសពីបទទទួលបាន ព័ត៌មានតាមរយៈការរំលោភបំពានលើគោលការណ៍សម្ងាត់របស់ តុលាការ ។ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់អ្នកសារព័ត៌មានជនជាតិ បារាំងដែលត្រូវបានចោទប្រកាន់នោះ តុលាការសិទ្ធិមនុស្សទ្វីប អឺរ៉ុបបានអះអាងថា សេរីភាពក្នុងការបញ្ចេញមតិយោបល់គឺជា មូលដ្ឋានដ៏សំខាន់មួយរបស់ប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យ ដូច្នេះការការពារសារព័ត៌មានពិតជាមានសារសំខាន់ ។ តុលាការ មិនត្រឹមតែបានទទួលស្គាល់ពីកិច្ចការផ្សព្វផ្សាយព័ត៌មាន និង គោលគំនិតរបស់សារព័ត៌មានថែមទាំងបានទទួលស្គាល់ពីសិទ្ធិរបស់ សាធារណជនក្នុងការទទួលបានព័ត៌មានពីអ្នកសារព័ត៌មាន ។

ឌុយប៉ុស គាំទ្រគោលការណ៍ដែលថា ក្នុងករណីដែលពាក់ ព័ន្ធនឹងបញ្ហាជជែកវែកញែកជាសាធារណៈដ៏សំខាន់ តុលាការសិទ្ធិ មនុស្សទ្វីបអឺរ៉ុប តម្រូវឲ្យបង្ហាញយ៉ាងច្បាស់ពីភាពចាំបាច់ក្នុងការ រំលោភលើសេរីភាពក្នុងការបញ្ចេញមតិ ។ តុលាការបានយល់ ឃើញថា នៅពេលដែលអ្នកសារព័ត៌មានរាយការណ៍ពីព័ត៌មាន ដែលដកស្រង់ចេញពីការរំលោភបំពានលើការស៊ើបអង្កេតសម្ងាត់ របស់តុលាការ ប៉ុន្តែបម្រើដល់ការជជែកវែកញែកជាសាធារណៈ ដ៏មានសារសំខាន់ នោះអ្នកសារព័ត៌មានបានដើរតួជា «អ្នកឃ្លាំ មើល» លទ្ធិប្រជាធិបតេយ្យ ហេតុដូច្នេះ អ្នកសារព័ត៌មានគួរតែ អនុញ្ញាតឲ្យទទួលបានព័ត៌មានកាន់តែទូលាយ ។ ដូច្នេះ នៅក្នុងការ ពិចារណាលើគោលការណ៍ត្រឹមត្រូវតាមផ្លូវច្បាប់នៃការសម្ងាត់ និង ប្រយោជន៍របស់សាធារណជនក្នុងការទទួលបានព័ត៌មានដែលអ្នក សារព័ត៌មានទាំងពីរនាក់បានផ្សព្វផ្សាយ នោះតុលាការសិទ្ធិមនុស្ស ទ្វីបអឺរ៉ុបបានសម្រេចថា តុលាការរបស់ប្រទេសបារាំងបាន រំលោភលើសេរីភាពក្នុងការបញ្ចេញមតិរបស់អ្នកសារព័ត៌មាន ។

អ្វីដែលសំខាន់នៅក្នុងរឿងក្តីរបស់ ឌុយប៉ុស គឺការទទួល ស្គាល់របស់តុលាការដែលដាក់កម្រិតលើសេរីភាពក្នុងការបញ្ចេញ មតិយោបល់គឺពិតជាពិបាកក្នុងការកំណត់ថា ពេលណាដែលសិទ្ធិ របស់អ្នកនយោបាយមានជាប់ពាក់ព័ន្ធ ពីព្រោះបុគ្គលទាំងនោះមាន កាតព្វកិច្ចពាក់ព័ន្ធនឹងកិច្ចការត្រួតពិនិត្យ ហេតុដូច្នេះ អ្នកទាំងអស់នេះ ត្រូវតែបង្ហាញនូវការអធ្យាស្រ័យ ៖ «តុលាការផ្សារភ្ជាប់សារសំខាន់ បំផុតនៃសេរីភាពក្នុងការបញ្ចេញមតិទៅក្នុងបរិបទនៃការជជែក

វែកញែកផ្នែកនយោបាយ ហើយយល់ឃើញថា ហេតុផលដ៏រឹងមាំត្រូវបានតម្រូវឲ្យមានដើម្បីកំណត់ការរឹតត្បិតលើការបញ្ចេញមតិជាសាធារណៈ» ។ ដោយសារតែរឿងផ្ទាល់ខ្លួនរបស់ប្រធានាធិបតីបារាំងត្រូវបានទទួលរងគ្រោះថ្នាក់ និងដោយសារតែតួនាទីរបស់ប្រធានាធិបតីបានធ្វើឲ្យប្រធានាធិបតីប្រឈមមុខនឹងការតាមដានរបស់មជ្ឈដ្ឋានសាធារណៈ នោះប្រយោជន៍របស់សាធារណៈមានប្រៀបជាងប្រយោជន៍នៃរឿងផ្ទាល់ខ្លួន ។ ស្រដៀងគ្នានេះ អ្នកសារព័ត៌មានដែលបានទទួលរងការគំរាមកំហែងដោយទណ្ឌកម្មនៅឯតុលាការខ្មែរក្រហមគឺជាអ្នកសារព័ត៌មានដែលរាយការណ៍ពីព័ត៌មានទាក់ទងនឹងអង្គនីតិវិធីសំខាន់របស់តុលាការ ដែលក្នុងនោះរួមមានអ្នកដែលមានជាប់ពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទលម្មៀងផ្នែកនយោបាយ ។ ដូចគ្នានឹងរឿងក្តីរបស់ ឌុយប៉ុស អ្នកសារព័ត៌មានកំពុងតែដើរតួជាអ្នកឃ្លាំមើលដំណើរលទ្ធិប្រជាធិបតេយ្យ ដោយធានាថាតុលាការមានការទទួលខុសត្រូវក្នុងការផ្សព្វផ្សាយព័ត៌មានទៅកាន់មជ្ឈដ្ឋានសាធារណៈ ។ បន្ថែមលើនេះ បុគ្គលដែលរឿងផ្ទាល់ខ្លួនត្រូវបានរងគ្រោះថ្នាក់ នោះគឺសុទ្ធតែជាអតីតមន្ត្រីរដ្ឋាភិបាល ។ ដូចគ្នានឹងលោកប្រធានាធិបតីបារាំងក្នុងរឿងក្តីឌុយប៉ុស អតីតមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមបានលះបង់នូវរឿងផ្ទាល់ខ្លួន នៅពេលដែលអ្នកទាំងអស់នេះ ចាប់ផ្តើមឡើងគ្រប់គ្រងតំណែងបន្តទៀត ។ ដូច្នេះ ប្រយោជន៍នៃរឿងផ្ទាល់ខ្លួនរបស់អតីតមេដឹកនាំជាន់ខ្ពស់ទាំងអស់នេះមានប្រៀបតិចជាប្រយោជន៍របស់ប្រជាជនកម្ពុជាទូទៅ ដូច្នេះ ប្រយោជន៍របស់សាធារណជនមានភាពលើសលុបជាង ។

**១) ព័ត៌មានគឺជាការពិចារណាដ៏សំខាន់មួយនៅក្នុងការរំលោភបំពានលើសេរីភាពក្នុងការបញ្ចេញមតិ**

នៅក្នុងការពិចារណាពីការព្រួយបារម្ភពីសេរីភាពក្នុងការបញ្ចេញមតិយោបល់ និងការស៊ើបអង្កេតដោយសម្ងាត់ តុលាការសិទ្ធិមនុស្សអឺរ៉ុប ធ្វើការពិចារណាលើព័ត៌មានស្តីពីការរំលោភបំពាន និងវិភាគថាតើព័ត៌មាននោះគឺជាព័ត៌មានដែលបានលេចធ្លាជាសាធារណៈហើយឬនៅ នៅពេលដែលមានការចោទប្រកាន់ពីបទរំលោភបំពាននោះ ។ ជាឧទាហរណ៍ នៅក្នុងរឿងក្តីរបស់ វ៉ែបឺ និងប្រទេសស្វ៊ីស តុលាការបានសម្រេចថា ព័ត៌មានដែលបានលេចធ្លាទៅកាន់មជ្ឈដ្ឋានសាធារណៈ នៅពេលដែលព័ត៌មាននេះត្រូវបានផ្សព្វផ្សាយដោយអ្នកសារព័ត៌មានម្នាក់នោះគឺឋិតនៅក្រៅវិសាលភាពនៃគោលការណ៍សម្ងាត់ ។ នៅក្នុងរឿងក្តីរបស់ វ៉ែបឺ អ្នកសារព័ត៌មានជនជាតិស្វ៊ីសម្នាក់ត្រូវបានចោទប្រកាន់ពីបទរំលោភបំពានលើការសម្ងាត់នៃដំណើរការស៊ើបអង្កេតរបស់តុលាការនៅពេលដែលគាត់បានធ្វើសេចក្តីថ្លែងការណ៍មួយនៅក្នុងសន្និសីទកាសែតដែលគាត់បាននិយាយពីការចាប់ផ្តើមនៃដំណើរការស៊ើបអង្កេតរបស់តុលាការ ។ ចៅក្រមអង្គជំនុំជម្រះក្តីបានសម្រេចថាបើទោះបីជាមានការអះអាងថា បញ្ហានេះត្រូវបានដឹងឮជាសាធារណៈក៏ដោយ ក៏វាមិនសូវមានសារសំខាន់ដែរ ។ ដូច្នេះ ចៅក្រមបានសម្រេចរកឃើញពីអំពើពិរុទ្ធនៃបទឧក្រិដ្ឋកម្ម បើទោះបីជាបទល្មើសនោះត្រូវបានប្រព្រឹត្តឡើងដោយគ្មានចេតនាក៏ដោយ ។

នៅក្នុងបណ្តឹងឧទ្ធរណ៍ តុលាការសិទ្ធិមនុស្សអឺរ៉ុប បានយល់ឃើញថា ព័ត៌មាននោះបានលេចធ្លាទៅមជ្ឈដ្ឋានសាធារណៈរួចហើយ ។ ហើយដោយសារតែគ្មានការរំលោភបំពានលើព័ត៌មានណាមួយ នោះការរំលោភបំពានលើសេរីភាពក្នុងការបញ្ចេញមតិគឺមិនត្រឹមត្រូវទេ ។ តុលាការបានយល់ស្របថា ការដាក់ពិន័យសម្រាប់ការចោទប្រកាន់ពីបទរំលោភបំពានរបស់ វ៉ែបឺ គឺជាការជ្រៀតជ្រែកដ៏មិនសមហេតុផលមួយលើសិទ្ធិក្នុងការទទួលបានសេរីភាពក្នុងការបញ្ចេញមតិ ។ បើទោះបីជាប្រយោជន៍របស់រដ្ឋាភិបាលក្នុងការធានាឲ្យបាននូវដំណើរការស៊ើបអង្កេតដ៏ត្រឹមត្រូវមួយមានសារសំខាន់ក៏ដោយ ក៏ការដាក់ពិន័យដើម្បីជាប្រយោជន៍ដល់ការប្រកាន់ខ្ជាប់នូវគោលការណ៍សម្ងាត់មិនគួរកើតមានដែរ នៅពេលដែល វ៉ែបឺ បានផ្សព្វផ្សាយព័ត៌មានដែលត្រូវបានលេចធ្លាទៅកាន់មជ្ឈដ្ឋានសាធារណៈ ។ ដូច្នេះរឿងក្តីរបស់ វ៉ែបឺ បានបង្កើតជាគោលការណ៍សំខាន់មួយគឺថា ៖ បើទោះបីជាការការពារដំណើរការស៊ើបអង្កេតសម្ងាត់របស់តុលាការអាចនឹងមានសារសំខាន់ក៏ដោយ ក៏នៅពេលដែលព័ត៌មានត្រូវបានលេចធ្លាជាសាធារណៈហើយ នោះការបង្ហាញពីព័ត៌មានស្តីពីការដំណើរការស៊ើបអង្កេតសម្ងាត់របស់តុលាការ ឬក៏ខ្លឹមសារនៃព័ត៌មានដែលត្រូវបានដឹងឮជាសាធារណៈទាំងអស់នេះមិនអាចចាត់ទុកជាការរំលោភលើ

វិធានការរបស់តុលាការបានឡើយ ។

គោលការណ៍ដែលត្រូវបានចែងនៅក្នុងរឿងក្តីរបស់ វ៉ៃបឺ ពិតជាមានសារសំខាន់ បើយើងពិចារណាឲ្យកាន់តែច្រើនលើព័ត៌មានដែលមានផ្ទុកនៅក្នុងការស៊ើបអង្កេតសម្ងាត់របស់តុលាការ នៅឯតុលាការខ្មែរក្រហមដែលត្រូវបានដឹងឮជាសាធារណៈហើយនោះ ។ ជាឧទាហរណ៍ អត្តសញ្ញាណរបស់ ឌុច និងការជាប់ពាក់ព័ន្ធរបស់ ឌុច ជាមួយនឹងមន្ទីរស-២១ ត្រូវបានដឹងឮយ៉ាងច្បាស់ ហើយបានកត់ត្រាទុកទៀតផង ។ បន្ថែមលើនេះ តុលាការខ្មែរក្រហមមានយុត្តាធិការក្នុងការកាត់ទោសជនដែលប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងកាលពីសាមសិបឆ្នាំមុន ។ បើយើងពិចារណាពីរយៈពេលស៊ើបអង្កេតរបស់តុលាការដែលបានពន្យារពេលជាច្រើនខែ នោះការរំលោភបំពានលើគោលការណ៍សម្ងាត់ដោយអចេតនាគឺមិនសូវសំខាន់ប៉ុន្មានទេ ពីព្រោះគ្មានឥទ្ធិពលអ្វីដែលអាចប៉ះពាល់ដល់លទ្ធផលនៃដំណើរការស៊ើបអង្កេតរបស់តុលាការឡើយ ប្រសិនបើអង្គហេតុមួយចំនួនត្រូវបានលេចឮដល់សាធារណជន ។ ហើយបើយើងពិចារណាលើប្រយោជន៍របស់សាធារណជនក្នុងការទទួលបានព័ត៌មានទាក់ទងនឹងតុលាការខ្មែរក្រហម និងកាតព្វកិច្ចរបស់តុលាការក្នុងការផ្សព្វផ្សាយព័ត៌មានដល់សាធារណជន នោះការរំលោភបំពានដោយគ្មានឥទ្ធិពលលើព័ត៌មានគួរតែមិនដើរតួជាមូលដ្ឋានសម្រាប់ការដាក់ទណ្ឌកម្មតាមវិធាន៣៥ ឡើយ ។

### ៥) សេចក្តីណែនាំទៅកាន់តុលាការខ្មែរក្រហមទាក់ទងនឹងការប្រើប្រាស់ទណ្ឌកម្មលើអ្នកសារព័ត៌មាន ដែលអនុលោមទៅតាមវិធានផ្ទៃក្នុង៣៥ (១) (ក)

ដោយសារតែមូលដ្ឋានជាគោលការណ៍របស់តុលាការគឺផ្អែកលើច្បាប់ស៊ីវិលឡ តុលាការខ្មែរក្រហមគឺជាតុលាការឧក្រិដ្ឋកម្មអន្តរជាតិដ៏ខុសប្លែកមួយដែលដំណើរនីតិវិធីរបស់ខ្លួនតាមវិធាននីតិវិធី ដែលខុសប្លែកពីវិធានដែលគ្រប់គ្រងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការផ្សេងទៀត ។ ដូច្នេះ ការអនុលោមតាមវិធានរបស់ខ្លួនដែលថាការរំលោភបំពានលើដំណើរការស៊ើបអង្កេតដោយសម្ងាត់របស់តុលាការដំណើរការជាការរំលោភលើវិធានផ្ទៃក្នុង៣៥ (១) (ក) របស់តុលាការខ្មែរក្រហមមិនអើពើចំពោះលក្ខណៈខុសប្លែកនេះ និងកាតព្វកិច្ចរបស់តុលាការខ្មែរក្រហមក្នុងការផ្សព្វផ្សាយព័ត៌មានដល់សាធារណជនទាំងអស់ពីដំណាក់កាលនៃអង្គនីតិវិធីនោះទេ ។

ផ្នែក "ក" ណែនាំយ៉ាងសង្ខេបថា តុលាការខ្មែរក្រហមគួរតែបង្កើតបទដ្ឋានដ៏ច្បាស់លាស់មួយដែលធ្វើការគ្រប់គ្រងលើការផ្សព្វផ្សាយព័ត៌មាន ។ ផ្នែក "ខ" ណែនាំថា នៅក្នុងសេចក្តីព្រមានរបស់តុលាការទៅកាន់អ្នកសារព័ត៌មានដែលបានរំលោភលើគោលការណ៍សម្ងាត់នៃដំណើរការស៊ើបអង្កេតរបស់តុលាការខ្មែរក្រហមគួរតែរកឲ្យឃើញហេតុផលដែលច្បាស់លាស់ឲ្យបានគ្រប់គ្រាន់ក្នុងការព្រមានអ្នកសាព័ត៌មានដើម្បីចៀសវាងការបង្កជាឧបសគ្គក្នុងការរាយការណ៍លើបញ្ហារសើប ។ ចុងក្រោយ ផ្នែក "គ" ណែនាំថា វិធីសាស្ត្រកាត់ក្តីតាមសាច់រឿងដើម្បីវាយតម្លៃលើការប្រើប្រាស់ទណ្ឌកម្មលើអ្នកសារព័ត៌មាន ។ វាត្រូវតែជាទណ្ឌកម្មមួយដែលធ្វើការពីភ័ស្តុតាងដែលគួសបញ្ជាក់ពីការជ្រៀតជ្រែក សារសំខាន់នៃតម្រូវការសម្ងាត់ និងចេតនារបស់អ្នកសារព័ត៌មានដែលត្រូវបានចោទប្រកាន់ ។

#### ក) តុលាការខ្មែរក្រហមគួរតែបង្កើតបទដ្ឋានមួយដ៏ច្បាស់លាស់ទាក់ទងនឹងព័ត៌មានដែលត្រូវបានការពារនៅក្នុងអំឡុងដំណើរការស៊ើបអង្កេតសម្ងាត់របស់តុលាការ

នៅឯតុលាការខ្មែរក្រហម វាស្ទើរតែគ្មានភាពច្បាស់លាស់ទាល់តែសោះបើនិយាយពីព័ត៌មានណាដែលតុលាការខ្លួនឯងចាត់ទុកថាជាព័ត៌មានសម្រាប់សាធារណៈ និងព័ត៌មានណាដែលត្រូវបានការពារដោយដំណើរការស៊ើបអង្កេតសម្ងាត់របស់តុលាការ ។ សម្រាប់ប្រទេសកម្ពុជាដែលប្រជាជនមួយភាគធំគឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នោះព័ត៌មានទាំងឡាយណាដែលពាក់ព័ន្ធនឹងខ្មែរក្រហមមិនអាចលាក់បាំងបានទេ ហើយការលាក់បាំងនេះក៏មិនមែនជារឿងដែលប្រជាជនកម្ពុជាគាំទ្រដែរ ។ ដោយសារតែឧក្រិដ្ឋកម្មដែលជនជាប់ចោទទាំងអស់ត្រូវកាត់ទោសបានកើតឡើងតាំងពីសាមសិបឆ្នាំមុន នោះព័ត៌មានមួយភាគធំទាក់ទងនឹងជនជាប់ចោទត្រូវបានដឹងឮជាសាធារណៈរួចហើយ ។ ដូច្នេះ ដើម្បីធ្វើយ៉ាងណាឲ្យសាធារណជនបានដឹងពីដំណើរការកាត់ទោសរបស់ជនជាប់ចោទដែលជាកាតព្វកិច្ចរបស់តុលាការក្នុងការដើរតួជាមធ្យោបាយមួយសម្រាប់ការផ្សះផ្សាជាតិ និងធ្វើ

ជាគំរូដល់តុលាការកម្ពុជា នោះតុលាការខ្មែរក្រហមគួរតែដំណើរការទៅដោយអនុវត្តតាមបទដ្ឋានច្បាស់លាស់ដែលគ្រប់គ្រងលើកិច្ចការផ្សព្វផ្សាយព័ត៌មានទៅកាន់មជ្ឈដ្ឋានសាធារណៈ ។

ការខ្វះខាតនូវបទដ្ឋានស្តីពីព័ត៌មានដែលត្រូវបានការពារនឹងបន្តឲ្យជាឧបសគ្គដល់ការរាយការណ៍ពីបញ្ហារសើបនៅតុលាការខ្មែរក្រហម ។ ឧបសគ្គនេះនឹងបន្តរារាំងដល់ការទទួលបានព័ត៌មានរបស់សាធារណជន ហើយវានឹងប៉ះពាល់ដល់ការទទួលស្គាល់ពីសេរីភាពសារព័ត៌មាន ។ ដូចដែលបានឃើញនៅក្នុងរឿងក្តីរបស់ហាម៉ាន់ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានសម្រេចថា ហាម៉ាន់ គួរតែបានទទួលការទទួលស្គាល់លើព័ត៌មាននៅក្នុងសៀវភៅរបស់គាត់ពីតុលាការមុនពេលដែលបោះពុម្ពសៀវភៅនោះ ។ ប៉ុន្តែ ការដែលទាមទារឲ្យអ្នកសារព័ត៌មានរបស់តុលាការខ្មែរក្រហមទទួលបានការទទួលស្គាល់លើព័ត៌មានរបស់ខ្លួនពីតុលាការមុនពេលបោះផ្សាយ នោះគឺជារឿងមួយដែលមិនសមហេតុផល ហើយក៏មិនបម្រើឲ្យប្រយោជន៍សាធារណជនដែរ ។ ការទាមទារបែបនេះអាចនឹងជំរុញឲ្យសាធារណជនមានការសង្ស័យថាមានការជ្រៀតជ្រែកផ្នែកនយោបាយ ហើយអាចនឹងបន្តបង្កផលប៉ះពាល់ដល់ជោគជ័យរបស់តុលាការតាមរយៈឱកាសប្រព្រឹត្តអំពើពុករលួយ ឬភាពលម្អៀង ។

បន្ថែមលើសពីនេះ បទដ្ឋានច្បាស់លាស់ដែលធ្វើការបែងចែករវាងព័ត៌មានសម្ងាត់ និងព័ត៌មានសាធារណៈមិនត្រឹមតែជំរុញឲ្យសារព័ត៌មានធ្វើការរាយការណ៍ពីដំណើរអង្គនីតិវិធីរបស់តុលាការខ្មែរក្រហម ខណៈពេលដែលព្យាយាមធានាឲ្យបាននូវការការពារភាពចាំបាច់នូវការសម្ងាត់តែប៉ុណ្ណោះទេ តែវាថែមទាំងផ្តល់ជាឧទាហរណ៍ដ៏វិជ្ជមានមួយសម្រាប់តុលាការក្នុងស្រុករបស់កម្ពុជា ។ ដូច្នេះ ការអនុវត្តគោលការណ៍ផ្សព្វផ្សាយព័ត៌មានបច្ចុប្បន្នដែលឈរលើមូលដ្ឋានដែលខ្វះខាតនូវភាពស៊ីសង្វាក់គ្នា ឬសេចក្តីសម្រេចដ៏សមហេតុផលមួយ នោះអាចបង្កឲ្យមានបញ្ហាអំពើពុករលួយ និងការលាក់បាំងកាន់តែខ្លាំងឡើងនៅក្នុងប្រព័ន្ធតុលាការក្នុងស្រុករបស់កម្ពុជា ។

ដោយសារតែគ្មានបទដ្ឋានច្បាស់លាស់នៅឯតុលាការខ្មែរក្រហមនេះហើយ ដែលតុលាការក្នុងស្រុកកម្ពុជាមិនមានឆន្ទៈក្នុងការបំពេញកិច្ចការរបស់ខ្លួនឲ្យមានតម្លាភាពកាន់តែប្រសើរឡើង ។ ដោយសារតែការខ្វះខាតនូវតម្លាភាពទាំងនៅតុលាការខ្មែរក្រហម និងតុលាការក្នុងស្រុក សាធារណជននឹងគ្មានភាពជឿជាក់លើប្រព័ន្ធកម្ពុជាឡើយ ហើយកេរដំណែលដែលតុលាការខ្មែរក្រហមសង្ឃឹមថា សម្រេចបានអាចនឹងរងការប៉ះទង្គិច ។

**១) តុលាការខ្មែរក្រហមគួរតែចេញដីកាព្រមានឲ្យបានច្បាស់ នៅពេលដែលការសម្ងាត់នៃដំណើរការស៊ើបអង្កេតរបស់តុលាការត្រូវបានរំលោភបំពាន**

ដោយសារតែតុលាការខ្មែរក្រហមសន្មតថា ព័ត៌មាននៅក្នុងអំឡុងពេលស៊ើបអង្កេតមុនអង្គជំនុំជម្រះក្តីចាប់ផ្តើមគឺជាការសម្ងាត់ នោះវាពិតជាចាំបាច់ដែលថាតុលាការខ្មែរក្រហមចេញការព្រមាន ឬដីកាមុននឹងសម្រេចដាក់ទណ្ឌកម្មលើអ្នកសារព័ត៌មាន ។ ខ្លឹមសារធម្មតារបស់មាត្រា៣៥(១)(ក) តម្រូវថា ដើម្បីរកឃើញការជ្រៀតជ្រែកនឹងការគ្រប់គ្រងលើវិស័យយុត្តិធម៌ នោះជនម្នាក់ត្រូវតែបានផ្សព្វផ្សាយ «ព័ត៌មានសម្ងាត់ដែលរំលោភបំពានលើដីការបស់សហចៅក្រមស៊ើបអង្កេត ឬចៅក្រមអង្គជំនុំជម្រះ» ។

បើទោះបីជាតុលាការខ្មែរក្រហមចេញការព្រមានទៅកាន់អ្នកសារព័ត៌មានដោយគ្រាន់តែថែងថាអត្ថបទណាដែលបានរំលោភបំពានលើការស៊ើបអង្កេតសម្ងាត់របស់តុលាការក៏ដោយ ក៏ដីកាបែបនេះនឹងមិនអាចពន្យល់បកស្រាយអ្វីបន្ថែមឲ្យបានច្បាស់លាស់នោះទេ ។ ការព្រមាននេះមិនបានបង្ហាញឲ្យឃើញថាតើព័ត៌មានណាដែលជាព័ត៌មានបង្កឲ្យមានការរំលោភបំពាន ឬបញ្ជាក់ពីមូលហេតុថាតើហេតុអ្វីបានជាការផ្សព្វផ្សាយព័ត៌មាននោះត្រូវបានហាមឃាត់នោះទេ ។ លទ្ធផលនៃបញ្ហានេះគឺថាអ្នកសារព័ត៌មានត្រូវបានបង្ខំឲ្យធ្វើការសម្រេចចិត្តដ៏លំបាកដែលត្រូវតែធ្វើឲ្យមានតុល្យភាពរវាងកាតព្វកិច្ចវិជ្ជាជីវៈរបស់ខ្លួនក្នុងការផ្សព្វផ្សាយព័ត៌មានដល់សាធារណជន និងភាពភ័យខ្លាចដែលថាខ្លួនអាចនឹងត្រូវបានដាក់ទណ្ឌកម្មដោយតុលាការខ្មែរក្រហម ។ ដូច្នេះ អ្នកសារព័ត៌មានមិនជឿលើការរាយការណ៍ពីបញ្ហាសំខាន់ៗ នៅឯតុលាការខ្មែរក្រហមទេ ដែលនេះគឺជាបញ្ហាមួយដែលរារាំងមិនឲ្យតុលាការសម្រេចគោលដៅរបស់ខ្លួនគឺ «ដើម្បីការផ្សះផ្សាជាតិ» និងដើរតួនាទីជាគំរូដល់ប្រព័ន្ធច្បាប់ក្នុងស្រុករបស់កម្ពុជា ។ ដូច្នេះ

តុលាការខ្មែរក្រហមគួរតែផ្សព្វផ្សាយព័ត៌មានដែលបណ្តាលឲ្យមានការរំលោភបំពានលើដំណើរការស៊ើបអង្កេតដើម្បីធានាព័ត៌មានសើបត្រូវបានការពារ ប៉ុន្តែព័ត៌មាននោះគួរតែអនុញ្ញាតឲ្យសាធារណជនបានដឹងឮឲ្យបានច្រើនតាមតែអាចធ្វើបាន ។

### គ) តុលាការខ្មែរក្រហមគួរតែចូលរួមនៅក្នុងការស៊ើបអង្កេតតាមសាច់រឿងដើម្បីកំណត់ថាតើការជ្រៀតជ្រែកនឹងការគ្រប់គ្រងលើវិស័យយុត្តិធម៌ពិតជាបានកើតមានឡើងឬយ៉ាងណា

បទដ្ឋានស្តីពីឯកសារសម្ងាត់ដែលមានលក្ខណៈមិនច្បាស់លាស់ រួមជាមួយនឹងកាតព្វកិច្ចធំធេងពេកនៃគោលការណ៍សម្ងាត់ដែលមានចែងនៅក្នុងបទបញ្ជាអនុវត្តរបស់តុលាការ និងភាពជាប់ពាក់ព័ន្ធដ៏ទូលាយនៃការដាក់ទណ្ឌកម្មតាមវិធានផ្ទៃក្នុង៣៥ជំរុញឲ្យតុលាការខ្មែរក្រហមចេញសេចក្តីសម្រេចមួយ ដែលខុសពីសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលការរំលោភបំពានលើដីកាការពាររបស់ "តុលាការ" មានលក្ខណៈស្មើគ្នានឹងការជ្រៀតជ្រែកនឹងការគ្រប់គ្រងលើវិស័យយុត្តិធម៌ ។ ដាំងនេះ ការសន្មតយកដំណើរការស៊ើបអង្កេតសម្ងាត់របស់តុលាការ និងការខ្វះខាតនូវដីកាការពារការបញ្ចេញមតិធ្វើការគាំទ្រការពិនិត្យពិច័យដោយតុល្យភាពតាមសាច់រឿងស្តីពីចេតនារបស់រដ្ឋាភិបាល និងការជ្រៀតជ្រែកលើសេរីភាពក្នុងការបញ្ចេញមតិ ។ ការវិភាគនីមួយៗ គួរតែពិចារណាកត្តាបីយ៉ាងគឺ ៖ ព័ត៌មានទាក់ទងនឹងការជ្រៀតជ្រែក ភាពត្រឹមត្រូវតាមច្បាប់នៃភាពចាំបាច់នៃការសម្ងាត់ និងចេតនារបស់អ្នកសារព័ត៌មាន ។

#### គ.១) ការជ្រៀតជ្រែកលើព័ត៌មាន

ដំបូង ក្នុងវិធីសាស្ត្រពិនិត្យតាមសាច់រឿងតុលាការខ្មែរក្រហមគួរតែតម្រូវឲ្យមានការជ្រៀតជ្រែកលើព័ត៌មាននឹងការគ្រប់គ្រងលើវិស័យយុត្តិធម៌មុននឹងចេញដីកាដាក់ទណ្ឌកម្មដែលអនុលោមតាមវិធាន៣៥ ។ បើទោះបីជាការឃ្លាតចាកពីការអនុវត្តតាមយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី អាចនឹងត្រូវបានកើតមានឡើងដោយសារតែតុលាការចេញ ដីកាការពារដ៏ត្រឹមត្រូវក៏ដោយ ក៏តុលាការខ្មែរក្រហមប្រតិបត្តិដំណើរការនីតិវិធីតាមបទដ្ឋានខុសប្លែកគ្នា ។ ដោយសារតែហេតុផលដែលថាព័ត៌មានទាំងអស់ត្រូវតែរក្សាការសម្ងាត់ នោះព័ត៌មានមួយភាគធំត្រូវបានដឹងឮជាសាធារណៈ ។ ដោយសារតែភាពមិនច្បាស់លាស់ថាព័ត៌មានណាជាព័ត៌មានសាធារណៈ នោះតុលាការខ្មែរក្រហមគួរតែជំរុញឲ្យសាធារណជនទទួលបានព័ត៌មានដោយធ្វើការបន្ធូរបន្ថយការរឹតត្បិតលើសេរីភាពរបស់អ្នកសារព័ត៌មាន ។ ដោយសារតែមានភាពមិនច្បាស់លាស់ថាព័ត៌មានណា ជាព័ត៌មានដែលត្រូវបានការពារ នោះព័ត៌មានដែលមិនអាចជាព័ត៌មានដែលរំលោភបំពានលើដីការបស់តុលាការមិនមានភាពយុត្តិធម៌ឡើយសម្រាប់អ្នកសារព័ត៌មានដែលដើរតួនាទីជាអ្នកឃ្លាំមើលដំណើរការលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសដែលយាយីដោយអំពើពុករលួយ ។ ការអនុវត្តការដាក់ទណ្ឌកម្មដោយគ្មានការអះអាងថាមានការជ្រៀតជ្រែកផ្នែកព័ត៌មានគ្រាន់តែជំរុញឲ្យមានការការពារលើដំណើរការស៊ើបអង្កេតសម្ងាត់របស់តុលាការដោយខ្វះខាតនូវហេតុផលនៃកត្តាជំរុញនេះតែប៉ុណ្ណោះ ហើយនឹងបង្កផលប៉ះពាល់ដល់ទស្សនៈរបស់មជ្ឈដ្ឋានសាធារណៈមកលើតុលាការខ្មែរក្រហម ។

#### គ.២) ភាពត្រឹមត្រូវតាមច្បាប់នៃបទបញ្ញត្តិស្តីពីការសម្ងាត់

តុលាការខ្មែរក្រហមគួរតែពិចារណាឲ្យប្រុងប្រយ័ត្នពីលក្ខណៈនៃព័ត៌មានដែលធានាឲ្យបាននូវការការពារ មុននឹងសម្រេចថាគួររំលោភលើសេរីភាពក្នុងការបញ្ចេញមតិឬយ៉ាងណា ពីព្រោះថាការផ្សះផ្សាមិនអាចសម្រេចបានទេប្រសិនបើគ្មានការស្វែងរកការពិត ។ សាធារណជនមានចំណាប់អារម្មណ៍ខ្លាំងលើដំណើរការនីតិវិធីរបស់តុលាការខ្មែរក្រហម ដូច្នេះ តុលាការខ្មែរក្រហមគួរតែតម្រូវថា គោលដៅសម្រេចឲ្យបាននូវភាពត្រឹមត្រូវតាមច្បាប់មានប្រៀបជាងចំណាប់អារម្មណ៍របស់សាធារណជនក្នុងការទទួលបានព័ត៌មានមុននឹងរំលោភលើសេរីភាពក្នុងការបញ្ចេញមតិរបស់អ្នកសារព័ត៌មាន ។

ការទាមទារឲ្យបាននូវមូលហេតុដែលត្រឹមត្រូវតាមច្បាប់សម្រាប់បទបញ្ញត្តិស្តីពីការសម្ងាត់គឺពិតជាមានសារសំខាន់ដើម្បីធានាថាសាធារណជនទទួលបានព័ត៌មានគ្រប់គ្រាន់ ហើយតុលាការនឹងទទួលបានការគោរព និងគាំទ្រដែលលទ្ធផលនេះនឹងមិនប៉ះពាល់

ដល់ការយល់ឃើញរបស់សាធារណជនលើប្រព័ន្ធតុលាការ ។ កាលពីខែកញ្ញា ឆ្នាំ២០១០ ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានកត់សម្គាល់ថា ប្រទេសកម្ពុជា "ពុំសូវជាមាន ...គុណភាពសមរម្យមួយរវាងការការពារកិត្តិយសឯកជន និងការផ្តល់ព័ត៌មានដល់សាធារណៈទាក់ទងនឹងប្រយោជន៍របស់សាធារណៈ ។ រដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថា "ប្រព័ន្ធតុលាការមិនទាន់ទទួលបានការជឿទុកចិត្តពីមជ្ឈដ្ឋានសាធារណៈពេញលេញនៅឡើយទេ" ហើយប្រជាជនកម្ពុជាបានស្វែងរកមធ្យោបាយផ្សេងៗដើម្បីទទួលបានយុត្តិធម៌ ។ ការអនុម័តការពិនិត្យពិច័យឲ្យមានតុល្យភាពដែលធ្វើការពិចារណាលើភាពត្រឹមត្រូវនៃប្រយោជន៍នៃការការពារនឹងផ្តល់ជាឧទាហរណ៍ដ៏ល្អមួយដល់តុលាការកម្ពុជាថា ការដាក់ទណ្ឌកម្មសម្រាប់ការរំលោភបំពានលើគោលការណ៍សម្ងាត់អាចនឹងអនុវត្តទៅបាន លុះត្រាតែភាពចាំបាច់នៃការសម្ងាត់ដែលត្រឹមត្រូវតាមផ្លូវច្បាប់កើតមានឡើង ។ ដោយសារតែការខ្វះខាតនូវការជឿទុកចិត្តរបស់សាធារណៈមកលើតុលាការ ប្រជាជនកម្ពុជានឹងមិនជឿលើប្រព័ន្ធតុលាការក្នុងស្រុករបស់កម្ពុជាដដែល ។ ដូច្នេះ តុលាការខ្មែរក្រហមនឹង មិនអាចសម្រេចគោលដៅរបស់ខ្លួនក្នុងការផ្តល់ជាកេរដំណែលមួយស្តីពីលទ្ធិប្រជាធិបតេយ្យនោះទេ ។

### គ.៣) ចេតនារបស់អ្នកសារព័ត៌មាន

តុលាការខ្មែរក្រហមគួរតែដាក់ទណ្ឌកម្មលើអ្នកសារព័ត៌មានណាដែលប្រព្រឹត្តសកម្មភាពដោយមានចេតនាជ្រៀតជ្រែកនឹងការគ្រប់គ្រងលើវិស័យយុត្តិធម៌ ហើយការការពារក្តីដោយផ្អែកលើកំហុស អង្គហេតុគួរតែអាចធ្វើបានសម្រាប់អ្នកសារព័ត៌មានដែលផ្សព្វផ្សាយព័ត៌មានសម្ងាត់ដោយអចេតនា ។ ដោយសារតែការខ្វះខាតនូវបទដ្ឋានច្បាស់លាស់ទាក់ទងនឹងការផ្សព្វផ្សាយព័ត៌មាន កាតព្វកិច្ចទូលំទូលាយនៃគោលការណ៍ការសម្ងាត់ និងលក្ខណៈនៃព្រឹត្តិការណ៍ជាច្រើនដែលមានជាប់ពាក់ព័ន្ធនឹងការស៊ើបអង្កេតការកាត់ទោសឲ្យអ្នកសារព័ត៌មានមានការទទួលខុសត្រូវសម្រាប់ការផ្សព្វផ្សាយព័ត៌មានដែលត្រូវបានការពារដោយអចេតនាមិនត្រឹមតែអយុត្តិធម៌សម្រាប់អ្នកសារព័ត៌មានតែប៉ុណ្ណោះទេ វាថែមទាំងបន្តបង្កជាឧបសគ្គក្នុងការរាយការណ៍ព័ត៌មានសេរី ។

ខុសពីរឿងក្តីរបស់ ហាម៉ាន់ ដែលតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានបដិសេធលក្ខន្តិកៈទាមទាររកចេតនាជាក់លាក់របស់ជនជាប់ចោទក្នុងការជ្រៀតជ្រែកនឹងការគ្រប់គ្រងលើវិស័យយុត្តិធម៌ និងមិនបានទទួលស្គាល់ការការពារក្តីរបស់ ហាម៉ាន់ ដោយផ្អែកលើកំហុសអង្គហេតុ សេចក្តីសម្រេចរបស់តុលាការខ្មែរក្រហមគឺពិតជាខុសប្លែកពីសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ ដំបូងនៅក្នុងរឿងក្តីភាគច្រើនរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីត យូហ្គោស្លាវី បុគ្គលជាច្រើនត្រូវបានព្រមានថាអ្នកទាំងអស់នេះបានទទួលបានព័ត៌មានសម្ងាត់យ៉ាងច្រើន ពីព្រោះដីកាការពារដាច់ខាតរបស់តុលាការត្រូវបានអនុម័តតាមវិធាន៦៩ និង៥៣ ។ ដោយសារតែព័ត៌មានមួយភាគធំត្រូវបានដឹងឮជាសាធារណៈ ហើយដោយសារតែការខ្វះខាតនូវដីកាការពារដាច់ខាត នោះតុលាការខ្មែរក្រហមគួរតែទាមទារឲ្យបាននូវការបង្ហាញឲ្យឃើញពីចេតនាជាក់លាក់បំផុតជាងកម្រិតចេតនាដែលតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានទាមទារដើម្បីធានាថាទណ្ឌកម្មត្រូវបានអនុវត្តលើជនដែលជ្រៀតជ្រែកនឹងការគ្រប់គ្រងវិស័យយុត្តិធម៌ដោយចេតនា ។

### ៦) សេចក្តីសន្និដ្ឋាន

នៅតុលាការកូនកាត់ដំបូងគេបង្អស់ដែលអង្គការសហប្រជាជាតិគាំទ្រ ដែលអនុវត្តទាំងស្រុងតាមច្បាប់ក្នុងស្រុកនោះ តុលាការខ្មែរក្រហមត្រូវតែប្រកាន់ខ្ជាប់នូវតុល្យភាពដើម្បីដឹកនាំសហគមន៍អន្តរជាតិ ដោយដើរតួនាទីជាគំរូដល់យុត្តិធម៌ និងការផ្សះផ្សា ។ ដើម្បីដើរតួជាគំរូដល់តុលាការកម្ពុជា និងជាយានសម្រាប់ការផ្សះផ្សាជាតិនោះ តុលាការខ្មែរក្រហមមានសក្តានុពលភាពក្នុងការជួយលុបបំបាត់អំពើពុករលួយនៅក្នុងប្រទេសកម្ពុជា ហើយនឹងជួយចែករំលែកជាវិភាគទានសម្រាប់ការអភិវឌ្ឍន៍ប្រព័ន្ធតុលាការត្រឹមត្រូវនឹងយុត្តិធម៌ ។

ប៉ុន្តែ ដើម្បីសម្រេចគោលដៅ និងគោលនយោបាយរបស់ខ្លួនក្នុងការធ្វើឲ្យមានដំណើរការនីតិវិធីដ៏មានតម្លាភាពនោះ តុលាការខ្មែរក្រហមត្រូវតែផ្តល់សារព័ត៌មាននូវព័ត៌មានប្រចាំថ្ងៃ

របស់តុលាការ ។ ការមិនស៊ីសង្វាក់គ្នានៃការផ្សព្វផ្សាយព័ត៌មានអាចនឹងប៉ះពាល់ដល់ភាពត្រឹមត្រូវតាមច្បាប់របស់តុលាការ និងបង្កការខូចខាតដល់ប្រព័ន្ធច្បាប់ក្នុងស្រុករបស់កម្ពុជា ។

បើទោះបីជាការសន្មតនៃការស៊ើបអង្កេតសម្ងាត់របស់តុលាការមានភាពស៊ីសង្វាក់គ្នានឹងតុលាការផ្សេងទៀតដែលដើរតាមច្បាប់ស៊ីវិលឡូក៏ដោយ ក៏គោលការណ៍នេះមិនត្រូវបានរំលោភបំពានដាច់ខាត ។ នៅក្នុងអំឡុងដំណើរការស៊ើបអង្កេតដែលពន្យារពេលជាច្រើនខែ ហើយផ្ទុកទៅដោយព័ត៌មានដែលបានដឹងឮដោយមជ្ឈដ្ឋានសាធារណៈហើយនោះ ពលរដ្ឋកម្ពុជាមិនគួរដកហូតសិទ្ធិក្នុងការទទួលបានព័ត៌មានសំខាន់ទេ ហើយអ្នកសារព័ត៌មានក៏មិនគួរត្រូវបានបង្ខំឲ្យពិនិត្យថាព័ត៌មានណាដែលត្រូវបានការពារឬមិនការពារឡើយ ។ ដាងនេះ តុលាការខ្មែរក្រហមគួរតែដំណើរទៅតាមបទដ្ឋានច្បាស់លាស់ ដែលគ្រប់គ្រងលើការផ្សព្វផ្សាយព័ត៌មានដើម្បីកាត់បន្ថយចំនួននៃការផ្សព្វផ្សាយព័ត៌មានដោយអចេតនា ។ ប្រសិនបើព័ត៌មានសម្ងាត់ត្រូវបានផ្សព្វផ្សាយ នោះតុលាការខ្មែរក្រហមគួរតែចេញការព្រមានឲ្យបានច្បាស់លាស់ ។ យ៉ាងណាមិញ ការព្រមាននោះមិនគួរចុះផ្សាយប្រភពដែលទម្លាយព័ត៌មានសម្ងាត់ ។ ផ្ទុយទៅវិញ តុលាការខ្មែរក្រហមគួរតែប្រឹងប្រែងដើម្បីចាត់វិធានការស្តីពីការសម្ងាត់នេះឲ្យតូចជាងនេះ ដើម្បីផ្តល់ព័ត៌មានទៅកាន់មជ្ឈដ្ឋានសាធារណៈឲ្យបានច្រើន ។ បទដ្ឋានច្បាស់លាស់ អមជាមួយនឹងការព្រមានដាក់លាក់ស្តីពីការរំលោភបំពានលើគោលការណ៍សម្ងាត់នឹងជួយកាត់បន្ថយការប្រើប្រាស់ទណ្ឌកម្មដែលអនុលោមតាមវិធាន៣៥ ។ ប៉ុន្តែ ប្រសិនបើឱកាសក្នុងការដាក់ទណ្ឌកម្មគួរតែកើតមានឡើង នោះតុលាការខ្មែរក្រហមគួរតែអនុម័តធ្វើការពិនិត្យរឿងក្តីតាមករណីនីមួយៗសម្រាប់អង្គនីតិវិធីស្តីពីបទប្រមាថមើលងាយដែលជាយុត្តិសាស្ត្រមួយខុសប្លែកពីយុត្តិសាស្ត្រថ្មីៗដែលតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានអនុវត្តនៅក្នុងរឿងក្តីរបស់ ហាម៉ាន់ ។

បើទោះបីជាតុលាការព្រហ្មទណ្ឌសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានដើរតួជាគំរូដ៏ល្អមួយសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិជាច្រើនក៏ដោយ ក៏យុត្តិសាស្ត្រថ្មីៗនេះរបស់តុលាការស្តីពីបទឧក្រិដ្ឋរបស់អ្នកសារព័ត៌មាន និងបទប្រមាថមើលងាយគឺកំពុងតែមានបញ្ហា ។ បទបញ្ញត្តិដែលទើបតែបង្កើតឡើងនាពេលថ្មីៗនេះនៅក្នុងរឿងក្តីរបស់ ហាម៉ាន់ បង្កផលប៉ះពាល់ដល់សេរីភាពក្នុងការបញ្ចេញមតិយោបល់ ដោយតុលាការបែរជាធ្វើការការពារលើបទបញ្ញត្តិស្តីពីការសម្ងាត់ ហើយបែរជាមិនទទួលស្គាល់ភាពចាំបាច់ក្នុងការបង្ហាញឲ្យឃើញពីការជ្រៀតជ្រែកផ្នែកព័ត៌មាន និងការបង្ហាញឲ្យឃើញពីចេតនាជាក់ស្តែងរបស់ជនជាប់ចោទ ។ ប្រសិនបើតុលាការខ្មែរក្រហមអនុវត្តតាមបទបញ្ញត្តិនេះដោយសារតែការខ្វះខាតនូវដីកាការពារសិទ្ធិបញ្ចេញមតិយោបល់ ហើយដោយសារតែបទបញ្ញត្តិស្តីពីការសម្ងាត់ដ៏ធំត្រូវតែគោរពទៅតាមកាតព្វកិច្ចក្នុងការលាក់ការសម្ងាត់ នោះបទដ្ឋាននៃបទបញ្ញត្តិបែបនេះអាចនឹងបង្កផលប៉ះពាល់ដល់ជោគជ័យរបស់តុលាការការផ្សះផ្សាជាតិ ហើយប៉ះពាល់ដល់ភាពត្រឹមត្រូវតាមច្បាប់របស់តុលាការនៅក្នុងក្រសែភ្នែករបស់សាធារណជន ។

ការពិនិត្យពិច័យដោយតុល្យភាពដែលបង្កើតឡើងដោយតុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលទាមទារឲ្យមានការបង្ហាញពីប្រយោជន៍ដែលត្រឹមត្រូវតាមច្បាប់ក្នុងការគោរពតាមគោលការណ៍សម្ងាត់ដែលរកឃើញថា វាពិតជាប្រយោជន៍ដ៏សំខាន់ក្នុងការរកឃើញការរំលោភលើសេរីភាពក្នុងការបញ្ចេញមតិយោបល់ ហើយថាការជ្រៀតជ្រែកគឺជាលក្ខណៈសមរម្យ នៅពេលពិចារណាពីផលប្រយោជន៍របស់សាធារណជន បានផ្តល់ជាបទដ្ឋានសមរម្យមួយដើម្បីណែនាំលើការវិវត្តនៃច្បាប់ករណីរបស់តុលាការខ្មែរក្រហម ។ តាមរយៈការអនុវត្តតាមវិធីសាស្ត្រពិនិត្យតាមករណីនីមួយៗ តុលាការអាចធានាថាអ្នកសារព័ត៌មានមិនត្រូវបានរារាំងមិនឲ្យអនុវត្តតួនាទីដ៏សំខាន់របស់អ្នកសារព័ត៌មានពេក ។ ប្រសិនបើសេចក្តីណែនាំទាំងអស់នេះត្រូវបានអនុលោមតាមនោះ តុលាការខ្មែរក្រហមអាចនឹងបន្តជួយសម្របសម្រួលដល់ការផ្សះផ្សាជាតិ និងធានាថាតុលាការអាចដើរតួជាគំរូសម្រាប់ប្រព័ន្ធច្បាប់កម្ពុជាដោយអនុវត្តឲ្យមានអង្គនីតិវិធីដ៏តម្លាភាពដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់នៅក្នុងក្រសែភ្នែកប្រជាជានកម្ពុជាដែលតុលាការខ្មែរក្រហមត្រូវបានបង្កើតឡើងដើម្បីអ្នកទាំងអស់នោះ ។

**គ្រីស្កា ណោលសាន់**

# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org គឺជា «ប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា»ទាំងមូល ។ រយៈពេលជាងប្រាំពីរឆ្នាំកន្លងមកនេះ ព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការទាំងមូលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សំណុំរឿងព្រហ្មទណ្ឌលេខ០០១ ទាក់ទិននឹងការវិនិច្ឆ័យសេចក្តីលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនិងនៅក្រោមបទបញ្ជារបស់អតីតប្រធានមន្ទីរស-២១ ឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច បានឈានដល់ដំណាក់កាលបញ្ចប់សវនាការជាស្ថាពរដោយ ឌុចត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតកាលពីខែកុម្ភៈកន្លងទៅ ។

លើសពីនេះទៅទៀត សំណុំរឿងព្រហ្មទណ្ឌលេខ០០២ ដែលទាក់ទិននឹងជនជាប់ចោទបីនាក់ទៀតគឺ ខៀវ សំផន (គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ) នួន ជា (អនុលេខាបក្ស និងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យ) និង អៀង សារី (ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ) បានចាប់ផ្តើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២០១១ ។

ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបានតាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតដោយមានផ្នែកជាច្រើន ទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ (BLOG) វីដេអូសវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងទៅនិងសវនាការ (MULTIMEDIA) សារព័ត៌មានផ្សេងៗជុំវិញតុលាការ (NEWS) របាយការណ៍របស់តុលាការនិងអង្គការក្រៅរដ្ឋាភិបាល (ECCC & NGO REPORTS) ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ


លោក វ៉ាន់ថាន់ ពៅដារ៉ា ឡើងធ្វើបទបង្ហាញអំពីគេហទំព័រឃ្លាំមើលតុលាការខ្មែរក្រហមដល់និស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម

(*TRIAL PROCEEDINGS*) ប្រវត្តិសាស្ត្រ (*HISTORY*) ប្រវត្តិរបស់តុលាការនេះ (*TRIBUNAL BACKGROUND*) និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ (*COMMENTARY*) ។

គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិនិងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញនិងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី «សហកម្មឧក្រិដ្ឋកម្មរួម» ដែលភាសាអង់គ្លេសហៅថា «*Join Criminal Enterprise*» ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម «ផែនការឧក្រិដ្ឋរួម» ដែលភាសាអង់គ្លេសហៅថា «*Common Criminal Plan*» ។ ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ (*TRIAL PROCEEDINGS*) ឬបទអត្ថាធិប្បាយរបស់អ្នកជំនាញ (*COMMENTARY*) ដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអ.វ.ត.ក? តើមានភាគីផ្សេងទៀតដែរឬទេដែលមានយោបល់ទៅលើបញ្ហានេះ?

ឧទាហរណ៍មួយទៀត ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ (BLOG) ។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។

គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានការត្រួតពិនិត្យដោយលោកសាស្ត្រាចារ្យច្បាប់ ដេវីដ ស្សេហ្វើ (*David Scheffer*) អ្នកជំនាញពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានកិច្ចសហប្រតិបត្តិការជាមួយ *Illinois Holocaust Museum and Education Center* ជំនួយឧបត្ថម្ភពីសំណាក់ *B.J. and M.K. Pritzker Family Foundation* និង *Northwestern University School of Law's Center for International Human Rights* ។

**ឌ៉ាន់ថាន់ ពៅដារ៉ា**




**ក្រុមការងារគម្រោងឃ្លាំមើលតុលាការខ្មែរក្រហមថតរូបជាមួយនិស្សិត និងគ្រូបង្រៀននៅសាកលវិទ្យាល័យបាត់ដំបង**

# វិសាលភាពនៃកាតព្វកិច្ចស៊ើបអង្កេតរបស់ សហចៅក្រមស៊ើបអង្កេត

កាលពីឆ្នាំមុន សហចៅក្រមស៊ើបអង្កេតរបស់តុលាការខ្មែរក្រហមបានប្រកាសថាខ្លួនអាចនឹងបញ្ចប់ការស៊ើបអង្កេតលើសំណុំរឿង០០៣ បើទោះបីជាសហចៅក្រមស៊ើបអង្កេតមិនទាន់បានសម្ភាសន៍សាក្សីណាម្នាក់ ចុះទៅពិនិត្យទីតាំងឧក្រិដ្ឋកម្ម ឬជម្រាបជនជាប់ចោទណាម្នាក់ថាអ្នកទាំងនោះកំពុងតែត្រូវបានស៊ើបអង្កេតក៏ដោយ ។ ដោយសារតែរដ្ឋាភិបាលកម្ពុជាប្រឆាំងដាច់ខាតនឹងដំណើរការរបស់តុលាការលើរឿងក្តី០០៣ សេចក្តីសម្រេចបញ្ចប់ការស៊ើបអង្កេតលើសំណុំរឿងនេះបានបង្កឲ្យមានប្រតិកម្មប្រឆាំងភ្លាមៗដែលបណ្តាលឲ្យតុលាការប្រឈមមុខនឹងភាពចម្រូងចម្រាស់ ការចោទប្រកាន់គ្នាទៅវិញទៅមក និងភាពរញ៉េរញ៉ៃ ។ ដូច្នេះ មានមតិខ្លះបានសន្និដ្ឋានថា បញ្ហាទាំងអស់នេះអាចនឹងបង្កឲ្យមាន "ជម្លោះដែលមិនអាចនឹងដោះស្រាយបាន" ។

ប្រតិកម្មរបស់សាធារណជនទៅលើការស៊ើបអង្កេតលើសំណុំរឿង០០៣ឆ្លុះបញ្ចាំងឲ្យឃើញពីសារសំខាន់នៃការគូសបញ្ជាក់ពីវិសាលភាពនៃកាតព្វកិច្ចស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ។ ហើយកាតព្វកិច្ចនេះមានសារសំខាន់ក្នុងការធានាឲ្យបាននូវភាពប្រត្យក្សនៃច្បាប់នៅក្នុងអង្គនីតិវិធីនៅចំពោះមុខតុលាការដែលធ្វើឲ្យសាធារណជនជឿជាក់លើឯករាជ្យភាព និងភាពមិនលំអៀងរបស់តុលាការ និងផ្តល់ជាសេចក្តីរំពឹងទុកដល់ពិភពលោកថាតុលាការខ្មែរក្រហមនឹងនាំមកនូវយុត្តិធម៌ និងការផ្សះផ្សាជាតិឲ្យប្រទេសកម្ពុជា ។

ដោយសារតែសហព្រះរាជអាជ្ញាអន្តរជាតិមានបំណងប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបញ្ចប់ដំណើរការស៊ើបអង្កេតក្នុងករណីដែលគ្មានវិធានការស៊ើបអង្កេតបន្ថែមទៀតត្រូវបានធ្វើឡើង នោះភារកិច្ចនេះនឹងធ្លាក់ទៅលើអង្គបុរេជំនុំជម្រះក្នុងការសម្រេចថាតើសហ



ព្រលានយន្តហោះខេត្តកំពង់ឆ្នាំងដែលបានកសាងឡើងនៅក្នុងសម័យខ្មែរក្រហមជាទីតាំងស៊ើបអង្កេតមួយក្នុងករណី០០៣

ចៅក្រមស៊ើបអង្កេតបានបំពេញកាតព្វកិច្ចស៊ើបអង្កេតរបស់ខ្លួនបានគ្រប់ជ្រុងជ្រោយហើយ ឬនៅ ។ ក្នុងការចេញសេចក្តីសម្រេចលើបញ្ហានេះ វាពិតជាសំខាន់ដែលថាអង្គបុរេជំនុំជម្រះចែងពីបទដ្ឋានស៊ើបអង្កេតមួយដែលស៊ីសង្វាក់គ្នាទៅនឹងសំណុំឯកសារស្នើសុំធ្វើជាសហចៅក្រមស៊ើបអង្កេតដែលតម្រូវឲ្យសហចៅក្រមស៊ើបអង្កេតគោរពតាមកាតព្វកិច្ចរបស់ខ្លួនក្នុងសមាសធាតុជាមន្ត្រីរបស់តុលាការដែលមានអត្តចរិកប្រកបដោយ "សីលធម៌ខ្ពង់ខ្ពស់ ភាពមិនលម្អៀង និងសុចរិត" ។ បទដ្ឋាននេះគួរតែអាចយកមកប្រើប្រាស់នៅក្នុងបណ្តឹងឧទ្ធរណ៍ខាងមុខសម្រាប់ការស្នើសុំឲ្យចាត់វិធានការស៊ើបអង្កេតលើសំណុំរឿង០០៣ដែលត្រូវបានបដិសេធរួចហើយនោះ និងសម្រាប់ដំណើរការស៊ើបអង្កេតដែលនៅសេសសល់សម្រាប់សំណុំរឿង០០៤ ។

ដើម្បីកំណត់បទដ្ឋានបែបនេះ តុលាការគួរតែប្រើប្រាស់សេចក្តីណែនាំតាមបទដ្ឋានអន្តរជាតិសម្រាប់ការស៊ើបអង្កេតលើការរំលោភសិទ្ធិមនុស្សដែលផ្សារភ្ជាប់យ៉ាងទូលាយរវាងកាតព្វកិច្ចក្នុងការស៊ើបអង្កេតឲ្យមានប្រសិទ្ធភាពលើការរំលោភសិទ្ធិមនុស្សជាមួយនឹងកាតព្វកិច្ចរបស់រដ្ឋក្នុងការបញ្ចប់វប្បធម៌និទ្ទណ្ឌភាព ។ ជាមួយគ្នានេះ យុត្តិសាស្ត្រអន្តរជាតិបានចាត់ទុកធាតុផ្សំបួនដែលសំខាន់ក្នុងការសម្រេចឲ្យបាននូវការស៊ើបអង្កេតដែលមានប្រសិទ្ធភាពមួយ និងមានលក្ខណៈគ្រប់ជ្រុងជ្រោយដើម្បីអនុវត្តកាតព្វកិច្ចបញ្ចប់វប្បធម៌និទ្ទណ្ឌភាព ៖ ១) សមត្ថភាពក្នុងការសម្របសម្រួលដល់ការដាក់ទណ្ឌកម្ម ២) ឯករាជ្យភាព ៣) តម្លាភាព និង ៤) ដំណើរការកាត់ទោសឆាប់រហ័ស ។

បើទោះបីជាមិនមានលក្ខណៈទូលំទូលាយក៏ដោយ ក៏ធាតុផ្សំដូចគ្នាទាំងអស់នេះរកឃើញនូវវិធីសាស្ត្រដោះស្រាយដែលឋិតនៅក្នុងច្បាប់គ្រប់គ្រង និងយុត្តិសាស្ត្ររបស់តុលាការកាត់ទោសខ្មែរក្រហម ។ ដូច្នេះ ការទាមទារឲ្យសហចៅក្រមស៊ើបអង្កេតអនុវត្តការស៊ើបអង្កេតដែលមានប្រសិទ្ធភាពនឹងធានាថា ការស៊ើបអង្កេតត្រូវបានអនុវត្តទៅតាមបទដ្ឋានដែលច្បាប់គ្រប់គ្រង និងយុត្តិសាស្ត្ររបស់តុលាការកាត់ទោសខ្មែរក្រហមរំពឹងចង់បាន ។ អាស្រ័យហេតុនេះ តុលាការកាត់ទោសខ្មែរក្រហមនឹងអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយពេញចិត្តដើម្បីបញ្ចប់និទ្ទណ្ឌភាពរបស់ជនដែលដល់នៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដែលទទួលរងគ្រោះដោយជនរងគ្រោះនៃរបបខ្មែរក្រហម ។

## ច្បាប់ជាប់ពាក់ព័ន្ធ

នៅក្នុងអង្គនីតិវិធីចំពោះមុខតុលាការខ្មែរក្រហម សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចទទួលខុសត្រូវចម្បងក្នុងការស៊ើបអង្កេតលើបទឧក្រិដ្ឋកម្ម និងជនសង្ស័យដែលត្រូវបានចោទប្រកាន់ដើម្បី "ស្វែងរកការពិត" ។ តួនាទីរបស់សហចៅក្រមស៊ើបអង្កេតរបស់តុលាការខ្មែរក្រហមមានចែងនៅក្នុងនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងបារាំង ។ សម្រាប់ដំណើរការស៊ើបអង្កេតដែលអនុវត្តដោយសហចៅក្រមស៊ើបអង្កេតជាតិវិញ វិសាលភាពនៃការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតនោះ គឺត្រូវតែគោរពទៅតាមអង្គហេតុដែលមានចែងនៅក្នុងសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ។ យ៉ាងណាមិញ បែបបទជាក់ស្តែងស្តីពីកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការស៊ើបអង្កេតជុំវិញបទឧក្រិដ្ឋកម្មនៅតែមិនមានភាពប្រត្យក្សនៅឡើយ បើយោងតាមច្បាប់គ្រប់គ្រងរបស់តុលាការខ្មែរក្រហម និងវិធាននីតិវិធីកម្ពុជា និងបារាំងដែលផ្តល់ការគូសបញ្ជាក់បន្ថែមតិចតួចបំផុតនោះ ។ នៅពេលដែលមានចន្លោះប្រហោង និងភាពស្រពេចស្រពិលនៅក្នុងបទបញ្ញត្តិនៃវិធានផ្ទៃក្នុងតុលាការខ្មែរក្រហម និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចៅក្រមអាចនឹងងាកមករកសេចក្តីណែនាំតាមវិធាននីតិវិធីអន្តរជាតិ បាន ។

វិធានផ្ទៃក្នុងមិនបានចែងឲ្យបានច្បាស់ពីវិសាលភាពនៃកាតព្វកិច្ចក្នុងការស៊ើបអង្កេតទេ ។ យោងតាមវិធានផ្ទៃក្នុង៥៥ ការស៊ើបអង្កេតលើឧក្រិដ្ឋកម្មដែលឋិតនៅក្រោមយុត្តាធិការរបស់តុលាការខ្មែរក្រហមគឺជាកាតព្វកិច្ចដែលត្រូវតែអនុវត្តហើយត្រូវគោរពតាម "អង្គហេតុដែលបានកំណត់" នៅក្នុងសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា" ឲ្យបានដាច់ខាត ។ ជុំវិញរឿងនេះ សហចៅក្រមស៊ើបអង្កេតត្រូវតែស្វែងរកទាំងភស្តុតាងដាក់បន្ទុក និងដោះបន្ទុកដើម្បី "ធានាឲ្យបាននូវការពិត" ។ អំណាចក្នុងការអនុវត្តដំណើរការស៊ើបអង្កេត និងអំណាចឆន្ទានុសិទ្ធិទូលំទូលាយត្រូវបានផ្តល់ឲ្យសហចៅក្រមស៊ើបអង្កេតដើម្បីសម្របសម្រួលដល់កាតព្វកិច្ចស្វែងរកការពិតរបស់សហចៅក្រមស៊ើបអង្កេត ។

ប៉ុន្តែ វិធានផ្ទៃក្នុងនេះគ្រាន់តែចែងថា សហចៅក្រមស៊ើបអង្កេត "អាច" សម្រេចអនុវត្តសិទ្ធិអំណាចទាំងនេះបាន ប្រសិនបើខ្លួនមិនត្រូវបានបង្ខិតបង្ខំឲ្យធ្វើដូច្នោះ ។ ដូច្នេះ វិធីសាស្ត្រក្នុងការអនុវត្តសិទ្ធិក្នុងការស៊ើបអង្កេតទូលំទូលាយធំ និងព័ត៌មានដែលការស៊ើបអង្កេតគួរតែទាញយកនៅតែមានភាពស្រពិចស្រពិលដដែល ។

ខ្លឹមសារនៃលក្ខន្តិកៈរបស់ក្រមនីតិវិធីព្រហ្មទណ្ឌក៏មានភាពស្រពិចស្រពិលស្រដៀងគ្នានេះដែរ ។ បើទោះបីជាមាត្រា៤៤ និង១២៧នៃក្រមនីតិវិធីព្រហ្មទណ្ឌតម្រូវឲ្យមានការស៊ើបអង្កេតមួយលើការរំលោភធ្ងន់ធ្ងរលើច្បាប់ក្នុងស្រុក និងផ្តល់អំណាចដ៏ទូលាយដល់ចៅក្រមស៊ើបអង្កេតដើម្បីអនុវត្តការស៊ើបអង្កេតដោយ "ធានាឲ្យបាននូវការពិត" ក៏ដោយ ក៏ខ្លឹមសារនៃវិធានទាំងនោះនៅមិនមានភាពច្បាស់លាស់ថាតើសហចៅក្រមស៊ើបអង្កេតត្រូវបំពេញតួនាទីស្វែងរកការពិតរបស់ខ្លួនតាមរយៈការស៊ើបអង្កេតនេះឲ្យបានលម្អិតដល់កម្រិតណានោះ ។

ដូចគ្នានេះ វិធានច្បាប់បារាំងក៏មិនផ្តល់ជាសេចក្តីណែនាំឲ្យបានគ្រប់ជ្រុងជ្រោយឲ្យលើសពីបទបញ្ញត្តិដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធានផ្ទៃក្នុងរបស់តុលាការខ្មែរក្រហមដែរ ។ តាមច្បាប់បារាំង សហចៅក្រមស៊ើបអង្កេតមានការទទួលខុសត្រូវចម្បងក្នុងការស៊ើបអង្កេត ហើយទទួលបាននូវសិទ្ធិទូលំទូលាយដើម្បី "អនុវត្ត...ជំហាននៃការស៊ើបអង្កេតដែលខ្លួនចាត់ទុកថាមានសារប្រយោជន៍សម្រាប់ការស្វែងរកការពិត" ។ តាមការអនុវត្តបទបញ្ញត្តិទាំងអស់នេះបានបង្កើតជាប្រព័ន្ធមួយដែលផ្អែកខ្លាំងទៅលើការចាត់តាំងមន្ត្រីចៅក្រមដែលមានសមត្ថភាព និងសតិសម្បជញ្ញៈ ។ ដូច្នេះ ប្រព័ន្ធច្បាប់បារាំងប្រើប្រាស់យន្តការផ្សេងៗក្នុងការជំនះភាពជាប់គាំងផ្នែកច្បាប់ និងធានាឲ្យបាននូវការស៊ើបអង្កេតដែលប្រកបដោយប្រសិទ្ធភាព ៖ សហចៅក្រមស៊ើបអង្កេតទទួលបាននូវ "វគ្គបណ្តុះបណ្តាលពិសេសក្នុងការស្វែងរកការពិត" ។ ដើមបណ្តឹងរដ្ឋប្បវេណីមានតួនាទីសកម្មមួយក្នុងការ "ជំរុញឲ្យចៅក្រមស៊ើបអង្កេត...អនុវត្តការស៊ើបអង្កេតឲ្យបានហ្មត់ចត់" ។ ហើយដំណើរការកាត់ទោសនីមួយៗត្រូវចាត់តាំង "មន្ត្រីតុលាការគ្រប់ប្រភេទដែលមានសមត្ថភាពក្នុងការគាំទ្រមន្ត្រីផ្សេងទៀត និងជួយគ្នាទៅវិញទៅមក" ។ "ការគាំទ្រ" ទាំងអស់នេះដើរតួជាការត្រួតពិនិត្យលើភាពអសមត្ថភាព និងការធ្វេសប្រហែសផ្នែកច្បាប់ ហើយពង្រឹងភាពចាំបាច់ឲ្យមាន "ការស៊ើបអង្កេតលម្អិត" ដើម្បីបំពេញតួនាទី "ស្វែងរកការពិត" នៃប្រព័ន្ធច្បាប់បារាំង ។ សរុបសេចក្តីមក បើទោះបីជាខ្លឹមសារធម្មតានៃក្រមព្រហ្មទណ្ឌមិនបានគូសបញ្ជាក់ឲ្យច្បាស់ពីសេចក្តីណែនាំជាក់លាក់ណាមួយដើម្បីកំណត់វិសាលភាពនៃដំណើរការស៊ើបអង្កេតក៏ដោយ ក៏ប្រព័ន្ធច្បាប់បារាំងរំពឹងថា ចៅក្រមស៊ើបអង្កេតនឹងចាត់ដំណើរការស៊ើបអង្កេតឲ្យស្របតាមបទដ្ឋានខ្ពស់បំផុតស្តីពីសមត្ថភាព សតិសម្បជញ្ញៈ និងភាពមិនលំអៀងដើម្បីធានាឲ្យបាននូវការស៊ើបអង្កេតដែល "រឹងមាំ" និង លម្អិត ។

យុត្តិសាស្ត្រអន្តរជាតិបានផ្តល់ជាសេចក្តីណែនាំដែលតុលាការខ្មែរក្រហម និងច្បាប់ក្នុងស្រុកខ្វះខាតដោយផ្សារភ្ជាប់កាតព្វកិច្ចស៊ើបអង្កេតលើការរំលោភសិទ្ធិមនុស្សដែលក្នុងនោះរួមមានការរំលោភទាំងឡាយណាដែលឋិតនៅក្នុងអណត្តិរបស់តុលាការខ្មែរក្រហម ទៅនឹងកាតព្វកិច្ចរបស់រដ្ឋក្នុងការបញ្ឈប់និទ្ទណ្ឌភាពរបស់ជនដៃដល់ ។ ការផ្សារភ្ជាប់នេះគឺមានជាប់ពាក់ព័ន្ធជាពិសេសទៅនឹងកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេតក្នុងកិច្ចការស៊ើបអង្កេត ចាប់តាំងពីពេលដែលតុលាការខ្មែរក្រហមត្រូវបានបង្កើតឡើងតាមការស្នើសុំរបស់រដ្ឋាភិបាលកម្ពុជាសហការជាមួយនឹងអង្គការសហប្រជាជាតិ ដើម្បីជួយប្រទេសកម្ពុជាបំបាត់កេរដំណែលនៃអំពើនិទ្ទណ្ឌភាព ហើយ "ឆ្លើយតបទៅនឹងការរំលោភធ្ងន់ធ្ងរកាលពីអតីតកាលលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិដើម្បីជាមធ្យោបាយមួយក្នុងការនាំឲ្យនូវការផ្សះផ្សាជាតិ ពង្រឹងលទ្ធិប្រជាធិបតេយ្យ និងដោះស្រាយបញ្ហាទទួលខុសត្រូវរបស់បុគ្គល" ។ ដូច្នេះ តាមរយៈការអនុវត្តតាមបទដ្ឋានអន្តរជាតិនៃការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត តុលាការអាចអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការបញ្ឈប់អំពើនិទ្ទណ្ឌភាពរបស់ជនដៃដល់នៃការរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្សនៅក្នុងសតវត្សរ៍ទី២០ ហើយអាចឲ្យតុលាការដើរតាមបទដ្ឋានដែលខ្លួនបានកំណត់ ។

### កាតព្វកិច្ចក្នុងការបញ្ឈប់អំពើនិទ្ទណ្ឌភាព និងករណីយកិច្ចក្នុងការស៊ើបអង្កេតលើការរំលោភសិទ្ធិមនុស្ស

រដ្ឋទាំងអស់មានករណីយកិច្ចទូទៅមួយក្នុងការ "ចាត់វិធាន

ការដើម្បីប្រឆាំងនឹងអំពើនិទ្ទណ្ឌភាព» ដែលត្រូវបានចាត់ទុកថាជា «ការខ្វះខាតការស៊ើបអង្កេត ការចាប់ខ្លួន ការកាត់ទោស និងការចោទប្រកាន់ជនទាំងឡាយណាដែលមានការទទួលខុសត្រូវ» សម្រាប់ការរំលោភសិទ្ធិមនុស្ស ។ ករណីយកិច្ចនេះទាមទារឲ្យរដ្ឋចាត់វិធានការដាក់លាក់ដើម្បីប្រឆាំងនឹងអំពើនិទ្ទណ្ឌភាព និងធានាឲ្យបាននូវសិទ្ធិជាមូលដ្ឋានក្នុងការដឹងឮ សិទ្ធិក្នុងការទទួលបានយុត្តិធម៌ និងសិទ្ធិក្នុងការទទួលបានសំណងដែលសិទ្ធិទាំងអស់នេះចាំបាច់ត្រូវតែស្តារឡើងវិញ ក្រោយពីការរំលោភសិទ្ធិមនុស្សបានកើតឡើង ។ វិធានការទាំងអស់នេះរួមមាន ៖ ការស្វែងរកការពិតស្តីពីការរំលោភសិទ្ធិមនុស្ស ការកាត់ទោស ជំនុំជម្រះក្តី និងការដាក់ទោសជនដៃដល់ ផ្តល់ជាសំណងដល់ជនរងគ្រោះ ការជំរុញឲ្យប្រជាជនជឿជាក់លើស្ថាប័នរដ្ឋាភិបាល និងការការពារមិនឲ្យមានការកកើតឡើងវិញនូវការរំលោភសិទ្ធិមនុស្សនេះជាដាច់ខាត ។ ដោយសារតែការស៊ើបអង្កេតគឺពិតជាមានសារសំខាន់ក្នុងការអនុវត្តវិធីសាស្ត្រទាំងអស់នេះ នោះកាតព្វកិច្ចក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើនិទ្ទណ្ឌភាពដោយប្រសិទ្ធភាពគឺរាប់បញ្ចូលទាំងកាតព្វកិច្ចក្នុងការស៊ើបអង្កេតលើការរំលោភសិទ្ធិមនុស្ស ។

តុលាការសិទ្ធិមនុស្សអន្តរជាតិបានគូសសម្គាល់ធាតុផ្សំបួនដែលមានសារសំខាន់ដើម្បីបំពេញកាតព្វកិច្ចក្នុងការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពលើការរំលោភសិទ្ធិមនុស្ស ។ តាមរយៈវិភាគលើវិធានការដែលរដ្ឋត្រូវតែអនុវត្តតាមដើម្បីប្រឆាំងនឹងអំពើនិទ្ទណ្ឌភាពឲ្យជោគជ័យ និងស្តារឡើងវិញនូវសិទ្ធិក្នុងការដឹងឮ សិទ្ធិក្នុងការទទួលបានយុត្តិធម៌ និងសិទ្ធិក្នុងការទទួលបានសំណងរបស់ប្រជាជនទាំងអស់ នោះការស៊ើបអង្កេតដែលប្រកបដោយប្រសិទ្ធភាពត្រូវតែ ១) សម្របសម្រួលការដាក់ទណ្ឌកម្ម ២) មានតម្លាភាព ៣) ឯករាជ្យ ៤) ដំណើរការកាត់ទោសឆាប់រហ័ស ។ មានតែការស៊ើបអង្កេតដែលដើរតាមបទដ្ឋានទាំងអស់នេះទេដែលមានសមត្ថភាពក្នុងការការពារ និងស្តារឡើងវិញនូវសិទ្ធិក្នុងការដឹងឮ សិទ្ធិក្នុងការទទួលបានយុត្តិធម៌ និងសិទ្ធិក្នុងការទទួលបានសំណង ។

បើទោះបីជាកាតព្វកិច្ចក្នុងការស៊ើបអង្កេតលើការរំលោភសិទ្ធិមនុស្សជារបស់រដ្ឋក៏ដោយ ក៏កាតព្វកិច្ចនេះមានជាប់ពាក់ព័ន្ធនឹងដំណើរការនីតិវិធីនៅចំពោះមុខតុលាការខ្មែរក្រហម ពីព្រោះតុលាការខ្មែរក្រហមបានអនុវត្តកាតព្វកិច្ចមួយក្នុងការបញ្ឈប់អំពើនិទ្ទណ្ឌភាពរបស់ជនដៃដល់នៃការរំលោភសិទ្ធិមនុស្សទ្រង់ទ្រាយធំរបស់របបខ្មែរក្រហម ។ បន្ថែមលើនេះ ការវិភាគលម្អិតលើ



រណ្តៅសាកសពរួមដែលបានគាស់ក្រោយរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩

ច្បាប់គ្រប់គ្រង និងយុត្តិសាស្ត្ររបស់តុលាការខ្មែរក្រហមឆ្លុះបញ្ចាំងឲ្យឃើញថាធាតុផ្សំនៃការស៊ើបអង្កេតដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ នៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខតុលាការខ្មែរក្រហមគឺជាប់ពាក់ព័ន្ធនឹងធាតុផ្សំនៃការស៊ើបអង្កេតដែលប្រកបដោយប្រសិទ្ធភាពដើម្បីអនុវត្តកាតព្វកិច្ចក្នុងការបញ្ឈប់អំពើនិទ្ទណ្ឌភាព ដែលមានចែងនៅក្នុងច្បាប់ថ្នាក់អន្តរជាតិ ។ តាមរយៈការអនុវត្តតាមបទដ្ឋានអន្តរជាតិទាំងនេះដើម្បីឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបអង្កេត នោះតុលាការអាចអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការបញ្ឈប់អំពើនិទ្ទណ្ឌភាពរបស់ជនដែលដល់នៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុតនៅក្នុងសតវត្សរ៍ទី២០នេះ ហើយអាចឲ្យតុលាការដើរតាមបទដ្ឋានដែលខ្លួនបានកំណត់ ។

ទីមួយ ដើម្បីឲ្យការស៊ើបអង្កេតមានប្រសិទ្ធភាព ការស៊ើបអង្កេតត្រូវតែអនុវត្តឡើងដើម្បីជាយានសម្របសម្រួលដល់ការដាក់ទណ្ឌកម្ម ។ លក្ខន្តិកៈនេះធានាថា “ការពិតស្តីពី...ការបកស្រាយពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរត្រូវបានពន្យល់បកស្រាយ ហើយថាជនដែលមានការទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្ម នោះអាចនឹងត្រូវបានគូសសម្គាល់អត្តសញ្ញាណ កាត់ទោស និងដាក់ទណ្ឌកម្ម ។ ដើម្បីចៀសវាងកុំឲ្យក្លាយជា “នីតិវិធីដែលត្រូវបានចាត់ទុកជាមុនថាគ្មានប្រសិទ្ធភាព” នោះការស៊ើបអង្កេតត្រូវតែ “ធ្វើឡើងក្នុងឥរិយាបថហ្មត់ចត់” ដោយមាន “គោលដៅ” មួយច្បាស់លាស់ ហើយមានសមត្ថភាព “ក្នុងការលាតត្រដាងអត្តសញ្ញាណ និងដាក់ទណ្ឌកម្មជនដែលមានការទទួលខុសត្រូវ” សម្រាប់ការរំលោភសិទ្ធិមនុស្ស ។ កាតព្វកិច្ចនេះត្រូវបានអនុវត្តនៅពេលដែលអាជ្ញាធរមានអំណាចព្យាយាមបញ្ជាក់ពីការពិតនៃស្ថានភាពដែលឋិតនៅជុំវិញការប្រព្រឹត្តអំពើហិង្សាតាមរយៈការអនុវត្តទៅតាម “ដំណាក់កាលនីមួយៗនៃការស៊ើប អង្កេត..ដើម្បីធានាឲ្យបាននូវភ័ស្តុតាង” ដែលឋិតនៅក្នុងបរិបទនៃសំណុំរឿងនោះ ។ សំខាន់ជាងនេះ ការអាក់ខានមិនបានអនុវត្តការស៊ើបអង្កេតដែលត្រូវបានគាក់តែងឡើងដើម្បីសម្របសម្រួលដល់ការដាក់ទណ្ឌកម្មអាចក្លាយជាឧបសគ្គដែលរារាំងមិនឲ្យការគូសសម្គាល់អត្តសញ្ញាណ កាត់ទោស និងដាក់ទណ្ឌកម្មលើជនដែលទទួលខុសត្រូវសម្រាប់ការរំលោភសិទ្ធិមនុស្ស ហើយបែរជាការពារជនដែលរំលោភសិទ្ធិមនុស្សនោះមិនឲ្យចូលខ្លួនមកទទួលខុសត្រូវតាមច្បាប់ព្រហ្មទណ្ឌ ។ ដូច្នេះ វាអាចជំរុញឲ្យមានអំពើនិទ្ទណ្ឌភាពកាន់តែផុសផុលឡើង” ហើយដាក់បន្ទុកឲ្យរដ្ឋធ្វើការទទួលខុសត្រូវតាមបទដ្ឋានអន្តរជាតិដើម្បីផ្តត់ផ្គង់ដល់ចលនាបេសកកម្មបំបាត់ការរំលោភសិទ្ធិមនុស្ស ។

ស្រដៀងគ្នាដែរ លក្ខន្តិកៈដែលថាការស៊ើបអង្កេតត្រូវតែធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតដែលដំណើរការឡើងដើម្បីសម្របសម្រួលដល់ការដាក់ទណ្ឌកម្មគឺត្រូវឋិតនៅក្នុងគោលដៅ និង គោលបំណងរបស់តុលាការខ្មែរក្រហម ។ ច្បាប់នៃការបង្កើតតុលាការខ្មែរក្រហមបានទទួលស្គាល់ពីភាពចាំបាច់ក្នុងការដោះស្រាយ “បញ្ហាកេរដំណែលនៃឧក្រិដ្ឋកម្ម និងកេរដំណែលនៃអំពើនិទ្ទណ្ឌភាព” ដែល “តាមលងបន្ទាចប្រទេសកម្ពុជា” និងពីភាពចាំបាច់ក្នុងការ “ឆ្លើយតបទៅនឹងការរំលោភច្បាប់ជាតិ និងអន្តរជាតិធ្ងន់ធ្ងរកាលពីអតីតកាល ដើម្បីធ្វើជាយានមួយសម្រាប់ការផ្សះផ្សាជាតិ ការពង្រឹងលទ្ធិប្រជាធិបតេយ្យ និង ការដោះស្រាយបញ្ហាស្តីពីការទទួលខុសត្រូវរបស់បុគ្គល” ។ បញ្ហាទាំងអស់នេះមានជាប់ពាក់ព័ន្ធនឹងការព្រួយបារម្ភដូចគ្នាពីបញ្ហាសិទ្ធិក្នុងការដឹងឮ សិទ្ធិក្នុងការទទួលបានសំណង និងសិទ្ធិក្នុងការទទួលបានយុត្តិធម៌ ។

ដើម្បីជួយសម្របសម្រួលតុលាការក្នុងការបំពេញកិច្ចការនេះ អាជ្ញាធរមានអំណាចក្នុងការស៊ើបអង្កេតដែលសំដៅទៅលើសហចៅក្រមស៊ើបអង្កេតត្រូវតែបានផ្តល់ឲ្យនូវឆន្ទានុសិទ្ធិទូលំទូលាយ ។ យ៉ាងណាមិញ ឆន្ទានុសិទ្ធិនេះមិនមែនគ្មានព្រំដែនកំណត់ទេ តែឆន្ទានុសិទ្ធិនេះត្រូវតែផ្សារភ្ជាប់ជាមួយនឹងកាតព្វកិច្ចទាំងមូលរបស់សហចៅក្រមស៊ើបអង្កេតក្នុងការស៊ើបអង្កេត “ដើម្បីស្វែងរកការពិត” ហើយក៏មានជាប់ពាក់ព័ន្ធនឹងកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការស្វែងរកភ័ស្តុតាងដាក់បន្ទុក និងដោះបន្ទុក ដើម្បីចាត់តាំងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងនាំជនដែលដល់នៃការរំលោភសិទ្ធិមនុស្ស ក្នុងរបបកម្ពុជាប្រជាធិបតេយ្យមកកាត់ទោស ។

ដូច្នេះ ក្នុងការស៊ើបអង្កេតលើសំណុំរឿង០០៣ សហចៅក្រមស៊ើបអង្កេតត្រូវតែអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីកំណត់ថាតើអង្គហេតុដែលត្រូវបានចោទប្រកាន់នៅក្នុងសេចក្តីសន្និដ្ឋានបឋមរបស់ព្រះរាជអាជ្ញាពិតជាឧក្រិដ្ឋកម្មដែលឋិតនៅក្រោម

យុត្តាធិការរបស់តុលាការខ្មែរក្រហមដែរឬយ៉ាងណា និងដើម្បីគូសសម្គាល់ពីអត្តសញ្ញាណជនសង្ស័យដែលមិនត្រូវបានបញ្ចេញឈ្មោះ និងដើម្បីកំណត់ថា តើភស្តុតាងដែលចោទប្រកាន់លើជនសង្ស័យនោះមានចំនួនគ្រប់គ្រាន់ដើម្បីដំណើរការអង្គជំនុំជម្រះក្តីបានដែរឬយ៉ាងណា ។ មានតែធ្វើដូច្នេះទេ ទើបការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតអាចអនុញ្ញាតឲ្យចៅក្រមបំពេញអាណត្តិរបស់ខ្លួនក្នុងការនាំជនដែលមានការទទួលខុសត្រូវសម្រាប់ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរក្នុងរបបកម្ពុជាប្រជាធិបតេយ្យមកកាត់ទោស និងបញ្ឈប់អំពើនិទ្ទណ្ឌភាពសេសសល់ដែលនៅតាមលងបន្ទាចប្រទេសកម្ពុជាជាយូរយារណាស់មកហើយ ។

ទីពីរ ការស៊ើបអង្កេតលើការរំលោភសិទ្ធិមនុស្សត្រូវតែមានតម្លាភាពក្នុងន័យដែលថាការស៊ើបអង្កេតនោះមានលក្ខណៈបើកចំហ "ដល់ការតាមដានពីសំណាក់សាធារណជន" ដើម្បីធានាឲ្យបាននូវការទទួលខុសត្រូវនៅក្នុងការអនុវត្ត និងតាមទ្រឹស្តី" ។ ការស៊ើបអង្កេតដែលមានតម្លាភាពគឺពិតជាមានសារសំខាន់ក្នុងការស្តារឡើងវិញនូវ "ជំនឿទុកចិត្តរបស់សាធារណជនមកលើច្បាប់" និងដើម្បីធានាថាគ្មាន "ការឃុបឃិតក្រៅផ្លូវការ ឬ ការអត់ឱនចំពោះការប្រព្រឹត្តខុសច្បាប់នោះទេ" ។ សំខាន់ជាងនេះ អ្នកដែលទទួលរងគ្រោះផ្ទាល់បំផុតពីការរំលោភសិទ្ធិមនុស្សដែលសំដៅទៅលើជនរងគ្រោះ និង ក្រុមគ្រួសាររបស់ជនរងគ្រោះត្រូវតែអនុញ្ញាតឲ្យ "ចូលរួម" និង ទទួលបានព័ត៌មាន "សំខាន់ដើម្បីការពារប្រយោជន៍ តាមផ្លូវច្បាប់របស់អ្នកទាំងអស់នេះ" ។ ដូច្នេះលក្ខន្តិកៈទាមទារឲ្យមានតម្លាភាពនេះជួយទាញយកជំនឿទុកចិត្តរបស់សាធារណជនទៅលើស្ថាប័នរដ្ឋាភិបាល ហើយធានាឲ្យបាននូវ "ការគោរពច្បាប់" ។ លើសពីនេះ លក្ខន្តិកៈនេះធ្វើការការពារ "សិទ្ធិរបស់ជនរងគ្រោះ ឬសាច់ញាតិដទៃទៀតរបស់ជនរងគ្រោះដែលទទួលរងគ្រោះដោយសារការរំលោភសិទ្ធិមនុស្ស ហើយការពារការទទួលខុសត្រូវស្មើគ្នា ដែលត្រូវបានពន្យល់បកស្រាយដោយរដ្ឋ តាមរយៈការស៊ើបអង្កេត និងការកាត់ទោស" ។

តាមរយៈការឆ្លុះបញ្ចាំងឲ្យឃើញពីក្តីព្រួយបារម្ភលើលក្ខន្តិកៈស្តីពីតម្លាភាពក្នុងកម្រិតអន្តរជាតិ វិធានផ្ទៃក្នុងរបស់តុលាការខ្មែរក្រហមតម្រូវឲ្យមានតម្លាភាពរាល់ដំណើរការនីតិវិធីទាំងអស់របស់តុលាការ ហើយក៏បង្គាប់ឲ្យការស៊ើបអង្កេតត្រូវតែមានតម្លាភាព ដើម្បីធានាថាសិទ្ធិរបស់ភាគីទាំងអស់ដែលជាប់ពាក់ព័ន្ធនឹងសំណុំរឿងកាត់ទោសត្រូវបានការពារ ។ ដូចគ្នាដែរ យុត្តាធិការរបស់តុលាការ ខ្មែរក្រហមបានទទួលស្គាល់ពីភាពចាំបាច់នៃតម្លាភាពដើម្បីផ្តល់ប្រយោជន៍ពិសេសដល់ជនរងគ្រោះនៅក្នុងអង្គនីតិវិធីចំពោះមុខចៅក្រម ។ អង្គជំនុំជម្រះសាលាដំបូងបានសង្កត់ធ្ងន់ថា ជនរងគ្រោះត្រូវតែទទួលបានព័ត៌មានពីសហចៅក្រមស៊ើបអង្កេតដើម្បីកំណត់ថាតើជនរងគ្រោះអាចដាក់ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីទទួលបាននូវការចូលរួមការធ្វើជាតំណាងនៅក្នុងដំណើរនីតិវិធីនៅចំពោះមុខចៅក្រម និងលទ្ធភាពក្នុងការទទួលបានសំណង ។

ដូច្នេះ លក្ខន្តិកៈស្តីពីតម្លាភាពដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង និងយុត្តាធិការរបស់តុលាការខ្មែរក្រហមចង្អុលបង្ហាញឲ្យឃើញពីក្តីព្រួយបារម្ភដូចគ្នាមួយជាថ្នាក់អន្តរជាតិក្នុងការធានាឲ្យបាននូវ "ធាតុផ្សំគ្រប់គ្រាន់មួយសម្រួលដល់ការតាមដានរបស់សាធារណជន" ដើម្បីស្តារឡើងវិញនូវការជឿទុកចិត្តរបស់សាធារណជនទៅលើប្រព័ន្ធច្បាប់ដោយទាមទារឲ្យមានការគោរពសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួម និងទទួលបានព័ត៌មានពាក់ព័ន្ធនឹងដំណើរការនីតិវិធីទាំងស្រុងនៅចំពោះមុខចៅក្រម ហើយក៏ដើម្បីធានាថាការទទួលបានព័ត៌មានទាក់ទងនឹងការស៊ើបអង្កេតក្នុងការការពារសិទ្ធិជនរងគ្រោះ និងសិទ្ធិរបស់សាធារណជនក្នុងការដឹងពីការពិតពីហេតុការណ៍ដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជានៅក្នុងរបបគ្រប់គ្រងរបស់ខ្មែរក្រហម ។

ទីបី ការស៊ើបអង្កេតលើការរំលោភសិទ្ធិមនុស្សត្រូវមានលក្ខណៈឯករាជ្យដើម្បីធានា ពង្រឹង និងបង្កើតច្បាប់ដ៏រឹងមាំ ។ ឯករាជ្យភាពនៃច្បាប់ទាមទារឲ្យមានការកំណត់ពី "អង្គហេតុសំខាន់ៗ" ជាជាងការអះអាងមិនសមហេតុផលពី "ការជះឥទ្ធិពលគំរាមកំហែង និងការជ្រៀតជ្រែក" ពីសំណាក់បុគ្គលដែលមានសមត្ថភាពដែលក្នុងនោះរួមមានការបណ្តុះបណ្តាលសមរម្យ និងគុណសម្បត្តិល្អ ។ ការស៊ើបអង្កេតដែលត្រូវបានបំពុលដោយកង្វះខាតនូវឯករាជ្យភាពផ្នែកច្បាប់អាចនឹងបំផ្លាញដល់ដំណើរការនីតិវិធីទាំងស្រុងដែលនាំទៅរកការចេញសាលក្រមកាត់ទោសដ៏

អយុត្តិធម៌ ។ ដោយសារតែ «ការបំផ្លិចបំផ្លាញដែលបណ្តាលមកពី...ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅតែបន្តកើតមាននៅក្នុងសង្គមជាតិ និងសហគមន៍អន្តរជាតិ...ជនដែលទទួលខុសត្រូវ ត្រូវតែបានស៊ើបអង្កេត និងដាក់ទណ្ឌកម្ម» តាមរយៈដំណើរការមួយដោយគ្មានភាពមន្ទិលសង្ស័យ ។ មានតែអនុវត្តតាមមធ្យោបាយនេះទេទើបលទ្ធផលនៃការស៊ើបអង្កេត និង អង្គជំនុំជម្រះក្តី ការកាត់ទោស និងការចេញសាលក្រមក្រោយៗទៀត អាចផ្តល់ទីបញ្ចប់មួយដែលមានសារសំខាន់ក្នុងការនាំមកនូវសេចក្តីពេញចិត្តជូនដល់ជនរងគ្រោះ ស្តារឡើងវិញនូវការជឿទុកចិត្តរបស់សាធារណជនទៅលើច្បាប់ និងធានាឲ្យបាននូវសិទ្ធិក្នុងការដឹងពិត និងសិទ្ធិក្នុងការទទួលបានយុត្តិធម៌ ។

ដូចគ្នានេះដែរ កិច្ចព្រមព្រៀង ច្បាប់ និងវិធានផ្ទៃក្នុងរបស់តុលាការខ្មែរក្រហមចែងយ៉ាងច្បាស់ថា សហចៅក្រមស៊ើបអង្កេតបំពេញតួនាទីដោយឯករាជ្យនៅពេលធ្វើការស៊ើបអង្កេត ។ នៅឯតុលាការខ្មែរក្រហម លក្ខខណ្ឌតិកៈស្តីពីឯករាជ្យភាពមានទិសដៅធានាថាអង្គនីតិវិធីបំរើដល់ «ផលប្រយោជន៍នៃយុត្តិធម៌» ជាជាង «ដំណើរការជាក់លាក់» ផ្សេងទៀតដើម្បីជៀសវាងកុំឲ្យលទ្ធផលនៃអង្គជំនុំជម្រះ ឆ្លុះបញ្ចាំងឲ្យឃើញពី «ឧបាយកល...របស់អាជ្ញាធរដែលធ្វើការស៊ើបអង្កេតលើអង្គហេតុ ចេញសេចក្តីចោទប្រកាន់ និងសម្រេចសាលក្រមកាត់ទោស» ។ ដូច្នេះ ដើម្បីធានាថា សហចៅក្រមស៊ើបអង្កេតអនុវត្តឯករាជ្យភាពក្នុងប្រព័ន្ធច្បាប់ក្នុងការអនុវត្តកាតព្វកិច្ចស៊ើបអង្កេតរបស់ខ្លួននោះ ទាំងកិច្ចព្រមព្រៀង និងច្បាប់តុលាការខ្មែរក្រហមទាមទារឲ្យសហចៅក្រមស៊ើបអង្កេតជា «បុគ្គលដែលមានក្រមសីលធម៌ខ្ពស់ មិនលម្អៀង និងគោលការណ៍រឹងមាំ» ។ ដូច្នេះ លក្ខខណ្ឌតិកៈស្តីពីឯករាជ្យភាពរបស់តុលាការខ្មែរក្រហមធានាឲ្យបាននូវសិទ្ធិក្នុងការទទួលបានយុត្តិធម៌ និងសិទ្ធិក្នុងការទទួលបានសំណងដោយធានាឲ្យបាននូវការស៊ើបអង្កេតដ៏ឯករាជ្យដែលមានសារសំខាន់ក្នុងការស្តារឡើងវិញនូវផលប៉ះពាល់ដែលបណ្តាលមកពីការរំលោភសិទ្ធិមនុស្សរបស់ខ្មែរក្រហម និងដើម្បីស្តារឡើងវិញនូវការជឿទុកចិត្តរបស់ប្រជាជនឲ្យជឿលើច្បាប់ ។

ចុងក្រោយបង្អស់ «ដំណើរការកាត់ទោសឲ្យឆាប់រហ័ស និងការបង្កើនល្បឿន» មានបញ្ជាក់នៅក្នុងកាតព្វកិច្ចទាំងស្រុងរបស់អាជ្ញាធរស៊ើបអង្កេតដើម្បីរៀបចំ «ដំណាក់កាលសមហេតុផល» ក្នុងការស៊ើបអង្កេតលើការរំលោភសិទ្ធិមនុស្សដែលត្រូវបានចោទប្រកាន់ ។ ជាទូទៅ ភាពឆាប់រហ័សទាមទារឲ្យ «អាជ្ញាធរស៊ើបអង្កេត...ចាត់វិធានការស៊ើបអង្កេតឲ្យលឿនតាមតែអាចធ្វើបាន នៅពេលដែលមានការដាក់ពាក្យបណ្តឹងជាផ្លូវការ» ។ ការស៊ើបអង្កេតដែលឆាប់រហ័សពិតជាមានសារសំខាន់ក្នុងការអនុវត្តកាតព្វកិច្ចស៊ើបអង្កេតមួយប្រកបដោយប្រសិទ្ធភាពលើការរំលោភសិទ្ធិមនុស្ស ពីព្រោះថា «កត្តាពេលវេលា...អាចនឹងប៉ះពាល់ដល់គុណភាព និងចំនួនភ័ស្តុតាងដែលមាន» ហើយបង្កើតឲ្យមាន «ការឆ្លុះបញ្ចាំងឲ្យឃើញពី...កង្វះខាតនូវភាពឈ្លាសវៃ» ដែលកើតចេញពីអាជ្ញាធរស៊ើបអង្កេត ។ ដូច្នេះ វា «អាចបង្កឲ្យមានមន្ទិលសង្ស័យលើការជឿទុកចិត្តលើកិច្ចខំប្រឹងប្រែងស៊ើបអង្កេត និង «អូសបន្លាយបទពិសោធន៍ឈឺចាប់របស់» ជនរងគ្រោះ និងក្រុមគ្រួសាររបស់គេ ។ ដូច្នេះ លក្ខខណ្ឌតិកៈស្តីពីភាពឆាប់រហ័សនឹង «ពង្រឹងការជឿទុកចិត្តរបស់សាធារណជនក្នុងការគោរពតាមច្បាប់ ហើយ...រារាំងកុំឲ្យមានការឃុបឃិត ឬ ការអត់ឱនចំពោះការប្រព្រឹត្តខុសច្បាប់» ។

ច្បាប់គ្រប់គ្រងវិធានស្តីពីដំណើរនីតិវិធី និង យុត្តាធិការរបស់តុលាការខ្មែរក្រហមក៏បានគូសបញ្ជាក់ពីលក្ខខណ្ឌតិកៈស្តីពីភាពឆាប់រហ័សក្នុងការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ។ វិធាន២១(៤) ចែងថា «ដំណើរការនីតិវិធីចំពោះមុខតុលាការខ្មែរក្រហមត្រូវតែសម្រេចជាស្ថាពរតាមពេលវេលាសមរម្យមួយ» ។ អង្គបុរេជំនុំជម្រះបានផ្សារភ្ជាប់លក្ខខណ្ឌតិកៈនេះជាមួយនឹង «សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការកាត់ទោសតាមពេលវេលាសមរម្យមួយ និងសិទ្ធិក្នុងការទទួលបានការស៊ើបអង្កេតតាមផ្លូវច្បាប់ដ៏ពេញលេញដែលទាមទារឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបអង្កេតឲ្យបានឆាប់រហ័ស ។

អង្គបុរេជំនុំជម្រះទទួលស្គាល់យ៉ាងច្បាស់ពីសារសំខាន់នៃដំណើរការស៊ើបអង្កេតដែលឆាប់រហ័សដើម្បីរារាំងកុំឲ្យមាន «ការលេចឡើងនូវការខ្វះខាតភាពឈ្លាសវៃរបស់សហចៅក្រមស៊ើបអង្កេត ដែលប៉ះពាល់ដល់ការជំរុញឲ្យមានការជឿទុកចិត្ត

ឡើងវិញលើប្រព័ន្ធច្បាប់ដោយប្រកាន់ខ្ជាប់នូវគោលគំនិតមួយថា ការអាក់ខានមិនបានផ្តល់ព័ត៌មានដល់ជនរងគ្រោះឲ្យបានទាន់ពេលវេលាគឺជាកិច្ចសន្យាមួយនៃកាតព្វកិច្ចរបស់ "ការប្រុងប្រយ័ត្នក្នុងផ្លូវច្បាប់" របស់សហចៅក្រមស៊ើបអង្កេត ។

## ការស៊ើបអង្កេតលើសំណុំរឿង០០៣មិនបានបំពេញកាតព្វកិច្ចស៊ើបអង្កេតឲ្យបានគ្រប់ជ្រុងជ្រោយទេ

ជាសរុប ការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតលើសំណុំរឿង០០៣មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនដោយធ្វើការស៊ើបអង្កេតឲ្យមានប្រសិទ្ធភាពលើឧក្រិដ្ឋកម្មដែលឋិតនៅក្រោមយុត្តាធិការរបស់តុលាការខ្មែរក្រហម ដូចដែលមានចែងនៅក្នុងការស៊ើបអង្កេតតាមបទដ្ឋានអន្តរជាតិ និងរំពឹង ទុកដោយច្បាប់គ្រប់គ្រង និងយុត្តាធិការរបស់តុលាការទេ ។ ក្រៅពីការប្រើប្រាស់អំណាចក្នុងការស៊ើបអង្កេតឲ្យបានធំទូលាយដើម្បីរៀបចំ"វិធានការគ្រប់បែបយ៉ាង....ដែលមានសារសំខាន់ក្នុងការ ស្វែងរកការពិត" និងចាត់ "វិធានាការសមរម្យដែលមានដើម្បីធានាឲ្យបាននូវ" ភ័ស្តុតាងជាប់ពាក់ព័ន្ធនោះ ការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតលើសំណុំរឿង០០៣មានលក្ខណៈប្រហាក់ប្រហែលគ្នានឹង "នីតិវិធីដែលចាត់ទុកជាមុនថាគ្មានប្រសិទ្ធិភាព" ដែលត្រូវបានយកមកអនុវត្តដើម្បីបញ្ចប់ដំណើរការនីតិវិធីនៅចំពោះមុខតុលាការខ្មែរក្រហម ។

ជួសឲ្យការស៊ើបអង្កេតប្រកបដោយតម្លាភាពដែលរៀបចំឡើងដើម្បីធានាឲ្យបាននូវការទទួលខុសត្រូវទាំងក្នុងការអនុវត្ត និងទ្រឹស្តី និងធានា "ការជឿទុកចិត្តរបស់សាធារណជនក្នុងការគោរពតាមច្បាប់នោះ" ដំណើរការស៊ើបអង្កេតទាំងស្រុងបានប្រឈមមុខនឹងការចោទប្រកាន់ពីការប្រកាន់បក្សពួក ភាពលម្អៀង និងអសមត្ថភាព ដែលអាចជះឥទ្ធិពលដល់កេរតំណែលដែលតុលាការរំពឹងនឹងបន្សល់ទុក ។ ជាក់ស្តែងជាងនេះ សហចៅក្រមស៊ើបអង្កេតមិនបានកោតសរសើរជនរងគ្រោះរួមទាំងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនចំពោះការចូលរួមរបស់អ្នកទាំងអស់នេះនៅក្នុងដំណើរការស៊ើបអង្កេតរបស់ខ្លួនទេ ។ នេះគឺជាការបំពានលើលក្ខន្តិកៈរបស់អង្គបុរេជំនុំជម្រះដែលចែងថា"ជនរងគ្រោះត្រូវតែបានដឹងពុំពីដំណើរការរបស់តុលាការ ហើយសិទ្ធិរបស់ជនរងគ្រោះត្រូវតែបានគោរពនៅក្នុងអំឡុងដំណើរការនីតិវិធីទាំងមូល" ។

ស្រដៀងគ្នានេះដែរ សកម្មភាពរបស់សហចៅក្រមស៊ើបអង្កេតស៊ើរតែខ្វះខាតទាំងស្រុងនូវឯករាជ្យភាពដែលជាកត្តាសំខាន់ក្នុងការជំរុញឲ្យមានការស៊ើបអង្កេតដែលប្រកបដោយប្រសិទ្ធភាព ។ បើទោះបីជាខ្វះខាតនូវការស៊ើបអង្កេតដ៏ពេញលេញមួយក៏ដោយ ក៏សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបញ្ចប់ដំណើរការស៊ើបអង្កេតកើតចេញក្រោយពេលដែលរដ្ឋាភិបាលកម្ពុជាបានបង្ហាញពីការមិនគាំទ្រយ៉ាងដាច់ខាតចំពោះការកាត់ទោសលើសំណុំរឿង០០៣ ។ មតិសាធារណជនដែលថាចៅក្រមអាចនឹងទទួលរងការគាបសង្កត់ពីរដ្ឋាភិបាលបានបណ្តាលឲ្យមានការជឿជាក់ជាទូទៅថា ការជ្រៀតជ្រែកពីភាគីខាងក្រៅជាដាងការបេ្តជ្ញាចិត្តដើរតាមអង្គហេតុបានជះឥទ្ធិពលដល់ការចេញសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ។

ចុងក្រោយ ក្រៅពី "ការចាត់វិធានការភ្លាមៗក្រោយពេលដែលការដាក់ពាក្យបណ្តឹងជាផ្លូវការត្រូវបានធ្វើឡើងនោះ" ការដែលសហចៅក្រមស៊ើបអង្កេតអនុញ្ញាតឲ្យការស៊ើបអង្កេតរបស់ខ្លួនផ្អាកដំណើរការរហូតដល់រយៈពេលម្ភៃខែដែលនៅក្នុងអំឡុងពេលនោះគ្មានការស៊ើបអង្កេតបន្ថែមណាមួយ ត្រូវបានធ្វើឡើងនេះ បានឆ្លុះបញ្ចាំងឲ្យឃើញថាសហចៅក្រមស៊ើបអង្កេតមិនបានជម្រាបជនសង្ស័យពីការចុះទៅធ្វើការស៊ើបអង្កេតតាមផ្លូវរបស់ខ្លួន ហើយចំណែកឯជនរងគ្រោះវិញមិនទទួលបានព័ត៌មានឲ្យទាន់ពេលវេលាឡើយ ។

ដូច្នេះ ជំនួសឲ្យការស្តារឡើងវិញនូវការជឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធច្បាប់ និងការពារសិទ្ធិរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី នោះការស៊ើបអង្កេតលើសំណុំរឿង០០៣ដែលត្រូវបានដំណើរការឡើងរហូតមកដល់សព្វថ្ងៃនេះបានបណ្តាលឲ្យតុលាការខ្មែរក្រហមជាប់ពាក់ព័ន្ធនឹងបទចោទប្រកាន់លើការអសមត្ថភាពផ្នែកច្បាប់ ការជាប់ពាក់ព័ន្ធជាមួយនឹងភាគីខាងក្រៅ និងភាពលម្អៀងរវាងសិទ្ធិរបស់ជនរងគ្រោះ និងជនជាប់ចោទដែលបញ្ហាទាំងអស់បានប៉ះពាល់ដល់សមត្ថភាពរបស់តុលាការក្នុងការស្វែងរកការពិតពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយខ្មែរក្រហម ។ ដូច្នេះ ការស៊ើបអង្កេតដែលមានលក្ខណៈគ្រប់គ្រាន់អាចជួយទប់

ស្កាត់ផលប៉ះពាល់ខាងលើ ហើយផ្ដល់ការពេញចិត្ត និងសំណងដល់ប្រជាជនកម្ពុជាទាំងមូលបាន ។

សំខាន់ជាងគេ សំណុំរឿង០០៣ចាំបាច់ត្រូវតែបញ្ចប់ដោយសារតែមូលហេតុអនុវត្តច្បាប់មួយចំនួន ។ យ៉ាងណាមិញ ការបញ្ចប់លើការស៊ើបអង្កេតនេះមិនត្រូវផ្អែកលើដំណើរការស៊ើបអង្កេតក្លែងក្លាយដាច់ខាត ។ ប្រជាជនកម្ពុជាសមតែនឹងទទួលបាននូវការស្ដារឡើងវិញនូវសិទ្ធិក្នុងការដឹងពិត សិទ្ធិក្នុងការទទួលបានយុត្តិធម៌ និងសិទ្ធិក្នុងការទទួលបានសំណងរបស់អ្នកទាំងអស់គ្នា ។ ហេតុដូច្នេះ ដំណើរការស៊ើបអង្កេតលើសំណុំរឿង០០៣ប្រកបដោយប្រសិទ្ធភាពអាចនឹងជួយធានាឲ្យបាននូវសិទ្ធិទាំងអស់នេះ ។ បន្ថែមលើនេះ ដោយគ្មានការបែងចែក និងពង្រឹងបទដ្ឋានសម្រាប់ដំណើរការស៊ើបអង្កេត នោះតុលាការខ្មែរក្រហមរួមទាំងអង្គការសហប្រជាជាតិដែលបានផ្ដល់ជំនួយ អ្នកជំនាញ និងសិទ្ធិអំណាចឲ្យតុលាការនេះអាចនឹងបែរមកការពារជនដៃដល់នៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដែលពិភពលោកមិនទាន់បានដឹង និងឃើញនៅឡើយ នោះឲ្យរួចផុតពីការដាក់ទណ្ឌកម្ម ហើយបែរជាដាក់ទម្ងន់ជាជាងបញ្ឈប់ អំពើនិទ្ទណ្ឌភាពទៅវិញទេ ។

តាមរយៈការអនុវត្តតេស្ដដែលមានចែងនៅក្នុងបទដ្ឋានអន្តរជាតិ អង្គបុរេជំនុំជម្រះអាចពង្រឹងបទដ្ឋានដែលចាប់ផ្ដើមកើតមាននៅក្នុងផ្នត់គំនិតរបស់ខ្លួន និងធានាឲ្យបាននូវភាពស៊ីសង្វាក់គ្នានៅក្នុងការវាយតម្លៃលើដំណើរការស៊ើបអង្កេត ។ សំខាន់ជាងនេះ តាមរយៈការតម្រូវឲ្យសហចៅក្រមស៊ើបអង្កេតប្រកាន់យកបទដ្ឋានស្ដីពីភាពមិនលម្អៀង ការប្រកាន់តាមគោលការណ៍ និងសីលធម៌ខ្ពស់ដែលមានចែងនៅក្នុងឯកសារបង្កើតតុលាការខ្មែរក្រហម និងតាមរយៈការជំរុញឲ្យមានដំណើរការស៊ើបអង្កេតដែលប្រកបដោយប្រសិទ្ធភាព នោះអង្គបុរេជំនុំជម្រះអាចធានាឲ្យបាននូវកេរដំណែលល្អរបស់តុលាការខ្មែរក្រហម និងអនុញ្ញាតឲ្យតុលាការខ្មែរក្រហមបំពេញតួនាទីរបស់ខ្លួនក្នុងការស្វែងរកយុត្តិធម៌ និងការផ្សះផ្សាជាតិដែលតុលាការខ្មែរក្រហមមានគោលបំណងប្រគល់ឲ្យប្រជាជនកម្ពុជាទាំងមូល ។ **ថាឆាណា សៃណាធី**

# ប្រកាសរកឪពុកមា និងក្រុមគ្រួសាររបស់គាត់



ខ្ញុំបាទឈ្មោះ ប៊ូណាតាន់ តាំ សព្វថ្ងៃរស់នៅទីក្រុងតូរ៉ុនតូ ប្រទេសកាណាដា ។ ខ្ញុំបាទសូមប្រកាសសួររកឪពុកមារបស់ខ្ញុំនិងគ្រួសាររបស់គាត់ដែលបានបែកគ្នានៅពេលដែលយោធាខ្មែរក្រហមវាយចូលទីក្រុងភ្នំពេញក្នុងខែមេសា ឆ្នាំ១៩៧៥ ។ ឪពុកមារបស់ខ្ញុំឈ្មោះ តាំ ណាំសែ្ស ហើយភរិយារបស់គាត់ឈ្មោះ ជុយ ណៃ ។ គាត់ទាំងពីរមានកូនប្រាំពីរនាក់ ប្រុសប្រាំនាក់ និងស្រីពីរនាក់ គឺ ១) តាំង គីមគួង, ២) តាំង ស្សយទី, ៣) តាំង គីមហៃ, ៤) តាំង គីមស៊ុង, ៥) តាំង ឥស្សី, ៦) តាំង អាមួយ និង ៧) តាំង មេងហេក ។

គ្រួសារនេះធ្លាប់រស់នៅផ្សារកាប់គោមុនរបបខ្មែរក្រហម ។ នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៩ គ្រួសារនេះត្រូវបានជម្លៀសទៅនៅស្រែក្រោម ឬស្រែស្អាង ក្នុងស្រុកស្អាង ខេត្តកណ្ដាល ហើយតាំងពីពេលនោះមក ខ្ញុំមិនដែលទទួលដំណឹងអ្វីសោះពីគ្រួសាររបស់គាត់ ។ ប្រសិនបើមា ឬបងប្អូនបានឮពីដំណឹងនេះ សូមទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈអាសយដ្ឋានផ្ទះលេខ ៦៦ ផ្លូវព្រះសីហនុ រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១៦ ៨៧៦ ៦៩២ ឬទាក់ទងមកខ្ញុំបាទផ្ទាល់តាមរយៈអ៊ីម៉ែល jon7888@gmail.com ។

***សូមអរគុណ!***

# ស៊ីវ ធួន : ដំណើរឆ្លងកាត់របបខ្មែរក្រហម


ស៊ីវ ធួន ឆ្នាំ១៩៨៤

ខ្ញុំមានស្រុកកំណើតនៅក្នុងឃុំសំរោង ស្រុកបន្ទាយមាស ខេត្តកំពត ។ ស្រុកនេះលាតសន្ធឹងពីជើងទៅត្បូងរហូតដល់ស្រុកកំពង់ត្រាច ដែលសំបូរទៅដោយដំណាំស្រូវ ពោត ស្វាយ និងដូង ស្ថិតនៅវាលរាបដែលមានភ្នំព័ទ្ធជុំវិញមានសណ្ឋានដូចពងក្រពើ ។ ស្រុកបន្ទាយមាស មានផ្លូវថ្នល់មួយខ្សែ ដែលកសាងនៅក្នុងសម័យអាណានិគមនិយមបារាំង និងមានផ្លូវរថភ្លើងមួយខ្សែទៀត ភ្ជាប់ពីរាជធានីភ្នំពេញទៅកាន់កំពង់ផែអន្តរជាតិក្រុងព្រះសីហនុ កសាងនៅក្នុងសម័យសង្គមរាស្ត្រនិយម ។ តាំងពីបុរាណ តំបន់នេះមានច្រកចេញចូលមួយឈ្មោះថា ច្រកសៀម ដែលមានសណ្ឋានផ្លូវបត់បែនដូចពស់លូន ហើយស្ងាត់ជ្រងំនៅត្រង់មុំចម្ការម៉ែសាក់ ។ អ្នកធ្វើដំណើរឆ្លងកាត់ខ្លាចរអាគ្រប់ៗគ្នាពីព្រោះតំបន់នេះមានប្រវត្តិដ៏យូរលង់ណាស់មកហើយ ដែលដំបូងគឺជាសមរភូមិដែលទ័ពសៀមនឹងខ្មែរច្បាំងគ្នា ហើយទ័ពខ្មែរបានយកសញ្ជ័យលើទ័ពសៀមយ៉ាងបុិនប្រសព្វដោយល្បិចកល ។ សម័យក្រោយមកទៀត ច្រកសៀមជាកន្លែងដែលចលនាឥស្សរៈ និងក្រុមចោរព្រៃធ្វើជាជម្រក ហើយចាប់តាំងពីឆ្នាំ១៩៧០មក ក៏ជាកន្លែងដែលខ្មែរក្រហមប្រើប្រាស់ជាបន្ទែកសម្រាប់ធ្វើសកម្មភាពប្រឆាំងនឹងទ័ព លន់ នល់ ។

### កុមារភាព

នៅក្នុងវ័យកុមារ ឪពុកម្តាយបានបញ្ជូនខ្ញុំឲ្យទៅរៀននៅសាលាបឋមសិក្សាបរិវាស ដែលមានចម្ងាយប្រមាណតែ២៥០ម៉ែត្រពីផ្ទះរបស់ខ្ញុំ ។ ដំបូង ការសិក្សានៅក្នុងថ្នាក់ពុំសូវមានការលំបាកសម្រាប់ខ្ញុំទេ ព្រោះឪពុកខ្ញុំធ្លាប់ជាអ្នកបួស បានបង្រៀនព្យញ្ជនៈ និងស្រៈឲ្យខ្ញុំចេះសរសេរ និងអានស្ទាត់រួចហើយ ។ ប៉ុន្តែពេលខ្ញុំរៀនដល់ថ្នាក់៩ (សង្គមចាស់) សាលាក៏បន្ថែមកម្មវិធីបង្រៀនភាសាបារាំងតាមសៀវភៅ លោក ចែត ឆែម ពេលនោះសិស្សត្រូវរៀនប្រកបព្យញ្ជនៈ និងស្រៈផ្សំដូចប្រកបអក្សរខ្មែរ ។ ខ្ញុំរៀននៅសាលាបរិវាសដល់ថ្នាក់ទី៧ ទើបប្រលងកុងគួរជាប់ (ប្រលងបញ្ចប់កម្រិតថ្នាក់បឋមសិក្សាដើម្បីបន្តចូលរៀនកម្រិតមធ្យមសិក្សាបឋមភូមិ) នៅអនុវិទ្យាល័យទូកមាស ដែលទើបតែបើកទទួលសិស្សឲ្យចូលរៀនបានរយៈពេលពីរឆ្នាំប៉ុណ្ណោះ ។ អនុវិទ្យាល័យនេះមានទីតាំងជាប់នឹងផ្លូវជាតិលេខ៣១ដែលស្ថិតខាងត្បូងផ្សារទូកមាសប្រហែលបីគីឡូម៉ែត្រ និងមានចម្ងាយប្រមាណដប់មួយគីឡូម៉ែត្រពីភូមិខ្ញុំ ។

### ចូលអនុវិទ្យាល័យ

នៅពេលនោះ ទោះបីខ្ញុំប្រលងជាប់ក៏ដោយ ក៏ពេលចូលរៀនដំបូង សិស្សម្នាក់ៗតម្រូវឲ្យបង់ថ្លៃសាលាចំនួន២.៥០០រៀល ដែលមានតម្លៃថ្លៃណាស់ ព្រោះបើគិតជាមាសស្មើនឹង៨ជី ។ ដោយសារថ្លៃសាលាមានតម្លៃខ្ពស់ដូច្នេះ ទើបសិស្សមួយចំនួនដែលឪពុកម្តាយមានជីវភាពខ្វះខាតបានសុំសាលាបង់រំលោះជាពីរបីដំណាក់កាល ។ រៀងរាល់ថ្ងៃ ខ្ញុំត្រូវជិះកង់ពីផ្ទះមកសាលារៀន

មួយថ្ងៃពីរគ្រឡប់ ព្រោះរៀនព្រឹក និងពេលល្ងាច ។ បន្ទាប់ពីរៀនរយៈពេលពីរឆ្នាំ ខ្ញុំក៏សុំផ្ទះបងប្អូនដែលស្ថិតនៅជិតសាលាស្នាក់នៅជាមួយ ព្រោះមានការយ៉ាប់យ៉ឺនដោយមានភ្លៀងធ្លាក់ច្រើននៅរដូវវស្សា និងខ្យល់បោកបក់ខ្លាំងនៅរដូវរងារ ដែលរំខានដល់ល្បឿនកង់មិនឲ្យស្ទុះទៅមុខបានស្រួល ទោះបីជាខំបញ្ចេញកម្លាំងធាក់យ៉ាងណាក្តី ក៏កង់ទៅមុខយឺតៗមិនទាន់ម៉ោងរៀន ។

នៅក្នុងថ្នាក់ ខ្ញុំបានជួបលោកសាស្ត្រាចារ្យក្មេងៗដែលបង្រៀនល្អ និងអាកប្បកិរិយាថ្លៃថ្នូរ សមជាអ្នកចេះដឹង ។ ដូច្នេះហើយ ទើបធ្វើឲ្យខ្ញុំមានទឹកចិត្តព្យាយាមសិក្សារៀនសូត្រដោយក្តីគោរពកោតក្រែង ។ មុខវិជ្ជាដែលខ្ញុំស្រឡាញ់ចូលចិត្តជាងគេគឺអក្សរសាស្ត្រខ្មែរ ប្រវត្តិវិទ្យា ភូមិវិទ្យា ដែលរៀនអំពីស្នាដៃអ្នកនិពន្ធល្បីនៅសម័យមុន និងស្គាល់តួអង្គប្រវត្តិសាស្ត្រ ដ៏ល្បីៗលើពិភពលោក ព្រមទាំងប្រទេសប្លែកៗដែលមានការរីកចម្រើន ។ នៅរៀងរាល់ឆ្នាំ ខ្ញុំតែងតែជួបនឹងមិត្តភក្តិថ្មីៗដែលទើបនឹងឡើងថ្នាក់បានប្រណាំងប្រជែងគ្នាពេញមួយឆ្នាំសិក្សា ។ ខ្ញុំសប្បាយចិត្តយ៉ាងខ្លាំងអំពីលទ្ធផលនៃការសិក្សាដែលទទួលបាន ។ នៅទសវត្សរ៍៦០ សាលាមានវិន័យតឹងរឹងខ្លាំងណាស់ចំពោះសិស្សអវត្តមាន ដោយគ្មានមូលហេតុ នាយកសាលានឹងហៅមកដាក់វិន័យមិនខាន ។ ចំណែកការទាក់ទងគ្នារវាងសិស្ស ប្រុស និងសិស្សស្រីតាមរយៈសរសេរសំបុត្រដោយជួរមនោសញ្ចេតនា បើចាប់បាននឹងត្រូវលុបឈ្មោះសិស្សនោះចេញពីបញ្ជីសិក្សាទាំងពីរនាក់ ។ សិស្សដែលរៀនពូកែចាប់ពីលេខមួយដល់លេខបី លោកគ្រូ និងនាយកសាលាតែងតែលើកសរសើររៀងរាល់ខែ ។

## បាតុកម្មសិស្ស

នៅក្នុងឆ្នាំ១៩៦៧ សិស្សសាលាបានធ្វើបាតុកម្មឥតឈប់ឈរនៅគ្រប់ទីខ្វែង ដែលផុសចេញពីចលនារបស់ ខៀវ សំផន, ហ៊ូ នឹម និង ហ៊ូ យន់ ដែលសុទ្ធតែជាបញ្ញវន្តមានទិន្នាការកុម្មុយនីស្ត និងធ្លាប់ទៅសិក្សានៅប្រទេសបារាំង ។ ចលនាកុម្មុយនីស្តនោះ បានចាត់ទុកអ្នកមានទ្រព្យសម្បត្តិ និងនាយទុនដែលភាគច្រើនជាជនជាតិចិន ជាអ្នកជិះជាន់ កេងប្រវ័ញ្ច និងជាឈ្លើងជញ្ជក់ឈាមប្រជាជនក្រីក្រ ។ គំនិតប្រឆាំងនេះ បានជ្រួតជ្រាបចូលក្នុងជួរសិស្សនិស្សិត បញ្ញវន្ត ដែលកំពុងស្រលាញ់ឧត្តមគតិ និងសង្គមស្អាតស្អំយ៉ាងឆាប់រហ័ស ។ បាតុកម្មក៏បានផ្ទុះមុនគេនៅក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម ដោយសិស្សនៅវិទ្យាល័យគន្ធបុប្ផាបាននាំគ្នាយកដើមគមកដាក់រាំងផ្លូវជាតិលេខ៧ ដើម្បីស្ទាក់រថយន្តឈ្នួល១២ បាំងរបស់ក្រុមហ៊ុនផ្លូនហាក់ដឹកអ្នកដំណើរពីភ្នំពេញទៅក្រចេះ នៅចំពីមុខវិទ្យាល័យគន្ធបុប្ផា ។ បាតុករបានដេញអ្នកដំណើរចុះចេញពីរថយន្ត រួចហើយដុតឡានចោល ដើម្បីសងសឹកចំពោះរថយន្តដែលបានបើកកិនសិស្សសាលាម្នាក់ស្លាប់នៅពេលដែលត្រឡប់មកពីមើលលទ្ធផលប្រឡងពេទ្យនៅភ្នំពេញកាលពីយប់ថ្ងៃមុន ។ សូមបញ្ជាក់ថា ស្រុកព្រៃឈរជាមណ្ឌលតំណាងរាស្ត្ររបស់ ហ៊ូ នឹម ហើយស្រុកកងមាសដែលនៅជាប់គ្នាខាងត្បូងស្រុកព្រៃឈរ គឺជាមណ្ឌលតំណាងរាស្ត្ររបស់ ហ៊ូ យន់ ។

ដំណឹងពីមរណៈភាពរបស់សិស្សរូបនេះ បានផ្សព្វផ្សាយយ៉ាងឆាប់រហ័សពាសពេញផ្ទៃប្រទេសតាមរយៈសារព័ត៌មានសុជីវធម៌ដែលមានលោក នុត ឈឿម ជាចាងហ្វាង ធ្វើឲ្យសិស្សសាលានៅទូទាំង ប្រទេសមានកំហឹង និងស្អប់ខ្ពើមវណ្ណៈនាយទុនកាន់តែខ្លាំង ។ ក្រោយមក ចលនាបាតុកម្មប្រឆាំងនាយទុននេះបានផ្ទុះឡើងជាបន្តបន្ទាប់នៅតាមបណ្តាខេត្តនានា ដែលធ្វើរថយន្តឈ្នួលខ្លាចរអាមិនហ៊ានបើកលឿនដូចពីមុន នៅពេលដែលសិស្សចេញពីសាលា ជាពិសេសគឺម៉ោង៥ល្ងាច ។ នៅវេលាម៉ោង៩ព្រឹក ឆ្នាំ១៩៦៧ មានសិស្សសាលាមកពីអនុវិទ្យាល័យទូកមាសជាច្រើននាក់ចាប់ពីថ្នាក់ទី៣ដល់ថ្នាក់ទី៥ បានប្រមូលផ្តុំគ្នា រួចហើយជិះកង់ទៅវាយហាងគុយទាវរបស់ជនជាតិចិននៅផ្សារទូកមាសបណ្តាលឲ្យខូចខាតសម្ភារៈយ៉ាងច្រើន ដោយសារមានកំហឹងពីថ្ងៃមុន កើតចេញពីសម្តីចិនហាងគុយទាវមើលងាយសិស្សថា គ្មានលុយស៊ីគុយទាវ ។ ចំណែកសិស្សវិញ បានចោទថាក្រុមនាយទុនចេះតែតម្លើងថ្លៃទំនិញស្រេចនឹងចិត្ត កាលពីមុនគុយទាវមួយចានបីរៀល ឥឡូវនេះឡើងដល់ប្រាំរៀល ។

## ឈប់រៀនទាំងបង្ខំ

ព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេច សីហនុ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ បានធ្វើឲ្យមានស្ថានភាពច្របូលច្របល់យ៉ាងខ្លាំងក្នុងចំណោមគ្រូបង្រៀន សិស្ស និស្សិត មន្ត្រីរដ្ឋការ និងប្រជាជន ។ ខ្ញុំបានផ្អាកការសិក្សាត្រឹមថ្នាក់ទី២ (បច្ចុប្បន្នថ្នាក់ទី

១០) ។ នៅពេលនោះ សង្គ្រាមក៏បានផ្ទុះឡើងពាសពេញផ្ទៃប្រទេសកម្ពុជា បណ្តាលមកពីកងទ័ពយៀកកុងចូលមក ហើយយកលេសថា មកជួយសម្តេច សីហនុ ឲ្យឡើងកាន់អំណាចវិញ ចំណែកកងទ័ពរដ្ឋការរបស់វៀតណាមខាងត្បូង (ធីវគី) បានប្រកាសថានឹងមកជួយការពាររដ្ឋាភិបាលសាធារណរដ្ឋខ្មែររបស់លោក លន់ នល់ ។ រៀងរាល់ថ្ងៃ នៅក្នុងស្រុកទូកមាស ខ្ញុំឃើញអ្នកស្លាប់ របួស ដែលកើតឡើងពីអំពើឆក់ប្លន់ទ្រព្យសម្បត្តិប្រជាជនខ្មែរ ធ្វើឡើងដោយកងទ័ពធីវគី រហូតដល់មានការដុតបំផ្លាញផ្ទះសម្បែងថែមទៀតផង ។ មិនត្រឹមតែប៉ុណ្ណោះ កងទ័ពទាំងនោះបានចាប់រំលោភស្ត្រីនៅក្នុងភូមិ ធ្វើទារុណកម្មលើរាងកាយបុរស ឬសម្លាប់ចោលដោយចោទថា ចូលដៃជើងជាមួយខ្មាំង ។ សាលារៀនតាមខេត្តមួយចំនួនត្រូវបានបិទទ្វារ ចំណែកសិស្សដែលឈប់រៀនហើយមានកាតព្វកិច្ចចូលធ្វើជាកុម្មង់ដូយាមសាលា ។ យើងជាសិស្សមានការសោកស្តាយចំពោះការសិក្សា ដោយឃើញសាលាក្លាយជាបន្ទាយ ឬទីតាំងកាំភ្លើងធំធុន១០៥ មីលីម៉ែត្រ ។

នៅអំឡុងខែខសភា ឆ្នាំ១៩៧០ នៅចម្ងាយបីគីឡូម៉ែត្រប៉ែកខាងត្បូងអនុវិទ្យាល័យទូកមាស កងទ័ពរដ្ឋការ (វៀតណាមខាងត្បូង) បានធ្វើការវាយប្រយុទ្ធយ៉ាងខ្លាំងក្លាទៅលើកងទ័ពយៀកកុងដើម្បីដណ្តើមអាវុធដែលគេលាក់ទុកក្នុងរូងភ្នំកៀនដុំសម្រាប់ត្រៀមធ្វើសង្គ្រាមយូរអង្វែងក្នុងប្រទេសកម្ពុជា ។ ការវាយប្រយុទ្ធគ្នានេះ បានអូសបន្លាយអស់រយៈពេលកន្លះខែ ដោយមានការគាំទ្រពីកងកាំភ្លើងធំ កងរថក្រោះ និង យន្តហោះធុនស្កាយរ៉េដឌ័រ របស់ទ័ពអាកាសវៀតណាមខាងត្បូងដែលគាំទ្រដោយសហរដ្ឋអាមេរិក ។ កងទ័ពទាំងសងខាងរងការខូចខាតសម្ភារយ៉ាងធ្ងន់ធ្ងរ និងបាត់បង់ពលទាហានអស់ជាច្រើននាក់ ។ នៅក្នុងអំឡុងពេលប្រតិបត្តិការនេះ កងទ័ពរដ្ឋការវៀតណាមខាងត្បូងបានទទួលជ័យជម្នះ និងរឹបអូសកាំភ្លើងម៉ាក CKC បានចំនួន៧.០០០ ដើម យកមកគរនៅផ្សារដើមមៀនស្ថិតនៅជើងទីរួមស្រុកទូកមាសរួចប្រគល់ឲ្យចៅហ្វាយស្រុក អ៊ុច សាខាំខន ពាក់សក្តិបួនកន្លះ (អតីតជាសាស្ត្រាចារ្យ) ជាអ្នកគ្រប់គ្រង ។

នៅរដូវវស្សា ភ្លៀងដើមឆ្នាំចាប់ផ្តើមធ្លាក់មកជាច្រើនមេ បណ្តាលឲ្យផ្លូវបែកភក់ និងមានទឹកដក់ពេញវាលស្រែ ។ នៅតាមផ្លូវពីកំពង់ត្រាចទៅចំការដូងមានការវាយប្រយុទ្ធគ្នាយ៉ាងសាហាវ ដោយបន្សល់ទុកឆ្អឹងរថយន្តឆេះខ្មោចជាច្រើនគ្រឿងនៅរាយប៉ាយពាសពេញផ្លូវ ហើយក្នុងមួយថ្ងៃៗ កងទ័ព លន់ នល់ ដែលយាមការពារបណ្តាក់គ្នានៅតាមបណ្តោយផ្លូវនេះតែងតែប្រកាសភាពអាសន្នប្រាប់ប្រជាជនចំនួន៤-៥ដងក្នុងមួយថ្ងៃ ដើម្បីឲ្យប្រុងប្រយ័ត្នពីការវាយប្រហាររបស់កងទ័ពរំដោះ ។ នៅដើមខែខសភា កងទ័ពយៀកកុងបានវាយសន្ធាប់យកសាលាខេត្តកំពត និងកាន់កាប់អស់រយៈពេលមួយយប់ ។ ប៉ុន្តែក្រោយពីមានការវាយប្រយុទ្ធយ៉ាងខ្លាំងក្លាពីសំណាក់កងឯកភាពដែលបញ្ជូនមកពីខេត្តព្រះវិហារ កងទ័ពយៀកកុងទន់ដៃ ក៏ដកចេញអស់ ។ នៅក្រោយព្រឹត្តិការណ៍នេះ តុលាការសឹកបានបើកសវនាការកាត់ទោសប្រហារជីវិតចៅហ្វាយខេត្ត តុំ សារ៉ាវ៉ាន់ ពាក់សក្តិ៥ ដោយចោទថា ក្បត់ចូលដៃជើងជាមួយកងទ័ពយៀកកុងគាំទ្រសម្តេចឪ ។

## ភូមិកំណើតជាកន្លែងគ្រោះថ្នាក់

ក្រោយពីឈប់រៀនមួយរយៈ ខ្ញុំបានត្រឡប់មករស់នៅផ្ទះជាមួយឪពុកម្តាយក្នុងតំបន់រំដោះដោយក្រៀមក្រំ ។ ផ្លូវជាតិលេខ៣១ ដែលជាផ្លូវសំខាន់តភ្ជាប់ពីតាកែវទៅកំពត ត្រូវបំផ្លាញដោយពួករំដោះ ដោយកាត់ផ្តាច់ជាកង់ៗ ព្រមទាំងកាន់កាប់ដោយអន្ទើរជាច្រើនកន្លែង ។ ផ្សារត្រាំសសរដែលជាទីប្រជុំជនឃុំសំរោងដែលធ្លាប់មានមនុស្សកុះករទៅមកទិញអីវ៉ាន់ ឬម្ហូបអាហារត្រូវអន្តរាយទាំងស្រុង ហើយក្លាយជាបន្ទាយទាហានរបស់ទ័ពកន្សែងសនៃកងពលលេខ៣២ ។ ខ្ញុំតែងតែឮប្រជាជនក្នុងភូមិជជែកគ្នាពីស្ថានការស្រុកទេស ជាពិសេសអំពីជ័យជម្នះរបស់កងទ័ពយៀកកុងលើរបបសាធារណរដ្ឋខ្មែរ (ចាស់ៗភាគច្រើននិយមសម្តេចឪ ចំណែកក្មេងសិស្សសាលានិយមរបប លន់ នល់) ។ សិស្សដែលចេញទៅរៀននៅទីក្រុងភ្នំពេញ ឬទីរួមខេត្តនានា ត្រូវខ្មែរក្រហមចោទថា “អាក្មេងគំនិតចក្រពត្តិ” ។ ក្រោយមក ដោយមិនអាចទ្រាំទ្រនឹងការរើសអើង មនោគមវិជ្ជាពីសំណាក់ប្រជាជនក្នុងភូមិមិនបានតទៅទៀត មកពីមានទស្សនៈខុសគ្នា (ពេលនោះសូម្បីតែឪពុកនិងកូន មានិងក្មួយ ក៏ចងអាឃាតនឹងគ្នាដែរ ព្រោះមាននិន្នាការនយោបាយខុសគ្នា) ។ ម្យ៉ាងទៀត ដោយស្តាយការសិក្សា ខ្ញុំក៏សម្រេចចិត្តចាកចេញពីឪពុកម្តាយទាំងទឹកភ្នែក ដើម្បីទៅចូលរៀនបន្ត

ថ្នាក់ទី១ (សង្គមចាស់) នៅវិទ្យាល័យតានី ។ ដោយមានការប្តេជ្ញាជាមួយមិត្តភក្តិរៀនជំនាន់គ្នាថា នឹងរៀនរហូតដល់បញ្ចប់ថ្នាក់មធ្យមសិក្សា ជាពិសេស គឺត្រូវប្រលងយកសញ្ញាបត្របាក់ឌុបឲ្យបាន ។ ខ្ញុំរៀននៅវិទ្យាល័យតានីបានមួយឆ្នាំ ទើបយោធាខ្មែរក្រហមវាយដណ្តើមយកបាននៅរដូវប្រាំងឆ្នាំ១៩៧១ ។ ខ្ញុំក៏ដូចជាសិស្សដទៃទៀតដែរ បាននាំគ្នាភៀសខ្លួនមកកាន់ខេត្តតាកែវតាមផ្លូវជាតិលេខ២ ដែលមានការការពារពីកងពលលេខ៣២យ៉ាងរឹងមាំ ក្រោមបញ្ជារបស់លោកវរសេនីយ៍ទោ ចៅ ហៃសៀន ឬទ័ពកន្ទេងស ។ ផ្លូវជាតិនេះ មានសភាពទ្រុឌទ្រោមយ៉ាងខ្លាំង ដោយកន្លែងខ្លះត្រូវកាត់ផ្តាច់ ហើយស្ពានជាច្រើនកន្លែងត្រូវបាក់ ដោយគ្រាប់មីនជាពិសេស ស្ពានស្វាយព្រៃ ដែលជាស្ពានសំខាន់ដែលតភ្ជាប់ទីរួមខេត្តតាកែវ ជាមួយទីក្រុងភ្នំពេញត្រូវរមួលផ្តៀងមួយចំហៀង ដោយសារគ្រាប់មីនរបស់ពួកយៀកកុង ។ រថយន្តធំៗមិនអាចបើកបរលើផ្លូវនេះបានដូចពីមុនទៀតទេ គឺមានតែរ៉ឺម៉ក់ម៉ូតូប៉ុណ្ណោះ ដែលប្តូរនឹងគ្រោះថ្នាក់ដឹកអ្នកដំណើរពីតាកែវទៅភ្នំពេញ ព្រោះពេលនោះការរត់រ៉ឺម៉ក់ម៉ូតូរកកម្រៃបានច្រើន ។ នៅតាមផ្លូវតែងតែមានការវាយប្រយុទ្ធគ្នាជាញឹកញាប់រវាងកងទ័ពខ្មែរក្រហម និងកងទ័ព លន់ នល់ ដែលធ្វើឲ្យប្រជាជនមានការភិតភ័យយ៉ាងខ្លាំង នៅពេលធ្វើដំណើរតាមបណ្តោយផ្លូវនោះម្តងៗ តែងតែលើកដៃបន់ស្រន់គ្រប់បែបយ៉ាងដើម្បីឲ្យព្រះនិងគុណឪពុកម្តាយជួយ ។

នៅទីក្រុងភ្នំពេញ ពីមុនមានមុខមាត់ស្រស់បស់ដោយសួនច្បារធំទូលាយ ឥឡូវណែនណាន់ ដោយផ្ទះតូចៗ បាំងក្តារដើមស្រល់ ដែលយកពីកេះគ្រាប់ និងដំបូលប្រក់ដោយស័ង្កសី ឬប្រក់ក្រដាសសម្បកគ្រាប់ផ្លោង តម្រៀបគ្នាជាជួរៗក្នុងបឹងមានពណ៌ប្រផេះលាតសន្ធឹងពីលើព្រៃត្រាវដែលជាសំបុកមូស រួមរឹតដោយគគ្រួនព្រៃដុះចេញពីទឹកកខ្វក់ ជាពិសេសនៅម្តុំទួលគោក និងបឹងទំពុន ។ ចំណែកនៅតាមវត្តអារាម ក៏មានមនុស្សច្រើន ជាពិសេសសិស្សដែលរត់មកពីតំបន់រំដោះ ហើយដែលគ្មានបងប្អូនពឹងពាក់បាន ទៅរស់នៅទ្រហឹងអឹងកងដូចសត្វចូលសំបុកពេញវត្តអារាម ។ សូម្បីតែនៅលើដំបូលផ្ទះថ្មក៏មានសង់កូនខ្ទមឈើបន្ទុបរកេតរកូតពីលើពាសពេញទីក្រុងដែរ ។

នៅមុនឆ្នាំ១៩៧០ ទីក្រុងភ្នំពេញមានប្រជាជនប្រមាណជាង៦០០.០០០នាក់ប៉ុណ្ណោះរស់នៅ ប៉ុន្តែក្រោយមក ប្រជាជនបានកើនឡើងរហូតដល់ជាងបីលាននាក់ក្នុងចំណោមប្រជាជនប្រាំពីរលាននាក់ ដែលភាគច្រើនជាប្រជាជនភៀសសឹក ។ អ្នកទាំងនោះបានបោះបង់ដីស្រែចម្ការ និងទ្រព្យសម្បត្តិមួយចំនួន ។ ចំណែកសម្ភារប្រើប្រាស់ បន្លែ ត្រី សាច់ និងផ្លែឈើគ្រប់ប្រភេទបានឡើងថ្លៃកាន់តែខ្ពស់ (ត្រីក្រាញ់ដឹកតាមកប៉ាល់ហោះពីខេត្តកំពង់ឆ្នាំងមកលក់នៅផ្សារថ្មី ១គីឡូក្រាមតម្លៃ៣.០០០រៀល) ដែលបណ្តាលឲ្យបុគ្គលិករដ្ឋការធ្វើកូដកម្មដើម្បីទាមទារដំឡើងប្រាក់ខែស្មើរជារៀងរាល់ខែ ពិសេសបុគ្គលិកមកពីក្រសួងសិក្សាធិការជាតិ ។ ការបើកប្រាក់បៀវត្សរ៍មានការយឺតយ៉ាវព្រោះរដ្ឋខ្វះថវិកាកងទ័ពដែលចេញច្បាំងនៅសមរភូមិបានធ្លាក់ទឹកចិត្តដោយសារពុំមានប្រាក់សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ ដូច្នេះហើយទើបគេយកកូនប្រពន្ធរបស់គេទៅរស់នៅក្នុងបន្ទាយជាមួយ ស៊ីអត់ស៊ីឃ្លាននៅក្នុងលេណដ្ឋាន ។ ដោយសាររដ្ឋបើកប្រាក់ខែពុំទៀងទាត់ និងពុំមានការឧបត្ថម្ភបន្ថែម ទើបនៅពេលប្រយុទ្ធម្តងៗកងទ័ពរបស់ លន់ នល់ តែងតែទទួលបរាជ័យដោយបាក់ទឹកចិត្ត ។ ចំណែកមេទាហានមិនបានចុះដាប់នៅក្នុងសមរភូមិប្រយុទ្ធទេ ប៉ុន្តែបានមករស់នៅក្នុងវីឡាស្កុកស្តម្ភក្នុងទីក្រុងការពារដោយពលទាហាន និង កាំភ្លើងយន្តដាក់លើដំបូលផ្ទះ ដើម្បីការពារគ្រួសាររបស់គេយ៉ាងសុខស្រួលគ្មានខ្វល់ពីអ្នកណាទាំងអស់ ។

## ចូលរៀនបន្ត

ខ្ញុំបានមកស្នាក់នៅជាមួយផ្ទះម្តាយមីងនៅទួលគោក ស្ថិតនៅចម្ងាយ៣០០ម៉ែត្រ ខាងលិចអង់តែនទូរទស្សន៍ទាំងរសើប ព្រោះយូរៗម្តងមានគ្រាប់ផ្លោងធ្លាក់មកពីទិសខាងកប់ស្រូវ ។ ខ្ញុំចុះឈ្មោះចូលរៀនបន្តនៅវិទ្យាល័យយុវជនស្រោចស្រង់ជាតិមានទីតាំងជាប់ពហុកីឡាដ្ឋានស្តាតចាស់ ដែលនៅទីនោះ មានសិស្សភៀសខ្លួនរាប់ពាន់នាក់មកពីតំបន់ខ្លាំងកាន់កាប់ ។ ទោះបីខ្ញុំបានចូលរៀននៅវិទ្យាល័យនេះហើយក៏ដោយ ក៏ខ្ញុំនៅតែពិបាកចិត្ត និងរៀនសូត្រមិនដាប់លាប់ដូចសិស្សដទៃទៀតដែរ ដោយសារខ្ញុំខ្វះប្រាក់សម្រាប់ចាយវាយ ម្យ៉ាងទៀតមានអារម្មណ៍មិនសូវល្អព្រោះបែកពីឪពុកម្តាយ និងបងប្អូនជាទីស្រលាញ់ ។

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧១ ពេលកងទ័ព លន់ នល់

បើកប្រតិបត្តិការចេនឡាទី២ ដើម្បីវាយកាន់កាប់ផ្លូវជាតិលេខ៦ និងវាយរំដោះខេត្តកំពង់ធំដែលគ្រប់គ្រងដោយខ្មែរក្រហមមកវិញ ។ ប្រតិបត្តិការនេះបានឆក់យកជីវិតទាហានទាំងខាង លន់ នល់ និងខាងខ្មែរក្រហមអស់ជាច្រើន ។ ក្រោយពីបរាជ័យនៅសមរភូមិចេនឡាមក កងទ័ព លន់ នល់ មានសមត្ថភាពត្រឹមតែការពារទីតាំងប៉ុណ្ណោះ ។ នៅវេលាយប់ ខ្ញុំតែងតែឮស្នូរកាំភ្លើងបាញ់ដោយទាហានដែលផឹកស៊ីស្រវឹង ជំរុញឲ្យសភាពការណ៍ក្នុងទីក្រុងភ្នំពេញកាន់តែមានភាពចលាចលខ្លាំង ។ នៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧២ វេលាម៉ោងប្រហែល៨យប់ មានបាតុភូតច័ន្ទគ្រាស (រាហ៊ូចាប់ច័ន្ទ) កើតឡើង ប្រជាជនក្នុងទីក្រុងភ្នំពេញបានផ្អើលចេញទៅមើល ខណៈនោះស្រាប់តែទាហានខ្លះទាញកាំភ្លើងយន្តបាញ់ឡើងទៅលើ ដើម្បីជួយព្រះច័ន្ទ ជាល្បែងលេងសើចសប្បាយ (នៅសម័យបុរាណប្រជាជនគ្រាន់តែនាំគ្នាគោះជៅត គោះរគាំង ឬទូងស្គរនៅតាមវត្តអារាមប៉ុណ្ណោះ) នៅពេលដែលក្បាលគ្រាប់កាំភ្លើងធ្លាក់មកវិញ ក៏ត្រូវប្រជាជនស៊ីវិល បណ្តាលឲ្យស្លាប់ និងរបួសជាច្រើននាក់ ។ ពីមួយថ្ងៃទៅមួយថ្ងៃ នៅទីក្រុងភ្នំពេញត្រូវយោធាខ្មែរក្រហមបាញ់ផ្លោងរ៉ុក្កែត១២២មីលីម៉ែត្រចូលមកឥតឈប់ឈរ ។ ផ្លូវផ្គត់ផ្គង់ស្បៀង ត្រូវបានកាត់ផ្តាច់ទាំងស្រុង ។ ពេលនោះប្រជាជនទីក្រុងភ្នំពេញហាក់ដូចជារស់នៅក្នុងជំរុំឃុំឃាំងមួយ ពីព្រោះមិនអាចចេញទៅក្រៅក្រុងបាន ដោយនៅជុំវិញទីក្រុងខ្មែរក្រហមកាន់តែរំកិលទីតាំងមកជិតជាលំដាប់ ហើយធ្វើការបាញ់ផ្គត់ពុំស្រាកស្រាន្ត ដោយបង្ករបួស និងស្លាប់ស្ទើររៀងរាល់ថ្ងៃ ។

នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៣ ជាថ្ងៃអវសានវាទនៃការបញ្ឈប់ការទម្លាក់គ្រាប់មកលើប្រទេសកម្ពុជាពីសំណាក់កងទ័ពអាកាសសហរដ្ឋអាមេរិកដែលមានចំនួន៥៣៩ពាន់តោន ច្រើនជាងការទម្លាក់គ្រាប់បែកទៅលើប្រទេសជប៉ុននៅក្នុងអំឡុងសង្គ្រាមលោកលើកទី២ ។ នៅពេលនោះ ទីក្រុងភ្នំពេញទទួលការវាយប្រហារកាន់តែខ្លាំងពីសំណាក់ខ្មែរក្រហម ។ នៅតាមមន្ទីរពេទ្យធំៗ ដូចជាពេទ្យ៧០១ (ពេទ្យព្រះមុន្នីវង្ស) ពេទ្យបុរីកីឡា (ពេទ្យ៤០០) ពោរពេញដោយជនស៊ីវិល និងកងទ័ពរងរបួស ដែលបញ្ជូនមកពីសមរភូមិដែលពេលខ្លះមន្ទីរពេទ្យគ្មានគ្រែគ្រប់គ្រាន់សម្រាប់ឲ្យអ្នកជំងឺដេកទេ ។ ដូច្នេះ អ្នកជំងឺភាគច្រើនដេកតម្រៀបគ្នានៅលើឥដ្ឋការ៉ូ ហើយស្រែកថ្ងូរខ្លាំងៗ ដោយឈឺនឹងមុខរបួស ។

## ផ្លូវឆ្ពោះទៅរកបរាជ័យនៃរបប លន់ នល់

នៅឆ្នាំ១៩៧៣ ដោយសារពុំមានសោហ៊ុយរៀនសូត្រ ខ្ញុំក៏សម្រេចចិត្តដាក់ពាក្យប្រលងចូលរៀននៅសាលាពេទ្យព្រោះមានប្រាក់អាហារូបត្ថម្ភ (នៅពេលនោះ ក្រសួងសុខាភិបាលត្រូវការជ្រើសរើសគ្រូពេទ្យបន្ថែមព្រោះចំនួនអ្នកជំងឺកាន់តែកើនឡើងនៅគ្រប់មន្ទីរពេទ្យ) ។ បន្ទាប់ពីរៀនចប់ ខ្ញុំបានចេញបម្រើការងារនៅពេទ្យព្រះមុនីវង្ស ដោយមានភារកិច្ចជាអ្នកចាក់ថ្នាំ និងព្យាបាលរបួស ។

នៅរដូវប្រាំងឆ្នាំ១៩៧៤ កងទ័ពខ្មែរក្រហមបានបាញ់ផ្លោងចូលបឹងសាឡាង ជាប់នឹងផ្សារដើមគ បណ្តាលឲ្យឆេះផ្ទះប្រជាជនរាប់រយខ្នង ខូចខាតទ្រព្យសម្បត្តិ និងស្លាប់ប្រជាជនជាច្រើននាក់ ។ ចំណែកអ្នករងរបួសត្រូវដឹកទៅព្យាបាលនៅមន្ទីរពេទ្យធំ (មន្ទីរពេទ្យព្រះកេតុមាលា) ប៉ុន្តែដោយសារអ្នកជំងឺមួយចំនួនរលាកខ្លាំងពេក ក៏ស្លាប់នៅមន្ទីរពេទ្យតែម្តង ។ រហូតដល់ដើមឆ្នាំ១៩៧៥ មានពាក្យចចាមអារាមថា រដ្ឋាភិបាលលោក ឡុង បូរ៉េត នឹងសុំយាងសម្តេចសីហនុមកវិញ ដែលធ្វើឲ្យប្រជាជននៅទីក្រុងទាំងអស់សប្បាយរីករាយក្នុងចិត្តជាខ្លាំងព្រោះសង្ឃឹមថា សង្គ្រាមនឹងបានចប់ ។ ប៉ុន្តែដំណឹងនោះ មិនមែនជាការពិតទេ ព្រោះខ្មែរក្រហមមិនយល់ព្រមតាមការស្នើនេះឡើយ ទោះបីជាមានអន្តរាគមន៍ពីអាមេរិកដើម្បីបញ្ចប់សង្គ្រាមក៏ដោយ ។

នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៥ លោក ហ្សេរ៉ាល់ ហ្វ័ត បានប្រកាសថា ប្រសិនបើគ្មានជំនួយរបស់អាមេរិក របប លន់នល់ នឹងត្រូវដួលរលំមិនខាន ។ ប្រធានាធិបតីបានស្នើសុំជំនួយប្រមាណជាង៣០០លានដុល្លារដើម្បីផ្តល់ឲ្យរដ្ឋាភិបាលសាធារណៈរដ្ឋខ្មែរ ប៉ុន្តែត្រូវបដិសេធដោយសភាសហរដ្ឋអាមេរិក ។ នៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៥ លោកសេនាប្រមុខ លន់ នល់ បានចាកចេញតាមឧទ្ធម្ភាគចក្រនៃកងយោធាសហរដ្ឋអាមេរិកដែលមានមូលដ្ឋាននៅលើនាវាទី៧ប្រចាំសមុទ្រចិន ឆ្ពោះទៅកាន់រដ្ឋហាវ៉ៃ ។

## ជម្លៀសចេញពីទីក្រុង

រហូតដល់ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ វេលាម៉ោង៩ព្រឹក នៅមុំផ្សារទួលទំពូង ក្រុងភ្នំពេញ ខ្ញុំឈរមើលយោធាខ្មែរក្រហមដើរ

ដាច់ៗពីគ្នាជាក្រុមតូចៗដែលមានគ្នាមិនលើសពី១៥នាក់ ដោយមានសម្លៀកបំពាក់ខ្មៅជូតក្បាលក្រមា មូរជើងខោមួយចំហៀងត្រឹមជង្គង់ ប្រដាប់ដោយកាំភ្លើងអាការ និងបេការ៉ង់ ភាគច្រើនជាក្មេងដែលមានអាយុមិនលើសពី១៤ទៅ១៥ឆ្នាំ មានលាយមនុស្សវ័យ៣០ទៅ៤០ឆ្នាំខ្លះៗ បានដើរក្នុងទីក្រុងដោយមានទឹកមុខមាំនិយាយថា សូមឲ្យបងប្អូនចេញពីទីក្រុងឲ្យបានឆាប់ ព្រោះយន្តហោះអាមេរិកនឹងមកទម្លាក់គ្រាប់បែកឥឡូវហើយ ។

បន្ទាប់ពីជួបជុំគ្នារួចហើយ គ្រួសារខ្ញុំបានរៀបចំខោអាវ កន្ទេលមុង អង្ករ ទឹកត្រី ទឹកស៊ីអ៊ីវ ព្រមទាំងចានឆ្នាំង ដាក់លើរទេះរុញដោយចិត្តស្ទាក់ស្ទើរ ដំបូងយើងធ្វើដំណើរយឺតៗ ព្រោះនឹកស្តាយទ្រព្យសម្បត្តិមួយចំនួនដែលមិនអាចមកជាមួយបានអស់ ។ នៅតាមផ្លូវពោរពេញដោយមនុស្សខ្លះដើរ ខ្លះរុញរទេះ ខ្លះរែកអីវ៉ាន់ខ្លះទូល ដោយទឹកមុខក្រៀមក្រំ និងស្ងប់ស្ងៀម ហើយនៅលើរទេះរុញក៏មានមនុស្សចាស់ជរា ឬក៏អ្នកជំងឺដែលកំពុងថ្ងូរដោយសម្លេងឈឺចាប់នៅក្រោមកម្តៅថ្ងៃវេលាម៉ោង១០ព្រឹក លាយឡំនឹងសម្លេងស្រែកដង្ហោយហៅគ្នាដោយសម្លេងយំសោក ព្រោះបែកបងប្អូន ។ មានមនុស្សខ្លះទៀតដើរត្រឡប់ក្រោយ ដោយក្រឡេកមើលក្នុងហ្វូងមនុស្សក្រែងឃើញឪពុកម្តាយ ឬបងប្អូនដែលបែកគ្នានៅក្នុងពេលជម្លៀសដ៏តក់ក្រហល់នេះ ។ ឃើញដូច្នេះម្នាក់ៗប្រយ័ត្នប្រយែងព្រោះខ្លាចបាត់បង់បងប្អូនដូចគេ ក៏ដើរកាន់ដៃគ្នាជាប់ដោយភ្នែកសម្លឹងមើលគ្នាស្ទើរមិនហ៊ានព្រិច ហើយក៏មិនហ៊ានឈប់នៅតាមផ្លូវ ព្រោះខ្លាចកកស្ទះ និងខ្លាចយោធាខ្មែរក្រហមប្រដាប់ដោយកាំភ្លើង ។ នៅតាមផ្លូវ យើងប្រទះឃើញខ្មោចស្រស់ៗ ដែលខ្មែរក្រហមទើបនឹងចាក់ ឬបាញ់សម្លាប់ ដែលនាំឲ្យយើងមានអារម្មណ៍រន្ធត់ក្រៃលែង ព្រោះមិនដែលជួបប្រទះ ។ រយៈពេលពីរថ្ងៃ ទើបយើងទៅដល់វត្តព្រែកសំរោង ក្រុងតាខ្មៅ នៅពេលយប់ងងឹត រួចហើយក្រាលកន្ទេល ដេកនៅលើចិញ្ចើមថ្នល់តែម្តង ។ ជាទម្លាប់នៅពេលព្រលប់វេលាម៉ោង៨កន្លះ ពេលនៅភ្នំពេញខ្ញុំតែងតែស្តាប់វិទ្យុសម្លេង សហរដ្ឋអាមេរិកផ្សាយជាភាសាខ្មែរជាមួយនឹងកូនវិទ្យុម៉ាកណាស្យូណាល់បីបង់ ។ នៅយប់ថ្ងៃទី១៩ ខែមេសា វិទ្យុសម្លេងសហរដ្ឋអាមេរិកបានផ្សាយថា មានក្រុមមន្ត្រីជាន់ខ្ពស់ ទាំងយោធា និងស៊ីវិលប្រហែល៤០នាក់ ក្នុងនោះមានទាំងនាយករដ្ឋមន្ត្រី ឡុង បូរ៉េត, សម្តេចសង្ឃរាជ ហួត តាត, លន់ ណុន, ឧត្តមសេនីយ ឈឹម ឈួន និងអគ្គបញ្ជាការកងទ័ព ម៉ីស៊ីចន ត្រូវយោធាខ្មែរក្រហមបញ្ជាឲ្យវារដូចសត្វគោ ហើយឲ្យស្រែកអាក្រោសនៅមុំផ្សារកណ្តាលមុននឹងសម្លាប់ដោយអារកនឹងធាងត្នោត ។ នៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ យើងក៏ធ្វើដំណើរបន្តទៅព្រែកហូរ ហើយនៅតាមផ្លូវខ្ញុំឃើញរណ្តៅគ្រាប់បែក F១១១ជ្រៅៗជាច្រើនកន្លែង ។ មកដល់ខាងត្បូងព្រែកហូរ ខ្ញុំតក់ស្លុតយ៉ាងខ្លាំងជា មួយនឹងគំនរសាកសពទាហានដែលខ្មែរក្រហមយកទៅបោះចោលក្នុងរណ្តៅ ដែលក្នុងមួយរណ្តៅមានសាកសពប្រមាណ៣០នាក់ ហើម និងធុំក្លិនស្អុយអសោច ។ សាកសពទាំងនោះភាគច្រើនជាទាហានក្នុងកងពលលេខ៤៥ និងលេខ៤៨ ដែលមានពាក់សញ្ញាក្បាលខ្លាដែលភាគច្រើនមានដើមកំណើតនៅកម្ពុជាក្រោម ប្រទេសវៀតណាម ។ នៅវេលាប្រហែលម៉ោងបីល្ងាច ខ្ញុំបានមកដល់ភូមិព្រែករទាំង ដែលស្ថិតនៅខាងកើតវត្តព្រែកថ្មីង ។ ខ្ញុំបានស្នាក់នៅក្នុងភូមិនេះ ចំណែកម្តាយមីង និងកូនរបស់គាត់បានបែកទៅរស់នៅខេត្តព្រៃវែងវិញ ។

## ភូមិព្រែករទាំងជាសមរភូមិថ្មី

នៅក្នុងភូមិព្រែករទាំង ខ្មែរក្រហមបានចាត់តាំងឲ្យខ្ញុំធ្វើការងារជាច្រើនដូចជា ដាំថ្នឹងយកទឹកធ្វើស្រែ ភ្ជួរស្រែ លើកភ្លឺស្រែ និងជីរះស្មៅបារាំងនៅតាមវាលស្រែ ។ នៅទីនោះ ខ្ញុំតែងតែឮសូរស្នូរផ្ទុះគ្រាប់សីវែនធីណាញ (Seventy nine), គ្រាប់បែកចង្កោម (Cluster bomb) និងគ្រាប់៦០មីល្លីម៉ែត្រ ដែលកប់ក្នុងដី ព្រោះតំបន់នេះជាសមរភូមិប្រយុទ្ធខ្លាំងក្លារវាងកងទ័ពឆ័ត្រយោងរបស់ លន់ នល់ និងកងទ័ពខ្មែរក្រហម ។ ប្រជាជនជម្លៀសមួយចំនួនដែលមិនស្គាល់តំបន់នេះច្បាស់លាស់ពីមុនមក មិនបានប្រុងប្រយ័ត្ន ជួនកាលគ្រាន់តែចូលឆ្ការព្រៃ និងកាប់ដីដាំដំណាំនៅក្បែរមាត់ស្ទឹងស្លាប់ និងរបួសរាល់ថ្ងៃ ដោយសារផ្ទុះគ្រាប់ ។ ឃើញដូច្នេះ ខ្ញុំភិតភ័យយ៉ាងខ្លាំង ខ្ញុំក៏សម្រេចចិត្តលួចរត់ទៅរស់ជុំឪពុកម្តាយនៅខេត្តកំពត ឬក៏រត់ទៅនៅកន្លែងណាមួយដែលពុំមានគ្រោះថ្នាក់ ព្រោះសង្គ្រាមបានបញ្ចប់ទៅហើយ ប៉ុន្តែគ្រាប់នៅតែផ្ទុះ ហើយមនុស្សនៅតែរងរបួស ឬស្លាប់ដូចនៅក្នុងសម័យសង្គ្រាមដែរ ។

## អ្នកទោសគ្មានកំហុស

វេលាម៉ោង១១ព្រឹក នៅរដូវវស្សា ពេលខ្មែរក្រហមកំពុងបើករបបឲ្យប្រជាជនថ្មី ខ្ញុំក៏លួចដើរតាមបណ្តោយផ្លូវជាតិលេខ២សំដៅទៅសៀមរាបកន្ទួត ស្រុកកណ្តាលស្ទឹងដើម្បីរកផ្លូវទៅកាន់ស្រុកកំណើតវិញ ។ ប៉ុន្តែរហូតដល់ម៉ោង៥ល្ងាច ខ្ញុំមកដល់ត្រឹមភូមិកណ្តឹងប៉ុណ្ណោះ ព្រោះមិនស្គាល់ផ្លូវ ម្យ៉ាងទៀត ភ័យខ្លាចក្រែងខ្មែរក្រហមតាមទាន់ ។ ខណៈនោះ ស្រាប់តែមានឈ្លបខ្មែរក្រហមពីរនាក់ស្ទាក់ផ្លូវ ហើយសួរថា តើមិត្តបងមកពីណា? ទៅណា? ខ្ញុំក៏ឆ្លើយប្រាប់តាមត្រង់ថាទៅស្រុកកំណើត ភ្លាមនោះ ឈ្លបទាំងពីរនាក់នោះសួររកលិខិតធ្វើដំណើរ ប៉ុន្តែដោយសារខ្ញុំពុំមានសំបុត្រ គេក៏ឲ្យខ្ញុំចូលទៅក្នុងផ្ទះ ដែលមានជញ្ជាំងលាបពណ៌ខៀវ (ប្រហែលជាផ្ទះរបស់ចិនពីសង្គមចាស់) ។ នៅខាងមុខផ្ទះ ខ្ញុំឃើញបុរសម្នាក់ (ប្រធានគុក) អាយុប្រហែល២៥ឆ្នាំ មាឌធំ សក់រួញ អង្គាដី ថ្គាមខ្លា និយាយមកកាន់ខ្ញុំថា “អង្គការសូមឃាត់មិត្តទុកនៅទីនេះមួយរយៈសិន មុននឹងអនុញ្ញាតឲ្យមិត្តបន្តដំណើរទៅស្រុកទៀត” ។ បន្ទាប់ពីនិយាយចប់ បុរសនោះក៏បើកទ្វារឲ្យខ្ញុំចូលទៅក្នុងផ្ទះដែលពួសំឡេងមនុស្សជជែកគ្នាអ៊ូអែ ស្រាប់តែខ្ញុំក្រឡេកទៅឃើញមនុស្សពីរបីវង់អង្គុយដួសបបរដាក់ចានចង្កឹះហូបជាមួយអំបិល នៅជុំវិញចានដើងដែកធំមួយ ។ ឃើញដូច្នេះ ខ្ញុំងឿងឆ្ងល់យ៉ាងខ្លាំង ក្រោយមកទើបខ្ញុំដឹងតាមរយៈ អ្នកទោសដែលជាប់ឃុំឃាំងនៅទីនេះប្រាប់ថា កន្លែងនេះជាមន្ទីរឃុំឃាំង០៧ ស្ថិតនៅតាមដងផ្លូវជាតិលេខ២ ដែលមានចម្ងាយប្រហែលបីគីឡូម៉ែត្រខាងជើងផ្សារសំរោងយ៉ោង ។ នៅឆ្នាំ១៩៨៤ ខ្ញុំបានជួបប្រធានមន្ទីរសន្តិសុខនេះ ធ្វើជាគ្រូបង្រៀនរស់នៅខាងលិចភ្នំចំបាប់ ។ អ្នកទោសនៅក្នុងមន្ទីរឃុំឃាំង០៧ ភាគច្រើនជានិស្សិត និងយុវជនក្មេងៗ ដែលមានអាយុចាប់ពី១៨ឆ្នាំទៅ២៥ឆ្នាំ ហើយជាប់ឃុំឃាំងតែរយៈពេលខ្លី មួយអាទិត្យ ឬពីរអាទិត្យ កងឈ្លបក៏ដោះលែងឲ្យទៅតាមសហករណ៍វិញ ។ ចំណែកអ្នកមូលដ្ឋានបានផ្លាស់ឲ្យទៅនៅភូមិផ្សេងពីភូមិកំណើត ។

នៅចម្ងាយមួយគីឡូម៉ែត្រពីមន្ទីរសន្តិសុខ០៧ មានមន្ទីរឃុំឃាំងកម្រិតធ្ងន់មួយទៀតឈ្មោះ មន្ទីរសន្តិសុខ០៨ ឬ មន្ទីរសន្តិសុខវត្តកោះ ដែលមានទីតាំងនៅក្នុងវត្ត និងមានរបងលួសបន្លាព័ទ្ធជុំវិញ ។ អ្នកទោសនៅទីនោះត្រូវកងសន្តិសុខដាក់ខ្នោះជើងដាក់នៅក្រោមព្រះវិហារ ហើយនៅពេលអ្នកទោសចេញធ្វើការនៅផ្នែកខាងក្រៅបរិវេណគុក មានកងយោធាស្ពាយកាំភ្លើងយាមជានិច្ច ។ អ្នកទោសនៅទីនោះ ពុំមានដោះលែងទេ ហើយនៅពេលសួរចម្លើយចប់កងសន្តិសុខបានដឹកយកទៅសម្លាប់ចោល ។ ក្រោយមក នៅពេលកងទ័ពវៀតណាមចូលមក ខ្មែរក្រហមបានបំផ្ទុះគ្រាប់មីនសម្លាប់អ្នកទោសដែលនៅសេសសល់ទាំងអស់ ។

## រួចខ្លួនដោយសារចម្លើយដដែល

នៅក្នុងមន្ទីរសន្តិសុខ០៧ កងសន្តិសុខបានចាត់តាំងឲ្យខ្ញុំកាស់គល់ឈើ និង កាស់គ្រឹះផ្ទះដែល បែកបាក់ដើម្បីយកដីដាំដំណាំដំឡូងមី ដំឡូងជ្វា ។ ខ្ញុំជាប់ឃុំឃាំងបាន កន្លះខែ ទើបប្រធានគុកហៅទៅសួរចម្លើយ នៅផ្ទះតូចមួយ ដែលជាកន្លែងធ្វើប្រវត្តិរូបអ្នកទោសមុនពេលចូលមន្ទីរឃុំឃាំង ។ កងសួរចម្លើយបានសួរសំណួរដដែលៗបីលើកដូចជា តើនៅភ្នំពេញ មិត្តឯងធ្វើការងារទាហាន? គយ? ឬប៉ូលីស? ប៉ុន្តែដោយពួកខ្ញុំឆ្លើយចម្លើយតែមួយទាំងបីលើក ទើបក្រោយមក កងសួរចម្លើយបានដោះលែងខ្ញុំ រួចបញ្ជូនឲ្យទៅរស់នៅភូមិព្រះម្លប់ ជិតវត្តកណ្តឹង ។ អង្គការបានចាត់តាំងខ្ញុំឲ្យភ្ជួររាស់ ដកស្ទូង ជាមួយប្រជាជនមូលដ្ឋាន ដែលស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅថ្មីៗ និងមានស្បែកជើងកង់ឡានពាក់គ្រប់ៗគ្នា ។ មួយរយៈក្រោយមក អង្គការបានប្តូរមុខព្រួញការងារខ្ញុំ និងប្រជាជន ១៧ មេសា មួយចំនួនទៀតឲ្យទៅកាប់កាស់ដីនៅម្តុំភ្នំតាម៉ៅដើម្បីដាំដំឡូងវិញ ។ ដោយសារដីនៅភ្នំតាម៉ៅសំបូរទៅដោយគុម្ពឫស្សី ដូច្នេះ នៅពេលត្រឡប់ពីធ្វើការងារម្តងៗ ខ្ញុំបានលួចកាច់ទំពាំងយកមកបបរជាមួយអង្ករហូបបន្ថែម ព្រោះនៅពេលនោះប្រជាជនថ្មីពុំមានរបបបន្លែ អង្ករ សាច់មាន់ សាច់ត្រី សាច់ជ្រូក និងបង្អែមដូចអ្នកនៅមូលដ្ឋានទេ ។

## រដូវបុណ្យភ្ជុំ

នៅសល់រយៈពេលមួយអាទិត្យដល់ថ្ងៃបុណ្យភ្ជុំបិណ្ឌ ចាប់តាំងពីពេលព្រឹកព្រលឹមស្រាងៗ ខ្មែរក្រហមប្រមូលប្រជាជន ១៧ មេសា ទាំងអស់ដើម្បីត្រៀមចាំឡើងឡាននៅខាងមុខខ្លោងទ្វារវត្តកណ្តឹង ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ២ ។ ខ្ញុំឃើញកុមារក្មេងជំទង់ និងមនុស្សចាស់ជរាអង្គុយកកកុញ តាមចិញ្ចើមថ្នល់ដោយម្នាក់ៗស្ពាយបង្វិចខោអាវ យួរកន្ត្រកដំឡូង ស្ពៃ និងចានឆ្នាំងសំពីងសំពោង ។ ប្រជាជន ១៧ មេសា ទាំងនេះ ដែលមានបងប្អូន

ជាអ្នកមូលដ្ឋានបានមកជូនដំណើរដោយយក ស្ករត្នោត អង្ករ ត្រី សម្រាប់ទុកឲ្យហូបនៅតាមផ្លូវ ។ ចំណែកខ្ញុំ ដោយសារពុំមានមិត្តភក្តិ និង សាច់ញាតិដូចគេ ក៏អង្គុយរង់ចាំពេលគេហៅឈ្មោះដើម្បីឡើងឡានប៉ុណ្ណោះ ។

ពីរបីម៉ោងក្រោយមក ខ្ញុំឃើញរថយន្តយោធាចំនួន១៧ គ្រឿងដែលផលិតនៅប្រទេសចិន បានមកឈប់ដំរៀបជាជួរ ។ មុននឹងហៅឈ្មោះប្រជាជនឲ្យឡើងលើឡាន ប្រធានឃុំបានប្រកាសប្រាប់ថា មិត្តទាំងអស់សុទ្ធតែអ្នកមានសំណាងហើយ ព្រោះបានទៅរស់នៅខេត្តបាត់ដំបង ដែលជាកន្លែងសំបូរស្រូវ អង្ករ និងត្រីសាច់ ។ ស្តាប់ពាក្យសម្តីនេះភ្លាម ប្រជាជនទាំងអស់សប្បាយចិត្តយ៉ាងខ្លាំង ចំណែកខ្ញុំកាន់តែមានការព្រួយបារម្ភ ដោយគិតថាខ្មែរក្រហមតែងតែនិយាយកុហក ក៏មានអារម្មណ៍ភ័យខ្លាចខ្មែរក្រហមដឹកយកទៅសម្លាប់ចោល ។ នៅម៉ោង១១ថ្ងៃត្រង់ ក្បួនរថយន្តចាប់ចេញដំណើរ ពេលនោះខ្ញុំឃ្លានបាយយ៉ាងខ្លាំង ព្រោះអង្គការពុំបានបើករបបឲ្យហូបនៅតាមផ្លូវទេ ។ រថយន្តបើកកាត់តាមកំពង់ទួល ស្រុកកណ្តាលស្ទឹងឆ្ពោះទៅផ្លូវជាតិលេខ៣ រួចបន្តដំណើរលើផ្លូវសហព័ន្ធរុស្ស៊ី ចំពីមុខព្រលានយន្តហោះពោធិ៍ចិនតុង ។ ខ្ញុំក្រឡេកមើលផ្ទះនៅសងខាងផ្លូវមានសភាពស្ងាត់ជ្រងំ គឺមានតែកងយោធា និងកម្មាភិបាលខ្មែរក្រហមដើរទៅធ្វើការយ៉ាងស្ងាត់ស្ងៀមនៅតាមមន្ទីរ ឬក្រសួងប៉ុណ្ណោះ ។ នៅវេលាម៉ោងប្រហែលមួយកន្លះ រថយន្តបានមកដល់ចំពីមុខសកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសកលវិទ្យាល័យបច្ចេកទេសមិត្តភាពខ្មែរសូវៀតដែលពីមុនធ្លាប់តែមាននិស្សិតអ៊ូអរ ប៉ុន្តែពេលនេះឃើញតែគំនរគុ និងកៅអីដែលខ្មែរក្រហមជញ្ជូនយកមកគរចោលនៅក្នុងទីធ្លាសាលា ។ និស្សិត និងសាស្ត្រាចារ្យជាច្រើនត្រូវខ្មែរក្រហមជម្លៀសចេញ ឬយកទៅសម្លាប់ចោល ។ រថយន្តបានបត់តាមស្តុបទួលគោកឆ្ពោះទៅស្ពានចាស់ ដែលធ្វើឲ្យខ្ញុំមើលសឹងតែមិនស្គាល់ ព្រោះខ្មែរក្រហមបានដាំដើមដូងជាជួរនៅអមសងខាងផ្លូវ ចំណែកស្ពានជ្រោយចង្វារនៅបាក់ពាក់កណ្តាលដដែល ដោយសារការបំផ្លិចបំផ្លាញពីកងកុម្មង់ដូវៀតកុងនៅយប់ថ្ងៃទី៦ តុលា ក្នុងរដូវបុណ្យភ្ជុំឆ្នាំ១៩៧២ ដែលកាលនោះទាហាន លន់ នល់ បានសម្លាប់កុម្មង់ដូវយៀកកុងអស់៤២នាក់ និងចាប់រស់មួយចំនួនទៀតពីក្នុងទឹកស្អុយបឹងកក់ដែលគ្របដណ្តប់ទៅដោយព្រៃកំប្លោកខ្ពស់ៗយ៉ាងក្រាស់ ។ ចំណែកមនុស្សមួយចំនួនក៏បានបាត់បង់ប្អូន ពុំព្រងំណឹងព្រោះស្ពានជ្រោយចង្វារបានបាក់ធ្លាក់ទៅក្នុងទឹកនៅចំពេលដែលចរាចរឆ្លងកាត់ កំពុងប្រព្រឹត្តទៅនៅឡើយ ។

ថ្ងៃរសៀល រថយន្តបានមកដល់ព្រែកព្នៅ ខ្ញុំឈរលើរថយន្តដោយទឹកមុខក្រៀមក្រំ និងស្រងូតស្រងាត់ព្រោះមិនដឹងទៅរស់នៅភូមិឃុំណាច្បាស់លាស់ឡើយ ។ ម៉ោងប្រាំល្ងាចរថយន្តបានឈប់នៅមុខទីប្រជុំជនព្រៃខ្មែរក្នុងខេត្តកំពង់ឆ្នាំង ។ បន្ទាប់មកកងយោធាខ្មែរក្រហមបានចែកអង្ករម្នាក់មួយកំប៉ុង ដើម្បីដាំបាយហូប រួចហើយឲ្យដើររកកន្លែងដេករៀងៗខ្លួន ។ នៅម៉ោង៧កន្លះព្រឹក ទើបរថយន្តចាប់ចេញដំណើរទៅឈប់នៅស្ថានីយ៍រថភ្លើងក្នុងខេត្តពោធិ៍សាត់ ដែលនៅទីនោះមានប្រជាជន ១៧ មេសារាប់ពាន់នាក់មានសម្លៀកបំពាក់ចម្រុះពណ៌ ។ ខ្ញុំបានដើររកឈើមកធ្វើរោងស្នាក់នៅបណ្តោះអាសន្ន ចំណែកប្រជាជនខ្លះបានទៅស្នាក់នៅក្នុងផ្ទះចិន ដែលមានក្លិនស្អុះស្អាប ដោយសារទឹកនោម និងលាមក ។ នៅពេលនោះ ដោយសារពុំមានទឹកផឹក និងគ្មានអនាម័យធ្វើឲ្យចាស់ និងក្មេងៗមួយចំនួនចាប់ផ្តើមឈឺរាករូស ចំណែកមនុស្សខ្លះទៀតបានស្លាប់ដោយសារអត់អាហារតែម្តង ។ រយៈពេលប្រហែលមួយសប្តាហ៍ក្រោយមក អង្គការបានប្រកាសហៅឈ្មោះប្រជាជនឡើងជិះរថភ្លើងយ៉ាងប្រញាប់ប្រញាល់ដោយមិនអើពើពីអ្នកឈឺធ្ងន់ ឬក៏ស្លាប់យ៉ាងណានោះទេ បើកប់មិនទាន់ត្រូវទុកចោល ។ នៅតាមបណ្តោយផ្លូវរថភ្លើងពីពោធិ៍សាត់ទៅបាត់ដំបងដែលសងខាងលាតសន្ធឹងដោយវាលស្រែដាច់កន្ទុយភ្នែក ពុំសូវឃើញប្រជាជនធ្វើស្រែទេ ។ ទៅដល់ភ្នំអធិបតី ខ្ញុំមានអារម្មណ៍រន្ធត់ និងតក់ស្លុតយ៉ាងខ្លាំង ដោយឃើញគំនរសាកសពទាហានមានខោអាវចម្រុះពណ៌ ដែលកងទ័ពខ្មែរក្រហមចាប់យកទៅសម្លាប់ចោលនៅរាយប៉ាយលើដី ។ នៅវេលាម៉ោង៨យប់ រថភ្លើងបានមកដល់ស្វាយស៊ីសុផុន ខ្ញុំឃើញមានគ្រួសារជម្លៀសរាប់ម៉ឺននាក់កំពុងរង់ចាំរទេះគោដឹកបន្តទៅស្រុកថ្មពួក, ព្រះនេត្រព្រះ, ភ្នំស្រុក និងស្រុកសេរីសោភ័ណ្ឌដែរ ចំណែកនៅតាមផ្ទះក្នុងទីប្រជុំជនស្វាយស៊ីសុផុន ខ្ញុំឃើញកម្មាភិបាលកំពុងរៀចនំអន្សមព្រោះដល់ថ្ងៃបុណ្យភ្ជុំបិណ្ឌហើយ ។ ជាបន្តបន្ទាប់ ខ្មែរក្រហមធ្វើការបែងចែក

ប្រជាជនជម្លៀសដែលទើបមកដល់ថ្មី ដែលមានឥវ៉ាន់សំពីងសំពោង ទៅតាមសហករណ៍នានាក្នុងតំបន់៥ ចំណែកអ្នកគ្មានគ្រួសារ អង្គការតម្រូវបញ្ចូលក្នុងកងចល័ត ដែលមានទីតាំងនៅតាមផ្លូវជាតិលេខ៦ ខាងកើតស្វាយស៊ីសុផុន ។

## ការដ្ឋានដើមពោធិ៍មួយដើម

អង្គការបានបញ្ជូនខ្ញុំទៅការដ្ឋានពោធិ៍មួយដើម ស្ថិតនៅខាងកើតស្វាយស៊ីសុផុន (នៅជាប់រោងម៉ាស៊ីនកិនស្រូវមានដើមពោធិ៍មួយដើម) ។ ពោធិ៍មួយដើមជាការដ្ឋានដែលគ្រប់គ្រងដោយសមមិត្ត ខាន់ ជាអតីតសាស្ត្រាចារ្យនៅវិទ្យាល័យជម្ពូវ័ន្ត ក្រុងភ្នំពេញ ។ ខ្មែរក្រហមបានបញ្ជាឲ្យកងចល័តលើកទំនប់កន្ទួតនៅកណ្តាលលំហទឹកជំនន់នៃស្ទឹងស្វាយ ដែលកន្លែងខ្លះមានជម្រៅស្មើនឹងដើមទ្រូងមនុស្សចាស់ និងកន្លែងខ្លះទៀតមានជម្រៅស្មើមាត់ ។ កងចល័តទាំងស្រីទាំងប្រុសចំនួន២០០នាក់ កាន់ចប ឬប៉ែលរួចមុជដីកយកអាចម៍ដីពីក្នុងទឹកមកចាក់តាមបណ្តោយខ្សែបន្ទាត់ ដែលខ្មែរក្រហមបោះតម្រុយ ។ ផ្ទៃទឹកដែលមានពណ៌ថ្លាខ្មៅនេះសំបូរសត្វឈ្លើងធំៗណាស់ កងចល័តនារីៗដែលជម្លៀសមកពីទីក្រុង និងមានសម្បុរសជ្រះ សាច់ឈាមត្រលុកត្រលន់ខ្លាចរអាយ៉ាងខ្លាំង ព្រោះមិនដែលស្គាល់ ។ ប៉ុន្តែ ទោះបីជាភ័យខ្លាចយ៉ាងណាក៏ដោយ ក៏គេត្រូវតែចុះដីកយកអាចម៍ដីក្នុងទឹកឲ្យបានតាមទិសរបស់អង្គការដែរ ។ រៀងរាល់ថ្ងៃ ខ្ញុំត្រូវចុះត្រាំទឹកចាប់តាំងពីព្រឹកព្រលឹមរហូតដល់ពេលល្ងាចដើម្បីមុជយកដី ហើយដោយសារអាកាសធាតុត្រជាក់ខ្លាំង បណ្តាលឲ្យកងចល័តមានជំងឺហើមពោះគ្រប់គ្នា ។ នៅពេលធ្វើការម្តងៗ ខ្ញុំតែងតែប្រុងប្រយ័ត្ន និងស្ទាបខ្លួនព្រោះខ្លាចឈ្លើងទាម ចំណែកកងចល័តនារីខ្លះដែលដឹងថាឈ្លើងកំពុងទាមជាប់ខ្លួន បានរត់ចុះឡើងដើម្បីរកគេជួយ ប៉ុន្តែទោះឃើញសភាពស្ទន់ស្ទោរយ៉ាងនេះក៏ដោយ ក៏កងចល័តប្រុសៗនៅក្បែរនោះមិនហ៊ានទៅបេះឈ្លើងចេញដែរ ព្រោះខ្លាចអង្គការចោទថាខុសសីលធម៌ ។ លើកទំនប់កន្ទួតបានបីខែ កងចល័តចាប់ផ្តើមឈឺចុកពោះ ហើម និងកើតដំបៅ ចំណែកខ្លះទៀតដែលមាន ជំងឺធ្ងន់ធ្ងរស្លាប់ដោយគ្មានអាហារគ្រប់គ្រាន់ និងគ្មានថ្នាំព្យាបាលជាបន្តបន្ទាប់ ។ រហូតដល់ចុងឆ្នាំ១៩៧៥ អាកាសធាតុត្រជាក់ស្រេបនៅពេលយប់ កងចល័តទាំងអស់ដេកមិនសូវលក់ទេ ព្រោះពុំមានសម្លៀកបំពាក់ និងភួយសម្រាប់ដណ្តប់ ហើយអុសសម្រាប់ដុតកម្តៅខ្លួនក៏ពុំមានដែរ ចំណែករបបអាហារ អង្គការបានផ្តល់ឲ្យតែបបររាវៗជាមួយអំបិលពីរបីគ្រាប់ប៉ុណ្ណោះ ។

## ទំនប់កំបោរស្រះ

បន្ទាប់ពីលើកទំនប់កន្ទួតចប់ អង្គការបានបញ្ជូនខ្ញុំឲ្យទៅធ្វើការបន្តនៅការដ្ឋានកំបោរស្រះដែល ទើបចាប់ផ្តើមដំណើរការនៅខែកុម្ភៈ ឆ្នាំ១៩៧៦ ដែលមានសេនាធិការនៅជុបវារី ក្នុងឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ក្រោមការគ្រប់គ្រងរបស់សមមិត្ត វ៉ាល់ ប្រធានកងចល័ត ។

នៅភូមិភាគពាយ័ព្យ អង្គការបានបើកការដ្ឋានជាច្រើនកន្លែងដូចជា ការដ្ឋានគោកពង្រ ស្ថិតខាងកើតភូមិឈ្នូរំពាក់ តាមបណ្តោយផ្លូវជាតិលេខ៦ គ្រប់គ្រងដោយសមមិត្ត ឡុំ ជាការដ្ឋានធ្វើស្រែ ។ ការដ្ឋានដាំកប្បាសនៅភ្នំកង់វ៉ា គ្រប់គ្រងដោយសមមិត្តឡេង (បាយភ្នែកមួយចំហៀង) ជាអនុលេខាតំបន់៥ផ្ទាល់ ។

នៅរដូវប្រាំងឆ្នាំ១៩៧៦ ខ្មែរក្រហមបានប្រមូលកងចល័តប្រមាណ២.០០០ ទៅ ៣.០០០នាក់ ដើម្បីទៅលើកទំនប់កំបោរស្រះ នៅក្រោមផ្ទៃមេឃស្រឡះវេលាម៉ោងប្រាំបីព្រឹក ទំនប់កំបោស្រះ ចាប់ផ្តើមពីភូមិស្រះ មានបណ្តោយប្រវែងជាងដប់គីឡូម៉ែត្រ ខ្នងលើបួនម៉ែត្រ និងកម្ពស់មួយម៉ែត្រកន្លះ រហូតដល់ភ្នំកំបោរ ។ ដីនៅទីនោះមានពណ៌ខ្មៅ ហើយស្អិត ព្រមទាំងមានដើមស្គា ឬ អណ្តាសដុះសិប់ទ្រុប ដែលជាជម្រកសត្វពស់មានពិសដូចជា ពស់វែកក្របី, ពស់ក្រឡាប្រាស, ហ្វូងកណ្តុរព្រៃ និងហ្វូងឆ្កែចចកដែលលូនៅវេលាយប់ស្ងាត់គួរឲ្យខ្លាច ។ អ្នកភូមិនៅទីនោះកម្រដើរឆ្លងកាត់វាលនេះណាស់ គឺមានតែអ្នកដើររកត្រីនៅតាមបឹងឆ្ងាយៗ ឬអ្នកប្រូតស្បូវតែប៉ុណ្ណោះ ។ នៅពេលដែលការដ្ឋានកំបោរស្រះប្រព្រឹត្តទៅអស់រយៈពេលប្រហែលពីរខែ ខ្មែរក្រហមបានផ្សព្វផ្សាយថា នឹងមានសម្តែងសិល្បៈភូមិភាគដើម្បីឲ្យកងចល័តទស្សនាកម្សាន្ត ។ ចាប់ពីពេលនោះមក យើងឃើញយោធាខ្មែរក្រហម បានសាងសង់រោងសិល្បៈអស់រយៈពេលប្រហែលកន្លះខែនៅខាងកើតភូមិស្រះ នៅកណ្តាលវាលស្រែ ។ រោងសិល្បៈនោះ បើតាមការប៉ាន់ស្មានត្រូវចំណាយឈើអស់ប្រហែលប្រាំបីម៉ែត្រគូប រាងខ្ពស់ស្រឡះដំបូលរាងក្រពើហា ប្រក់ដោយស័ង្កសី ។

នៅពេលដែលដឹងថា សិល្បៈភាគនឹងមកលេងនៅរយៈពេលតែពីរបីថ្ងៃខាងមុខ កងចល័តមានចិត្តរីករាយព្រោះសង្ឃឹមថា បានជួបប្រទះទស្សនីយភាពប្លែកៗ ដែលគេមិនដែលជួបប្រទះចាប់តាំងពីថ្ងៃជម្លៀសមក ។ ដោយសង្ឃឹមថា នឹងបានឃើញតួអង្គដែលតុបតែងស្អាតៗ ព្រមទាំងបានស្តាប់ភ្លេងដ៏ពីរោះ ដែលធ្វើឲ្យរាត្រីនោះជារាត្រីដ៏មនោរម្យពោរពេញដោយសេចក្តីសប្បាយរីករាយ បំភ្លេចនូវទុក្ខកង្វល់ពីការព្រាត់ប្រាស់បងប្អូន និងការនឿយហត់ ។ នៅពេលដែលសិល្បៈចាប់លេងប្រហែលម៉ោងប្រាំបីយប់ ម្នាក់ៗបានខំផ្សៀងសម្លឹងមើលមិនដាក់ភ្នែក ដើម្បីត្រងយកឈុតឆាកណាមួយដែលខ្លួនចូលចិត្ត ។ ប៉ុន្តែគួរឲ្យស្តាយ ទស្សនីយភាពនេះចាប់ផ្តើមឡើងដោយរបាំ អមដោយឧបករណ៍ភ្លេង មានអគ័រដេអុង និងម៉ង់ដូលីន ជាដើម លេងបែបបដិវត្តន៍ទៅវិញ ។ ពេលនោះ មានសម្តែងរបាំបុកស្រូវ ច្រូតស្រូវ បោកស្រូវ រាំលើកដៃរីងៗ ហើយកន្ត្រាក់ៗទៅតាមចម្រៀងដែលមានចង្វាក់ញាប់ៗ គ្រលរៗ ដោយកាន់កណ្តៀវ ចបកាប់ និងឃ្នាបបោកស្រូវដែលយើងដឹងថា នេះជាចម្រៀងបដិវត្តន៍យកតាមលំនាំចិន ។ អ្នកមើលមានការខកចិត្តនឹងទស្សនីយភាពដ៏ចម្លែកជាលើកដំបូង ដែលខុសពីមនោសញ្ចេតនាខ្មែរទាំងស្រុង ប៉ុន្តែគ្មាននរណាហ៊ានពោលថា មិនពិរោះ ឬមិនល្អនោះទេ ព្រោះខ្លាចខ្មែរក្រហមស្តាប់ឮ ត្រូវមានទោស ។ ម្យ៉ាងទៀតគេចេះតែទ្រាំមើលទាំងងងុយដេកដើម្បីកុំឲ្យខ្មែរក្រហមដឹងថា គេមិនចូលចិត្តនឹងសិល្បៈបែបបដិវត្តន៍ ។ កងចល័តបានគិតថា ក្រោយពីមើលសិល្បៈហើយ ប្រហែលពួកគេត្រូវបានសម្រាក ប៉ុន្តែផ្ទុយទៅវិញ នៅពេលព្រលឹមស្អែកឡើងត្រូវគេដេញឲ្យកាន់ចប បង្គីដដែល ។ នៅសម័យខ្មែរក្រហមប្រជុំពេលណា ក៏អង្គការលើកថា ឲ្យសន្សំសំចៃ ព្រោះអង្គការខ្វះខាត ។ ពាក្យនេះគេឮស្រកៀរត្រចៀកទៅហើយ ប៉ុន្តែបើគេក្រឡេកមើលរោងសិល្បៈដែលខ្មែរក្រហមសង់ឡើងដើម្បីសម្តែងតែមួយភ្លែតដោយប្រើឈើ និងស័ង្កសីអស់ជាច្រើន ។ ប៉ុន្តែ នៅក្រោយពេលសម្តែងអស់រយៈពេលប្រហែលកន្លះខែ រោងសិល្បៈនៅតែឈរកណ្តាលវាលស្រែ ហាលភ្លៀងខ្យល់ ពុំបានរុះរើយកទៅប្រើការអ្វីទៀតឡើយ ។ នៅល្ងាចថ្ងៃមួយ មានព្យុះភ្លៀងយ៉ាងខ្លាំង ពួកកងចល័តនាំគ្នាចូលជ្រកក្នុងរោងដែលជាជំរំ មានដំបូល ប្រក់ស្លឹកជាខ្នងវែង បណ្តោយប្រហែលម្ភៃម៉ែត្រ ស្រាប់តែខ្យល់ព្យុះបោកបក់គួចសន្លឹកស័ង្កសីរាប់រយសន្លឹករសាត់ឡើងទៅលើមេឃ ហើយធ្លាក់មកវិញធ្វើឲ្យរបួសដល់កងចល័តទៀតផង ។

## ពិធីបើកវគ្គនៅត្រពាំងក្រពើ

នៅមុនពេលចូលឆ្នាំខ្មែរប្រហែលពីរបីថ្ងៃប៉ុណ្ណោះ នៅត្រពាំងក្រពើ ខាងកើតភូមិស្រែះ ខ្មែរក្រហម បានរៀបចំពិធីបើកវគ្គមួយ (រៀបការ) ដោយមានកម្មាភិបាលថ្នាក់ស្រុក និងឃុំចូលរួម ។ ពេលនោះ មានកងចល័ត៥០គូ ត្រូវអង្គការរៀបចំឲ្យមានគូស្រករ ។ ក្រមា ខោអាវខ្មៅថ្មីៗ និងស្បែកជើងចាក់ ត្រូវគេចែកឲ្យគូស្រករថ្មីនៅពេលនោះដែរ ។ យុវជនយុវនារី ជាកងចល័ត អង្គុយលើកៅអីទល់មុខគ្នា ជាពីរជួរនៅក្រោមពន្លឺចង្កៀងម៉ាំងសុង ដែលមានពន្លឺខ្សោយ ដោយខ្លះមានទឹកមុខស្រពោន ព្រោះមិនស្គាល់ចិត្តគ្នា ខ្លះទៀតមិនពេញចិត្តនឹងគូស្រករ ដោយរូបសម្បត្តិមិនល្អ ។ ខ្លះទៀតហាក់ដូចជាមិនអើពើនឹងវិធីនេះ ព្រោះគេយល់ថា គេកំពុងឆ្លងកាត់នូវការផ្សងព្រេងយ៉ាប់យ៉ឺន នៅក្នុងប្រទេសមួយដែលពុំមានអនាគតត្រចះត្រចង់ ហេតុអ្វីក៏មកត្រេកត្រអាលនឹងការចាប់ប្រដល់គ្នានេះទៅវិញ ។ អាពាហ៍ពិពាហ៍នេះប្រព្រឹត្តទៅដោយពុំមានចាស់ទុំ ភ្លេងភ្លាត និងចំណីអាហារហូបឲ្យបានឆ្ងាញ់ និងគ្រប់គ្រាន់ឡើយ គ្រាន់តែហូបបាយសម្លធម្មតា ។ ពិធីនេះត្រូវបញ្ចប់ ដោយមានការចាប់អារម្មណ៍ពីអង្គការ និងការប្តេជ្ញាចិត្តរបស់គូស្រករម្នាក់ម្តងៗ រហូតដល់ចប់ទាំង៥០គូ ។ ការប្តេជ្ញានេះ មិនមានប្រើពាក្យអ្វីក្រៅពីបម្រើអង្គការ និងបំពេញភារកិច្ចឲ្យសម្រេចតាមផែនការរបស់អង្គការទេ ។ នៅម៉ោងប្រហែលដប់យប់ គូស្រកបានបំបែក ដោយមួយគូរៗបណ្តើរគ្នាឆ្ពោះទៅកាន់ខ្ទមដែលគេសង់ឲ្យជាជួរនៅខាងជើងទំនប់កំបោរស្រែះ ដើម្បីទុកឲ្យផ្សំដំណេក ។ នៅពេលផ្សំដំណេក ប្រធានកងចាត់ឲ្យគ្នាគេដើរឈ្លបចាំស្តាប់ក្រែងលោមាននិយាយអ្វីដែលថ្នាំងថ្នាក់ជាមួយអង្គការ ឬមិនចុះដំណេកនោះ ស្អែកឡើងនឹងត្រូវហៅទៅកសាង ។ ប៉ុន្តែបើនរណានិយាយពាក្យផ្តោះផ្តង ក្នាតាមផ្លូវស្នេហា ឬត្រេកត្រអាលតាមផ្លូវភេទ គេក៏យករឿងនេះមកនិយាយប្រាប់គ្នាគេដើម្បីជាល្បែងសើចលេង ។ អ្នកដែលទើបនឹងរៀបការថ្មី ត្រូវអង្គការអនុញ្ញាតឲ្យឈប់ចំនួនមួយថ្ងៃ ។ អ្នកដែលរៀបការក្នុងពេលនោះ មានមិត្ត

ឡិង, មិត្ត ភាន់ និងមិត្ត លីម ជាដើម ។ គូស្រកថ្មីទាំងនោះ ត្រូវផ្លាស់ប្តូរទៅកងថ្មីដែលគេហៅថា កងវីយកណ្តាល ។

**សត្វកណ្តុរម្ហូបចម្លែក**

ដំបូងកងចល័តហាក់ដូចជាមានការងារស្រួល ដោយមានអ្នកចាំកាប់ដីដាក់បង្គីផង និងអ្នករែកដី យកទៅចាក់លើទំនប់ផង ប៉ុន្តែធ្វើបានកន្លះខែ ដោយសារខ្លាចមិនហើយតាមផែនការកំណត់ ព្រោះនៅត្រង់កន្លែងត្រពាំងក្រពើ និងអូររន្ទះបាញ់មានសណ្ឋានដីទំនាប ហើយជ្រៅ ទើបខ្មែរក្រហមចែកបង្គីឲ្យ កងចល័តម្នាក់មួយគូកាប់ផងរែកផងដើម្បីលើកទំនប់ឲ្យបានហើយឆាប់ ។ ម្តងនេះខ្មែរក្រហមបានដាក់ផែនការថ្មី ដោយវាស់ដីកន្លះម៉ែត្រគូបឲ្យកងចល័តម្នាក់រែកឲ្យហើយក្នុងមួយថ្ងៃ បើនរណាធ្វើហើយអាចឈប់សម្រាកបាន ។ ទោះបីធ្វើហើយក៏ដោយ ក៏គេមិនព្រមសម្រាក គេត្រូវដើររកបន្លែ និងសត្វកណ្តុរ មកហូបបន្ថែមទៀត ព្រោះរបបអាហារតិចហូបមិនឆ្អែត ។ ចំណែកអ្នកធ្វើការងារមិនសម្រេចតាមផែនការកំណត់ អង្គការមិនចែករបបឲ្យទេ ។ ដោយសង្កេតឃើញការងារនៅធូរស្រាលនៅឡើយ អង្គការក៏ដាក់ផែនការបន្ថែមឲ្យជីកដីចាប់ពីមួយម៉ែត្រគូបរហូតដល់ពីរម៉ែត្រគុប ។ ក្រោយមកការងារកាន់តែធ្ងន់ធ្ងរទៅៗ ចាប់ពីបួនទៅប្រាំម៉ែត្រគូប ចំណែករបបអាហារកាន់តែថយជាលំដាប់ កងចល័តនារីនិងបុរសខ្លះធ្លាក់ខ្លួនឈឺពុំមាន ថ្នាំព្យាបាល គឺមានតែថ្នាំបុរាណ (ថ្នាំអាចម៍ទន្សាយ) សម្រាប់ព្យាបាលប៉ុណ្ណោះ ។ ការព្យាបាល បែបនេះមិនបានធ្វើឲ្យអ្នកជំងឺជាសះស្បើយទេ ហើយអ្នកជំងឺខ្លះកាន់តែមានសភាពធ្ងន់ធ្ងរទៅៗរហូតដល់ស្លាប់ ហើយពេទ្យបានយកទៅកប់ចោលដោយមិនបានប្រាប់បងប្អូនឲ្យដឹងឡើយ ។

**(នៅមានត)**

**ស៊ីវ ធួន**

# ដំណឹងស្វែររកឪពុកមា

នាងខ្ញុំឈ្មោះ លី ម៉ៃ អាយុ៤២ឆ្នាំ ជាជនជាតិចាម សព្វថ្ងៃរស់នៅភូមិខ្ជូង ឃុំខ្ជូង ស្រុកពញាឮ ខេត្តកណ្តាល ។ នាងខ្ញុំមានឪពុកឈ្មោះ ក សីម និងម្តាយឈ្មោះ អៃ សះ ។ នៅមុនរបបខ្មែរក្រហម ឪពុកម្តាយ ខ្ញុំរស់នៅឃុំព្រៃទប់ ក្រុងកំពង់សោម ។ ប៉ុន្តែក្រោយពីយោធាខ្មែរក្រហមទទួលជ័យជម្នះនៅឆ្នាំ១៩៧៥ ខ្មែរក្រហមយកគាត់ទាំងពីរនាក់ទៅសម្លាប់ចោលទាំងអស់ដោយបន្សល់ទុកខ្ញុំ និងប្អូនពីរនាក់ទៀតនៅរស់ជីវិតរហូតមកដល់បច្ចុប្បន្ននេះ ។

នាងខ្ញុំសូមប្រកាសរកឪពុកមាខាងម្តាយឈ្មោះ អាប៉ា តល់ម៉ាឡេក មានសម្បុរសណ្តែកបាយ ។ កាលពីជំនាន់ខ្មែរក្រហម គាត់មានកូនស្រីពីរនាក់ ដោយកូនម្នាក់ឈ្មោះ ម៉ា ស៊ីតះ នៅរស់ជីវិតរហូតមកដល់ពេលនេះ ។ ក្រោយមក តាមរយៈអ្នកភូមិដែលធ្លាប់ស្គាល់ឪពុកមាខ្ញុំ បានមកប្រាប់ខ្ញុំថា ឪពុកមាខ្ញុំបានរត់ទៅជំរំជនភៀសខ្លួននៅក្នុងប្រទេសថៃ ដើម្បីសុំសិទ្ធិទៅរស់នៅប្រទេសទីបី ។

ក្នុងអំឡុងពេលនៅជំរំនោះ ឪពុកមាខ្ញុំបានផ្ញើសំបុត្រមួយច្បាប់ឲ្យបងប្អូនគាត់ ប៉ុន្តែមកដល់សព្វថ្ងៃ សំបុត្រនោះបានបាត់បង់ទៅហើយដោយសារមិនបានរក្សាទុកត្រឹមត្រូវ ។ ចាប់តាំងពីពេលនោះមក នាងខ្ញុំ និងបងប្អូនបានបាត់ដំណឹងគាត់រហូត ។ អាស្រ័យហេតុនេះ ប្រសិនបើប្អូនណាបានស្គាល់ ឬឮឈ្មោះឪពុកមាខ្ញុំ អាប៉ា តល់ម៉ាឡេក សូមមេត្តាផ្តល់ដំណឹងមកនាងខ្ញុំតាមរយៈអាសយដ្ឋាន ដូចមានរៀបរាប់ខាងលើ ឬហាគីមភូមិខ្ជូង ទូរស័ព្ទលេខ ៖ ០១២ ៧៥៧ ៥០៤ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា អាសយដ្ឋាន ៖ ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬតាមរយៈទូរស័ព្ទលេខ ៖ ០២៣ ២១១ ៨៧៥, ០១៦ ៨៧៦ ៦៩២ ។

សូមអរគុណ!

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោម ៖**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ ៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ ៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ ៖ លេខទូរស័ព្ទ អាសយដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម ៖**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ ៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។










ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានគ្រឹះសំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ន័រវេ៍ និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 151, July 2012 ◆ Funded by Norway and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.